# ព្រះ

# ត្រៃបិដកបាលី

នឹង

សេចក្ដីប្រែជាភាសាខ្មែរ

## សុត្តន្តបិដក

ខុទ្ទកនិកាយ ជាតក

ឯកាទសមភាគ

## ៦២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០៣

សុត្តន្តបិដក

ខុទ្ទកនិកាយ ជាតក

ឯកាទសមភាគ

៦២

ព.ស. ២៥០៣

## មហានិបាតជាតកំ

### តេមិយជាតកំ(១)

(១) មា បណ្ឌិច្ចយំ វិភាវយ ពាលមតោ ភវ សព្វបាណិនំ
សព្វោ តំ ជនោ ឱចិនាយតុ ឯវំ តវ អត្ថោ ភវិស្សតិ ។

(២) ករោមិ តេ តំ វចនំ យំ មំ ភណសិ ទេវតេ
អត្ថកាមាសិ មេ អម្ម ហិតកាមាសិ ទេវតេ ។

(៣) កិន្នុ សន្តរមានោវ កាសុំ ខណសិ សារថិ
បុដ្ឋោ មេ សម្ម អក្ខាហិ កឹ កាសុយា ករិស្សសិ ។

(៤) រញ្ញោ មូគោ ច បក្ខោ ច បុត្តោ ជាតោ អចេតសោ
សោម្ហិ រញ្ញា សមជ្ឈិដ្ឋោ បុត្តំ មេ និខណំ វនេ ។

១ ម. មូគបក្ខជាតកំ ។



## មហានិបាតជាតក

### តេមិយជាតក

(១) (ទេវតាពោលថា) អ្នកកុំប្រកាសខ្លួនថាជាអ្នកប្រាជ្ញ ចូរឲ្យជនទាំងពួង ដឹងថាជាមនុស្សល្ងង់ ជនទាំងអស់ចូរមើលងាយអ្នកចុះ សេចក្តីចំរើននឹងមានដល់អ្នក ដោយវិធីយ៉ាងនេះ ។

(២) (ព្រះមហាសត្វត្រាស់ថា) បពិត្រទេវតា អ្នកនិយាយពាក្យណាដល់ខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកនោះ បពិត្រទេវតា អ្នកឈ្មោះថាប្រាថ្នាឲ្យសេចក្តីចំរើនដល់ខ្ញុំ បពិត្រទេវតា អ្នកឈ្មោះថាប្រាថ្នានូវប្រយោជន៍ (ដល់ខ្ញុំ) ។

(៣) (ព្រះមហាសត្វ) នែនាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្តៅ តើព្រោះហេតុអ្វី ម្នាលសំឡាញ់ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅ ។

(៤) (នាយសារថី) ព្រះរាជបុត្តកើតមកហើយ គផង ខ្វិនផង ដូចជាឥតចិត្ត ខ្ញុំនោះព្រះរាជាទ្រង់ត្រាស់ប្រើមកហើយថា អ្នកត្រូវជីកកប់កូនអញក្នុងព្រៃចុះ ។

(៥) ន ពធិរោ ន អមូគោស្មិ ន បក្ខោ ន ច បិដ្ឋណោ(១)
អធម្មំ សារថិ កយិរា មញ្ចេ តុំ និក្ខណំ វនេ ។
ឩរូ ពាហុំ ច មេ បស្ស ភាសិតញ្ច សុណោហិ មេ
អធម្មំ សារថិ កយិរា មញ្ចេ តុំ និក្ខណំ វនេ ។
(៦) ទេវតា នុសិ គន្ធព្វោ អាទុ សក្កោ បុរិន្ទទោ
កោ វា ត្វំ កស្ស វា បុត្តោ កថំ ជានេមុ តំ មយំ ។
(៧) នម្ហិ ទេវោ ន គន្ធព្វោ នាបិ សក្កោ បុរិន្ទទោ
កាសិរញ្ញោ អហំ បុត្តោ យំ កាសុយា និខញ្ញសិ
តស្ស រញ្ញោ អហំ បុត្តោ យំ ត្វំ សម្មូបជីវសិ
អធម្មំ សារថិ កយិរា មញ្ចេ តុំ និក្ខណំ វនេ
យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
ន តស្ស សាខំ ភញ្ជេយ្យ មិត្តទុព្ភោ ហិ បាបកោ
យថា រុក្ខោ តថា រាជា យថា សាខា តថា អហំ
យថា ឆាយូបគោ បោសោ ឯវំ ត្វមសិ សារថិ
អធម្មំ សារថិ កយិរា មញ្ចេ តុំ និក្ខណំ វនេ ។

១ ម. ឆ ចំ បក្ខុលោ ។ ឱ. ម ០ វិកលោ ។



(៥) (ព្រះមហាសត្វ) ខ្ញុំមិនថ្លង់ មិនគ មិនខ្វិនខាង មិនមែនវិកលវិការទេ ម្នាលនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើនូវអធម៌ អ្នកចូរមើលភ្លៅទាំងពីរនិងដៃខ្ញុំ ចាំចូរស្តាប់សំដីខ្ញុំ ម្នាលនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើនូវអធម៌ ។

(៦) (នាយសារថី) អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាបុរិន្ទទសក្កទេវរាជ អ្នកជាអ្វី ចាំជាកូនអ្នកណា យើងនឹងស្គាល់អ្នកបាន ដោយប្រការដូចម្តេច ។

(៧) (ព្រះមហាសត្វ) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាបុរិន្ទទសក្កទេវរាជទេ អ្នកកប់បុគ្គលណាក្នុងរណ្តៅ បុគ្គលនោះ គឺខ្ញុំជាកូនរបស់ព្រះបាទកាសិក: អ្នករស់នៅដោយស្រួល (ព្រោះអាស្រ័យ) នូវព្រះរាជាណា ខ្ញុំជាកូនរបស់ព្រះរាជានោះ ម្នាលនាយសារថី បើអ្នកនឹងកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើនូវអធម៌ បុគ្គលគប្បីអង្គុយ ឬដេកក្រោមម្លប់ឈើណា មិនគប្បីកាច់បំបាក់មែកឈើនោះទេ ព្រោះថាអ្នកប្រទូស្តមិត្រជាមនុស្សលាមក ម្នាលនាយសារថី ព្រះរាជាទុកដូចជាដើមឈើ ខ្ញុំទុកដូចជាមែកឈើដែរ អ្នកឯងទុកដូចបុរស ដែលចូលទៅជ្រកក្រោមម្លប់ឈើដូច្នោះ ម្នាលនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើនូវអធម៌ ។

(៨) ពហុភក្ខោ ភវតិ វិប្បវុត្ថោ សកាឃរា
ពហូ នំ ឧបជីវន្តិ យោ មិត្តានំ ន ទូភតិ ។
យំ យំ ជនបទំ យាតិ និគមេ រាជធានិយោ
សព្វត្ថ បូជិតោ ហោតិ យោ មិត្តានំ ន ទូភតិ ។
នាស្ស ចោរា បសហន្តិ នាតិមញ្ញេតិ ខត្តិយោ
សព្វេ អមិត្តេ តរតិ យោ មិត្តានំ ន ទូភតិ ។
អក្កុទ្ធោ សឃរំ ឯតិ សភាយ បដិនន្ទិតោ
ញាតីនំ ឧត្តមោ ហោតិ យោ មិត្តានំ ន ទូភតិ ។
សក្កត្វា សក្កតោ ហោតិ គរុ ហោតិ សគារវោ
វណ្ណកិត្តិភតោ ហោតិ យោ មិត្តានំ ន ទូភតិ ។
បូជកោ លភតេ បូជំ វន្ទកោ បដិវន្ទនំ
យសោកិត្តិញ្ច បប្បោតិ យោ មិត្តានំ ន ទូភតិ ។
អគ្គិ យថា បជ្ជលតិ ទេវតាវ វិរោចតិ
សិរិយា អជហិតោ ហោតិ យោ មិត្តានំ ន ទូភតិ ។



(៨) បុគ្គលណា មិនប្រទូស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះបើចេញផុតអំពីផ្ទះរបស់ខ្លួនហើយ ជាអ្នកមានភក្សាហារច្រើន ជនច្រើនអាស្រ័យចិញ្ចឹមជីវិត (អាស្រ័យ) បុគ្គលនោះ ។ បុគ្គលណាមិនប្រទូស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះ ទៅកាន់ជនបទនិគមរាជធានីណា ៗ តែងតែមានគេបូជាក្នុងទីទាំងអស់នោះ ។ បុគ្គលណា មិនប្រទូស្តចំពោះមិត្រទាំងឡាយ ពួកចោរមិនគ្របសង្កត់បុគ្គលនោះ ក្សត្រក៏មិនមើលងាយបុគ្គលនោះ បុគ្គលនោះ រមែងឆ្លងផុតសត្រូវទាំងអស់ ។ បុគ្គលណា មិនប្រទូស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះ មិនខឹង មកកាន់ផ្ទះរបស់ខ្លួន ជាអ្នកគេទទួលរីករាយក្នុងទីរោងសម្រាប់ប្រជុំ ជាបុគ្គលឧត្តមរបស់ពួកញាតិ ។ បុគ្គលធ្វើសក្ការៈចំពោះ (មិត្រ) រមែងត្រូវមិត្រធ្វើសក្ការៈវិញ ជាអ្នកគោរព (មិត្រ) រមែងបានសេចក្ដីគោរពវិញ បុគ្គលមិនប្រទូស្តមិត្រ រមែងពេញដោយគុណនិងកិត្តិសព្ទ ។ បុគ្គលអ្នកបូជាមិត្រ រមែងបានការបូជាវិញ ជាអ្នកសំពះមិត្រ រមែងបានការសំពះតបវិញ បុគ្គលមិនប្រទូស្តមិត្រ រមែងដល់នូវយសបរិវារនិងកិត្តិសព្ទ ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ បុគ្គលនោះ រមែងរុងរឿងដូចភ្លើង រុងរឿងដូចទេវតា ជាអ្នកមិនលះបង់ចាកសិរីឡើយ ។

គាវោ តស្ស បជាយន្តិ ខេត្តេ វុត្តំ វិរូហតិ

វុត្តានំ ផលមស្នាតិ យោ មិត្តានំ ន ទុព្ភតិ ។

ទរិតោ បព្វតាតោ វា រុក្ខតោ បតិតោ នរោ

ចុតោ បតិដ្ឋំ លភតិ យោ មិត្តានំ ន ទុព្ភតិ ។

វិរូឡ្ហមូលសន្តានំ និគ្រោធមិវ មាលុតោ

អមិត្តា នប្បសហន្តិ យោ មិត្តានំ ន ទុព្ភតិ ។

(៩) ឯហិ តំ បដិនេស្សាមិ រាជបុត្ត សកំ ឃរំ

រជ្ជំ ការេហិ ភទ្ទន្តេ កឹ អរញ្ញេ ករិស្សសិ ។

(១០) អលំ មេ តេន រជ្ជេន ញាតកេហិ ធនេន វា

យំ មេ អធម្មចរិយាយ រជ្ជំ លព្ភេថ សារថិ ។

(១១) បុណ្ណបត្តំ មំ លាភេហិ រាជបុត្ត ឥតោ គតោ



បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ គោទាំងឡាយរបស់បុគ្គលនោះសម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះសាបព្រោះក្នុងស្រែរមែងដុះដាល បុគ្គលនោះ រមែងបរិភោគផ្លែនៃពូជទាំងឡាយដែលខ្លួនសាបព្រោះហើយ ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ បុគ្គលនោះស្ទើរធ្លាក់ទៅក្នុងជ្រោះក្តី ភ្នំក្តី អំពីដើមឈើក្តី ធ្លាក់ហើយ រមែងបានទីពឹង ។ បុគ្គលណាមិនប្រទូស្តមិត្រទាំងឡាយ សត្រូវទាំងឡាយគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់មិនអាចគ្របសង្កត់ដើមជ្រៃ ដែលមានឫសនិងពូជដុះហើយ ។

(៩) (នាយសារថី) បពិត្រព្រះរាជបុត្រ សូមទ្រង់ស្តេចមក ខ្ញុំព្រះបង្គំជាខ្ញុំនឹងនាំទ្រង់ទៅកាន់ដំណាក់របស់ព្រះអង្គ សូមទ្រង់សោយរាជ្យចុះសេចក្តីចំរើនចូរមានដល់ទ្រង់ ទ្រង់នឹងធ្វើអ្វីក្នុងព្រៃ ។

(១០) (ព្រះមហាសត្វ) នែនាយសារថី រាជសម្បត្តិណាដែលខ្ញុំគប្បីបានដោយអធម្មចរិយៈ ខ្ញុំមិនត្រូវការដោយរាជសម្បត្តិនោះ ផងដោយពួកញាតិ ផងដោយទ្រព្យទេ ។

(១១) (នាយសារថី) បពិត្រព្រះរាជបុត្រ សូមទ្រង់ស្តេចទៅអំពីទីនេះ ហើយញ៉ាំងខ្ញុំព្រះបង្គំជាខ្ញុំឲ្យបាននូវគ្រឿងជាទីត្រេកអរ

បិតា មាតា ច មេ ទជ្ជុំ រាជបុត្ត តយី គតេ ។

ឱរោធា ច កុមារា ច វេសិយានា ច ព្រាហ្មណា

តេបិ អត្តមនា ទជ្ជុំ រាជបុត្ត តយី គតេ ។

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា

តេបិ អត្តមនា ទជ្ជុំ រាជបុត្ត តយី គតេ ។

សមាគតា ជានបទា នេគមា ច សមាគតា

ឧបាយនានិ មេ ទជ្ជុំ រាជបុត្ត តយី គតេ ។

(១៦) បិតុ មាតុ ចហំ ចត្តោ រដ្ឋស្ស និគមស្ស ច

អថោ សព្វកុមារកំ នត្ថិ មយ្ហំ សកំ បិយំ ។

អនុញ្ញាតោ អហំ មត្យា សញ្ចត្តោ បិតរា អហំ

ឯកោ អរញ្ញេ បព្វជិតោ ន កាមេ អភិបត្ថយេ ។



បពិត្រព្រះរាជបុត្រ កាលបើព្រះអង្គស្តេចទៅហើយ ព្រះរាជបិតា នឹងព្រះមាតា គប្បីប្រទាន (វត្ថុទាន) ដល់ទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្តេចទៅហើយ ពួកស្រីស្នំនឹងរាជ-កុមារ ពួកឈ្មួញនឹងពួកព្រាហ្មណ៍ ផងទាំងអម្បាលនោះមានចិត្តត្រេកអរ គប្បីឲ្យ (វត្ថុទានដល់ទូលព្រះបង្គំជាខ្ញុំ) ។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្តេចទៅហើយ ពួកហ្មដំរី ពួកពលរក្សាព្រះអង្គ ពួកពលរថ ពួកថ្មើរជើង ផងទាំងអម្បាលនោះ មានចិត្តត្រេកអរ គប្បីឲ្យ (វត្ថុទានដល់ទូលព្រះបង្គំជាខ្ញុំ) ។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្តេចទៅ ពួកអ្នកជនបទ នឹងពួកអ្នកនិគម មានធញ្ញាហារច្រើន មកប្រជុំគ្នា គប្បីឲ្យគ្រឿងបណ្ណាការទាំងឡាយដល់ទូលព្រះបង្គំជាខ្ញុំ ។

(១៦) (ព្រះមហាសត្វ...) ខ្ញុំដែលព្រះបិតាមាតា អ្នកដែន អ្នកនិគមនឹងពួករាជកុមារទាំងពួង បានលះបង់ហើយ ផ្ទះរបស់ខ្លួនខ្ញុំមិនមានទេ ខ្ញុំដែលព្រះមាតាបានអនុញ្ញាតឲ្យទទួលរាជ្យ ៧ ថ្ងៃហើយ ខ្ញុំដែលព្រះបិតាលះលែងស្រេចហើយ ខ្ញុំនឹងបួសនៅក្នុងព្រៃតែម្នាក់ឯង មិនប្រាថ្នានូវកាមទាំងឡាយឡើយ ។

(១៣) អបិ អតរមានានំ ផលាសាវ សមិជ្ឈតិ
វិបក្កព្រហ្មចរិយោស្មិ ឯវំ ជានាហិ សារថិ ។
អបិ អតរមានានំ សម្មទត្ថោ វិបច្ចតិ
វិបក្កព្រហ្មចរិយោស្មិ និក្ខន្តោ អកុតោភយោ ។
(១៤) ឯវំ វគ្គុកថោ សន្តោ វិសដ្ឋវចនោ ច សោ
កស្មា បិតុ ច មាតុ ច សន្តិកេ ន ភណី តទា ។
(១៥) នាហំ អសន្ធិតា បក្ខោ ន ពធិរោ អសោតតា
នាហំ អជិវ្ហតា មូគោ មា មំ មូគមធារយិ ។
បុរិមំ សរាមហំ ជាតិំ យត្ថ រជ្ជមការយិំ
ការយិត្វា តហិំ រជ្ជំ បាបត្ថំ និរយំ ភុសំ ។
វីសតិញ្ចេវ វស្សានិ តហិំ រជ្ជមការយិំ
អសីតិវស្សសហស្សានិ និរយម្ហិ អបច្ចិសំ ។
តស្ស រជ្ជស្សហំ(១) ភីតោ មា មំ រជ្ជាភិសេចយុំ
តស្មា បិតុ ច មាតុ ច សន្តិកេ ន ភណឹ តទា ។

១– រជ្ជស្សាហន្តិ អដ្ឋកថាយំ ទិស្សតិ ។



(១៣) សេចក្តីប្រាថ្នាជាផល តែងសម្រេចផលដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ (កាល ១៦ ឆ្នាំ) ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចផលដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យអំពីណា ។

(១៤) (នាយសារថី...) ទ្រង់នោះមានព្រះបន្ទូលពីរោះ មានព្រះបន្ទូលស្រួលស្រួយយ៉ាងនេះ ហេតុអ្វីបានជាទ្រង់ មិនមានព្រះបន្ទូលក្នុងសំណាក់ នៃព្រះបិតាព្រះមាតា ក្នុងពេលនោះ ។

(១៥) (ព្រះមហាសត្វ...) ខ្ញុំមិនមែនខ្វិនព្រោះមិនមានសន្លាក់ទេ ខ្ញុំមិនមែនថ្លង់ព្រោះមិនមានសោតប្រសាទទេ ខ្ញុំមិនមែនគព្រោះមិនមានជិវ្ហាប្រសាទទេ អ្នកកុំសំគាល់ខ្ញុំថាជាមនុស្សគឡើយ ។ ខ្ញុំរលឹកឃើញនូវជាតិមុន ជាជាតិដែលខ្ញុំបានសោយរាជ្យ លុះខ្ញុំសោយរាជ្យក្នុងជាតិនោះហើយ ក៏ធ្លាក់ទៅនរកក្រៃលែង ។ ខ្ញុំសោយរាជ្យក្នុងជាតិនោះអស់ ២០ ឆ្នាំ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ ។ ខ្ញុំខ្លាចរាជ្យនោះ កុំឲ្យព្រះមាតាបិតាអភិសេកខ្ញុំក្នុងរាជ្យ ព្រោះហេតុនោះ បានជាខ្ញុំមិននិយាយក្នុងសំណាក់ នៃព្រះបិតាមាតាក្នុងកាលនោះ ។

ឧច្ឆង្គេ មំ និសីទេត្វា បិតា អត្ថានុសាសតិ
ឯកំ ហនថ ពន្ធថ ឯកំ ខារាបតច្ឆិកំ(១) ។
ឯកំ សូលស្មិំ ឧប្បេថ ឥច្ចស្ស អនុសាសតិ
តាយាហំ ផរុសំ សុត្វា វាចាយោ សមុទីរិតា ។
អមូគោ មូគវណ្ណេន អបក្ខោ បក្ខសម្មតោ
សកេ មុត្តករីសស្មឹ អច្ឆាហំ សម្បរិប្លុតោ ។
កសិរញ្ច បរិត្តញ្ច តញ្ច ទុក្ខេន សំយុតំ
កោ មំ ជីវិតមាគម្ម វេរំ កយិរាថ កេនចិ ។
បញ្ញាយ ច អលាភេន ធម្មស្ស ច អទស្សនា
កោ មំ ជីវិតមាគម្ម វេរំ កយិរាថ កេនចិ ។
អបិ អតរមានានំ ផលាសាវ សមិជ្ឈតិ
វិបក្កព្រហ្មចរិយោស្មិ ឯវំ ជានាហិ សារថិ ។
អបិ អតរមានានំ សម្មទត្ថោ វិបច្ចតិ
វិបក្កព្រហ្មចរិយោស្មិ និក្ខន្តោ អកុតោភយោ

១ ភាពបច្ចេក្ខ អដ្ឋកថាយំ វិត្ថារិ ។



ព្រះរាជបិតាបានឲ្យខ្ញុំអង្គុយលើព្រះភ្លៅ ហើយទ្រង់វិនិច្ឆ័យក្តីថា អ្នកទាំងឡាយចូរសំឡាប់ ចោរ ១ នាក់ ចូរចងចោរ ១ នាក់ (ធ្វើចោរ ១ នាក់ឲ្យប្រឡាក់ដោយទឹកក្សារ ) ចូរដោតចោរ ១ នាក់លើឈើស្រួច ព្រះរាជបិតាត្រាស់បង្គាប់មហាជន ដោយប្រការដូច្នេះ ខ្ញុំស្តាប់នូវពាក្យក្រោធនោះ ដែលព្រះរាជបិតា ទ្រង់ត្រាស់ហើយ ។ ខ្ញុំមិនគរ តែមានកេរ្តិ៍ដូចបុគ្គលគ ខ្ញុំមិនខ្វិនទេ តែសន្មតជាដូចជាខ្វិន ខ្ញុំបានដេកប្រឡូកប្រឡាក់ក្នុងមូត្រនឹងករីសរបស់ខ្លួន ។ ជីវិត (របស់សត្វ) លំបាកផង តិចផង ជីវិតនោះប្រកបដោយទុក្ខ បុគ្គលណាអាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរដោយហេតុណាមួយ ។ បុគ្គលណាអាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរ ដោយហេតុណាមួយ ព្រោះមិនបានបញ្ញាផង ព្រោះមិនឃើញធម៌ផង ។ សេចក្តីប្រាថ្នាផល តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ម្នាលនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញបួសហើយ មិនមានភ័យអំពីណា ។

(១៦) អហម្បិ បព្វជិស្សាមិ រាជបុត្ត តវន្តិកេ

អវ្ហាយស្សុ មំ ភទ្ទន្តេ បព្វជ្ជា មម រុច្ចតិ ។

(១៧) រថំ និយ្យាតយិត្វាន អនណោ ឯហិ សារថិ

អនណស្ស ហិ បព្វជ្ជា ឯតំ ឥសីភិ វណ្ណិតំ ។

(១៨) យទេវ ត្យាហំ វចនំ អករំ ភទ្ទមត្ថុ តេ

តទេវ មេ ត្វំ វចនំ យាចិតោ កត្តុមរហសិ ។

ឥធេវ តាវ អច្ឆស្សុ យាវ រាជានមានយេ

អប្បេវ តេ បិតា ទិស្វា បតីតោ សុមនោ សិយា ។

(១៩) ករោមិ តេ តំ វចនំ យំ មំ ភណសិ សារថិ

អហម្បិ ទដ្ឋុកាមោស្មិ បិតរំ មេ ឥធាគតំ ។



(១៦) (នាយសារថី) បពិត្រព្រះរាជបុត្រ ខ្លួនព្រះបង្គំជាខ្ញុំនឹងបួសក្នុងសំណាក់ព្រះអង្គ បពិត្រព្រះរាជបុត្រដ៏ចំរើន សូមទ្រង់ត្រាស់ហៅខ្លួនព្រះបង្គំជាខ្ញុំ (ឲ្យបួសផង) ខ្លួនព្រះបង្គំជាខ្ញុំពេញចិត្តនឹងបព្វជ្ជាដែរ ។

(១៧) (ព្រះមហាសត្វ) នែនាយសារថី អ្នកចូរប្រគល់រថហើយ ជាអ្នកមិនមានបំណុលសឹមមកចុះ ព្រោះថាបព្វជ្ជា (រមែងសម្រេច) ដល់បុគ្គលមិនមានបំណុល បព្វជ្ជាកម្មនេះពួកឥសីសរសើរហើយ ។

(១៨) (នាយសារថី) សេចក្តីចំរើនចូរមានដល់ទ្រង់ ពាក្យណាដែលទ្រង់បានថ្លែងហើយ ខ្លួនព្រះបង្គំជាខ្ញុំនឹងធ្វើតាមពាក្យនោះ ទ្រង់ដែលខ្លួនព្រះបង្គំជាខ្ញុំអង្វរហើយ គួរធ្វើតាមពាក្យរបស់ខ្លួនព្រះបង្គំជាខ្ញុំនោះផង ។ សូមទ្រង់ស្តេចគង់នៅក្នុងទីនេះ ដរាបដល់ខ្លួនព្រះបង្គំជាខ្ញុំ នាំព្រះរាជាមកដល់ ព្រះបិតារបស់ទ្រង់ទតឃើញហើយ សមជាមានព្រះហឫទ័យត្រេកអររីករាយ ។

(១៩) (ព្រះមហាសត្វ) នែនាយសារថី អ្នកនិយាយពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកនោះ ខ្ញុំមានបំណង ដើម្បីជួបព្រះបិតារបស់ខ្ញុំ ដែលទ្រង់ស្តេចយាងមកក្នុងទីនេះដែរ ។

ឯហិ សម្ម និវត្តស្សុ កុសលំ វជ្ជាសិ ញាតិនំ
មាតរំ បិតរំ មយ្ហំ វុត្តោ វជ្ជាសិ វន្ទនំ ។
(២០)តស្ស បាទេ គហេត្វាន កត្វា ច នំ បទក្ខិណំ
សារថិ រថមារុយ្ហ រាជទ្វារំ ឧបាគមិ ។
(២១)សុញ្ញំ មាតា រថំ ទិស្វា ឯកំ សារថិមាគតំ
អស្សុបុណ្ណេហិ នេត្តេហិ រោទន្តី នំ ឧទិក្ខតិ
អយំ សោ សារថិ ឯតិ និហន្ត្វា មម អត្រជំ ។
និហតោ នូន មេ បុត្តោ បថព្យា ភូមិវឌ្ឍនោ
អមិត្តា នូន នន្ទន្តិ បតីតា នូន វេរិនោ
អាគតំ សារថិំ ទិស្វា និហន្ត្វា មម អត្រជំ ។
សុញ្ញំ មាតា រថំ ទិស្វា ឯកំ សារថិមាគតំ
អស្សុបុណ្ណេហិ នេត្តេហិ រោទន្តី នំ បរិបុច្ឆតិ ។
កិន្នុ មូគោ កិន្នុ បក្ខោ កិន្នុ សោ វិលបី តទា
និហញ្ញមានោ ភូមិយា តំ មេ អក្ខាហិ សារថិ ។



ម្នាលសំឡាញ់ អ្នកទៅចុះហើយ ចូរមកវិញ ចូរក្រឡប់ទៅសិនចុះ អ្នកក្រាបទូលសេចក្ដីសុខដល់ញាតិទាំងឡាយ អ្នកដែលខ្ញុំប្រាប់ហើយ គប្បីក្រាបទូលនូវការថ្វាយបង្គំ ចំពោះព្រះមាតាបិតា ។

(២០) (អភិសម្ពុទ្ធគាថា) នាយសារថី ចាប់ព្រះបាទនៃព្រះមហាសត្វនោះ ហើយក៏ធ្វើប្រទក្សិណព្រះមហាសត្វនោះ រួចឡើងជិះរថ បរចូលទៅកាន់រាជទ្វារ ។

(២១) ព្រះមាតាទតឃើញរថទទេ គឺមានព្រះនេត្រពេញទៅដោយព្រះអស្សុ ទ្រង់ព្រះកន្សែង ទៀងមើលទៅនាយសារថីនោះ ដែលមកវិញតែឯង ដោយគិតថា នាយសារថីនេះ សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ ។ កូនរបស់អញចំរើនផែនដី នាយសារថីកប់ក្នុងផែនដីដោយពិត ពួកសត្រូវ រីករាយត្រេកអរដោយពិត ពួកខ្មាំងទាំងឡាយត្រេកអរហើយដោយពិត ព្រោះឃើញនាយសារថី សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ ។ ព្រះមាតាទតឃើញរថទទេ គឺមានព្រះនេត្រពេញទៅ ដោយព្រះអស្សុ ទ្រង់ព្រះកន្សែង សួរទៅនាយសារថីនោះ ដែលមកវិញតែម្នាក់ឯងថា កូនរបស់ខ្ញុំនោះ ជាមនុស្សគ ឬអ្វី ជាមនុស្សខ្វិនឬអ្វី កាលអ្នកកប់ក្នុងផែនដី ក្នុងកាលនោះ កូនរបស់ខ្ញុំពិលាបដែរឬ ម្នាលនាយសារថី អ្នកចូរប្រាប់នូវហេតុនោះដល់ខ្ញុំ ។

កច្ចិ ហត្ថេហិ បាទេហិ មុខេន បរេត្វា វិជ្ជយិ(១)

និហញ្ញមានោ កាសុយា តំ មេ អក្ខាហិ បុច្ឆិតោ ។

(២២)អក្ខេយ្យន្តេ អហំ អយ្យ ទជ្ជាសិ អភយំ មម

យំ មេ សុតំ វា ទិដ្ឋំ វា រាជបុត្តស្ស សន្តិកេ ។

(២៣)អភយំ សម្ម តេ ទម្មិ អភីតោ ភណ សារថិ

យន្តេ សុតំ វា ទិដ្ឋំ វា រាជបុត្តស្ស សន្តិកេ ។

(២៤)ន សោ មូគោ ន សោ បក្ខោ វិសដ្ឋវចនោ ច សោ

រជ្ជស្ស កិរ សោ ភីតោ អករា អាលយេ ពហូ ។

បុរិមំ សរតិ សោ ជាតឹ យត្ថ រជ្ជមការយិ

ការយិត្វា តហឹ រជ្ជំ បាបត្ថ និរយំ ភុសំ ។

វីសតិញ្ចេវ វស្សានិ តហឹ រជ្ជមការយិ

អសីតិវស្សសហស្សានិ និរយម្ហិ អបច្ចិ សោ ។

១ វិជ្ជយីតិ សន្ទេហោ ទិស្សតិ ។



(កូនរបស់ខ្ញុំនោះ) ជាមនុស្សគ ជាមនុស្សខ្វិន កាលអ្នកកប់កូន ដែលមិន បានកម្រើកដៃជើងដូចម្ដេចដែរ (ម្នាលនាយសារថី) អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់រឿងនោះ ។

[២២] (នាយសារថី) បពិត្រព្រះអង្គជាម្ចាស់ (បើ) ព្រះអង្គឲ្យអភ័យដល់ខ្លួនព្រះបង្គំជាខ្ញុំ ហេតុណាដែលខ្ញុំបានឮហើយ ឬបានឃើញហើយ ក្នុងសំណាក់នៃព្រះរាជបុត្រ ខ្លួនព្រះបង្គំជាខ្ញុំ នឹងក្រាបទូលនូវហេតុនោះ ដល់ព្រះអង្គ ។

[២៣] (ព្រះរាជា) ម្នាលសារថីសំឡាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ហេតុណាដែលអ្នកបានឮហើយ ឬបានឃើញហើយក្នុងសំណាក់នៃព្រះរាជបុត្រ អ្នកកុំភិតភ័យ ចូរប្រាប់នូវហេតុនោះចុះ ។

[២៤] (នាយសារថី) ព្រះរាជបុត្រនោះ មិនមែនគទេ ព្រះរាជបុត្រនោះមិនមែនខ្វិនទេ ឯព្រះរាជបុត្រនោះ មានព្រះបន្ទូលក្បោះក្បាយច្បាស់លាស់ ព្រះរាជបុត្រនោះ ទ្រង់ខ្លាចរាជ្យ ទើបបានធ្វើនូវពុតត្បុតច្រើនយ៉ាង ។ ព្រះរាជបុត្រនោះ ទ្រង់រលឹកឃើញនូវជាតិមុន ជាជាតិដែលបានទ្រង់សោយរាជ្យ លុះសោយរាជ្យក្នុងទីនោះហើយ ធ្លាក់ទៅកាន់នរកស្ទើរ ។ ព្រះរាជបុត្រនោះ បានសោយរាជ្យក្នុងទីនោះ អស់ ២០ ឆ្នាំ តែបានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ ។

តស្ស រជ្ជស្ស សោ ភីតោ មា មំ រជ្ជេភិសេចយុំ
តស្មា បិតុ ច មាតុ ច សន្តិកេ ន គណី គតា ។
អង្គបច្ចង្គសម្បន្នោ អារោហបរិណាហវា
វិសជ្ជនេយោ បញ្ញោ មនុត្ត សព្វស្ស ភិជ្ជិតេ ។
សាច ត្វំ ធម្មកាមាសិ រាជបុត្តំ តវត្រជំ
ឯហិ តំ ឋាបយិស្សាមិ យត្ថ សម្មតិ តេមិយោ ។
(៤៨) យោជយិត្វា រថេ អស្សេ កដ្ឋំ ឆាតេ ចិកច្ចន
ទុធីរយិត្វា សន្ទំបណ្ណាក ឆេទ្ទ(១) ឯកោ ហេក្វាក ។
ឆេទ្ទ គោរិសន្ធា វេក្ខ ឆេទ្ទ ទុទ្ធី
តេគរា ច មំ អភេទ្ទ គច្ឆ បុត្តចិភិធលោ ។
ទិរេជា ច កុមារា ច វេសិយា ចា ច ព្រាហ្មណា
ចិច្ឆំ យហដាធិ យោជេត្វ គច្ឆ បុត្តចិភិធលោ ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
ចិច្ឆំ យហដាធិ យោជេត្វ គច្ឆ បុត្តចិភិធលោ ។

(១) ម. អីក ។ ម. ភិន្ន ។



ព្រះរាជបុត្រនោះ ទ្រង់ខ្លាចរាជ្យនោះហើយ (គឺតាំងព្រះរាជហឫទ័យថា) ព្រះរាជមាតាបិតា កុំអភិសេកអញក្នុងរាជ្យ ព្រោះហេតុនោះ ទើបព្រះរាជបុត្រ មិនមានបន្ទូលក្នុងសំណាក់នៃព្រះបិតា និងព្រះមាតាក្នុងកាលនោះ ។ ព្រះរាជបុត្រនោះ បរិបូណ៌ដោយអវយវៈតូចធំ មានកំពស់និងទំហំ (ដ៏សមសួន) មានព្រះបន្ទូលដ៏ក្បោះក្បាយ មានបញ្ញា ទ្រង់ឋិតនៅក្នុងផ្លូវស្ពឹក ។ បើព្រះនាងមានប្រាថ្នា ដើម្បីឃើញព្រះរាជបុត្រ ជាកូនបង្កើតរបស់ព្រះនាង សូមព្រះនាងយាងទៅចុះ តេមិយកុមារគង់នៅក្នុងទីណា ខ្ញុំព្រះបង្គំជាខ្ញុំនឹងនាំព្រះនាងឲ្យដល់ទីនោះ ។

(៤៨)(ព្រះបាទកាសិកៈ)នាយសារថីទាំងឡាយ ចូរទឹមសេះក្នុងរថ អ្នកទាំងឡាយ ចូរចងផ្ទន់ទង់ជ័យ សំពត់និងស្លូតបូរ លាន់សំឡេងឡើង សួនមានមុខក្តោងនាង ចូរលាន់សំឡេងឡើង ។ សួនដែលគេតាក់សព្វ ហើយចូរចងទ្វីសំឡេង សួនមានសំឡេងពីរោះ ចូរលាន់សំឡេងឡើង ទាំងពួកអ្នកនិគម ចូរទៅតាមយើងចុះ យើងនឹងទៅឲ្យកូនផលកូនរបស់យើង ។ ពួកស្រីស្នំនឹងរាជកុមារ ពួកឈ្មួញនឹងពួកព្រាហ្មណ៍ ចូរតាក់តាំងយានឲ្យឆាប់ យើងនឹងទៅឲ្យកូនផលកូនរបស់យើង ។ ពួកហ្មដំរី ពួកពលសេះ ពួករពលរថ ពួកពលថ្មើរជើង ចូរតាក់តាំងយានឲ្យឆាប់ យើងនឹងទៅឲ្យកូនផលកូនរបស់យើង ។

សមាគតា ជានបទា នេគមា ច សមាគតា
ទិស្វា យាចាមិ យោធេត្ថ ភត្តុំ បុត្តនិកេតោ ។

(៦៦) អស្សេ ច សារថី យុត្តេ សិន្ធវេ សីឃវាហនេ
កជ្ជារំ ឧបាគញ្ឆុំ យុត្តា នេន វរេ ហយេ ។

(៦៧) ថូលា ជវេន ហាយន្តិ កិសា ហាយន្តិ ថាមសា(១)
កិសេ ថូលេ វិវជ្ជិត្វា សំសដ្ឋា យោជិតា ហយា ។

(៦៨) តតោ រាជា តរមានោ យុត្តមារុយ្ហ សន្ទនំ
ឥត្ថាគារំ អជ្ឈភាសិ សព្វាវ អនុយាថ មំ ។
វាលវីជនិមុណ្ហីសំ ខគ្គំ ឆត្តញ្ច បណ្ឌរំ
ឧបាធី រថមារុយ្ហ សុវណ្ណេហិ អលង្កតា ។
តតោ ច រាជា បាយាសិ បុរក្ខត្វាន សារថី
ខិប្បមេវ ឧបាគញ្ឆិ យត្ថ សម្មតិ តេមិយោ ។

១ ម. ថាមុនា ។ ឱ. ពាមុនា ។



អ្នកជនបទ មកប្រជុំគ្នា ពួកអ្នកនិគមក៏មកប្រជុំគ្នា ហើយទូលថា ខ្ញុំបានឲ្យតាំង យើងនឹងទៅឲ្យកើត ផលដល់ខ្លួនរបស់យើង ។

(៦៦) (អភិសម្ពុទ្ធគាថា) ពួកនាយសារថី (បាននាំយក) នូវសេះសិន្ធពពង់ល្អ ជាពាហនៈមានសន្ទុះដ៏លឿន ដែលទឹម ហើយចូលមកកាន់ទ្វារ (ក្រាបបង្គំទូលថា) បពិត្រព្រះសម្មតិទេព សេះពពង់ល្អទាំងនេះ ទូលព្រះបង្គំបានទឹមរួចហើយ ។

(៦៧) (ព្រះរាជា) ពួកសេះធាត់ៗ រមែងសាបសូន្យចាកសន្ទុះ ពួកសេះស្គមៗ រមែងសាបសូន្យចាកកំឡាំង អ្នកទាំងឡាយត្រូវវៀរចេញនូវពួកសេះស្គមនឹងសេះធាត់ចេញ ហើយទឹមតែពួកសេះដែលប្រកប (ដោយវ័យសម្បូរ សន្ទុះ កំឡាំង) វិញ ។

(៦៨) លំដាប់នោះ ព្រះរាជាទ្រង់ប្រញាប់ប្រញាល់ឡើងកាន់រថ ដែលនាយសារថីទឹមហើយ ទ្រង់ត្រាស់ទៅនឹងស្រ្តីស្នំថា នាងទាំងអស់គ្នា ចូរទៅតាមយើងចុះ ។ នាងទាំងឡាយប្រដាប់ដោយមាសទាំងឡាយ ហើយកាន់យកនូវផ្លិត មកុដ ព្រះខាន់ ស្វេតច្ឆត្រ នឹងស្បែកជើង រួចឡើងជិះរថមក ។ បន្ទាប់ពីនោះមក ព្រះរាជាបានឲ្យនាយសារថីដើរមុខ ហើយទ្រង់ស្ដេចយាងទៅ រកព្រះកុមារនៅកន្លែងណា ក៏យាងទៅកន្លែងនោះយ៉ាងឆាប់ ។

(២៩) តញ្ច ទិស្វាន អាយន្តំ ជលន្តមិវ តេជសា

ខត្តសង្ឃបរិព្យូឡ្ហំ(១) តេមិយោ ឯតទព្រវិ ។

កច្ចិ នុ តាត កុសលំ កច្ចិ តាត អនាមយំ

សព្ពា ច រាជកញ្ញាយោ អរោគា មយ្ហ មាតរោ ។

(៣០) កុសលញ្ចេវ មេ បុត្ត អថោ បុត្ត អនាមយំ

សព្ពា ច រាជកញ្ញាយោ អរោគា តុយ្ហ មាតរោ ។

(៣១) កច្ចិ អមជ្ជបោ តាត កច្ចិ តេ សុរមប្បិយំ

កច្ចិ សច្ចេ ច ធម្មេ ច ទានេ តេ រមតេ មនោ ។

(៣២) អមជ្ជបោ អហំ បុត្ត អថោ មេ សុរមប្បិយំ

អថោ សច្ចេ ច ធម្មេ ច ទានេ មេ រមតេ មនោ ។

(៣៣) កច្ចិ អរោគំ យោគ្គន្តេ កច្ចិ វហតិ វាហនំ

កច្ចិ តេ ព្យាធយោ នត្ថិ សរីរស្សុបតាបិយា ។

១ ឧ. ខត្តសង្ឃបរិព្ពូឡ្ហំ ។ ម. ខត្តសង្ឃបរិព្យូឡ្ហំ ។



(២៩) តេមិយៈ ទតឃើញព្រះបិតានោះ កំពុងស្តេចយាងមក ហាក់ដូចជារុងរឿងដោយតេជៈ ដែលពួកអាមាត្យអ្នកកាន់ព្រះខាន់ ហែហមហើយ ទើបក្រាស់សួរព្រះបិតានោះថា បពិត្រព្រះបិតា ព្រះអង្គមានសេចក្តីសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះអង្គមិនមានព្រះរោគាពាធទេឬ រាជកញ្ញាទាំងអស់ ជាព្រះមាតារបស់ខ្ញុំ មិនមានរោគទេឬ ។

(៣០) (ព្រះរាជបិតា) នែកូន ខ្ញុំសុខសប្បាយទេ នែកូន ខ្ញុំមិនមានជម្ងឺផ្តាត់ទេ រាជកញ្ញាទាំងអស់ជាមាតារបស់អ្នក មិនមានរោគទេ ។

(៣១) (មហាសត្វ) បពិត្រព្រះបិតា ព្រះអង្គមិនសោយទឹកស្រវឹងទេឬ សុរាមិនពេញព្រះទ័យរបស់ព្រះអង្គទេឬ ព្រះទ័យរបស់ព្រះអង្គ ត្រេកអរក្នុងសច្ចៈក្នុងធម៌និងក្នុងទានដែរឬ ។

(៣២) (ព្រះរាជបិតា) នែកូន ខ្ញុំមិនផឹកទឹកស្រវឹងទេ មួយទៀត សុរាមិនពេញចិត្តខ្ញុំទេ ឯចិត្តរបស់ខ្ញុំ តែងត្រេកអរក្នុងសច្ចៈ ក្នុងធម៌និងក្នុងទាន ។

(៣៣) (មហាសត្វ) យានរបស់ព្រះអង្គមិនខូចទេឬ វាហនៈរបស់ព្រះអង្គតែងប្រព្រឹត្តទៅបានដែរឬ ព្យាធិទាំងឡាយជាគ្រឿងដុតកំដៅសរីរៈ មិនមានដល់ព្រះអង្គទេឬ ។

(៣៦)អថោ អភគ្គំ យោគ្គំ មេ អថោ វហតិ វាហនំ
អថោ មេ ព្យាធយោ នត្ថិ សរីរស្សុបតាបិយា ។

(៣៧)កច្ចិ អគ្គា ច តេ ទីឃា មជ្ឈេ ច ពហលា តវ
កោដ្ឋាគារញ្ច កោសញ្ច កច្ចិ តេ បដិសណ្ឋិតំ ។

(៣៨)អថោ អគ្គា ច មេ ទីឃា មជ្ឈេ ច ពហលា មម
កោដ្ឋាគារញ្ច កោសញ្ច សព្វំ មេ បដិសណ្ឋិតំ ។

(៣៩)សាគតន្តេ មហារាជ អថោ តេ អទុរាគតំ
បតិដ្ឋាបេន្តុ បល្លង្កំ យត្ថ រាជា និសក្កតិ ។

(៤០)ឥធេវ តេ និសិន្នស្ស និយតេ បណ្ណសន្ថរេ
ឯត្តោ ឧទកមាទាយ បាទេ បក្ខាលយស្សុ តេ ។

(៤១)ឥទម្បិ បណ្ណកំ មយ្ហំ រន្ធំ រាជ អលោណកំ
បរិភុញ្ជ មហារាជ បាហុនោ មេសិ អាគតោ ។



(៣៦) (ព្រះរាជា) ឯយានរបស់ខ្ញុំឥតមានខ្ចោះទេ ក៏វាហនៈរបស់ខ្ញុំក៏ប្រព្រឹត្តទៅបានដោយស្រួល ព្យាធិទាំងឡាយជាគ្រឿងផ្តក់ផ្តៅសរីរៈ មិនមានដល់ខ្ញុំទេ ។

(៣៧) (មហាសត្វ) ដែនចុងនៅទីប្រទេសដែន របស់ព្រះអង្គ (ស្រុកនិគម) របស់ព្រះអង្គទាំងមូល ដែលតាំងនៅកណ្តាលដែនដី ជាស្រុកសម្បូណ៌ដែរឬ ឃ្លាំងនិងទីជម្រក ព្រះអង្គបានតម្កល់ទុកស្រួលបួលទេឬ ។

(៣៨) (ព្រះរាជា) ដែនចុងនៅទីប្រទេសដែនរបស់ខ្ញុំ (ស្រុកនិគម)ទាំងមូលរបស់ខ្ញុំ ដែលតាំងនៅកណ្តាលដែនជាស្រុកសម្បូណ៌ ឃ្លាំងនិងទីជម្រកទាំងអស់ ខ្ញុំបានតម្កល់ទុកស្រួលបួលហើយ ។

(៣៩) (មហាសត្វ) បពិត្រមហារាជ ព្រះអង្គស្តេចយាងមកល្អហើយ មួយទៀត ព្រះអង្គស្តេចមកមិនមែនអាក្រក់ទេ រាជបុរសចូររៀបចំបល្ល័ង្កជាទីគង់របស់ព្រះរាជា ។

(៤០) ព្រះអង្គគង់លើកម្រាលស្លឹកឈើ ដែលគេតែងតាំងហើយ សូមព្រះអង្គយកទឹកអំពីទីនេះ លាងព្រះបាទា របស់ព្រះអង្គចុះ ។

(៤១) បពិត្រព្រះរាជា ស្លឹកនេះដែលអាត្មាភាពចំអិនហើយ ជារបស់មិនមានអំបិលទេ បពិត្រមហារាជ សូមព្រះអង្គស្តេចសោយចុះ ព្រះអង្គទើបស្តេចយាងមកដល់ ទុកជាភ្ញៀវរបស់អាត្មាភាព ។

(៦០)ន ចាហំ បណ្ណកំ ភុញ្ជេ ន ហេតំ មយ្ហ ភោជនំ
សាលីនំ ឱទនំ ភុញ្ជេ សុចិំ មំសូបសេចនំ ។

(៦១)អច្ឆេរកំ មំ បដិភាតិ ឯកកម្បិ រហោគតំ
ឯទិសំ ភុញ្ជមានានំ កេន វណ្ណោ បសីទតិ ។

(៦២)ឯកោ រាជ និបជ្ជាមិ និយតេ បណ្ណសន្ថរេ
តាយ មេ ឯកសេយ្យាយ រាជ វណ្ណោ បសីទតិ ។
ន ច នេត្តឹសពទ្ធា មេ រាជរក្ខា ឧបដ្ឋិតា
តាយ មេ ឯកសេយ្យាយ រាជ វណ្ណោ បសីទតិ ។
អតីតំ នានុសោចាមិ នប្បជប្បាមនាគតំ
បច្ចុប្បន្នេន យាបេមិ តេន វណ្ណោ បសីទតិ ។
អនាគតប្បជប្បាយ អតីតស្សានុសោចនា
ឯតេន ពាលា សុស្សន្តិ នឡោវ ហរិតោ លុតោ ។



(៦០) (សារថិ) ខ្ញុំមិនបរិភោគស្លឹកនេះទេ ព្រោះស្លឹកឈើនេះ មិនមែនជាភោជនរបស់ខ្ញុំ ខ្ញុំបរិភោគតែបាយ នៃស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត ។

(៦១) សេចក្តីអស្ចារ្យកើតប្រាកដដល់ខ្ញុំ ព្រោះឃើញ (លោក) នៅស្ងាត់តែម្នាក់ឯង កាលបរិភោគភោជនបែបនេះ សម្បុរ នៅតែស្រស់ថ្លាដោយហេតុដូចម្តេច ។

(៦២) (មហាសត្វ) បពិត្រព្រះរាជា អាត្មាភាពម្នាក់ឯងដេក លើគ្រោងស្លឹកដែលតាំងទុកហើយ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាពស្រស់ថ្លា ដោយដំណេកម្នាក់ឯងនោះ ។ ពួកអង្គរក្ស ព្រះរាជាដែលសៀតព្រះខាន់ មិនប្រាកដដល់អាត្មាភាពទេ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាព ថ្លាស្រស់ដោយដំណេកម្នាក់ឯងនោះ ។ អាត្មាភាព មិនកាន់សោកចំពោះអារម្មណ៍ ដែលកន្លងហើយ មិនប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលកើតឡើងចំពោះមុខ ហេតុនោះ បាន ជាវណ្ណៈរបស់អាត្មាភាព រមែងថ្លាស្រស់ ។ ជនពាលទាំងឡាយ តែងរីងស្ងួត ព្រោះសេចក្តីប្រាថ្នាអារម្មណ៍ ដែលមិនទាន់មកដល់ ព្រោះសេចក្តីកាន់សោកស្តាយអារម្មណ៍ ដែលកន្លងទៅហើយនេះ ដូចជាដើមបបុសមានសម្បុរខៀវ ដែលគេដកហាលថ្ងៃក្តៅ ។

(៥៣) ហត្ថានីកំ រថានីកំ អស្សេ បត្តី ច វម្មិនោ
និវេសនានិ រម្មានិ អហំ បុត្ត ទទាមិ តេ ។
ឥត្ថាគារម្បិ តេ ទម្មិ សព្វាលង្ការភូសិតំ
តា បុត្ត បដិបជ្ជស្សុ ត្វំ នោ រាជា ភវិស្សសិ ។
កុសលា នច្ចគីតស្ស សិក្ខិតា ចាតុរិត្ថិយោ
កាមេ តំ រមយិស្សន្តិ កឹ អរញ្ញេ ករិស្សសិ ។
បដិរាជូហិ តេ កញ្ញា អានយិស្សំ អលង្កតា
តាសុ បុត្តេ ជនេត្វាន អថ បច្ឆា បព្វជិស្សសិ ។
យុវា ច ទហរោ ចាសិ បឋមុប្បត្តិកោ សុសុ
រជ្ជំ ការេហិ ភទ្ទន្តេ កឹ អរញ្ញេ ករិស្សសិ ។
(៥៤) យុវា ចរេ ព្រហ្មចរិយំ ព្រហ្មចារី យុវា សិយា
ទហរស្ស ហិ បព្វជ្ជា ឯតំ ឥសីហិ វណ្ណិតំ ។
យុវា ចរេ ព្រហ្មចរិយំ ព្រហ្មចារី យុវា សិយា
ព្រហ្មចរិយំ ចរិស្សាមិ នាហំ រជ្ជេនមត្ថិកោ ។



(៥៣) (ព្រះរាជា) នែកូន ខ្ញុំនឹងឲ្យនូវពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកជនពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ មួយទៀត ខ្ញុំឲ្យនូវស្រីស្នំដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន ចូរអ្នកគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ អ្នកជាព្រះរាជារបស់យើង ។ ស្ត្រីទាំង ជាអ្នកឈ្លាសក្នុងការរាំនិងច្រៀង បានសិក្សា (ក្នុងកិច្ចស្ត្រី) ញុំាងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ ខ្ញុំនឹងនាំយករាជកញ្ញាដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃដល់អ្នក អ្នកចូរញុំាងកូនទាំងឡាយ ឲ្យកើតក្នុងស្ត្រីទាំងនោះ ហើយសឹមបួសក្នុងកាលជាខាងក្រោយ ។ អ្នកនៅក្មេងកំលោះប្រកបដោយបឋមវ័យមានសក់ខ្មៅស្រិល ចូរសោយរាជ្យ សេចក្តីចំរើនចូរមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។

(៥៤) (មហាសត្វ) បុគ្គលនៅក្មេងគប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីជាក្មេង ព្រោះថា បព្វជ្ជារបស់បុគ្គលនៅក្មេង ឥសីទាំងឡាយសរសើរហើយ ។ បុគ្គលនៅក្មេង គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីនៅក្មេង អាត្មាភាព នឹងប្រព្រឹត្តព្រហ្មចរិយធម៌ អាត្មាភាព មិនត្រូវការ ដោយរាជ្យទេ ។

ឧស្សាហំ ករោហិ ធីរំ   អព្ភុតាត វទន្តរំ

ភិក្ខាលទ្ធំ បិយំ មុត្តំ   អបព្ភារំ ជរំ មតំ ។

ឧស្សាហំ ករោហិ ធីរំ   កុមារំ ពាលុធស្សនំ

ឧសីសកលីរ(១)   បលុត្ថំ(២) ធីរតគ្គយំ ។

ធាតាកចិ ហំ មីយត្តិ   ធក ច អជ ធារិយោ

គត្ត គោ វិស្សុសេ ពោសោ   ធយាកេន្តិ ធីរគេ ។

យស្ស វត្យា វិសោធ   កាយុ អបព្ភរំ សិយា

អបេត្តធកោរ មធ្ជានំ   កិន្នុ គោមារកំ គហិ ។

មិក្ខុបញ្ញាហគោ លោភោ   មិន្ទញ្ញ បរិករគោ

អមោឃាសុ វជ្ជិសុ   កិំ មំ វដ្ឋកិសិញ្ចសិ ។

(២៧)គោធបញ្ញាហគោ លោភោ   គោធ ច បរិករគោ

កាយោ អមោឃា គច្ឆន្តិ   កិំ មេ អត្តាហំ មុច្ចិគោ ។

(២៨)មន្ទុបញ្ញាហគោ លោភោ   ជាលយ បរិករគោ

វត្យា អមោឃា គច្ឆន្តិ   បរំ ជាលាហំ ទត្តិយ ។

---

១ ម. ឧស្សីសកលីរ ។ ២ ម. ឧ. បលុត្ថំ ។



បពិត្រព្រះមាតានិមិត្ត កណ្ដាក ឃើញខ្លែងនៅក្នុង ទើបខំ បន្ទោយ ជាក្អួ ជាទីស្រឡាញ់ ដែលមានបំពង់ជាយ សំពុក មិនពាន់ពាល់ត្រាំត្រាហើយស្លាប់ ។ កណ្ដាក ឃើញនាង កុមារីមានសម្បុរដូចមាស ដែលមង្គល ចាប់ដករយ៉ាងដឹកហើយ ដូចជាដែកខ្លួនទាំងទីថុស្សម៉ិទ្ធ ។ នាងទេពធីតា ឬនាងនារី ទាំងឡាយ សូមរំលឹកនៅក្នុងគឺតែងស្លាប់ តើសត្វណាសម្បើមទុកចិត្ត ក្នុងដីនេះនោះជា កណ្ដាសញ្ញនៅក្នុងដូចនេះ ។ គះយៈនៃកុមារណា មានប្រមាណតិច ដោយការកន្ទុំនៅនៃយប់នីងរៃ ការនៃខ្លួន ជាកុមារក្នុងនេះ ទឹកស្ទើរដូចម្ដេចកើត ដូចទីមានទឹកតិចរបស់ត្រី ទាំងឡាយ ។ សត្វណាក ត្រៅសក្ការបៀតបៀនជាទិច្ចផង ត្រៅ សក្ការបៀកជាទិច្ចផង កាលយប់នឹងថ្ងៃទាំងឡាយមិនកន្ទុំនៅទេ ទេ តើព្រះអង្គនឹងកំសេកតាក្នុងកាត្រដូចម្ដេច ។

(២៧) (ព្រះរាជា) សត្វណាកាន់ ត្រៅសក្ការបៀតបៀនផង ក្រៅសក្ការបៀកផង ដូចជាតិដូចម្ដេច មិនកន្ទុំនៅទេ ខ្ញុំសួរ ហើយ អ្នកចូរប្រាប់ខ្ញុំដំណើរនោះ ។

(២៨) (ព្រះមហាសត្វ) សត្វណាក្រោមម្ចាស់បៀតបៀនផង ក្រៅដែកប្រើកផង ក្រោទាំងឡាយ រមែងកន្ទុំនៅមិនទទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គ ជ្រាបយ៉ាងនេះចុះ ។

យថាបិ តន្តេ វិតន្តេ  យំ យទេវូបវុយ្យតិ
អប្បកំ ហោតិ វេតព្វំ  ឯវំ មច្ចាន ជីវិតំ ។
យថា វារិវហោ បូរោ  គច្ឆំ ន បរិវត្តតិ
ឯវមាយុ មនុស្សានំ  គច្ឆំ ន បរិវត្តតិ ។
យថា វារិវហោ បូរោ  វហេ រុក្ខេ បកូលជេ
ឯវំ ជរាយ មរណេន  វុយ្ហន្តេ សព្វបាណិនោ ។
(៤៧) ហត្ថានីកំ រថានីកំ  អស្សេ បត្តិញ្ច វម្មិនោ
និវេសនានិ រម្មានិ  អហំ បុត្ត ទទាមិ តេ ។
ឥត្ថាគារញ្ច តេ ទម្មិ  សព្វាលង្ការភូសិតំ
តា បុត្ត បដិបជ្ជស្សុ  ត្វំ នោ រាជា ភវិស្សសិ ។
កុសលា នច្ចគីតស្ស  សិក្ខិតា ចាតុរិត្ថិយោ
កាមេ តំ រមយិស្សន្តិ  កឹ អរញ្ញេ ករិស្សសិ ។
បដិរាជូហិ តេ កញ្ញា  អានយិស្សំ អលង្កតា
តាសុ បុត្តេ ជនេត្វាន  អថ បច្ឆា បព្វជិស្សសិ ។



កាលតម្បាញដែលបុគ្គលត្បាញ របស់ណា ៗ ដែលបុគ្គលនឹងត្បាញ របស់ដែលត្រូវត្បាញ (នោះៗ) ជារបស់នៅសល់តិច យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញកាលហូរទៅ មិនត្រឡប់ថយក្រោយវិញ យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ កាលកន្លងទៅ មិនត្រឡប់វិញយ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញ តែងបណ្តែតទៅនូវដើមឈើទាំងឡាយដែលដុះក្បែរច្រាំង យ៉ាងណាមិញ សត្វទាំងអស់ ត្រូវជរានិងមរណៈបណ្តែតទៅ ក៏យ៉ាងនោះដែរ ។

(៤៧) (ព្រះរាជបិតា) នែកូន ខ្ញុំនឹងឲ្យពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកពលពាក់គ្រឿងក្រោះនឹងនិវេសនដ្ឋានទាំងឡាយជាទីត្រេកអរដល់អ្នក ។ មួយទៀត យើងនឹងឲ្យស្ត្រីស្នំដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន អ្នកចូរគ្រប់គ្រងពួកស្ត្រីទាំងនោះចុះ អ្នកនឹងជារាជារបស់យើង ស្ត្រីបួន ជាអ្នកឈ្លាសក្នុងការរាំនិងច្រៀង សិក្សា (ក្នុងកិច្ចរបស់ស្ត្រី) នឹងញ៉ាំងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។ យើងនឹងនាំយកពួកកញ្ញាដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃដល់អ្នក អ្នកញ៉ាំងកូនទាំងឡាយ ឲ្យកើតក្នុងពួកនាងកញ្ញាទាំងនោះ ហើយសឹមបួស ក្នុងកាលជាខាងក្រោយចុះ ។

យុវា ច ទហរោ ចាសិ បឋមុប្បត្តិកោ សុសុ
រជ្ជំ ការេហិ ភទ្ទន្តេ កឹ អរញ្ញេ ករិស្សសិ ។
កោដ្ឋាគារញ្ច កោសញ្ច វាហនានិ ពលានិ ច
និវេសនានិ រម្មានិ អហំ បដិទទាមិ តេ ។
គោមណ្ឌលបរិព្យូឡ្ហោ នារីសង្ឃបុរក្ខតោ
រជ្ជំ ការេហិ ភទ្ទន្តេ កឹ អរញ្ញេ ករិស្សសិ ។
(៤៨) កឹ មំ ធនេន ជីយេថ កឹ ភរិយាយ មរិស្សតិ
កឹ យោព្វនេន ជិណ្ណេន យំ ជរាយាភិភុយ្យតេ ។
តត្ថ កា នន្ទិ កា ខិឌ្ឌា កា រតិ កា ធនេសនា
កឹ មេ បុត្តេហិ ទារេហិ រាជ មុត្តោស្មិ ពន្ធនា ។
សោហំ ឯវំ បជានាមិ មច្ចុ មេ នប្បមជ្ជតិ
អន្តកេនាធិបន្នស្ស កា រតិ កា ធនេសនា ។
ផលានមិវ បក្កានំ និច្ចំ បតនតោ ភយំ
ឯវំ ជាតាន មច្ចានំ និច្ចំ មរណតោ ភយំ ។



អ្នកនៅក្មេងកំលោះប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យចុះ សេចក្ដីចំរើនចូរមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។ នែកូន ខ្ញុំនឹងឲ្យឃ្លាំង ជង្រុក ពាហនៈ ពល និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ អ្នកដែលក្រុមនៃគោដកញ្ញាមានចំណែកដ៏ល្អចោមរោមហើយ មានពួកនៃស្ត្រីហែហមហើយ ចូរសោយរាជ្យចុះ សេចក្ដីចំរើនចូរមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ។

(៤៨) (ព្រះមហាសត្វ) ប្រយោជន៍អ្វីដោយទ្រព្យដល់អត្តភាព ព្រោះទ្រព្យតែងអស់ទៅ ប្រយោជន៍អ្វីដោយភរិយា ព្រោះភរិយាក៏តែងស្លាប់ ប្រយោជន៍អ្វីដោយវ័យដែលគ្រាំគ្រា ជាវ័យត្រូវជរាគ្របសង្កត់ហើយ ។ ក្នុងលោកសន្និវាសនេះ នៅមានសេចក្ដីត្រេកអរអ្វី ការលេងសើចអ្វី ការរីករាយអ្វី ការស្វែងរកទ្រព្យអ្វី អាត្មាភាពត្រូវការអ្វីដោយកូននិងប្រពន្ធ បពិត្រព្រះរាជា អាត្មាភាពរួចស្រឡះចាកចំណងហើយ ។ អាត្មាភាពដឹងច្បាស់យ៉ាងនេះថា មច្ចុមិនធ្វេសប្រហែសចំពោះអាត្មាឡើយ អាត្មាភាពនោះ ត្រូវសេចក្ដីស្លាប់គ្របសង្កត់ហើយ នៅមានសេចក្ដីត្រេកអរដូចម្ដេច ការស្វែងរកទ្រព្យដូចម្ដេចទៀត ។ ផ្លែឈើទុំទាំងឡាយ តែងមានភ័យអំពីការជ្រុះជានិច្ច យ៉ាងណាមិញ សត្វទាំងឡាយ កើតមកហើយ តែងមានភ័យអំពីសេចក្ដីស្លាប់ ជានិច្ច យ៉ាងនោះដែរ ។

សាយមេកេ ន ទិស្សន្តិ បាតោ ទិដ្ឋា ពហូ ជនា

បាតោ ឯកេ ន ទិស្សន្តិ សាយំ ទិដ្ឋា ពហូ ជនា ។

អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ

ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។

ចោរា ធនស្ស បត្ថេន្តិ រាជ មុត្តោស្មិ ពន្ធនា

ឯហិ រាជ និវត្តស្សុ នាហំ រជ្ជេនមត្ថិកោតិ ។

តេមិយជាតកំ បឋមំ ។





ជនជាច្រើន ពួកខ្លះដែលគេឃើញក្នុងវេលាព្រឹក តែគេមិនឃើញក្នុងវេលាល្ងាច ជនជាច្រើន ពួកខ្លះដែលគេឃើញក្នុងវេលាល្ងាច តែគេមិនឃើញក្នុងវេលាព្រឹក ។ សេចក្តីព្យាយាមក្នុងកុសល គេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណា គប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក ព្រោះការបណ្តាក់ទៅក្តីអំពីសេចក្តីស្លាប់ ដែលមានសេនាច្រើននោះ មិនមានដល់យើងទេ ។ ពួកចោរទាំងឡាយតែងប្រាថ្នាទ្រព្យ បពិត្រព្រះរាជា អាត្មាភាព ផុតស្រឡះហើយអំពីចំណង បពិត្រព្រះរាជា សូមព្រះអង្គមក សូមព្រះអង្គត្រឡប់ព្រះហឫទ័យទៅវិញចុះ អាត្មាភាពមិនត្រូវការដោយរាជ្យទេ ។

ចប់ តេមិយជាតក ទី ១ ។

(៧៩) កោយំ មជ្ឈេ សមុទ្ទស្មឹ អបស្សំ តីរមាយុហេ
កំ ត្វំ អត្ថវសំ ញត្វា ឯវំ វាយមសេ ភុសំ

(៨០) និសម្ម វត្តំ លោកស្ស វាយាមស្ស ច ទេវតេ
តស្មា មជ្ឈេ សមុទ្ទស្មឹ អបស្សំ តីរមាយុហេ ។

(៨១) គម្ភីរេ អប្បមេយ្យស្មឹ តីរំ យស្ស ន ទិស្សតិ
មោឃោ តេ បុរិសវាយាមោ អប្បត្វាវ មរិស្សសិ ។

(៨២) អនណោ ញាតីនំ ហោតិ ទេវានំ បិតុនញ្ច សោ
ករំ បុរិសកិច្ចានិ ន ច បច្ឆានុតប្បតិ ។

(៨៣) អបារណេយ្យំ យំ កម្មំ អផលំ កិលមថុទ្ទយំ
តត្ថ កោ វាយមេនត្ថោ មច្ចុ យស្សាភិនិប្បតំ ។



(៧៩) (មាននាងទេវតាឈ្មោះមណីមេខលាសួរថា) បុគ្គលណានេះ កាលមិនឃើញត្រើយ ក៏ព្យាយាម (វាយ) ក្នុងកណ្តាលសមុទ្រ អ្នកដឹងនូវអំណាចនៃប្រយោជន៍ដូចម្តេច ក៏ព្យាយាមក្រៃពេកម្ល៉េះ ។

(៨០) (ព្រះមហាសត្វត្រាស់តបថា) ម្នាលទេវតា ខ្ញុំពិចារណានូវវត្តនៃសត្វលោក នឹងអានិសង្សនៃសេចក្តីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំសូម្បីមិនឃើញត្រើយ ក៏នៅតែព្យាយាមក្នុងកណ្តាលសមុទ្រ ។

(៨១) (នាងមណីមេខលា) អ្នកមិនឃើញត្រើយនៃសមុទ្រ ដ៏ជ្រៅប្រមាណមិនបាន ការព្យាយាមតាមកម្លាំងបុរសរបស់អ្នក ជាព្យាយាមសោះសូន្យទទេ អ្នកមិនដល់នូវត្រើយទេ មុខជានឹងស្លាប់ ។

(៨២) (ព្រះមហាសត្វ) បុគ្គលធ្វើនូវកិច្ចរបស់បុរស ទើបជាអ្នកមិនមានបំណុល (ក្នុងរវាង) ពួកញាតិ ពួកទេវតា នឹងពួកបិតា (ព្រហ្ម) ទាំងមិនក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ។

(៨៣) (នាងមណីមេខលា) ការងារណា មិនគប្បីសម្រេច (ដោយសេចក្តីព្យាយាមទេ) ការងារនោះ ជារបស់ឥតផល មានសេចក្តីលំបាកជាកម្រៃ សេចក្តីស្លាប់ រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះ មានប្រយោជន៍ដូចម្តេច ដោយសេចក្តីព្យាយាមក្នុងការងារនោះ ។

(៤៦) អបារណេយ្យមច្ចន្តំ យោ វិទិត្វាន ទេវតេ
ន រក្ខេ អត្តនោ បាណំ ជញ្ញា សោ យទិ ហាបយេ
អធិប្បាយផលំ ឯកេ អស្មឹ លោកស្មិ ទេវតេ
បយោជយន្តិ កម្មានិ តានិ ឥជ្ឈន្តិ វា ន វា ។
សន្ទិដ្ឋិកំ កម្មផលំ ននុ បស្សសិ ទេវតេ
សន្នា អញ្ញេ តរាមហំ តញ្ច បស្សាមិ សន្តិកេ
សោ អហំ វាយមិស្សាមិ យថាសត្តិ យថាពលំ
គច្ឆំ បារំ សមុទ្ទស្ស កស្សំ បុរិសការិយំ ។

(៤៧) យោ ត្វំ ឯវំ គតេ ឱឃេ អប្បមេយ្យេ មហណ្ណវេ
ធម្មវាយាមសម្បន្នោ កម្មុនា នាវសីទសិ
សោ ត្វំ តត្ថេវ គច្ឆាហិ យត្ថ តេ និរតោ មនោ ។



(៤៦) (ព្រះមហាសត្វ) ម្នាលទេវតា បុគ្គលណាដឹងច្បាស់ថាការងារមិនសម្រេចដោយពិត ហើយមិនរក្សាជីវិតរបស់ខ្លួន បុគ្គលនោះ បើបន្ថយសេចក្តីព្យាយាមគង់ដឹង (នូវផលនៃសេចក្តីខ្ជិលនោះមិនខាន) ។ ម្នាលទេវតា បុគ្គលពួកខ្លះ ក្នុងលោកនេះ (កាលឃើញ) នូវផលនៃសេចក្តីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះ សម្រេចខ្លះ មិនសម្រេចខ្លះ ។ ម្នាលទេវតា ក្រែងអ្នកបានឃើញផលនៃកម្មដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ជនទាំងឡាយដទៃលិចលង់ហើយ ខ្ញុំនៅឆ្លង ទាំងបានឃើញនូវផលប្រាកដក្នុងទីជិតនៃខ្ញុំ ។ ខ្ញុំនោះ នឹងព្យាយាមតាមសមគួរដល់សេចក្តីអាច នឹងសមគួរដល់កម្លាំង ខ្ញុំកាលទៅដល់ត្រើយនៃសមុទ្រ នឹងធ្វើនូវសេចក្តីព្យាយាមដែលបុរសគប្បីធ្វើ ។

(៤៧) (នាងមណីមេខលា) កាលមហាសមុទ្រមានអន្លង់ទឹកធំប្រមាណមិនបាន ប្រព្រឹត្តទៅយ៉ាងនេះ អ្នកណាប្រកបដោយសេចក្តីព្យាយាមដោយធម៌ រមែងមិនលិចចុះដោយកម្ម គឺសេចក្តីព្យាយាម ចិត្តរបស់អ្នកត្រេកអរក្នុងទីណា អ្នកនោះ ចូរទៅក្នុងទីនោះចុះ ។

(៤៦) សុរិយុគ្គមនេ និធិ　អថោ ឱគ្គមនេ(១) និធិ
អន្តោ និធិ ពហិ និធិ　ន អន្តោ ន ពហិ និធិ
អារោហនេ មហានិធិ　អថោ ឱរោហនេ និធិ
ចតូសុ មហាសាលេសុ　សមន្តា យោជនេ និធិ
ទន្តគ្គេសុ មហានិធិ　វាលគ្គេសុ ច កេបុកេ
រុក្ខគ្គេសុ មហានិធិ　សោឡសេតេ មហានិធី
សហស្សថាមោ បល្លង្កោ　សីវលារាធនេន ច ។

(៤៧) អាសីសេថេវ បុរិសោ　ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ　យថា ឥច្ឆឹ តថា អហុ ។
អាសីសេថេវ បុរិសោ　ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ　ឧទកា ថលមុព្ភតំ ។
វាយមេថេវ បុរិសោ　ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ　យថា ឥច្ឆឹ តថា អហុ ។
វាយមេថេវ បុរិសោ　ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ　ឧទកា ថលមុព្ភតំ ។

១ ម. ឧគ្គមនេ ។



(៤៦) (ព្រះបាទមហាជនក) កំណប់ធំ ១៦ នេះគឺ កំណប់ត្រង់ទីព្រះអាទិត្យរះ កំណប់ត្រង់ទីព្រះអាទិត្យលិច កំណប់ខាងក្នុង កំណប់ខាងក្រៅ កំណប់មិនមែនខាងក្នុង មិនមែនខាងក្រៅ កំណប់ធំត្រង់ទីសម្រាប់ឡើង កំណប់ត្រង់ទីសម្រាប់ចុះ កំណប់ត្រង់សាលព្រឹក្សធំទាំងបួន កំណប់ត្រង់ទីមួយយោជន៍ជុំវិញ កំណប់ធំត្រង់ចុងភ្លុកដំរីទាំងពីរ កំណប់ត្រង់ចុងកន្ទុយ កំណប់ក្នុងទឹក កំណប់ធំត្រង់ចុងឈើ សហស្សថាមក្តី បល្ល័ង្កប្រដាប់ និងញុំាងនាងសីវលីទេវីឲ្យត្រេកអរ ។

(៤៧) (ព្រះបាទមហាជនក) បុរសជាបណ្ឌិត គប្បីតែប្រាថ្នា មិនគប្បីនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួនឯង យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។ បុរសជាបណ្ឌិត គប្បីតែប្រាថ្នា មិនគប្បីនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន (ដែលទេវតា) ស្រង់អំពីទឹកមកដាក់លើគោក ។ បុរសជាបណ្ឌិត គប្បីតែព្យាយាម មិនគប្បីនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។ បុរសជាបណ្ឌិត គប្បីតែព្យាយាមមិនគប្បីនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន (ដែលទេវតា) ស្រង់អំពីទឹកមកដាក់លើគោក ។

ទុក្ខូបនីតោបិ នរោ សបញ្ញោ
អាសំ ន ឆិន្ទេយ្យ សុខាគមាយ
ពហូ ហិ ផស្សា អហិតា ហិតា ច
អវិតក្កិតា មច្ចុមុបព្វជន្តិ ។
អចិន្តិតម្បិ ភវតិ ចិន្តិតម្បិ វិនស្សតិ
ន ហិ ចិន្តាមយា ភោគា ឥត្ថិយា បុរិសស្ស វា ។
(៥៨) អបោរាណំ វត ភោ រាជា សព្ពភុម្មោ ទិសំបតិ
នាជ្ជ នច្ចេ និសាមេតិ ន គីតេ កុរុតេ មនោ ។
ន មិគេ នបិ ឧយ្យានេ នបិ ហំសេ ឧទិក្ខតិ
មូគោវ តុណ្ហីមាសីនោ ន អត្ថមនុសាសតិ ។
(៥៩) សុខកាមា រហោសីលា វធពន្ធា ឧបារតា
កស្ស នុ អជ្ជ អារាមេ ទហរា វុឌ្ឍា ច អច្ឆរេ ។
អតិក្កន្តវនថា ធីរា នមោ តេសំ មហេសិនំ
យេ ឧស្សុក្កម្ហិ លោកម្ហិ វិហរន្តិ អនុស្សុកា ។



នរជនមានប្រាជ្ញា សូម្បីសេចក្តីទុក្ខប៉ះពាល់ហើយ មិនគប្បីកាត់សេចក្តីប្រាថ្នា ដើម្បីដល់នូវសេចក្តីសុខទេ ព្រោះថាការប៉ះពាល់ដ៏ច្រើន ឥតប្រយោជន៍ក៏មាន មានប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងដល់នូវសេចក្តីស្លាប់ ។ ហេតុដែលបុគ្គលមិនបានគិត សម្រេចក៏មាន ហេតុដែលបុគ្គលគិតហើយ វិនាសទៅក៏មាន ព្រោះភោគៈទាំងឡាយ របស់ស្ត្រីបុរស មិនមែនសម្រេចដោយការគិតទេ ។

(៥៨) (មហាជន) ម្នាលអ្នកដ៏ចំរើន ព្រះរាជាគ្រប់គ្រងនូវផែនដីទាំងមូល ជាម្ចាស់នៃទិស មិនដូចពីដើមសោះ ថ្ងៃនេះមិនទ្រង់ព្រះសណ្តាប់ មិនទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះចំរៀង មិនទតម្រឹគ មិនទតឧទ្យាន មិនទតហង្ស ទ្រង់គង់នៅស្ងៀម ហាក់ដូចជាមនុស្សគ មិនទ្រង់កាន់សេចក្តី ។

(៥៩) (ព្រះបាទមហាជនក) ព្រះបច្ចេកពុទ្ធទាំងឡាយ ទាំងក្មេងទាំងចាស់ អ្នកប្រាថ្នានូវសេចក្តីសុខ មានសេចក្តីស្ងប់ស្ងាត់ជាប្រក្រតី ប្រាសចាកចំណងនិងការសម្លាប់ គង់នៅក្នុងអារាមនៃបុគ្គលណាហ្ន៎ ក្នុងថ្ងៃនេះ ។ អ្នកប្រាជ្ញទាំងឡាយណា បានកន្លងនូវតណ្ហាជាគ្រឿងមិនមានសេចក្តីខ្វល់ខ្វាយ នៅក្នុងលោក ដែលកំពុងខ្វល់ខ្វាយ ខ្ញុំសូមថ្វាយបង្គំអ្នកប្រាជ្ញទាំងនោះ ជាអ្នកស្វែងរកនូវគុណដ៏ធំ ។

តេ ឆេត្វា មច្ចុនោ ជាលំ តន្តំ មាយាវិនោ ទឡ្ហំ

ឆិន្នាលយត្តា គច្ឆន្តិ កោ តេសំ គតិ មាបយេ ។

(២០) កទាហំ មិថិលំ ផីតំ វិភត្តំ ភាគសោ មិតំ

បហាយ បព្វជិស្សាមិ តំ កទា(១)ស្សុ ភវិស្សតិ ។

កទាហំ មិថិលំ ផីតំ វិសាលំ សព្វតោ បភំ

បហាយ បព្វជិស្សាមិ តំ កទា ស្សុ ភវិស្សតិ ។

កទាហំ មិថិលំ ផីតំ ពហុបាការតោរណំ

បហាយ បព្វជិស្សាមិ តំ កទា ស្សុ ភវិស្សតិ ។

កទាហំ មិថិលំ ផីតំ ទឡ្ហមដ្ដាលកោដ្ឋកំ

បហាយ បព្វជិស្សាមិ តំ កទា ស្សុ ភវិស្សតិ ។

កទាហំ មិថិលំ ផីតំ សុវិភត្តំ មហាបថំ

បហាយ បព្វជិស្សាមិ តំ កទា ស្សុ ភវិស្សតិ ។

កទាហំ មិថិលំ ផីតំ សុវិភត្តន្តរាបណំ

បហាយ បព្វជិស្សាមិ តំ កទា ស្សុ ភវិស្សតិ ។

---

១ ម. តំ កុទស្សុ ។



អ្នកប្រាជ្ញទាំងឡាយនោះ កាត់ទំលាយនូវសំណាញ់ជាបណ្ដាញមាំទាំ របស់មច្ចុដែលមានមាយាចេញទៅរួច បុគ្គលណា គប្បីញុំាងគេឲ្យដឹង ផ្លូវដល់នូវគតិ (ដំណើរ) នៃអ្នកប្រាជ្ញទាំងនោះបាន ។

(២០) កាលណាអញនឹងលះនគរមិថិលា ជាក្រុងសម្បូណ៌ ដែលគេចែកហើយ (ដោយបាននាំចែកផ្លូវជាដើម) វាស់ហើយដោយចំណែក (នៃទ្វារនិងថ្នល់)ហើយបួស ការបួសនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ទូលាយ មានពន្លឺដោយជុំវិញ ហើយបួស ការបួសនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែងនិងខ្លោងទ្វារដ៏ច្រើន ហើយបួស ការបួសនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានប៉មនិងសុមខ្លោងទ្វារដ៏មាំមួន ហើយបួស ការបួសនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដែលគេចែកល្អ មានផ្លូវធំ ហើយបួស ការបួសនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកន្លែងផ្សារ ដែលគេចែកដោយល្អ ហើយបួស ការបួសនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ មិថិលំ ផីតំ  គវស្សរថបីឡិតំ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ មិថិលំ ផីតំ  អារាមវនមាលិនឹ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ មិថិលំ ផីតំ  ឧយ្យានវនមាលិនឹ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ មិថិលំ ផីតំ  បាសាទវនមាលិនឹ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ មិថិលំ ផីតំ  តិបុរំ រាជពន្ធុនឹ
មាបិតំ សោមនស្សេន  វេទេហេន យសស្សិនា
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ វិទេហេ ផីតេ  និចិតេ ធម្មរក្ខិតេ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ វិទេហេ ផីតេ  អជេយ្យេ ធម្មរក្ខិតេ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។





កាលណាអញ នឹងលះបង់នូវមិថិលា ជាក្រុងសម្បូណ៌ ដ៏កុះករដោយគោ សេះ និងរថ ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវមិ-ថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃសួន ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវមិថិលា ជាក្រុងសម្បូណ៌ មានរបៀប នៃព្រៃឧទ្យាន ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃប្រាសាទដ៏ប្រសើរ ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវមិថិលា ជាក្រុងសម្បូណ៌ មានកំពែង៣ជាន់ ពេញដោយពួកព្រះញាតិ ដែលព្រះបាទវេទេហៈព្រះនាមសោមនស្សមានយសទ្រង់សាងទុក ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវដែនវិទេហៈ ជាដែនសម្បូណ៌ បរិបូណ៌ដោយការសន្សំ (ស្បៀង អាហារជាដើម) ដែលគេរក្សាដោយធម៌ ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវដែនវិទេហៈ ជាដែនសម្បូណ៌ ដែលបច្ចាមិត្រឈ្នះមិនបាន ជាដែនគេរក្សាដោយធម៌ ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ អដ្ដបុរំ រម្មំ វិកត្តំ កាកសោ មំសំ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ អដ្ដបុរំ រម្មំ សុជាមត្តិកាលេបនំ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ អដ្ដបុរំ រម្មំ សុចិគន្ធំ មនោរមំ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ កុជាការេ ច វិកត្តេ កាកសោ មំសេ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ កុជាការេ ច សុជាមត្តិកាលេបនេ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ កុជាការេ ច សុចិគន្ធេ មនោរមេ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ កុជាការេ ច លិត្តេ ចន្ទនលោសិតេ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ សុវណ្ណមយត្ថម្ភេ តោរណេ ចិត្តសន្ថតេ
បហាយ បព្ពជិស្សាមិ តំ កទា សុ ភវិស្សតិ ។



កាលណាអញ នឹងលះបង់នូវរាងកន្លុំ ដែលជាទីរីករាយ ដែលជាផ្ទះ ដែលគេក្រាលដោយចំណែក ហើយបួស កាលលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវរាងកន្លុំ ជាទីរីករាយដែលគេលាបដោយកំបោរដីស ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរាងកន្លុំជាទីរីករាយ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវផ្ទះកំពូលទាំងឡាយ ដែលជាទីគួរហើយ ក្រាលហើយដោយចំណែក ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវផ្ទះកំពូលទាំងឡាយ ដែលគេលាបដោយកំបោរដីស ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះនូវផ្ទះកំពូលទាំងឡាយ ដែលមានក្លិនក្រអូបជាទីរីករាយនៃចិត្ត ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវផ្ទះកំពូលទាំងឡាយ ដែលលាបល្អហើយ ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវប្រាសាទទាំងឡាយ មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ មណិបល្លង្កេ  គោណកេ ចិត្តសន្ថតេ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ កប្បាសកោសេយ្យំ ខោមកោទុម្ពរានិ ច
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ បោក្ខរណី រម្មា  ចក្កវាកបកូជិតា
មន្ទាលកេហិ សញ្ឆន្នា  បទុមុប្បលកេហិ ច
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ ហត្ថិគុម្ពេ ច  សព្វាលង្ការភូសិតេ
សុវណ្ណកច្ឆេ មាតង្គេ  ហេមកប្បនវាសសេ
អារូឡ្ហេ គាមណីយេភិ  តោមរង្កុសបាណិភិ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។
កទាហំ អស្សគុម្ពេ ច  សព្វាលង្ការភូសិតេ
អាជានីយេវ ជាតិយា  សិន្ធវេ សីឃវាហនេ
អារូឡ្ហេ គាមណីយេភិ  ឥល្លិយាចាបធារិភិ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។

១ ម. ឥល្លិយាចាបធារិហិ ។



កាលណាអញ នឹងលះបង់នូវបល្ល័ង្កកែវមណី មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស កាលនេះនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់ នូវសំពត់អំបោះនឹងសំពត់សូត្រ សំពត់ទាំងឡាយដែលកើតអំពីដើមខោមៈនឹងកើតអំពីដើមកោទុម្ពរ ហើយបួស កាលនេះនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់ នូវស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចក្រពាកយំទ្រហឹង ដេរដាសដោយចង្កុលណីទាំងឡាយផង ដោយឈូកនិងព្រលិតទាំងឡាយផង ហើយបួស កាលនេះនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវហ្វូងដំរី ទាំងផ្ទះ ដែលស្អិតស្អាងហើយគ្រឿងអលង្ការគ្រប់មុខ មានខ្សែផ្ចិតមាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីមានលំពែងនិងកង្វេរក្នុងដៃ ឡើងជិះហើយ ហើយបួស កាលនេះនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវហ្វូងសេះ អាជានេយ្យតាមជាតិ ជាសេះសិន្ធព ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ ជាកពាហនៈលឿន ដែលអ្នកបរភ្ជិតកាន់សរកាន់ស៊ែវធ្នូ ឡើងជិះហើយ ហើយបួស កាលនេះនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ រថសេនិយោ  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ(១)
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។

កទាហំ សោវណ្ណរថេ  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។

កទាហំ សជ្ឈុរថេ ច  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។

កទាហំ អស្សរថេ ច  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ  តំ កទា សុ ភវិស្សតិ ។

---

១ ឱ. ម. វម្មិកិ ។



កាលណាអញ នឹងលះបង់នូវពួករថ ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទជុំដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួករថមាស ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទជុំដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថប្រាក់ ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទជុំដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវរថទឹមសេះ ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទជុំដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនិងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ ឧដ្ឋរថេ ច　　សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ　　សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ　　ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ　　តំ កទា សុ ភវិស្សតិ ។

កទាហំ គោណរថេ ច　　សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ　　សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ　　ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ　　តំ កទា សុ ភវិស្សតិ ។

កទាហំ អជរថេ ច　　សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ　　សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ　　ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ　　តំ កទា សុ ភវិស្សតិ ។

កទាហំ មេណ្ឌរថេ ច　　សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ　　សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ　　ចាបហត្ថេហិ ចម្មិភិ
បហាយ បព្វជិស្សាមិ　　តំ កទា សុ ភវិស្សតិ ។



កាលណាអញ នឹងលះបង់នូវរថទឹមអូដ្ឋ ប្រដាប់ហើយ មានទង់លើកហើយ ពាំងចិញ្ចាំងដោយស្បែកខ្លាដំបងនឹងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនឹងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវរថទឹមគោ ប្រដាប់ហើយ មានទង់លើកហើយ ពាំងចិញ្ចាំងដោយស្បែកខ្លាដំបងនឹងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនឹងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវរថទឹមពពែ ប្រដាប់ហើយ មានទង់លើកហើយ ពាំងចិញ្ចាំងដោយស្បែកខ្លាដំបងនឹងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនឹងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវរថទឹមចៀម ប្រដាប់ហើយ មានទង់លើកហើយ ពាំងចិញ្ចាំងដោយស្បែកខ្លាដំបងនឹងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូនឹងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ បិករថេ ច   សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ   សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេហិ   ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ ហត្ថារោហេ ច   សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ   តោមរង្កុសបាណិនោ(១)
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ អស្សារោហេ ច   សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ   ឥល្លិយាចាបធារិនោ(២)
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ រថារោហេ ច   សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ   ចាបហត្ថេ កលាបិនោ
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ ធនុគ្គហេ ច   សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ   ចាបហត្ថេ កលាបិនោ
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។

១ ម.ឆ. តោមរង្កុសបាណិនេ ។ ២ ម.ឆ. ឥល្លិយាចាបធារិនេ ។



កាលណាអញនឹងលះបង់នូវរថចំរើន ប្រដាប់ហើយ មានទង់លើក ហើយ តាំងបាំងដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់គ្រាន់ ដែលនាយសារថីមានធ្នូនៅក្នុងដៃ ឡើងជិះហើយ ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវពួកអ្នកជិះដំរី ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់គ្រាន់ កាន់ទាំងតោមរនិងកង្វេរ ជាអ្នកក្លៀវក្លា មានសំលៀកស្លៀកក្របីនឹងអាវក្រោះខៀវ ហើយបួស កាលលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះសេះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់គ្រាន់ កាន់ទាំងតាមគណ្ឌៀរ ជាអ្នកក្លៀវក្លា ប្រដាប់នូវស្បៃនឹងក្ដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះរថ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់គ្រាន់ កាន់ទាំងតាមគណ្ឌៀរ ជាអ្នកក្លៀវក្លា មានធ្នូនឹងព្រួញក្នុងដៃ ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវពួកខ្មាន់ធ្នូ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់គ្រាន់ កាន់ទាំងតាមគណ្ឌៀរ ជាអ្នកក្លៀវក្លា មានធ្នូនឹងបំពង់ព្រួញក្នុងដៃ ហើយបួស ការលះបង់នោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាហំ រាជបុត្តេ ច   សព្វាលង្ការភូសិតេ
ចិត្រវម្មធរេ សូរេ   កញ្ចនាវេឡធារិនោ
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ អរិយគណេ   វតវន្តេ អលង្កតេ
ហរិចន្ទនលិត្តង្គេ   កាសិកុត្តមធារិនោ
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ អមច្ចគណេ   សព្វាលង្ការភូសិតេ
បីតវម្មធរេ សូរេ   បុរតោ គច្ឆមាលិនោ
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ សត្តសតា ភរិយា   សព្វាលង្ការភូសិតា
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ សត្តសតា ភរិយា   សុសញ្ញា តនុមជ្ឈិមា
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។
កទាហំ សត្តសតា ភរិយា   អស្សវា បិយភាណិនី
បហាយ បព្វជិស្សាមិ   តំ កទា សុ ភវិស្សតិ ។



កាលណាអញនឹងលះបង់នូវពួករាជបុត្រ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាសនិងកែវពិទូរ្យ ហើយបួស កាលនេះនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវពួកអរិយជន ពីគ្រោះណាស់ដែលមានសីលគត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្តប់ដោយសំពត់ ដែលបានមកអំពីដែនកាសីដ៏ឧត្តម ហើយបួស កាលនេះនោះនឹងសម្រេច ក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវពួកអាមាត្យ ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរពីមុខ ហើយបួស កាលនេះនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវពួកស្រីស្នំ ៧០០ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ហើយបួស កាលនេះនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវពួកស្រីស្នំ ៧០០ ជាអ្នកសង្រួមល្អ មានចង្កេះរៀវ ហើយបួស កាលនេះនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអញ នឹងលះបង់នូវស្រីស្នំ ៧០០ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ហើយបួស កាលនេះនោះនឹងសម្រេច ក្នុងកាលណាហ្ន៎ ។

កទាហំ សតបល(១)កំសំ សោវណ្ណំ សតរាជិកំ
បហាយ បព្វជិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ ហត្ថិគុម្ពា សព្វាលង្ការភូសិតា
សុវណ្ណកច្ឆា មាតង្គា ហេមកប្បនវាសសា ។
អារូឡ្ហា គាមណីយេហិ តោមរង្កុសបាណិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ អស្សគុម្ពា សព្វាលង្ការភូសិតា
អាជានីយាវ ជាតិយា សិន្ធវា សីឃវាហនា
អារូឡ្ហា គាមណីយេហិ ឥល្លិយា ចាបធារិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ រថសេនិយោ សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារូឡ្ហា គាមណីយេហិ ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។

១ ម. សតផលំ កំសំ ។ ឱ. សតបលំ កំសំ ។





កាលណាអញនឹងលះបង់ភាជនៈមាស មានទម្ងន់ ១០០ បលៈ ប្រកបដោយស្នាមចំឡាក់ ១០០ ហើយបួស កាលបើនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាហ្វូងដំរីមានគជ្ជៈរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់គ្រាន់ មានខ្សែរង្គំមាស មានគ្រឿងស្អាង ដោយបណ្ដាញមាស ដែលពួកមេទាហានកាន់កង ស្នែងក្រចៅ នឹងកន្ត្រៃក្តឹង ឡើងជិះហើយ នឹងមិនដើរតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណា ហ្វូងសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់គ្រាន់ ជាសេះអាជានេយ្យដោយជាតិ ជាសេះសិន្ធព ជាពាហនៈដ៏លឿន ដែលពួកគ្រូអាចារ្យសេះ កាន់ព្រួញនិងធ្នូ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះ នឹងសម្រេច ក្នុងកាលណាហ្ន៎ ។ កាលណាពួករថរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងពិទ្ធចាំង ដោយស្បែកខ្លារខិន នឹងខ្លាធំ ស្អិតស្អាង ដោយគ្រឿងអលង្ការគ្រប់គ្រាន់ ដែលពួកនាយសារថី មានធ្នូនៅក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាម អញកាលទៅ ដំណើរនោះ នឹងសម្រេច ក្នុងកាលណាហ្ន៎ ។

កទា សុ មំ សុវណ្ណរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ សជ្ឈុរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ អស្សរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ ឱដ្ឋរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។



កាលណាពួករថមាសរបស់អាត្មាអញ ប្រដាប់ហើយ មានទង់លើកហើយ ព័ទ្ធជុំវិញ ដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់ចំពូក ដែលពួកនាយសារថីមានធ្នូនៅក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអាត្មាអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករថប្រាក់របស់អាត្មាអញ មានទង់លើកហើយ ព័ទ្ធជុំវិញដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់ចំពូក ដែលពួកនាយសារថីមានធ្នូនៅក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអាត្មាអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថសេះរបស់អាត្មាអញ ប្រដាប់ហើយ មានទង់លើកហើយ ព័ទ្ធជុំវិញដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់ចំពូក ដែលពួកនាយសារថីមានធ្នូនៅក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអាត្មាអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថអូដ្ឋរបស់អាត្មាអញ ប្រដាប់ហើយ មានទង់លើកហើយ ព័ទ្ធជុំវិញដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់ចំពូក ដែលពួកនាយសារថីមានធ្នូនៅក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអាត្មាអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទាសុ មំ គោណរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទាសុ ភវិស្សតិ ។
កទាសុ មំ អជរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទាសុ ភវិស្សតិ ។
កទាសុ មំ មេណ្ឌរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទាសុ ភវិស្សតិ ។
កទាសុ មំ មិគរថា សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ តំ កទាសុ ភវិស្សតិ ។



កាលណារថទឹមគោ របស់អញ ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទចុង ដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូនិងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមពពែរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទចុងដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមចៀមរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទចុងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណារថទឹមម្រឹគរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ពាំងបិទចុងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូនិងខែលក្នុងដៃឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេច ក្នុងកាលណាហ្ន៎ ។

កទា សុ មំ ហត្ថិគុម្ពា សព្វាលង្ការភូសិតា
នីលវម្មធរា សូរា តោមរង្កុសបាណិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ អស្សគុម្ពា សព្វាលង្ការភូសិតា
នីលវម្មធរា សូរា ឥល្លិយាចាបធារិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ រថសេនា សព្វាលង្ការភូសិតា
នីលវម្មធរា សូរា ចាបហត្ថា កលាបិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ ធនុគ្គហា សព្វាលង្ការភូសិតា
នីលវម្មធរា សូរា ចាបហត្ថា កលាបិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។
កទា សុ មំ រាជបុត្តា សព្វាលង្ការភូសិតា
ចិត្រវម្មធរា សូរា កញ្ចនាវេឡធារិនោ
យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ ។





កាលណាពួកពលដំរីរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការ ពាក់ឥត្តួន កាន់ទំលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នងក្របីនិងកង្វេរក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកពលសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការពាក់ឥត្តួន កាន់ទំលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ប្រដាប់ដាវនិងធ្នូ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួកពលរថរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការពាក់ឥត្តួន កាន់ទំលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូនិងកំពង់ព្រួញ ក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេច ក្នុងកាលណាហ្ន៎ ។ កាលណាពួកខ្មាន់ធ្នូរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការពាក់ឥត្តួន កាន់ទំលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូនិងកំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាពួករាជបុត្ររបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការពាក់ឥត្តួន កាន់ទំលមីវិចិត្រ ជាអ្នកក្លៀវក្លា ប្រដាប់ខ្សែមាសលើកំពូល នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។

កទា សុ មំ អរិយគណា វត្ថវន្តា អលង្កតា

ហរិចន្ទនលិត្តង្គា កាសិកុត្តមធារិនោ

យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ។

កទា សុ មំ អមច្ចគណា សព្វាលង្ការភូសិតា

បីតមដ្ឋជកា សូរា បុរតោ គច្ឆមាលិនី

យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ។

កទា សុ មំ សត្តសតា ភរិយា សព្វាលង្ការភូសិតា

យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ។

កទា សុ មំ សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា

យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ។

កទា សុ មំ សត្តសតា ភរិយា អស្សវា បិយភាណិនី

យន្តំ មំ នានុយិស្សន្តិ តំ កទា សុ ភវិស្សតិ។

កទាហំ បត្តំ គហេត្វាន មុណ្ឌោ សង្ឃាដិបារុតោ

បិណ្ឌិកាយ ចរិស្សាមិ តំ កទា សុ ភវិស្សតិ។



កាលណាពួកអរិយជន គឺព្រាហ្មណ៍ អ្នកមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវសំពត់ដ៏ឧត្តមដែលបានមកអំពីដែនកាសី នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចដល់កាលណាហ្ន៎ ។ កាលណាពួកអាមាត្យរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ពាក់សំពត់មានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចដល់កាលណាហ្ន៎ ។ កាលណាពួកស្រីស្នំ ៧០០ របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចដល់កាលណាហ្ន៎ ។ កាលណាពួកស្រីស្នំ ៧០០ របស់អញ ជាស្រីស្រស់ល្អ មានចង្កេះរៀវ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចដល់កាលណាហ្ន៎ ។ កាលណាពួកស្រីស្នំ ៧០០ របស់អញ ជាស្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះនឹងសម្រេចដល់កាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងបានទៅជាអ្នកកោរក្បាល ឃ្លុំសង្ឃាដិ កាន់បាត្រ ត្រាច់ទៅបិណ្ឌបាត ដំណើរនោះនឹងសម្រេចដល់កាលណាហ្ន៎ ។

កទាហំ បំសុកូលានំ ឧជ្ឈិតានំ មហាបថេ
សង្ឃាដិំ ធារយិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ សត្តាហំ មេឃេ ឱវុដ្ឋោ អល្លចីវរោ
បិណ្ឌិកាយ ចរិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ សព្វណ្ហំ គន្ត្វា រុក្ខា រុក្ខំ វនា វនំ
អនបេក្ខោ ចរិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ គិរិទុគ្គេសុ បហីនភយភេរវោ
អទុតិយោ គមិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ វីណំរុជ្ជកោវ សត្តតន្តិំ មនោរមំ
ចិត្តំ ឧជុំ ករិស្សាមិ តំ កទា សុ ភវិស្សតិ ។
កទាហំ រថការោវ បរិកន្តំ ឧបាហនំ
កាមសំយោជនេ ឆេច្ឆំ(*) យេ ទិព្វេ យេ ច មានុសេ ។
(៦០) តា ច សត្តសតា ភរិយា សព្វាលង្ការភូសិតា
ពាហា បគ្គយ្ហ បក្កន្ទុំ កស្មា នោ វិជហិស្សសិ ។

* ម. ឆេត្វា ។



កាលណា អាត្មាអញនឹងទ្រទ្រង់នូវសង្ឃាដិ នៃសំពត់បង្សុកូលទាំងឡាយ ដែលគេបោះបង់ចោលក្នុងផ្លូវធំ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញ កាលដែលមេឃបង្អុរភ្លៀងអស់ ៧ ថ្ងៃហើយ នឹងត្រាច់ទៅបិណ្ឌបាតទាំងចីវរទទឹក ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងចេញទៅពីគល់ឈើមួយ ទៅកាន់គល់ឈើមួយ ពីព្រៃមួយទៅកាន់ព្រៃមួយ ហើយនៅថ្ងៃនឹងយប់ទាំងអស់ ត្រាច់ទៅឥតអាល័យ ដំណើរនោះ នឹងសម្រេច ក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងលះបង់នូវភ័យនឹងភេរវ ហើយមិនមានគ្នាជាគំរប់ពីរនាក់ ដើរទៅលើភ្នំទាំងឡាយ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញធ្វើចិត្តឲ្យត្រង់ ដូចជាបុគ្គលវេញពិណ កាចវេញខ្សែទាំង ៧ ឲ្យជាទីរីករាយចិត្តបាន ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎ ។ កាលណាអាត្មាអញនឹងកាត់នូវកាមសំយោជន៍ជាទិព្វ ទាំងជារបស់មនុស្សបាន ដូចជាជាងរថកាត់នូវស្បែកជើងដូច្នោះ ។

(៦០) (អភិសម្ពុទ្ធគាថា) ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង ផ្គងដៃឡើងខ្ពស់ យំថា ព្រះអង្គនឹងលះបោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី ។

តា ច សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា
ពាហា បគ្គយ្ហ បក្កន្ទុំ កស្មា នោ វិជហិស្សសិ ។
តា ច សត្តសតា ភរិយា អស្សវា បិយភាណិនី
ពាហា បគ្គយ្ហ បក្កន្ទុំ កស្មា នោ វិជហិស្សសិ ។
តា ច សត្តសតា ភរិយា សព្វាលង្ការភូសិតា
ហិត្វា សម្បទ្ទវី(១) រាជា បព្វជ្ជាយ បុរក្ខតោ ។
តា ច សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា
ហិត្វា សម្បទ្ទវី រាជា បព្វជ្ជាយ បុរក្ខតោ ។
តា ច សត្តសតា ភរិយា អស្សវា បិយភាណិនី
ហិត្វា សម្បទ្ទវី រាជា បព្វជ្ជាយ បុរក្ខតោ ។
ហិត្វា សតបលំ កំសំ សោវណ្ណំ សតរាជិកំ
អគ្គហី មត្តិកាបត្តំ តំ ទុតិយាភិសេចនំ ។

១ ម. សំបទ្ទុ ។



ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីស្រទន់ល្អ មានចង្កេះរៀវ ផ្គងដើមដៃឡើងយំថា ព្រះអង្គនឹងលះបោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី ។ ពួកស្រីស្នំទាំង ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ផ្គងដើមដៃឡើងយំថា ព្រះអង្គនឹងលះបោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី ។ ព្រះរាជាទ្រង់លះនូវសម្បត្តិ ទាំងលះបង់ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ព្រះអង្គទ្រង់ធ្វើបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវសម្បត្តិ ទាំងលះបង់ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីស្រទន់ល្អ មានចង្កេះរៀវ ទ្រង់ធ្វើបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវសម្បត្តិ ទាំងលះនូវពួកស្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ទ្រង់ធ្វើបព្វជ្ជាបញ្ចូនទៅខាងមុខហើយ ។ ព្រះរាជាទ្រង់លះបង់នូវភាជន៍មាស មានទម្ងន់មួយរយបលៈ ដែលចារឹកដោយស្នាមបន្ទាត់មួយរយ ទ្រង់កាន់យកនូវបាត្រដី ការកាន់នូវបាត្រដីនោះ ទុកជាអភិសេកទី ២ ។

(៦២)កេស្វា អគ្គិសមជាលា កោសា ឌយ្ហន្តិ ភាគសោ
រជតំ ជាតរូបញ្ច មុត្តា វេឡុរិយា ពហូ
មណយោ សង្ខមុត្តា ច វត្ថិកំ ហរិចន្ទនំ
អជិនំ ទន្តភណ្ឌញ្ច លោហំ កាឡាយសំ ពហុំ
ឯហិ រាជ និវត្តស្សុ មា តេ តំ វិនសា ធនំ ។
(៦៣)សុសុខំ វត ជីវាម យេសំ នោ នត្ថិ កិញ្ចនំ
មិថិលាយ ឌយ្ហមានាយ ន មេ កិញ្ចិ អឌយ្ហថ ។
(៦៤)អដវិយោ សមុប្បន្នា រដ្ឋំ វិទ្ធំសយន្តិ តេ
ឯហិ រាជ និវត្តស្សុ មា រដ្ឋំ វិនសា ឥទំ ។
(៦៥) សុសុខំ វត ជីវាម យេសំ នោ នត្ថិ កិញ្ចនំ
រដ្ឋេ វិលុម្បមានម្ហិ ន មេ កិញ្ចិ អហីរថ
សុសុខំ វត ជីវាម យេសំ នោ នត្ថិ កិញ្ចនំ
បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។



(៦២) (ព្រះនាងសីវលីទេវី) ឃ្លាំងទាំងឡាយ គឺឃ្លាំងប្រាក់ ឃ្លាំងមាស ឃ្លាំងកែវមុក្តា ឃ្លាំងកែវពិទូរ្យ ឃ្លាំងកែវមណី ឃ្លាំងស័ង្ខ ឃ្លាំងកែវមុក្តាដ៏ច្រើន ឃ្លាំងសំពត់ ឃ្លាំងខ្លឹមចន្ទន៍ក្រហម ឃ្លាំងស្បែកខ្លាឃ្មុំ ឃ្លាំងរបស់ធ្វើពីភ្លុក ឃ្លាំងទង់ដែង និងឃ្លាំងដែកខ្មៅដ៏ច្រើនជាឃ្លាំងដែលកំពុងឆេះរៀបចំដោយចំណែក ត្រូវភ្លើងនេះ មានអណ្តាតភ្លើងស្មើគ្នា ឆេះរាល បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យទ្រព្យរបស់ព្រះអង្គនោះវិនាស ។

(៦៣) (ព្រះរាជា) កង្វល់មិនមាន ដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើក្រុងមិថិលាត្រូវភ្លើងឆេះ ភ្លើងមិនបានឆេះនូវទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ ។

(៦៤) (ព្រះនាងសីវលីទេវី) ចោរក្នុងដងព្រៃកើតឡើងហើយ បំផ្លាញដែនរបស់ព្រះអង្គ បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យដែននេះវិនាស ។

(៦៥) (ព្រះរាជា) កង្វល់មិនមាន ដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើដែនត្រូវពួកចោរប្លន់ ចោរមិនបានយកទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ យើងនឹងមានបីតិជាអាហារ ដូចពួកអាភស្សរទេវតា ។

(៦៦) កិន្នុ ឧច្ចាវចោ ឃោសោ កា នុ គាមេវ កីឡិយា

សមណ តេវ បុច្ឆាម កត្ថេសោ អភិសដោ ជនោ

(៦៧) មមំ ឱហាយ គច្ឆន្តំ ឯត្ថេសោ អភិសដោ ជនោ

សីមាតិក្កមនំ យន្តំ មុនិមោនស្ស បត្តិយា

មិស្សំ នន្ទីហិ គច្ឆន្តំ កិំ ជានមនុបុច្ឆសិ ។

(៦៨) មាស្សុ តិណ្ណោ អមញ្ញិត្ថោ សរីរំ ធារយំ ឥមំ

អតីរណេយ្យមិទំ កម្មំ ពហូ ហិ បរិបន្ថយោ ។

(៦៩) កោ នុ មេ បរិបន្ថស្ស មមំ ឯវំវិហារិនោ

យោ នេវ ទិដ្ឋេ នាទិដ្ឋេ កាមានមភិបត្ថយេ ។

(៧០) និទ្ទា តន្ទី វិជម្ភិតា អរតី ភត្តសម្មទោ

អាវសន្តិ សរីរដ្ឋា ពហូ ហិ បរិបន្ថយោ ។





(៦៦) (តាបសពោល) សំឡេងធំតូចនៃជនច្រើននេះ តើព្រោះហេតុអ្វី ស្រែកនោះជាអ្វី លេងជាមួយគ្នាក្នុងព្រៃ ដូចក្នុងស្រុក បពិត្រសមណៈ ខ្ញុំសួរលោកថា មហាជននុះ ប្រជុំគ្នាដើម្បីអ្វី ។

(៦៧) (ព្រះរាជា) ខ្ញុំកាលលះបង់នូវមហាជន ហើយចេញទៅ បានជាមហាជនប្រជុំគ្នាក្នុងទីនេះ ខ្ញុំកន្លងនូវដែនកិលេស ហើយទៅបួសដើម្បីបាននូវមោនធម៌ (គោលនៃញាណរបស់អនាគារិយៈ) មុនី ខ្ញុំកាលទៅកាន់ទីច្របូកច្របល់ដោយសេចក្ដីរីករាយទាំងឡាយ អ្នកដឹង ទើបសួរឬ (ឬមិនដឹង) ។

(៦៨) (តាបសពោល) ព្រះអង្គកាលទ្រទ្រង់នូវសរីរៈនេះ កុំសំគាល់ថាអញឆ្លងផុតកិលេសហើយឡើយ ព្រោះ កម្ម (គឺកិលេស) នេះបុគ្គលមិនអាចឆ្លងផុតបានទេ ព្រោះថាសេចក្ដីអន្តរាយ មានច្រើន ។

(៦៩) (ព្រះរាជា) ខ្ញុំណាមិនប្រាថ្នានូវកាមទាំងឡាយក្នុងមនុស្សលោកដែលបុគ្គលឃើញហើយ មិនប្រាថ្នានូវកាមទាំងឡាយក្នុងទេវលោក ដែលបុគ្គលមិនឃើញហើយ សេចក្ដីអន្តរាយដូចម្ដេចពិតនឹងមានដល់ខ្ញុំនោះ មានកិរិយានៅយ៉ាងនេះ ។

(៧០) (តាបសពោល) ម្យ៉ាងថា សេចក្ដីអន្តរាយ ទាំងឡាយដ៏ច្រើន គឺការងោកលក់ សេចក្ដីខ្ជិល ការបិតកាយ សេចក្ដីអផ្សុក ការពុលបាយ ទាំងនោះនៅក្នុងសរីរៈ រមែងកើត (ក្នុងសរីរៈវិញ) ។

(៧១) កល្យាណំ វត មំ ភវំ ព្រាហ្មណ អនុសាសសិ
ព្រាហ្មណ ត្វេវ បុច្ឆាមិ គោ នុ ត្វមសិ មារិស ។

(៧២) នារទោ ឥតិ នាមេន កស្សបោ ឥតិ មំ វិទូ
ភោតោ សកាសេ អាគច្ឆិំ សាធុ សព្ភិ សមាគមោ ។
តស្ស តេ សព្វោ អានន្ទោ វិហារោ ឧបវត្តតុ
យទូនំ(១) តំ បរិបូរេហិ ខន្តិយា ឧបសមេន ច ។
បសារយ សន្នតញ្ច ឧន្នតញ្ច បហារយ
កម្មំ វិជ្ជញ្ច ធម្មញ្ច សក្កត្វាន បរិព្វជ ។

(៧៣) ពហូ ហត្ថី ច អស្សេ ច នគរេ ជនបទានិ ច
ហិត្វា ជនក បព្វជិតោ កបាលេ រតិមជ្ឈគា
កច្ចិ នុ តេ ជានបទា មិត្តាមច្ចា ច ញាតកា
ទុព្ភិ អកំសុ ជនក កស្មា តេ តំ អរុច្ចថ ។

១ ឱ. យំ ឩនំ



(៧១) (ព្រះរាជា) បពិត្រព្រាហ្មណ៍ លោកដ៏ចំរើនប្រៀនប្រដៅខ្ញុំល្អណាស់ បពិត្រព្រាហ្មណ៍ ខ្ញុំសួរលោក បពិត្រលោកនិទុក្ខ លោកជាអ្វី ។

(៧២) (នារទតាបស) ជនទាំងឡាយស្គាល់អាត្មាភាពដោយនាមថា នារទៈ ដោយគោត្រថា កស្សបៈផង អាត្មាភាពមកកាន់សំណាក់ព្រះអង្គដ៏ចំរើន ដោយនឹកឃើញថា សមាគមដោយសប្បុរសទាំងឡាយ ជាកិច្ចញុំាងប្រយោជន៍ឲ្យសម្រេច ។ សេចក្តីត្រេកអរ (ក្នុងបព្វជ្ជា) ទាំងអស់ នឹងព្រហ្មវិហារ ចូរកើតដល់ព្រះអង្គនោះចុះ បរិកម្មនឹងឈានណា ការខ្វះខាត (ដោយសីលនឹងឈាន)ណា ព្រះអង្គចូរបំពេញនូវការខ្វះខាតនោះចុះ ព្រះអង្គ (ចូរប្រកប) ដោយអធិវាសនក្ខន្តី នឹងឧបសមៈ ។ ព្រះអង្គចូរសាយភាយនូវសេចក្តីមើលងាយនឹងសេចក្តីក្រអឺតក្រទម ចូរធ្វើការគោរពនូវកុសលកម្ម នូវវិជ្ជា នឹងធម៌ ។

(៧៣) (មិគាជិនតាបស) បពិត្រព្រះជនក ព្រះអង្គលះបង់ដំរីសេះ ពួកអ្នកនគរ នឹងជនបទជាច្រើន ហើយទ្រង់ព្រះផ្នួស ដល់នូវសេចក្តីត្រេកអរនឹងអំបែង បពិត្រព្រះជនក ពួកអ្នកជនបទ មិត្រអាមាត្យ នឹងញាតិ បានធ្វើនូវការប្រទូស្តចំពោះព្រះអង្គខ្លះដែរឬ ព្រោះហេតុអ្វី ក៏ព្រះអង្គពេញព្រះហឫទ័យនឹងអំបែងរបស់ព្រះអង្គនោះ ។

(៧៤) ន មិគាជិន ជាតុច្ឆេ អហំ កញ្ចិ កុទាចនំ
អធម្មេន ជិនេ ញាតិំ ន ចាបិ ញាតយោ មមំ ។

(៧៥) ទិស្វាន លោកវត្តន្តំ ខជ្ជន្តំ កទ្ទមីកតំ
ហញ្ញរេ វជ្ឈរេ ចេត្ថ យត្ថ សត្តោ បុថុជ្ជនោ
ឯតាហំ ឧបមំ កត្វា ភិក្ខុកោស្មិ មិគាជិន ។

(៧៦) កោ នុ តេ ភគវា សត្ថា កស្សេតំ វចនំ សុចិ
ន ហិ កប្បំ វា វិជ្ជំ វា បច្ចក្ខាយ រថេសភ
សមណមាហុ វត្តន្តំ យថា ទុក្ខស្សតិក្កមោ ។

(៧៧) ន មិគាជិន ជាតុច្ឆេ អហំ កញ្ចិ កុទាចនំ
សមណំ ព្រាហ្មណំ វាបិ សក្កត្វា អនុបាវិសិំ ។
មហតា ចានុភាវេន គច្ឆន្តោ សិរិយា ជលំ
គីយមានេសុ គីតេសុ វជ្ជមានេសុ វគ្គុសុ



(៧៤) (ព្រះមហាជនក) បពិត្រមិគាជិនៈ ក្នុងកាលណាមក ខ្ញុំមិនដែលឈ្នះញាតិណាមួយ ដោយអធម៌ជាដាច់ខាត ចំណែកញាតិ ក៏មិនដែលឈ្នះខ្ញុំ ដោយអធម៌ដែរ ។

(៧៥) បពិត្រមិគាជិនៈ ខ្ញុំបានឃើញនូវប្រវេណីនៃសត្វលោក ដែលកិលេសកំពុងទំពាស៊ី ធ្វើឲ្យដូចជាភក់ បុថុជ្ជន លិចចុះហើយ ក្នុងកិលេសវត្ថុណា សត្វទាំងឡាយ តែងបៀតបៀនគ្នាផង តែងជាប់ក្នុងកិលេសវត្ថុនោះផង ហើយក៏ធ្វើនូវក្តុកបុថុជ្ជនទាំងនេះឲ្យជាគ្រឿងប្រៀបធៀប ទើបបួសជាភិក្ខុ ។

(៧៦) (មិគាជិនតាបស) បពិត្រព្រះអង្គប្រសើរក្នុងរថ បុគ្គលមានភាគណា ជាសាស្តារបស់ព្រះអង្គ ពាក្យដ៏ពិរោះនេះ ជាពាក្យរបស់បុគ្គលណា ព្រោះថាអ្នកប្រាជ្ញទាំងឡាយ មិនវៀរនូវការបរិកម្មកសិណសម្រេចអភិញ្ញា ឬនូវព្រះវេទក្តុងដែលប្រកបដោយវិជ្ជា ហើយពោលនូវសមណៈថា អ្នកមានវត្ត ជាគ្រឿងកន្លងនូវទុក្ខទេ ។

(៧៧) (ព្រះមហាជនក) បពិត្រមិគាជិនៈ ខ្ញុំមិនដែលចូលទៅគោរពសមណៈនិងព្រាហ្មណ៍ណាមួយ ដោយដាច់ខាត ក្នុងកាលណាមួយឡើយ ។ បពិត្រមិគាជិនៈ ខ្ញុំកាលទៅ ដោយអានុភាពដ៏ធំ រុងរឿង ដោយសិរី កាលចម្រៀងដែលបុគ្គលកំពុងច្រៀង កាលតន្ត្រីមានសំឡេងដ៏ពិរោះ ដែលបុគ្គលកំពុងប្រគំ

តុរិយតាលិតសង្ឃុដ្ឋេ    សម្មតាលសមាហិតេ
សមិគាជិនមជ្ឈគំ    ផលឹ អម្ពំ(១) តិរោច្ឆទំ
ភុញ្ជមានំ(២) មនុស្សេហិ    ផលកាមេហិ ជន្តុភិ
សោ ខោ ហំ តំ សិរឹ ហិត្វា    ឱរោហិត្វា មិគាជិន
មូលំ អម្ពស្សុបាគច្ឆឹ    ផលិនោ និប្ផលស្ស ច
ផលឹ អម្ពំ ហតំ ទិស្វា    វិទ្ធស្តំ វិនឡីកតំ
អថេតំ ឥតរំ អម្ពំ    នីលោភាសំ មនោរមំ
ឯវមេវ នូនមម្ហេបិ    ឥស្សរេ ពហុកណ្ដកេ
អមិត្តា នោ វធិស្សន្តិ    យថា អម្ពោ ផលី ហតោ
អជិនម្ហិ ហញ្ញតេ ទីបិ    នាគោ ទន្តេហិ ហញ្ញតេ
ធនម្ហិ ធនិនោ ហន្តិ    អនិកេតមសន្ថវំ
ផលី(៣) អម្ពោ អផលោ ច    តេ សត្ថារោ ឧភោ មម ។

(៧៨) សព្វោ ជនោ បព្យាធិតោ    រាជា បព្វជិតោ ឥតិ
ហត្ថារោហា អនីកដ្ឋា    រថិកា បត្តិការកា
អស្សាសយិត្វា ជនតំ    ឋបយិត្វា បដិច្ឆទំ
បុត្តំ រជ្ជេ ឋបេត្វាន    អថ បច្ឆា បព្វជិស្សសិ ។

១ ម. ផលិំ ។ ម. ភក្ខំ អម្ពំ ។ ២ ម. [illegible] ។ ៣ ម. ផលី ។



បានឃើញស្វាយមានផ្លែ ខាងក្រៅកំពែង ដែលពួកមនុស្សអ្នកត្រូវការផ្លែ បេះផ្លែក្នុងឧទ្យានដែលអឺកធឹងដោយការប្រគំតន្ត្រី ជាទីគួរឲ្យត្រេកអរ ដោយសូរប្រគំដ៏ពីរោះ បពិត្រមិត្តជនៈ ខ្ញុំនោះបានលះបង់សិរីនោះ ហើយចុះ (អំពីដំរី) ចូលទៅកាន់គល់ស្វាយដែលមានផ្លែនិងមិនមានផ្លែ បានឃើញស្វាយមានផ្លែដែលបុគ្គលបៀតបៀនហើយ កំ-ចាត់ហើយ ទាំងមិនឲ្យមានស្លឹក និងស្វាយដើមក្រៅនេះ មានពណ៌ខៀវ ជាទីរីករាយនៃចិត្ត សត្រូវទាំងឡាយគង់សម្លាប់យើងដែលជាឥស្សរៈមានបច្ចាមិត្តច្រើនដោយពិត ដូចដើមស្វាយដែលមានផ្លែដែលបុគ្គលសម្លាប់ហើយ ខ្លាដំបង ត្រូវគេសម្លាប់ព្រោះស្បែក ដំរីត្រូវគេសម្លាប់ព្រោះភ្លុក បុគ្គលអ្នកមានទ្រព្យត្រូវគេសម្លាប់ព្រោះទ្រព្យ តើនរណា នឹងសម្លាប់បុគ្គលអ្នកមិនមានផ្ទះ មិនមានសន្ថវៈ ដើមស្វាយមានផ្លែនិងមិនមានផ្លែទាំងពីរនោះជាសាស្តារបស់ខ្ញុំ ។

(៧៨) (នាងសីវលី) ជនទាំងពួង គឺសេនាដំរី ពលសេះ ពលរថ ពលថ្មើរជើង បានឮថា ព្រះរាជាទ្រង់ផ្នួសហើយក៏តក់ស្លុត សូមព្រះអង្គលួងលោមនូវប្រជុំជន ហើយតាំងទុកនូវការរក្សា តាំងព្រះរាជបុត្រទុកក្នុងរាជសម្បត្តិ ហើយសឹមទ្រង់ព្រះផ្នួសក្នុងកាលជាខាងក្រោយចុះ ។

(៧៩) ចត្តា មយា ជានបទា    មិត្តាមច្ចា ច ញាតកា
សន្តិ បុត្តា វិទេហានំ    ទីឃាវុ រដ្ឋវឌ្ឍនោ
តេ រជ្ជំ ការយិស្សន្តិ    មិថិលាយំ បជាបតិ ។
(៨០) ឯហិ តំ អនុសិក្ខាមិ    យំ វាក្យំ មម រុច្ចតិ
រជ្ជំ តុវំ ការយន្តំ    បាបំ ទុច្ចរិតំ ពហុំ
កាយេន វាចា មនសា    យេន គច្ឆសិ ទុគ្គតឹ
បរទិន្នកេន បរនិដ្ឋិតេន បិណ្ឌេន យាបេហិ ស ធីរធម្មោ
(៨១) យោបិ ចតុត្ថេ    ភត្តកាលេ ន ភុញ្ជេ
អជុដ្ឋមារីវ    ខុទាយ មិយ្យេ
ន ត្វេវ បិណ្ឌំ លុឡិតំ អនរិយំ
កុលបុត្តរូបោ សប្បុរិសោ ន សេវេ
តយិទំ ន សាធុ តយិទំ ន សុដ្ឋុ
សុនខុច្ឆិដ្ឋកំ ជនក ភុញ្ជសេ តុវំ ។



(៧៩) (ព្រះមហាជនក) ខ្ញុំលះបង់ជនបទ មិត្រអាមាត្យនិងញាតិ ទាំងឡាយដែលយើងលះបង់ហើយ កូនរបស់អ្នកដែនវិទេហៈឈ្មោះ ទីឃាវុកុមារអ្នកញុំាងដែនឲ្យចំរើន ម្នាលបជាបតី កូនទាំងនោះនឹង សោយរាជ្យក្នុងក្រុងមិថិលាចុះ ។

(៨០) នាងទូលថា: ពាក្យណាដែលគាប់ចិត្តខ្ញុំ ខ្ញុំនឹង ប្រាប់នូវពាក្យនោះ ព្រះអង្គនឹងទៅកាន់ទុគ្គតិ ដោយកាយវាចាចិត្ត ណា ព្រះអង្គកាលសោយរាជ្យ (ឈ្មោះថាធ្វើ) នូវបាបទុច្ចរិត ដ៏ច្រើន ដោយកាយវាចាចិត្តនោះ ព្រះអង្គញុំាងអត្តភាពឲ្យប្រព្រឹត្ត ទៅដោយដុំបាយ ដែលបុគ្គលដទៃឲ្យហើយ ដែលបុគ្គលដទៃ សម្រេចហើយ (នេះ) ជាធម៌របស់អ្នកប្រាជ្ញ ។

(៨១) (នាងសីវលី) បុគ្គលណាមិនបរិភោគភោជនក្នុង កាលនៃភត្តជាគំរប់ ៤ បុគ្គលនោះគប្បីស្លាប់ដោយសេចក្ដី ស្រេកឃ្លាន ដូចបុគ្គលដល់នូវសេចក្ដីស្លាប់ដ៏ពិត មានសភាពជា កុលបុត្រមិនគប្បីបរិភោគដុំបាយ ដែលប្រឡាក់ដោយធូលី មិន ស្អាតទេ ឬការបរិភោគនោះ មិនល្អទេ មិនប្រសើរទេ បពិត្រ មហាជនក ព្រះអង្គសោយនូវដុំបាយដែលសល់អំពីឆ្កែ ។

[៤២] ន តាវិ មេ សិរីសិ សោ អកម្មា

យំ ហោតិ ចត្តំ គិហិនោ សុខស្ស កិ

យេ កេចិ ភោគា ឥធ ធម្មលទ្ធា

សព្វេ សោ កក្ខោ អនរិយាតិ វុត្តោ ។

[៤៣] កុមារិកេ ឧបសេនិយេ និច្ចំ និគ្គលមណ្ឌិតេ

កស្មា តេ ឯកោ ភុជោ ជនតិ ឯកោ តេ ន ជនតី ភុជោ ។

[៤៤] ឥមស្មឹ មេ សមណ ហត្ថេ បដិមុក្កា ទុនីវរា

សង្ឃដ្ដា ជាយតេ សទ្ទោ ទុតិយស្សេវ សា គតិ

ឥមស្មឹ មេ សមណ ហត្ថេ បដិមុក្កា ឯកនីវរា

សោ អទុតិយោ ន ជនតិ មុនិភូតោវ តិដ្ឋតិ

វិវាទប្បត្តោ ទុតិយោ កោ តេនំ វិវទិស្សតិ

តស្ស តេ សគ្គកាមស្ស ឯកត្តមុបរោចតំ ។



[៤២] (ព្រះរាជា) ម្នាលសិរីស៍ កិច្ចណាដែលគ្រហស្ថ ប្តូរសុខទ្រលះបង់ហើយ កិច្ចនោះ មិនមែនជាកម្មមិនល្អ ទាំងទេ ភោគៈទាំងឡាយណានីមួយក្នុងលោកនេះ ដែលបានដោយធម៌ ភោគៈទាំងអស់នោះ លោកពោលថាជា កម្មមិនមានទោស ។

[៤៣] (ព្រះរាជា) ម្នាលនាងកុមារិកា ជាកូនអ្នកជិតខាង នៅឡើយមានគ្រឿងប្រដាប់មិនឃ្លាតអំពីខ្លួនជានិច្ច ដៃម្ខាងរបស់នាងលាន់ឮសំឡេង ដៃម្ខាងមិនលាន់ឮសំឡេង តើព្រោះហេតុអ្វី ។

[៤៤] (នាងកុមារិកា) បពិត្រសមណៈ កងពីរដែលពាក់នឹងដៃរបស់ខ្ញុំនេះប៉ះគ្នាហើយ សំឡេងក៏កើតឡើង នោះជាគតិនៃកងពីរគឺ បពិត្រសមណៈ កងមួយដែលពាក់នឹងដៃរបស់ខ្ញុំនេះ កងនោះមិនមានកងដទៃទៀតជាគំរប់ពីរ ទើបមិនលាន់ឮសំឡេង ដូចជាអ្នកបួស ជាអ្នកស្ងប់ស្ងៀម ឯបុគ្គលមានគ្នាជាគំរប់ពីរតែង រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់នឹងជជែកជាមួយនឹងបុគ្គលណាកើត ព្រោះអ្នកនោះជាអ្នកប្រាថ្នានូវឋានសួគ៌ សូមប្រែចិត្តពេញចិត្តនឹងភាពនៃបុគ្គលម្នាក់ឯងចុះ ។

(៨៥)សុណាសិ សីវលី កថា កុមារិយា បវេទិតា

បេសិយា មំ គរហិត្ថោ ទុតិយស្សេវ សា គតិ

អយំ ទ្វេធាបថោ ភទ្ទេ អនុចិណ្ណោ បថាវិហិ

តេសំ ត្វំ ឯកំ គណ្ហាហិ អហមេកំ បុនាបរំ

មា ច មំ ត្វំ បតិ មេតិ នាហំ ភរិយាតិ តំ បុន ។

ឥមមេវ កថយន្តា ថូណំ នគរុបាគមុំ ។

កោដ្ឋកេ ឧសុការស្ស ភត្តកាលេ ឧបដ្ឋិតេ

តត្រ ច សោ ឧសុការោ ឯកំ ទណ្ឌំ ឧជុំ កតំ

ឯកញ្ច ចក្ខុំ និគ្គយ្ហ ជិម្ហមេកេន បេក្ខតិ ។

(៨៦)ឯវំ នោ សាធុ បស្សសិ ឧសុការ សុណោហិ មេ

យទេកំ ចក្ខុំ និគ្គយ្ហ ជិម្ហមេកេន បេក្ខសិ ។

(៨៧)ទ្វីហិ សមណ ចក្ខូហិ វិសាលំ វិយ ខាយតិ

អប្បត្វា[*] បរមំ លិង្គំ នុជុភាវាយ កប្បតិ ។

* ម. ម. អសម្បត្វា ។



(៨៥) (ព្រះរាជា) ម្នាលនាងសីវលី នាងឮពាក្យដែល នាងកុមារីការពោលហើយឬទេ នាងកុមារីនោះតិះដៀលខ្ញុំថាខ្ញុំដូចជាអ្នកបំរើ ឯនាងឯងជាគតិនៃបុគ្គលទីពីរនោះ ម្នាលនាងដ៏ចំរើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវតែងដើរទៅ បណ្ដាផ្លូវទាំងពីរនោះ នាងចូរកាន់ផ្លូវ ១ ខ្ញុំនឹងកាន់ផ្លូវ ១ ដទៃទៀត នាងកុំហៅខ្ញុំថាជាស្វាមីរបស់អញ ខ្ញុំក៏មិនហៅនាងថាជាប្រពន្ធទៀតដែរ ។

(អភិសម្ពុទ្ធគាថា) ព្រះរាជា និងនាងសីវលី កាលពោលនូវពាក្យនេះហើយ ក៏ចូលទៅកាន់ថូណនគរ ។ កាលដែលវេលាភត្តព្រះរាជា (ក៏យាង) ដល់ក្ដារនៃជាងព្រួញ ជាងព្រួញនោះបិទភ្នែកម្ខាង សំឡឹងមើលដងព្រួញរៀចមួយ ដែលធ្វើឲ្យត្រង់ដោយភ្នែកម្ខាង ដ៏នៅក្នុងក្ដារនោះ ។

(៨៦) (ព្រះរាជា) ម្នាលជាងព្រួញ អ្នកចូរស្ដាប់ពាក្យខ្ញុំ អ្នកបិទភ្នែកម្ខាងសំឡឹងមើលដងព្រួញរៀច អ្នកមើលឃើញនេះស្រួលឬ ។

(៨៧) (ជាងព្រួញ) បពិត្រសមណៈ ទីក្រោកដ ដូចជាទូលាយ ដោយភ្នែកពីរ កិច្ចដោយការៈ នៃព្រួញត្រង់ រមែងមិនសម្រេច ព្រោះមិនឃើញ នូវទីរៀចខាងចុង ។

ឯកញ្ច ចក្ខុំ និគ្គយ្ហ ជិម្ហមេកេន បេក្ខតោ
សម្បត្វា បរមំ លិង្គំ ឧជុភាវាយ កប្បតិ ។
វិវាទប្បត្តោ ទុតិយោ កោនេកោ វិវទិស្សតិ ។
តស្ស តេ សគ្គកាមស្ស ឯកត្តមុបរោចិតំ ។
(៨៨) សុណាសិ សីវលី កថា ឧសុការេន វេទិតា
បេសិយា មំ គរហិត្ថោ ទុតិយស្សេវ សា គតិ
អយំ ទ្វេធាបថោ ភទ្ទេ អនុចិណ្ណោ បថាវិហិ
តេសំ ត្វំ ឯកំ គណ្ហាហិ អហមេកំ បុនាបរំ
នេវ មំ ត្វំ បតី មេតិ មាហំ ភរិយាតិ វា បុន
មុញ្ជាវេសិកា[១] បវាឡ្ហា ឯកា វិហរ សីវលីតិ ។

មហាជនកជាតកំ ទុតិយំ ។

១. ឧ. មុញ្ជាវេសិកា បវាឡ្ហា ។ ម. មុញ្ជាវេសិកា ពព្វាឡ្ហា ។



កាលបុគ្គលបង្ខិចភ្នែកម្ខាង សំឡឹងមើលទៅវៀច ដោយភ្នែកម្ខាង កិច្ចដ៏ឧត្តម នៃព្រួញក្រង់ រមែងសម្រេច ព្រោះឃើញទីវៀច នានាមុខ ។ បុគ្គលជាគំរប់ពីរ រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់ឯង នឹងជជែកគ្នាជាមួយនឹងអ្នកណាកើត កាលព្រះអង្គនោះប្រាថ្នានូវឋានសួគ៌ សូមពេញព្រះទ័យនឹងភាពនៃបុគ្គលម្នាក់ឯងចុះ ។

(៨៨) (ព្រះកថា...) នែនាងសីវលី នាងឮពាក្យដែលជាងព្រួញពោលហើយឬទេ ជាងព្រួញតិះដៀលអាត្មាដូចជាអ្នកបំរើ នោះជាគតិនៃបុគ្គលគំរប់ពីរ ម្នាលនាងដ៏ចំរើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវ តែងដើរទៅ បណ្ដាផ្លូវទាំងពីរនោះ នាងចូរកាន់យកផ្លូវ ១ អាត្មានឹងកាន់យកផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មានឹងមិនហៅនាងថាជាភរិយារបស់អាត្មាវិញ ម្នាលនាងសីវលី នាងចូរនៅម្នាក់ឯងចុះ ដូចស្មៅបាបុសដែលគេដកហើយ ។

ចប់ មហាជនកជាតក ទី ២ ។

## សុវណ្ណសាមជាតកំ

[៨៩] កោ នុ មំ ឧសុនា វិជ្ឈិ    បមត្តំ ឧទហារកំ
ខត្តិយោ ព្រាហ្មណោ វេស្សោ    កោ មំ វិទ្ធា និលីយសិ ។
ន មេ មំសានិ ខជ្ជានិ    ចម្មេនត្ថោ ន វិជ្ជតិ
អថ កេន នុ វណ្ណេន    វិទ្ធេយ្យំ មំ អមញ្ញថ ។
កោ វា ត្វំ កស្ស វា បុត្តោ    កថំ ជានេមុ តំ មយំ
បុដ្ឋោ មេ សម្ម អក្ខាហិ    កឹ មំ វិទ្ធា និលីយសិ ។

[៩០] រាជាហមស្មិ កាសីនំ    បិលយក្ខោតិ មំ វិទូ
លោភា រដ្ឋំ បហិត្វាន    មិគមេសំ(១) ចរាមហំ
ឥស្សត្ថេ ចស្មិ កុសលោ    ទឡ្ហធម្មោតិ វិស្សុតោ
នាគោបិ មេ ន មុច្ចេយ្យ    អាគតោ ឧសុបាតនំ ។
កោ វា ត្វំ កស្ស វា បុត្តោ    អត្តានំ មេ បវេទយ
បិតុនោ អត្តនោ ចាបិ    នាមគោត្តំ បវេទយ ។

---
១ ម. មិគមេសោ ។

## សុវណ្ណសាមជាតក

(៨៩) (សុវណ្ណសាមបណ្ឌិតសួរថា) នរណាហ្ន៎ បាញ់ខ្ញុំជាអ្នកដងទឹក ធ្វេសប្រហែស(១) ដោយព្រួញ ជនណាជាក្សត្រ ឬជាព្រាហ្មណ៍ ឬជាវេស្សៈ បាញ់ខ្ញុំហើយពួន ។ សាច់ទាំងឡាយរបស់ខ្ញុំ មិនមែនជារបស់គួរទំពាស៊ីទេ សេចក្តីត្រូវការដោយស្បែកមិនមានទេ កាលបើដូច្នេះ តើអ្នកសំគាល់នូវខ្ញុំ ជាគួរបាញ់ដោយហេតុដូចម្តេច ។ អ្នកជាអ្វី ជាបុត្ររបស់អ្នកណា យើងស្គាល់អ្នក ដូចម្តេចបាន សំឡាញ់ អ្នកខ្ញុំសួរហើយ ចូរប្រាប់ ម្តេចក៏បាញ់ខ្ញុំហើយពួន ។

(៩០) (ព្រះបាទបិលយក្ខត្រាស់ថា) ខ្ញុំជាព្រះរាជារបស់ពួកអ្នកកាសី គេស្គាល់ខ្ញុំថា ឈ្មោះបិលយក្ខ ខ្ញុំលះបង់នូវដែនមកត្រាច់ស្វែងរកម្រឹគ ព្រោះលោភ (ចង់ស៊ីសាច់) ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បសាស្ត្រ ជាអ្នកមានឈ្មោះល្បីល្បាញ ថាជាអ្នកប្រកបដោយធ្នូដ៏មាំមួន(២) សូម្បីដំរីដែលមកត្រង់មុខព្រួញរបស់ខ្ញុំហើយ មិនរួចទេ ។ ចុះអ្នកជាអ្វី ជាបុត្ររបស់អ្នកណា ដូចម្តេចទើបយើងស្គាល់អ្នកបាន សូមអ្នកប្រាប់នូវនាមនិងគោត្ត របស់បិតាផង របស់ខ្លួនផង ។

---
១ [illegible] ។ ២ [illegible] ។

(៤១) នេសាទបុត្តោ ភទ្ទន្តេ សាមោ ឥតិ មំ ញាតយោ
អាមន្តយឹសុ ជីវន្តំ ស្វាជ្ជេវង្គតោ សយេ ។
វិទ្ធោស្មិ បុថុសល្លេន សវិសេន យថា មិគោ
សកម្ហិ លោហិតេ រាជ បស្ស សេមិ បរិប្លុតោ ។
បដិវាមគតំ សល្លំ បស្ស ធិម្ហាមិ លោហិតំ
អាតុរោ ត្យានុបុច្ឆាមិ កឹ មំ វិទ្ធា និលីយសិ ។
អជិនម្ហិ ហញ្ញតេ ទីបិ នាគោ ទន្តេហិ ហញ្ញតេ
អថ កេន នុ វណ្ណេន វិទ្ធេយ្យំ មំ អមញ្ញថ ។
(៤២) មិគោ ឧបដ្ឋិតោ អាសិ អាគតោ ឧសុបាតនំ
តំ ទិស្វា ឧព្វិជ្ជី សាម តេន កោធោ មមាវិសិ ។
(៤៣) យតោ សរាមិ អត្តានំ យតោ បត្តោស្មិ វិញ្ញុតំ
ន មំ មិគា ឧត្រសន្តិ អរញ្ញេ សាបទានិបិ ។

១ ឱ. ម. បរិប្លុតោ ។



(៤១) (ព្រះមហាសត្វ...) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំ (ជាកូនរបស់ឥសី) ជាបុត្ររបស់តាបសនេះ ពួកញាតិហៅទូលបង្គំជាខ្ញុំកាលរស់នៅថា សាមៈ ថ្ងៃនេះ ទូលបង្គំជាខ្ញុំនោះដល់ (នាក់មច្ចុរាជ) ហើយដេកនៅយ៉ាងនេះ ។ ខ្ញុំដែលព្រះអង្គបាញ់ហើយ ហាក់ដូចម្រឹគ ដែលព្រានព្រៃបាញ់ហើយ ដោយព្រួញដ៏ប្រកបដោយថ្នាំពិសដូច្នោះ បពិត្រព្រះរាជា សូមទ្រង់ទតចុះ ទូលបង្គំជាខ្ញុំ ដេកត្រាំនៅក្នុងឈាមរបស់ខ្លួន ។ សូមទ្រង់ទតព្រួញដែលមុតធ្លុះទៅខាងឆ្វេង ទូលបង្គំជាខ្ញុំខ្ជាក់ឈាម ទូលបង្គំជាខ្ញុំ ចាប់កើតណាស់ បានជាសួរព្រះអង្គរឿយៗ ម្ដេចក៏ទ្រង់បាញ់ទូលបង្គំជាខ្ញុំហើយពួន ។ ខ្លាដំបងឺគេសម្លាប់ព្រោះតែស្បែក ដំរីគេសម្លាប់ព្រោះភ្លុកទាំងឡាយ កាលបើដូច្នោះ តើព្រះអង្គសំគាល់នូវទូលបង្គំជាខ្ញុំថា គួរបាញ់ដោយហេតុដូចម្ដេច ។

(៤២) (ព្រះបាទបិលយក្ខនិយាយតបថា) ម្រឹគមកប្រាកដចំពោះព្រួញរបស់ខ្ញុំហើយ ឃើញអ្នកហើយក៏ភ្ញាក់ផ្អើលទៅ ម្នាលសាមៈ ព្រោះហេតុនោះ បានជាខ្ញុំមានសេចក្ដីក្រោធគ្របសង្កត់ ។

(៤៣) (ព្រះមហាសត្វ...) តាំងពីកាលដែលខ្ញុំរឭកឃើញនូវខ្លួន តាំងពីកាលដែលខ្ញុំដល់នូវភាពជាអ្នកដឹងក្ដី ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល (ឃើញ) ទូលបង្គំជាខ្ញុំ ហើយតក់ស្លុតទេ ។

យតោ ជដំ បរិហរិំ   យតោ បត្តោស្មិ យោព្វនំ

ន មំ មិគា ឧត្រាសន្តិ   អរញ្ញេ សាបទានិបិ ៗ

ភីរូ កិម្បុរិសា រាជ   បព្វតេ គន្ធមាទនេ

សម្មោទមានា គច្ឆាម   បព្វតានិ វនានិ ច

អជ្ជ កេន នុ វណ្ណេន   ឧត្រាសន្តិ មិគា មមំ ៗ

(៤៦) ន តំ តស(១)មិគោ សាម   កិន្តាហំ អលិកំ ភណេ

កោធលោភាភិភូតាហំ   ឧសុំ តេ តំ អវស្សជឹ ៗ

កុតោ នុ សាម អាគម្ម   កស្ស វា បហិតោ តុវំ

ឧទហារោ នទឹ គច្ឆ   អាគតោ មិគសម្មតំ ៗ

(៤៧) អន្ធា មាតាបិតា មយ្ហំ   តេ ភរាមិ ព្រហាវនេ

តេសាហំ ឧទកាហារោ   អាគតោ មិគសម្មតំ ៗ

(៤៨) អត្ថិ តេសំ ឧសាមត្តំ   អថ សាហស្ស ជីវិតំ

ឧទកស្ស អលាភេន   មញ្ញេ អន្ធា មរិស្សរេ ៗ

១ ម. ឧ ឧត្តសា ។ ឧក្ក ឥ ឧត្តសតិ ឥតិ ឧត្តសាតិ អដ្ឋកថាយំ ទិស្សតិ ។



តាំងពីកាលដែលខ្ញុំស្លៀកសំពត់សំបកឈើ តាំងពីកាលដែលខ្ញុំដល់នូវវ័យជំទង់ ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល (ឃើញ) ខ្លាចខ្ញុំហើយតក់ស្លុតទេ ។ បពិត្រព្រះរាជា ពួកកិន្នរទាំងឡាយ ដែលជាសត្វខ្លាច(ទៅ)នាភ្នំគន្ធមាទន៍(មិនដែលឃើញខ្ញុំហើយតក់ស្លុតទេ) យើងទាំងឡាយតែងរីករាយជាមួយគ្នា ទៅកាន់ភ្នំ និងព្រៃ កាលបើដូច្នោះ ម្រឹគទាំងឡាយ (ឃើញ) ខ្ញុំទូលបង្គំជាខ្ញុំ ហើយតក់ស្លុតដោយហេតុដូចម្តេច ។

(៤៦) (ព្រះបាទបិលយក្ខ) ម្នាលសាមៈ ម្រឹគមិនមែនស្លុតនឹងអ្នកទេ ខ្ញុំនឹងនិយាយកុហកធ្វើអ្វី ខ្ញុំមានសេចក្តីក្រោធនឹងសេចក្តីលោភគ្របសង្កត់ហើយ ទើបបាញ់អ្នកនឹងព្រួញនោះ ។ ម្នាលសាមៈ អ្នកមកអំពីប្រទេសណា ឬនរណាប្រើមកថា អ្នកដងទឹក ចូរទៅកាន់ស្ទឹង ដូច្នេះ បានជាអ្នកមកកាន់ស្ទឹងមិគសម្មតៈ (ទេ) ។

(៤៧) (ព្រះមហាសត្វ) មាតាបិតារបស់ទូលបង្គំជាខ្ញុំខ្វាក់ ទូលបង្គំជាខ្ញុំតែងចិញ្ចឹមគាត់ក្នុងព្រៃធំ ទូលបង្គំជាខ្ញុំជាអ្នកដងទឹកដើម្បីអ្នកមានគុណទាំងឡាយ បានជាមកកាន់ស្ទឹងមិគសម្មតៈ(ទេ) ។

(៤៨) (ព្រះមហាសត្វពោល) មាតាបិតាទាំងឡាយនោះ មានត្រឹមតែកម្តៅ កាលបើយ៉ាងនេះ (ជីវិតនឹងប្រព្រឹត្តទៅ) ត្រឹម ៦ ថ្ងៃ ព្រោះគាត់ខ្វាក់ បុត្រជាទីស្រឡាញ់ដងទឹកពុំបាន ។

ន មេ ឥទំ តថា ទុក្ខំ   លព្ភា ហិ បុមុនា ឥទំ
យញ្ច អម្មំ ន បស្សាមិ   តំ មេ ទុក្ខតរំ ឥតោ ។
ន មេ ឥទំ តថា ទុក្ខំ   លព្ភា ហិ បុមុនា ឥទំ
យញ្ច តាតំ ន បស្សាមិ   តំ មេ ទុក្ខតរំ ឥតោ ។
សា នូន កបណា អម្មា   ចិរំ រត្តាយ រុច្ឆតិ
អឌ្ឍរត្តេ វ រត្តេ វា   នទីវ អវសុស្សតិ ។
សោ នូន កបណោ តាតោ   ចិរំ រត្តាយ រុច្ឆតិ
អឌ្ឍរត្តេ វ រត្តេ វា   នទីវ អវសុស្សតិ ។
ឧដ្ឋានបាទចរិយាយ   បាទសម្ពាហនស្ស ច
សាម តាត វិលបន្តា   ហិណ្ឌិស្សន្តិ ព្រហាវនេ ។
ឥទម្បិ ទុតិយំ សល្លំ   កម្បេតិ ហទយំ មម
យញ្ច អម្មំ ន បស្សាមិ   មញ្ញេ(១)ហិស្សាមិ ជីវិតំ ។

១ ឱ. ម. ឥស្សាមិ ។ ២ ម. ទំ ១៨ ។



ទុក្ខនេះមិនមែនជាទុក្ខរបស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះបុរសក្រៅតែបានច្រើនដែលទូលបង្គំជាខ្ញុំ បានឃើញមក ដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ (ទៅទៀត) ។ ទុក្ខនេះ មិនមែនជាទុក្ខរបស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថាទុក្ខនេះបុរសក្រៅតែបាន ច្រើនដែលទូលបង្គំជាខ្ញុំ បានឃើញមក ដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំជាងទុក្ខនេះ (ទៅទៀត) ។ ម្ល៉េះ សមមាតានៅកំព្រា ខ្សឹកយំតាំងតែអធ្រាត្រ ឬទីបំផុតនៃរាត្រី អស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួតទៅ ដូចជាស្ទឹង (ក្នុងគិម្ហរដូវ) ពុំខាន ។ ម្ល៉េះ សមបិតា នៅកំព្រា ខ្សឹកយំតាំងតែអធ្រាត្រ ឬទីបំផុតនៃរាត្រី អស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួតដូចជាស្ទឹងពុំខាន ។ បពិត្រព្រះរាជា មួយវិញទៀត (ខ្ញុំតែងក្រោកក្នុងមួយយប់ពីរបីដង) ដើម្បីបំរើបាទាដោយព្យាយាម នឹងដើម្បីគក់ច្របាច់ ម្ល៉េះសមមាតានឹងដើរត្រាច់ចរក្នុងព្រៃធំ ដង្ហោយហៅថា អើពុកសាមៈ ដូច្នេះពុំខានឡើយ ។ បើទូលបង្គំជាខ្ញុំ បានឃើញផងព្រួញទាំងពីរនោះដោយហេតុណា ហេតុនោះឯង ទុក្ខជាសរទីពីរដែលញាំញីហឫទ័យរបស់ទូលបង្គំជាខ្ញុំឲ្យញាប់ញ័រ មុខជាជីវិតទូលបង្គំជាខ្ញុំនឹងវិនាសពុំខាន ។

(៤៧) មា ពាឡ្ហំ បរិទេវេសិ សាម កល្យាណទស្សន
អហំ កម្មករោ ហុត្វា ភរិស្សន្ត ព្រហ្មចារិនេ ។
ឥស្សត្ថេ ចស្មិ កុសលោ ទឡ្ហធម្មោតិ វិស្សុតោ
អហំ កម្មករោ ហុត្វា ភរិស្សន្ត ព្រហ្មចារិនេ ។
មិគានំ វិឃាសមន្វេសំ វនមូលផលានិ ច
អហំ កម្មករោ ហុត្វា ភរិស្សន្ត ព្រហ្មចារិនេ ។
កតមន្តំ វនំ សាម យត្ថ មាតាបិតា តវ
អហន្តេ តថា ករិស្សំ យថា តេ អភរី តុវំ ។
(៤៨) អយំ ឯកបទី រាជ យោយំ ឧស្សីសកេ មម
ឥតោ គន្ត្វា អឌ្ឍយោសំ(*) តត្ថ នេសំ អគារកំ
យត្ថ មាតាបិតា មយ្ហំ តេ ភរស្សុ ឥតោ គតោ ។
(៤៩) នមោ តេ កាសិរាជត្ថុ នមោ តេ កាសិវឌ្ឍន
អន្ធា មាតាបិតា មយ្ហំ តេ ភរស្សុ ព្រហាវនេ ។

* ម. ឧ. អឌ្ឍកោសំ ។



(៤៧) (ព្រះបាទបិលយក្ខ) ម្នាលសាមៈ ជាអ្នកមានរូបល្អ ចូរឲ្យអស់អន់ អ្នកកុំខ្សឹកខ្សួលខ្លាំងឡើយ ខ្ញុំនឹងជាអ្នកធ្វើការងារចិញ្ចឹមនូវជនទាំងឡាយនោះ ក្នុងព្រៃ ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូស្រាច់ មានឈ្មោះល្បីល្បាញថាជាអ្នកប្រកបដោយធ្នូដ៏មាំ ខ្ញុំជាអ្នកធ្វើការងារ ចិញ្ចឹមនូវជនទាំងឡាយនោះ ក្នុងព្រៃ ។ ខ្ញុំនឹងជាអ្នកធ្វើការងារ ស្វែងរកចំណីនៃម្រឹគ និងមើមឈើផ្លែឈើទាំងឡាយក្នុងព្រៃ ហើយនឹងចិញ្ចឹមនូវជនទាំងឡាយនោះ ក្នុងព្រៃ ។ ម្នាលសាមៈ មាតាបិតារបស់អ្នកនៅក្នុងព្រៃណា ព្រៃនោះដូចម្តេច អ្នកបានចិញ្ចឹមនូវមាតាបិតាយ៉ាងណា ខ្ញុំនឹងចិញ្ចឹមនូវគាត់យ៉ាងនោះដែរ ។

(៤៨) (ព្រះមហាសត្វ) បពិត្រព្រះរាជា ផ្លូវដើរតែម្នាក់នេះនៅជាន់ក្បាលដំណេកទូលព្រះបង្គំខ្ញុំ ព្រះអង្គយាងទៅអំពីទីនេះ កន្លះយោសៈ (នឹងឃើញ)ខ្ទមជាទីនៅរបស់មាតាបិតាទូលព្រះបង្គំខ្ញុំនោះ ព្រះអង្គយាងទៅអំពីទីនេះ សូមទ្រង់ចិញ្ចឹមនូវគាត់ក្នុងទីនោះចុះ ។

(៤៩) បពិត្រព្រះរាជាជាធំក្នុងដែនកាសី ទូលបង្គំខ្ញុំ សូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះរាជា ទ្រង់មានសេចក្តីចំរើនក្នុងដែនកាសី ទូលបង្គំខ្ញុំ សូមថ្វាយបង្គំព្រះអង្គ មាតាបិតាទាំងឡាយ របស់ទូលបង្គំខ្ញុំ ជាមនុស្សខ្វាក់ សូមទ្រង់ចិញ្ចឹមនូវគាត់ ក្នុងព្រៃធំផង ។

អញ្ជលិន្តេ បគ្គណ្ហាមិ    កាសិរាជ នមត្ថុ តេ
មាតរំ បិតរំ មយ្ហំ    វុត្តោ វជ្ជាសិ វន្ទនំ ។

(១០០) ឥទំ វត្វាន សោ សាមោ    យុវា កល្យាណទស្សនោ
មុច្ឆិតោ វិសវេគេន    វិសញ្ញី សមបជ្ជថ ។

(១០១) ស រាជា បរិទេវេសិ    ពហុំ ការុញ្ញសញ្ហិតំ
អជរាមរោហំ អាសឹ    អជ្ជេតំ ញាមិ នោ បុរេ
សាមំ កាលកតំ ទិស្វា    នត្ថិ មច្ចុស្ស នាគមោ
យស្សុ មំ បដិមន្តេតិ    សវិសេន សមប្បិតោ ។
ស្វាជ្ជេវង្គតេ កាលេ    ន កិញ្ចិមភិភាសតិ
និរយំ នូន គច្ឆាមិ    ឯត្ថ មេ នត្ថិ សំសយោ ។
តទា ហិ បកតំ បាបំ    ចិររត្តាយ កិព្វិសំ[1]
ភវន្តិ តស្ស វត្តារោ    គាមេ កិព្វិសការកោ[2]
អរញ្ញេ និម្មនុស្សម្ហិ    កោ មំ វត្តុមរហតិ ។

១ កិព្វិសន្តិ កត្ថចិ ទិស្សតិ ។ ២ កិព្វិសការកោតិបិ បាឋោ ។



ទូលបង្គំជាខ្ញុំ សូមផ្គងអញ្ជលីចំពោះព្រះអង្គ បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះអង្គ ទូលបង្គំជាខ្ញុំ សូមផ្ដាំទុក សូមទ្រង់ពាំបណ្ដាំការថ្វាយបង្គំ ចំពោះមាតាបិតារបស់ទូលបង្គំជាខ្ញុំផង ។

(១០០) (អភិសម្ពុទ្ធគាថា) សាមៈ កំលោះ អ្នកមានរូបល្អ គួររមិលមើលនោះ លុះពោលនូវពាក្យនេះរួចហើយ ក៏ស្រប់សន្លប់ដោយកម្លាំងពិស ។

(១០១) ព្រះរាជាអង្គនោះ ទ្រង់ព្រះកន្សែងរៀបរាប់នូវពាក្យដែលប្រកបដោយសេចក្ដីករុណា មានប្រមាណច្រើនថា អាត្មាអញធ្លាប់យល់ថាអញ មិនចាស់មិនស្លាប់ ថ្ងៃនេះ អញឃើញនូវសុវណ្ណសាមនេះ ទើបការក៏រលាយហើយ ទើបដឹងនូវហេតុនោះ ពីដើមមិនដឹងថាការមកនៃសេចក្ដីស្លាប់ មិនមែនមិនមានឡើយ ។ សាមៈដែលរងគ្រោះដោយថ្នាំពិស កំពុងតែពោលជាមួយនឹងអញ (ក្នុងកាលអម្បាញ់មិញនេះ) ឥឡូវនេះ គាត់លែងនិយាយពាក្យតិចតួចក្នុងកាលប្រព្រឹត្តទៅយ៉ាងនេះក្នុងថ្ងៃនេះ អាត្មាអញមុខជានឹងទៅកាន់នរកពុំខាន អាត្មាអញឥតមានសេចក្ដីសង្ស័យក្នុងដំណើរនេះទេ ។ ព្រោះថា អំពើបាបដែលអាត្មាអញ ធ្វើទុកហើយក្នុងគ្រានោះ នឹងជាទោសឲ្យផលលាមកអស់កាលជាអង្វែង (បើ) ក្នុងស្រុក គង់មានពួកអ្នកតិះដៀលអញនោះថា ព្រះអង្គជាអ្នកធ្វើនូវអំពើអាក្រក់ដូច្នេះ តែក្នុងអរញ្ញប្រទេស ដែលឥតមនុស្ស តើនរណាតិះដៀលអញបាន ។

សាយន្តិ ហិ កាន្មានិ  តាមេ សន្តិដ្ឋ មាណវា
អរញ្ញេ និម្មនុស្សម្ហិ  កោ នុ មំ សារយិស្សតិ ។

(១០២)សា ទេវតា អន្តរហិតា  បព្វតេ គន្ធមាទនេ
រញ្ញោ អនុកម្បាយ  ឥមា គាថា អភាសថ ។
អាគុំ កិរ មហារាជ  អការិ កម្មទុក្កដំ
អទូសកា បិតាបុត្តា  តយោ ឯកូសុនា ហតា ។
ឯហិ តំ អនុសិក្ខាមិ  យថា តេ សុគតី សិយា
ធម្មេនន្ធេ(១) វនេ បោស  មញ្ញេហំ សុគតី សិយា ។

(១០៣) ស រាជា បរិទេវិត្វា  ពហុំ ការុញ្ញសញ្ហិតំ
ឧទកកុម្ភមាទាយ  បក្កាមិ ទក្ខិណាមុខោ ។

(១០៤)កស្ស នុ ឯសោ បទសទ្ទោ មនុស្សស្សេវ អាគតោ
នេសោ សាមស្ស និគ្ឃោសោ កោ នុ ត្វមសិ មារិស ។
សន្តំ ហិ សាមោ វជតិ  សន្តំ បាទានិ នេយតិ(២)
នេសោ សាមស្ស និគ្ឃោសោ កោ នុ ត្វមសិ មារិស ។

១ ១. ធម្មេន វេ ។ ២ ធម្មេន តេ ។ ២ ហញ្ញតិ បតិទ្វេទតិ គម្ពីរជាយ វិសុទ្ធិ ។



ហ៊ឹកស្រែក ពួកមាណពប្រថ្មី ហើយហៅប្រាប់ខ្ញុំអើពីចំងាយ (របស់អញ) ក្នុងអរញ្ញប្រទេសដែលឥតមនុស្ស តើនរណានឹងហៅប្រាប់អញ ។

(១០២) ទេវតានោះ(១) បាត់អំពីភ្នំគន្ធមាទន៍ ហើយពោលនូវគាថាទាំងឡាយនេះ ដោយអនុគ្រោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គទ្រង់បានធ្វើនូវបាបកម្ម ដែលជាអំពើអាក្រក់ ជនទាំងបីនាក់គឺមាតាបិតានិងបុត្ត ជាអ្នកមិនប្រទូស្ត ទ្រង់បានសម្លាប់ហើយដោយព្រួញតែមួយ ។ សូមទ្រង់មក សុគតិភព នឹងគប្បីមានដល់ព្រះអង្គយ៉ាងណា ខ្ញុំនឹងពន្យល់ព្រះអង្គយ៉ាងនោះ សូមទ្រង់ចិញ្ចឹមនូវជនខ្វាក់ទាំងពីរនាក់នោះឯងដោយធម៌ ខ្ញុំយល់ថា សុគតិគប្បីមាន ។

(១០៣) ព្រះរាជាអង្គនោះ ទ្រង់កំសត់រៀបរាប់ ប្រកបដោយសេចក្ដីករុណាមានប្រមាណច្រើន ហើយកាន់ក្អមទឹកយាងឆ្ពោះទៅទិសទក្សិណ ។

(១០៤)(ទុកូលបណ្ឌិត...)សូរជើងនរណានុ៎ះហ្នុ៎ះ ដែលដើរមកនេះគិតជាសូរជើងមនុស្ស តែសូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិរទុក្ខ អ្នកជាអ្វីហ្នឹង ។ ព្រោះសាមៈតែងដើរថយៗ លើកដាក់ជើងស្រាលៗ សូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិរទុក្ខ អ្នកជាអ្វីហ្នឹង

១ តាមសេចក្ដីនេះ ប្រាកដជាមាតាពោធិសត្វក្នុងជាតិទី ៧ សុវណ្ណកជាតកនោះបង្គុំនឹង នេះ តាមតែបច្ចេកាលៈទេសៈ ពួកខ្មែរនិយម ។

(១០៥) រាជាហមស្មិ កាសីនំ បិលិយក្ខោតិ មំ វិទូ
លោភា រដ្ឋំ បហិត្វាន មិគមេសំ ចរាមហំ ។
ឥស្សត្ថេ ចស្មិ កុសលោ ទឡ្ហធម្មោតិ វិស្សុតោ
នាគោបិ មេ ន មុច្ចេយ្យ អាគតោ ឧសុបាតនំ ។

(១០៦) ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ
ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។
តិន្ទុកានិ បិយាលានិ មធុកេ កាសុមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ រាជ វរំ វរំ ។
ឥទម្បិ បានីយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ ។

(១០៧) នាលំ អន្ធា វនេ ទដ្ឋុំ កោ នុ វោ ផលមាហរិ
អនន្ធស្សេវយំ សម្មា និវាបោ មយ្ហ ខាយតិ ។



(១០៥) (ព្រះរាជបិលយក្ខ...) ខ្ញុំជាព្រះរាជារបស់ពួកអ្នកដែនកាសី គេស្គាល់ខ្ញុំថាបិលយក្ខ ខ្ញុំលះបង់នូវដែន ព្រោះសេចក្ដីលោភ (សាច់) ។ ម្យ៉ាងទៀត ខ្ញុំជាអ្នកឈ្លាសវៃ ក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថាជាអ្នកប្រើប្រាស់នូវធ្នូមាំមួន សូម្បីដំរី មកចំផ្លូវព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ ។

(១០៦) (ស្វាគតន្តេ...) បពិត្រមហារាជ ព្រះករុណាដំណើរមករបស់ព្រះអង្គល្អហើយ ព្រោះដំណើរមករបស់ព្រះអង្គមិនអាក្រក់ទេ ព្រះអង្គជាធំ ទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូលចុះ ។ បពិត្រព្រះរាជា ផលាផល គឺផ្លែទន្លាប់ ទះប៉ែន ស្រគំ សីនមានរសផ្អែមដូចទឹកឃ្មុំ កន្ធារគត ប្រមូលមកក្នុងទីនេះជាមួយគ្នា សូមទ្រង់សោយនូវផលាផល មានរសឆ្ងាញ់ៗ ។ នេះ ទឹកត្រជាក់ សម្រាប់សោយដែលដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ បើទ្រង់សព្វព្រះទ័យ ទ្រង់ (ដង) អំពីទីនេះសោយចុះ ។

(១០៧) (ព្រះរាជា...) អ្នកទាំងពីរនេះជាមនុស្សខ្វាក់ មិនអាចឃើញ (ផ្លូវ) ក្នុងព្រៃទេ តើនរណា ប្រមូលនូវផលាផល មកជូនអ្នក អាហារដែល (បាន) ដោយប្រពៃនេះ ប្រាកដដល់ខ្ញុំ ដូចជាអាហាររបស់មនុស្សមិនខ្វាក់ ។

(១០៨) ទហរោ យុវា នាតិព្រហា សាមោ កល្យាណ-
ទស្សនោ
ទីឃស្ស កេសា អសិតា អថោ សូនគ្គវេល្លិតា ។
សោ ហវេ ផលមាហរិត្វា ឥតោ អាទាយ កមណ្ឌលុំ
នទីំ គតោ ឧទហារោ មញ្ញេ ន ទូរមាគតោ ។
(១០៩) អហន្តំ អវធិំ សាមំ យោ តុយ្ហំ បរិចារកោ
យំ កុមារំ បវេទេថ សាមំ កល្យាណទស្សនំ ។
ទីឃស្ស កេសា អសិតា អថោ សូនគ្គវេល្លិតា
តេសុ លោហិតលិត្តេសុ សេតិ សាមោ មយា ហតោ ។
(១១០) កេន ទុកូល មន្តេសិ ហតោ សាមោតិ វាទិនា
ហតោ សាមោតិ សុត្វាន ហទយំ មេ បវេធតិ ។
អស្សត្ថស្សេវ តរុណំ បវាឡំ មាលុតេរិតំ
ហតោ សាមោតិ សុត្វាន ហទយំ មេ បវេធតិ ។
(១១១) បារិកេ កាសិរាជាយំ សោ សាមំ មិគសម្មតេ
កោធសា ឧសុនា វិជ្ឈិ តស្ស មា បាបមិច្ឆិម្ហា ។
(១១២) កិច្ឆា លទ្ធោ បិយោ បុត្តោ យោ អន្ធេ អភរី វនេ
តមេកបុត្តំ ឃាតិម្ហិ កថំ ចិត្តំ ន កោបយេ ។





(១០៨) (ទុកូលបណ្ឌិត...) សាមៈ កំលោះមៅក្រើ មិនខ្ពស់ មិនទាបពេក ជាមនុស្សមានរូបល្អគួរគយគន់ មានសក់វែងខ្មៅ ចាំងមានចុងទន់ល្មន់ ។ សាមៈនោះឯង រែករែងស្វែងរកផលាផល ជាអ្នកដងទឹក បានកាន់យកក្អមទឹកអំពីទីនេះ ទៅកាន់ស្ទឹង ប្រហែលជាជិតមកដល់ហើយ ។

(១០៩) (ព្រះបាទបិលិយក្ស...) សាមៈជាអ្នកបំរើអ្នកទាំងឡាយ សំដៅកុមារឈ្មោះសាមៈណា ដែលមានរូបល្អគួរគយគន់ សាមៈនោះ ខ្ញុំសម្លាប់ហើយ ។ សាមៈ ដែលមានសក់វែង ពណ៌ខ្មៅ ចុងទន់ល្មន់ (ដូច្នេះ) ខ្ញុំសម្លាប់ដួលដេកលើសក់ទាំងនោះ ប្រឡាក់ហើយដោយឈាម ។

(១១០) (នាងបារិកា) បពិត្រទុកូល អ្នកប្រឹក្សាជាមួយនរណា ដែលបាននិយាយថា ខ្ញុំសម្លាប់សាមៈហើយ បេះដូងខ្ញុំញាប់ញ័រ ព្រោះឮថា សាមៈស្លាប់ហើយ ។ ហឫទ័យខ្ញុំញាប់ញ័រ ហាក់ដូចត្រួយពោធិព្រឹក្ស ដែលមានខ្យល់បក់ទង្គិច ព្រោះឮថា សាមៈ ស្លាប់ហើយ ។

(១១១) (ទុកូលបណ្ឌិត...) ម្នាលនាងបារិកា នេះជាព្រះរាជា ជាធំក្នុងដែនកាសី ព្រះអង្គបាញ់សាមៈដោយព្រួញ ក្បែរស្ទឹងមិគសម្មតៈ ដោយសេចក្តីក្រោធ យើងកុំបីឲ្យមានបាបដល់ព្រះអង្គឡើយ ។

(១១២) (នាងបារិកា..) បុត្រដែលចិញ្ចឹមយើងជនងងឹតក្នុងព្រៃ ជាបុត្រជាទីស្រឡាញ់ យើងរកបានដោយកម្រ ចិត្តមិនគប្បីខ្ញាល់ក្នុងបុរស អ្នកសម្លាប់កូនប្រុសតែមួយនោះ ដូចម្តេចបាន ។

(១១៣) កិច្ចា លទ្ធោ បិយោ បុត្តោ យោ អទ្ធ អគរី វត

តមេកបុត្តឃាតម្ហិ អក្កោសំ អាហុ បណ្ឌិតា ។

(១១៤) មា តាញ្ញ បរិទេវេជ ហោតោ សាយោតិ ភណិតា

អហំ កម្មការោ ហុត្វា កាំសុភ្នំ ព្រហាវេទ ។

វស្សន្តេ ចស្មិ កុសលោ ឥល្បធម្មោតិ វិស្សុតោ

អហំ កម្មការោ ហុត្វា កាំសុភ្នំ ព្រហាវេទ ។

មិកានំ វិឃាសមទ្ទស់ វេមូលផលានិ ច

អហំ កម្មការោ ហុត្វា កាំសុភ្នំ ព្រហាវេទ ។

(១១៥) នេស ធម្មោ មហារាជ នេតំ អម្ហេសុ កប្បតិ

រាជា ខូមសិ អម្ហាកំ តាទេ វត្ថម តេ មយំ ។

(១១៦) ធម្មំ នេសាន ភណាថ ការា អបចិតី គយោ

បិតា ខូមសិ អម្ហាកំ មាតា ខូមសិ ភារិកា ។

(១១៧) ធមោ តេ កាសិក្ខេត្តុ ធមោ តេ កាសិវឌ្ឍន

អញ្ជលិន្តេ បគ្គណ្ហាម យាវ សាមានុបាបយ ។



(១១៣) (ខ្ញុំលបណ្ឌិត...) បុត្តដែលបិតាម្ដាយយើងនឹងនឹកនឹងលំបាកនៅព្រៃ ជាបុត្តជាទីស្រឡាញ់ យើងនឹកភ្នកជាយកម្រ បណ្ឌិតទាំងឡាយ សរសើរ សេចក្តីមិនក្រោធ ចំពោះបុរសអ្នកសម្លាប់បុត្តតែមួយនោះ ។

(១១៤) (ព្រះបាទចលយក្ខ...) អ្នកទាំងពីរ កុំបរិទេវកន្លួលទាំងឡ ចំពោះខ្ញុំអ្នកពោលថា សាមៈខ្ញុំសម្លាប់ហើយ ខ្ញុំនឹងជាអ្នកធ្វើការដើម្បីចិញ្ចឹម (អ្នកទាំងពីរ) ក្នុងព្រៃ ។ ព្រោះខ្ញុំជាអ្នកឈ្លាសវៃ ក្នុងសិល្បៈធ្នូ ឈ្មោះល្បីល្បាញថា ជាអ្នកប្រព្រឹត្តធ្នូដ៏ម៉ាំ ខ្ញុំនឹងធ្វើការដើម្បីចិញ្ចឹម (អ្នក) ក្នុងព្រៃ ។ ខ្ញុំនឹងធ្វើការដើររកសត្វម្រឹគទាំងឡាយ ទាំងដើមឈើ ផ្លែឈើ ហើយចិញ្ចឹម (អ្នក) ក្នុងព្រៃ ។

(១១៥) (ជនទាំងពីរ...) បពិត្រមហារាជ នេះមិនមែនជាទំនៀមទម កិរិយាធ្វើនូវតែគី (របស់ព្រះអង្គ) នេះ មិនសមគួរដល់យើងឡើយ ព្រះអង្គជាព្រះរាជារបស់យើង ។ សូមថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ ។

(១១៦) (ព្រះរាជា...) បពិត្រអ្នកនេសាទ អ្នកពោលនូវធម៌ អ្នកធ្វើនូវសេចក្តីគោរព (ចំពោះខ្ញុំ) អ្នកទុកជាបិតារបស់ខ្ញុំ បពិត្រនាងបារិកា នាងទុកជាមាតារបស់ខ្ញុំ ។

(១១៧) (ជនទាំងពីរ...) បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ខ្ញុំបង្គំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គចម្រើនដែនកាសី ខ្ញុំបង្គំ សូមថ្វាយបង្គំព្រះអង្គ ខ្ញុំបង្គំទាំងឡាយ សូមប្រណម្យអញ្ជលីចំពោះព្រះអង្គ

តស្ស ធាតេ សមជ្ជន្ត(១) មុខញ្ច កុជនស្សរំ
សំសុក្ខមាលា អគ្គានំ កាលមាគមយាមសេ ។

[១០៨] ព្រហាកព្យមិតាការិណ្ណំ អាកាសន្តំ និស្សតិ
យត្ថ សាមោ ហតោ សេតិ ចន្ទោវ បតិតោ ឆមា ។
ព្រហាកព្យមិតាការិណ្ណំ អាកាសន្តំ និស្សតិ
យត្ថ សាមោ ហតោ សេតិ សុរិយោ បតិតោ ឆមា ។
ព្រហាកព្យមិតាការិណ្ណំ អាកាសន្តំ និស្សតិ
យត្ថ សាមោ ហតោ សេតិ បំសុនា បរិកុណ្ឋិតោ(២) ។
ព្រហាកព្យមិតាការិណ្ណំ អាកាសន្តំ និស្សតិ
យត្ថ សាមោ ហតោ សេតិ ឥធេវ វសថស្សមេ ។

[១០៩] យទិ តត្ថ សហាសព្ពនិ សតានិ និយុតានិ ច
នេវម្ហាកំ ភយំ កោចិ វនេ វាឡេសុ វិជ្ជតិ ។

១ ម. បវត្តន្ត ។ ២ ម. ឆ. បរិកុណ្ឋិតោ ។



សូមព្រះអង្គនាំខ្ញុំបន្តិចទៅដល់សាមៈ ខ្ញុំបពិត្រអ្នកទាំងឡាយ នឹងប្រញាប់ដើរ ស្ទាបមុខ ស្ទាបមើលរបស់សាមៈ ពោរពេញទៅដោយធូលីទាំងឡាយ សេចក្ដីស្លាប់ចុះ ណ្ហះ ។

(១០៨) (ព្រហាកព្យមិត្ត...) សាមៈ ដែលស្លាប់ហើយ ដួលដេកដូចជាព្រះចន្ទធ្លាក់មកលើប្រថពី ក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។ សាមៈ ដែលស្លាប់ហើយ ដួលដេក ដូចជាព្រះអាទិត្យធ្លាក់មកលើប្រថពីក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។ សាមៈដែលស្លាប់ហើយ ដួលដេកប្រឡាក់ប្រឡូសដោយធូលីដី ក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស ។ សាមៈ ដែលស្លាប់ហើយ ដួលដេកនៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រើង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស (ព្រោះហេតុនោះ) អ្នកទាំងឡាយ ចូរនៅតែក្នុងអាស្រមនេះហើយ ។

(១០៩) (យទិ តត្ថ...) បើក្នុងព្រៃណាជាទីនោះ (មានម្រឹគសាហាវ) ដោយ ពាន់ ម៉ឺនក្ដី ខ្ញុំបពិត្រអ្នកទាំងពីរ នឹងមានសេចក្ដីភ័យអំពីទួល ព្រោះសត្វសាហាវទាំងឡាយក្នុងព្រៃ ។

(១៦០) តតោ អន្ធានមាទាយ កាសិរាជា ព្រហាវនេ
ហត្ថេ គហេត្វា បក្កាមិ យត្ថ សាមោ ហតោ អហុ ។

(១៦១) ទិស្វាន បតិតំ សាមំ បុត្តកំ បំសុកុណ្ឋិតំ
អបវិទ្ធំ ព្រហារញ្ញេ ចន្ទំវ បតិតំ ឆមា ។
ទិស្វាន បតិតំ សាមំ បុត្តកំ បំសុកុណ្ឋិតំ
អបវិទ្ធំ ព្រហារញ្ញេ សុរិយំវ បតិតំ ឆមា ។
ទិស្វាន បតិតំ សាមំ បុត្តកំ បំសុកុណ្ឋិតំ
អបវិទ្ធំ ព្រហារញ្ញេ កលូនំ(១) បរិទេវយុំ ។
ទិស្វាន បតិតំ សាមំ បុត្តកំ បំសុកុណ្ឋិតំ
ពាហា បគ្គយ្ហ បក្កន្ទុំ អធម្មោ កិរ ភោ ឥតិ ។
ពាឡ្ហំ ខោ ត្វំ បមត្តោសិ(២) សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ ន កិញ្ចិ មភិភាសសិ ។
ពាឡ្ហំ ខោ ត្វំ បទិត្តោសិ(៣) សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ ន កិញ្ចិ មភិភាសសិ ។
ពាឡ្ហំ ខោ ត្វំ បកុទ្ធោសិ(៤) សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ ន កិញ្ចិ មភិភាសសិ ។

១ ម. ករុណំ ។ ២ ម. សុត្តោ ។ ៣ ម. មត្តោ ។ ៤ ម. បមត្តោ ។



(១៦០) (អភិសម្ពុទ្ធគាថា...) គ្រានោះ ព្រះរាជាជាធំក្នុងដែនកាសី នាំជនខ្វាក់ (ទាំងពីរ) ដឹកដៃទៅក្នុងព្រៃធំ ត្រង់កន្លែងដែលសាមៈស្លាប់ ។

(១៦១) មាតាបិតា ឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូស ដោយធូលីដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ហាក់ដូចព្រះចន្ទដែលធ្លាក់មកលើផែនដី ។ ឃើញនូវសាមៈ ជាបុត្ត ដួលប្រឡាក់ប្រឡូសដោយធូលីដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ដូចព្រះអាទិត្យដែលធ្លាក់មកលើផែនដី ។ ឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយធូលីដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ក៏យំកាន់រៀបរាប់គួរឲ្យករុណា ។ ឃើញនូវសាមៈ ជាបុត្ត ដួលប្រឡាក់ប្រឡូសដោយធូលីដី ហើយផ្គងដៃទាំងពីរ យំខ្សឹកខ្សួលថា ចុះដំណើរ (ការស្លាប់នេះ) ជាសភាពមិនគួរទេ ។ ម្នាលសាមៈ មានរូបល្អ គួរឲ្យត្រេកអរមើល បាងនឹងជាមនុស្សស្រវឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកមិននិយាយរកយើងបន្តិចបន្តួចសោះ ។ ម្នាលសាមៈ មានរូបល្អគួរឲ្យត្រេកអរមើល បាជាមនុស្សក្រអឺតក្រអិនខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកមិននិយាយរកយើងបន្តិចបន្តួចសោះ ។ ម្នាលសាមៈ អ្នកមានរូបល្អ គួរឲ្យត្រេកអរមើល បាងនឹងខឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ អ្នកមិននិយាយរកយើង បន្តិចបន្តួចសោះ ។

ពាឡ្ហំ ខោ ត្វំ បមត្តោសិ   សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ   ន កិញ្ចិ មភិភាសសិ ។
ពាឡ្ហំ ខោ ត្វំ វិមនោសិ   សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ   ន កិញ្ចិ មភិភាសសិ ។
ជដំ វលិនំ(១) បំសុគតំ   កោ ទានិ សណ្ឋបេស្សតិ
សាមោ អយំ កាលកតោ   អម្ហាកំ បរិចារកោ ។
កោ មេ សម្មជ្ជនាទាយ   សម្មជ្ជិស្សតិ អស្សមំ
សាមោ អយំ កាលកតោ   អម្ហាកំ បរិចារកោ ។
កោ ទានិ ន្ហាបយិស្សតិ   សីតេនុណ្ហោទកេន ច
សាមោ អយំ កាលកតោ   អម្ហាកំ បរិចារកោ ។
កោ ទានិ ភោជយិស្សតិ   វនមូលផលានិ ច
សាមោ អយំ កាលកតោ   អម្ហាកំ បរិចារកោ ។
(១៦៦) ទិស្វាន បតិតំ សាមំ   បុត្តកំ បំសុកុណ្ឋិតំ
អដ្ដិតា(២) បុត្តសោកេន   មាតា សច្ចំ អភាសថ ។
យេន សច្ចេនយំ សាមោ   ធម្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន   វិសំ សាមស្ស ហញ្ញតុ ។

[illegible]



ម្នាលសាមៈ មានរូបល្អគួរឲ្យក្រឡេកមើល បាឯងដេកលក់ស៊ប់ បានជា ក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឯងនិយាយនឹងបន្តិចបន្តួចសោះ ។ ម្នាលសាមៈ មានរូបល្អគួរឲ្យក្រឡេកមើល បាជាបុគ្គលខូចចិត្តខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឯងនិយាយនឹងបន្តិចបន្តួចសោះ ។ ឥឡូវនេះ នរណានឹងរៀបចំជដា ដ៏សៅហ្មងប្រឡាក់ប្រឡូសដោយធូលីដី ព្រោះសាមៈ ជាអ្នកបំរើយើងទាំងពីរនាក់នេះ ធ្វើមរណកាលហើយ ។ នរណា នឹងកាន់អំបោស បោសអាស្រមរបស់យើង ព្រោះសាមៈ ជាអ្នកបំរើយើងទាំងពីរនាក់នេះ ធ្វើមរណ-កាលហើយ ។ ឥឡូវនេះ នរណានឹងផ្ងូត (យើង) ដោយទឹកត្រជាក់ ទឹកក្តៅ ព្រោះសាមៈ ជាអ្នកបំរើយើងទាំងពីរនាក់នេះ ធ្វើមរណកាលហើយ ។ ឥឡូវនេះ នរណា នឹងឲ្យយើងបរិភោគ មើមឈើ ផ្លែឈើ ព្រោះសាមៈ ជាអ្នកបំរើយើងទាំងពីរនាក់នេះ ធ្វើមរណកាលហើយ ។

(១៦៦) មាតា ឃើញសាមៈ ជាបុត្ត ដួលប្រឡាក់ប្រឡូសដោយធូលីដី ត្រូវសេចក្តីសោក ព្រោះកូន បៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឲ្យពិស របស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ ។

យេន សច្ចេនយំ សាមោ ព្រហ្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ សច្ចវាទី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ មាតាបេត្តិភរោ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ កុលេ ជេដ្ឋាបចាយិកោ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ បាណា បិយតរោ មម
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យំ កិញ្ចិត្ថិ កតំ បុញ្ញំ មយ្ហញ្ចេវ បិតុច្ច តេ
សព្វេន តេន កុសលេន វិសំ សាមស្ស ហញ្ញតុ ។
(១២៣) ទិស្វាន បតិតំ សាមំ បុត្តកំ បំសុកុណ្ឋិតំ
អដ្ដិតា បុត្តសោកេន បិតា សច្ចំ អកាសយំ ។
យេន សច្ចេនយំ សាមោ ធម្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ ព្រហ្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។



ក្នុងកាលមុន សាមៈនេះជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកពោលនូវពាក្យសច្ចៈដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាអ្នកបំរើមាតាបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូលដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាទីស្រឡាញ់ដោយពិសេសរបស់ខ្ញុំ ជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ បុណ្យណាមួយ ដែលខ្ញុំផង ដែលបិតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ។

(១២៣) បិតាឃើញសាមៈ ជាបុត្រ ដួលប្រឡាក់ប្រឡូសដោយធូលីដី ត្រូវសេចក្ដីសោកព្រោះកូនបៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈសាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។

យេន សច្ចេនយំ សាមោ ធម្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ មាតាបេត្តិភរោ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ កុលេ ជេដ្ឋាបចាយិកោ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ បាណា បិយតរោ មម
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យន្តិញ្ចិត្ថិ កតំ បុញ្ញំ មយ្ហញ្ចេវ បិតុច្ច តេ
សព្វេន តេន កុសលេន វិសំ សាមស្ស ហញ្ញតុ ។

(១៦៥) សា ទេវតា អន្តរហិតា បព្វតេ គន្ធមាទនេ
សាមស្ស អនុកម្បាយ ឥមំ សច្ចំ អភាសថ ។
បព្វត្យាហំ គន្ធមាទនេ ចិរំ រត្តំ និវាសិនី
ន មេ បិយតរោ កោចិ អញ្ញោ សាមេន វិជ្ជតិ
ឯតេន សច្ចវជ្ជេន វិសំ សាមញ្ញស្ស ហញ្ញតុ ។
សព្វេ វនា គន្ធមយា បព្វតេ គន្ធមាទនេ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។





ក្នុងកាលមុន សាមៈនេះ ជាអ្នកពោលនូវពាក្យសច្ច ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកចិញ្ចឹមមាតាបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ ។ សាមៈនេះ ជាបុគ្គលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិតដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចនុ៎ះ ។ បុណ្យណាមួយ ដែលខ្ញុំផង ដែលមាតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ។

(១៦៦) ទេវតានោះ បាត់អាត់ក្នុងភ្នំគន្ធមាទន៍ បានពោលនូវពាក្យសច្ចៈនេះ ដោយសេចក្ដីអនុគ្រោះសាមៈថា ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍ អស់កាលជាយូរអង្វែងហើយ ជនដទៃណាមួយ ដែលជាទីស្រឡាញ់ ដោយវិសេសរបស់ខ្ញុំជាងសាមៈទេ ដោយការពោលសច្ចៈនុ៎ះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ។ នៅភ្នំគន្ធមាទន៍ សព្វព្រៃព្រឹក្សាទាំងឡាយ សុទ្ធសឹងតែមានក្លិនក្រអូប ដោយការពោលសច្ចៈនេះសូមឲ្យពិស របស់សាមៈ សាបរលាបទៅ ។

តេសំ លាលប្បមានានំ ពហុំ ការុញ្ញសញ្ហិតំ

ខិប្បំ សាមោ សមុដ្ឋាសិ យុវា កល្យាណទស្សនោ ។

(១២៥) សាមោហមស្មិ ភទ្ទំ តេ សោត្ថិនាម្ហិ សមុដ្ឋិតោ

មា ពាឡ្ហំ បរិទេវេថ មញ្ជុនាភិវទេថ មំ ។

(១២៦) ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ

ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។

តិន្ទុកានិ បិយាលានិ មធុកេ កាសុមារិយោ

ផលានិ ខុទ្ទកប្បានិ ភុញ្ជ រាជ វរំ វរំ ។

អត្ថិ មេ បានិយំ សីតំ អាភតំ គិរិគព្ភរា

តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ ។

(១២៧) សម្មុយ្ហាមិ បមុយ្ហាមិ សព្វា មុយ្ហន្តិ មេ ទិសា

បេតន្តំ សាមមទ្ទក្ខឹ កោ នុ ត្វំ សាម ជីវសិ ។



កាលបើជនទាំងនោះ កំពុងយំរៀបរាប់នូវពាក្យ ប្រកបដោយសេចក្ដីករុណា មានប្រមាណច្រើន សាមៈជាមនុស្សកំលោះ មានរូបល្អគួរឲ្យរមិលមើល ក៏ក្រោកឡើងភ្លាម ។

[១២៥] (មហាសត្វ...) ខ្ញុំឈ្មោះសាមៈ សេចក្ដីចំរើន ចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងដោយសួស្ដីហើយ សូមលោកទាំងឡាយកុំខ្សឹកខ្សួលខ្លាំងឡើយ សូមលោកទាំងឡាយពោលចំពោះខ្ញុំ ដោយពាក្យពីរោះ ។

[១២៦] បពិត្រមហារាជ ព្រះរាជដំណើររបស់ព្រះអង្គមកល្អហើយ ទ្រង់យាងមកមិនអាក្រក់ទេ ព្រះអង្គជាម្ចាស់ទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូល ។ បពិត្រមហារាជ ផលា-ផល មានផ្លែទន្លាប់ មៈប៉ែន ស្រគំ សង្កែមានរសផ្អែមដូចទឹកឃ្មុំ ទូលបង្គំជាខ្ញុំប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផ្លែផលដែលមានរសឆ្ងាញ់ៗ ។ បពិត្រមហារាជ ទឹកសម្រាប់សោយដ៏ត្រជាក់ ទូលបង្គំជាខ្ញុំបាននាំមកអំពីជ្រោះភ្នំ បើព្រះអង្គមានសេចក្ដីត្រូវការ សូមទ្រង់ផឹកពីទឹកនោះសោយចុះ ។

[១២៧] (ព្រះបាទបិលយក្ខ...) ខ្ញុំវង្វេង ភ្លេចភាំងស្មារតី ងងឹតងងល់សព្វទិសទាំងអស់ ព្រោះបានឃើញសាមៈនោះធ្វើមរណកាលហើយ ម្នាលសាមៈ អ្នកដូចម្ដេច ក៏រស់ឡើងវិញ ។

(១២៨) អបិ ជីវំ មហារាជ បុរិសំ គាឡ្ហវេធំ
ឧបនីតមនសង្កប្បំ ជីវន្តំ មញ្ញតេ មតំ ។
អបិ ជីវំ មហារាជ បុរិសំ គាឡ្ហវេធំ
តំ ទិរាគតំ សន្តំ ជីវន្តំ មញ្ញតេ មតំ ។

(១២៩) យោ មាតរំ បិតរំ វា មច្ចោ ធម្មេន បោសតិ
ទេវាបិ នំ តិកិច្ឆន្តិ មាតាបេត្តិភរំ នរំ ។
យោ មាតរំ បិតរំ វា មច្ចោ ធម្មេន បោសតិ
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ ។

(១៣០) ឯស ភិយ្យោ បមុយ្ហាមិ សព្វា មុយ្ហន្តិ មេ ទិសា
សរណំ សាម គច្ឆាមិ ត្វញ្ច មេ សរណំ ភវ ។

(១៣១) ធម្មំ ចរ មហារាជ មាតាបិតូសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ បុត្តទារេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។



(១២៨) (មហាសត្វ...) បពិត្រមហារាជ (សត្វលោក) តែងសំគាល់នូវបុរសដែលមានវេទនាក្លៃ តែនៅរស់ ឬមានសេចក្តីត្រិះរិះក្នុងចិត្ត ធ្លាក់ចុះក្នុងកាលដ៏ ដែលនៅរស់ ថាស្លាប់ ។ បពិត្រមហារាជ មួយវិញទៀត (សត្វលោក) តែងសំគាល់នូវបុរសដែលមានវេទនាក្លៃ តែនៅរស់ ឬចូលនិរោធ នៅរស់នោះ ថាស្លាប់ហើយ ។

(១២៩) សត្វណា តែងចិញ្ចឹមនូវមាតានិងបិតាដោយធម៌ ទេវតាទាំងឡាយ តែងព្យាបាលនូវសត្វ អ្នកចិញ្ចឹមមាតាបិតានោះ ។ សត្វណា តែងចិញ្ចឹមមាតានិងបិតាដោយធម៌ បណ្ឌិតទាំងឡាយក្នុងលោកនេះឯង តែងសរសើរនូវសត្វនោះ សត្វនោះ លុះលះបង់លោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

(១៣០) (ព្រះបាទបីលយក្ស...) ខ្ញុំនឹងតែតែវង្វេង ក៏ខ្លាំងឡើង សព្វទិសានុទិស ម្នាលសាមៈ ខ្ញុំសូមយកអ្នកជាទីពឹង អ្នកចូរជាទីពឹងរបស់ខ្ញុំ ។

(១៣១) (មហាសត្វ...) បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមាតានិងបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះបុត្តនិងភរិយា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មញ្ចរ មហារាជ មិត្តាមច្ចេសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មញ្ចរ មហារាជ វាហនេសុ ពលេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មញ្ចរ មហារាជ គាមេសុ និគមេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មញ្ចរ មហារាជ រដ្ឋេសុ ជនបទេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មញ្ចរ មហារាជ សមណេសុ ព្រាហ្មណេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មញ្ចរ មហារាជ មិគបក្ខីសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។



បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមិត្តនិងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសត្វពាហនៈនិងពល បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះស្រុកនិងនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែនដីអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសមណៈនិងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះម្រឹគនិងបក្សី បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ធម៌ដែលប្រព្រឹត្តល្អហើយតែងនាំមកនូវសុខ បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

មហានិបាត តតិយំ សុវណ្ណសាមជាតកំ

ធម្មញ្ចរ មហារាជ ធម្មោ ចិណ្ណោ សុខាវហោ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មញ្ចរ មហារាជ ឥន្ទា ទេវា សព្រហ្មកា
សុចិណ្ណេន ទិវំ បត្តា មា ធម្មំ រាជ បាមទោតិ ។

សុវណ្ណសាមជាតកំ តតិយំ ។

---



មហានិបាត សុវណ្ណសាមជាតក ទី ៣

បពិត្រព្រះមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ (ព្រោះ) ទេវតានិងព្រហ្ម ដែលបានដល់ នូវឋានសួគ៌ ក៏ព្រោះធម៌ ដែលខ្លួនប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ ។

ចប់ សុវណ្ណសាមជាតក ទី ៣ ។

---

## នេមិរាជជាតកំ

(១៣២) អច្ឆេរំ វត លោកស្មឹ ឧប្បជ្ជន្តិ វិចក្ខណា
យទា អហុ និមិរាជា បណ្ឌិតោ កុសលត្ថិកោ
រាជា សព្វវិទេហានំ អទា ទានំ អរិន្ទមោ ។
តស្ស តំ ទទតោ ទានំ សង្កប្បោ ឧទបជ្ជថ
ទានំ វា ព្រហ្មចរិយំ វា កតមំ សុ មហប្ផលំ ។
(១៣៣) តស្ស សង្កប្បមញ្ញាយ មឃវា ទេវកុញ្ជរោ
សហស្សនេត្តោ បាតុរហុ វណ្ណេន វិហនំ តមំ(១) ។
សលោមហដ្ឋោ មនុជិន្ទោ វាសវំ អវចា និមិ
ទេវតា នុសិ គន្ធព្វោ អាគុ សក្កោ បុរិន្ទទោ ។
ន ច មេ តាទិសោ វណ្ណោ ទិដ្ឋោ វា យទិ វា សុតោ
អាចិក្ខ មេ ត្វំ ភទ្ទន្តេ កថំ ជានេមុ តំ មយំ ។
សលោមហដ្ឋំ ញត្វាន វាសវោ អវចា និមឹ
សក្កោហមស្មិ ទេវិន្ទោ អាគតោស្មិ តវន្តិកេ
អលោមហដ្ឋោ មនុជិន្ទ បុច្ឆ បញ្ហំ យមិច្ឆសិ ។

១ ម. ធំហន់ តមំ ។



## នេមិរាជជាតក

[១៣២] (អភិសម្ពុទ្ធគាថា) ក្នុងកាលដែលព្រះបាទនេមិ ជាបណ្ឌិត អ្នកត្រូវការដោយកុសល ជាព្រះរាជាអ្នកទូន្មាននូវសត្រូវ ទ្រង់បានឲ្យទានដល់ជនអ្នកនៅក្នុងដែនវិទេហៈទាំងឡាយគ្រប់គ្នា គ្រានោះ (មនុស្សនិងទេវតាទាំងឡាយតែងសរសើរថា) គួរអស្ចារ្យណាស់ អ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាជាគ្រឿងពិចារណា កើតឡើងក្នុងលោកហើយ ។ កាលព្រះរាជាអង្គនោះ ទ្រង់ឲ្យទាននោះ សេចក្តីត្រិះរិះកើតឡើងថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាមួយ មានផលច្រើនជាង ។

[១៣៣] ទេវរាជឈ្មោះមឃវៈ ជាទេវកុញ្ជរ ជាសហស្សនេត្រ បានជ្រាបព្រះតម្រិះរបស់ព្រះរាជានោះ ហើយមកប្រាកដ (ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា) កំចាត់បង់នូវងងឹតដោយវណ្ណៈ ។ ព្រះបាទនេមិរាជ ជាធំជាងមនុស្ស ទ្រង់ព្រឺព្រះលោមា បានសួរទេវរាជឈ្មោះវាសវៈថា អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាសក្កៈ បុរិន្ទទៈ ។ សម្បុរដូច្នោះ ខ្ញុំពុំដែលឃើញ ពុំធ្លាប់ឮឡើយ បពិត្រអ្នកដ៏ចំរើន អ្នកចូរប្រាប់ខ្ញុំ ធ្វើម្តេចយើងស្គាល់អ្នកបាន ។ ទេវរាជ ឈ្មោះវាសវៈជ្រាបថា ព្រះបាទនេមិព្រឺព្រះលោមាហើយ ទើបទូលថា ខ្ញុំជាព្រះឥន្ទ្រ ជាធំជាងទេវតា មកកាន់សំណាក់ព្រះអង្គ បពិត្រព្រះអង្គ ជាធំជាងមនុស្ស ទ្រង់កុំព្រឺព្រះលោមាឡើយ ព្រះអង្គមានសេចក្តីប្រាថ្នា ដើម្បីសួរនូវប្រស្នាណា សូមទ្រង់សួរចុះ ។

សោ ច តេន ការេន ការេសោ ភិសរិ អហោ ឆិមិ

បុច្ឆាមិ តំ មហារាជ សព្វភូតានមិស្សរ

ទានំ វា ព្រហ្មចរិយំ វា កតមំ សុ មហប្ផលំ ។

សោ បុដ្ឋោ នរទេវេន ភាសតេ អហោ ឆិមិ

វិបាកំ ព្រហ្មចរិយស្ស ជានំ អក្ខាសិ ជានតោ ។

ហីនេន ព្រហ្មចរិយេន ខត្តិយេ ឧបបជ្ជតិ

មជ្ឈិមេន ច ទេវត្តំ ឧត្តមេន វិសុជ្ឈតិ ។

ន ហេតេ សុលភា កាយា យាចយោគេន កេនចិ

យេ កាយេ ឧបបជ្ជន្តិ អនាគារា តបស្សិនោ ។



ចំណែកព្រះបាទនេមិរាជអង្គនោះ លុះព្រះអង្គត្រាស់គិត ធ្វើទានហើយ ក៏ទ្រង់ក្រាស់សួរទៅកាន់ឈ្មោះសក្កៈថា បពិត្រទេវរាជជាឥស្សរៈជាធំ សព្វសត្វទាំងឡាយ ខ្ញុំសូមសួរព្រះអង្គថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាមានផលច្រើនជាង ។ ព្រះសក្កៈនោះ ដែលព្រះបាទនេមិ ជាមនុស្សទេពសួរហើយ ក៏ឆ្លើយតបព្រះបាទនេមិវិញ ព្រះសក្កៈនោះ ក្រាបទូលផលនៃព្រហ្មចរិយៈ បានទូលព្រះបាទនេមិ ដែលមិនជ្រាបថា បុគ្គលកើតក្នុងត្រកូលក្សត្រដោយព្រហ្មចរិយៈថោកទាប(១) ដល់នូវភាពជាទេវតាដោយព្រហ្មចរិយៈជាកណ្តាល(២) បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់(៣) ។ ពួកអ្នកបួសប្រព្រឹត្តតបៈទាំងឡាយ ទៅកើតក្នុងពួកព្រហ្មណា ពួកព្រហ្មទាំងនុ៎ះ បុគ្គលអ្នកប្រកបក្នុងការសូមណាមួយមិនអាចបានសោះទេ ។

---

១-២-៣ តាមសេចក្តីយល់របស់សក្កទេវរាជ ពោលតាមលោកអដ្ឋកថាថា សីលដែលប្រព្រឹត្តរៀបតែអាត្មាប៉ុណ្ណោះ ហៅថា ព្រហ្មចរិយៈថោកទាប អាចញ៉ាំងបុគ្គលឲ្យទៅកើតក្នុងត្រកូលក្សត្រ ។ បរិយាយម្យ៉ាងទៀត ហៅថា ព្រហ្មចរិយៈជាកណ្តាល អាចញ៉ាំងបុគ្គលឲ្យទៅកើតជាទេវតា។ សមាបត្តិប្រាំបីហៅថា ព្រហ្មចរិយៈខ្ពង់ខ្ពស់ អាចញ៉ាំងបុគ្គលឲ្យទៅកើតក្នុងព្រហ្មលោក ។ ពួកតាបសរសាងតែសីលដោយព្រហ្មលោកនោះមិនទាន់ផុត ។ ក្នុងលោកសាសនា ព្រហ្មចរិយៈរបស់ភិក្ខុ ដែលមានសីលបរិសុទ្ធ តែប្រាថ្នាយកទេវនិកាយណាមួយ ជាព្រហ្មចរិយៈថោកទាប សមាបត្តិប្រាំបី ជាព្រហ្មចរិយៈកណ្តាល អរហត្តមគ្គ ជាព្រហ្មចរិយៈខ្ពង់ខ្ពស់ ។

[១៣៦] ទុទ្ទីបោ សាគរោ សេលោ មុចលិន្ទោ ភគីរសោ(១)

ឧសិន្នរោ អដ្ឋកោ(២) ច អស្សកោ ច បុថុជ្ជនោ(៣) ។

ឯតេ ចញ្ញេ ច រាជានោ ខត្តិយា ព្រាហ្មណា ពហូ

បុថុយញ្ញំ យជិត្វាន បេតត្តំ នាតិវត្តិសុ(៤) ។

[១៣៧] យេ អទុតិយា ន រមន្តិ ឯកិកា

វិវេកជំ យេ ន លភន្តិ បីតិំ

កិញ្ចាបិ តេ ឥន្ទសមានភោគា

តេ វេ បរាធីនសុខា វរាកា ។

[១៣៨] អទ្ធាយិមេ អតិវត្តិសុ(៥) អនាគារា តបស្សិនោ

សត្តិសយោ យាមហនុ សោមយាមោ មនោជវោ ។

សមុទ្ទោ មាឃោ ភរតោ(៦) ឥសិ កាលបុរក្ខតោ

អង្គីរសោ កស្សបោ ច កិសវច្ឆោ អកត្តិ(៧)ច ។

---

១ ឱ. ទុជ្ជីប្បោ ភគីរសោ ។ ទុទ្ទីប្បោ ភគីរសោតិ អដ្ឋកថា ។ ២ ឱ. ឧសិន្នរោ កស្សបោ ច ។ ៣ ម. បុថុជ្ជនោ ។ ៤ ឱ. បេតត្តំ នាតិវត្តិសុន្តិ ។ ៥ អទ្ធាយិមេ អវត្តិសុ ។ ៦ ម. ភរតោ ។ ៧ ឱ. អកិត្តិ ច ។ ម. អកត្តិ ច ។



[១៣៦] ព្រះបាទទុទ្ទីបៈ១ ព្រះបាទសាគរៈ១ ព្រះបាទសេលៈ១ ព្រះបាទមុចលិន្ទ១ ព្រះបាទភគីរសៈ១ ព្រះបាទឧសិន្នរៈ១ ព្រះបាទអដ្ឋកៈ១ ព្រះបាទអស្សកៈ១ ព្រះបាទបុថុជ្ជនៈ១ ។ ព្រះរាជាទាំងឡាយអន្លើនេះក្តី ព្រះរាជាទាំងឡាយដទៃក្តី ពួកក្សត្រ ពួកព្រាហ្មណ៍ជាច្រើនក្តី ដែលបូជានូវគ្រឿងយញ្ញ យ៉ាងច្រើន មិនប្រព្រឹត្តកន្លងនូវបេតភាព (ការជាប្រេត) ឡើយ ។

[១៣៧] ជនទាំងឡាយណា មិនមានគូ ជាបុគ្គលម្នាក់ឯង ហើយមិនត្រេកអរ (ត្រេកអរតែក្នុងការនៅប្រមូលប្រជុំដោយពួក) ជនទាំងឡាយណា មិនបានបីតិ ដែលកើតអំពីវិវេក ជនទាំងឡាយនោះ ទុកជាមានភោគៈស្មើដោយព្រះឥន្ទ ក៏ដោយចុះ ជនទាំងឡាយនោះ ក៏ឈ្មោះថាជាបុគ្គលកំសត់ មានសេចក្តីសុខព្រោះការអាស្រ័យនូវបុគ្គលដទៃដោយពិត ។

[១៣៨] ឥសី ៧ អង្គនេះ គឺឥសីឈ្មោះយាមហនុ១ សោមយាគៈ១ មនោជវៈ១ សមុទ្ទៈ១ មាឃៈ១ ភរតៈ១ ឥសីឈ្មោះកាលបុរក្ខិតៈ១ គឺឥសីទាំងឡាយ ៤ អង្គ គឺ ឥសីឈ្មោះអង្គីរសៈ១ កស្សបៈ១ កិសវច្ឆៈ១ អកត្តិ១ ជាអនាគារបុគ្គល មានតបៈជាធំ ផុតកន្លង (ការជាប្រេត) ដោយពិត ។

(១៣៧) ទក្ខិណេន នទី សីតា   គម្ភីរា ទុរតិក្កមា

នឡគ្គិវណ្ណា(*) ជោតន្តិ   សទា កញ្ចនបព្ពតា ។

បរូឡ្ហកច្ឆា តគរា   បរូឡ្ហកច្ឆា វនា នគា

តត្រាស្សុំ ទសសហស្សា   បោរាណា ឥសយោ បុរេ ។

អហំ សេដ្ឋោស្មិ ទានេន   សញ្ញមេន ទមេន ច

អនុត្តរំ វតំ កត្វា   បកិរចារី សមាហិតេ ។

ជាតិមន្តំ អជច្ចញ្ច   អហំ ឧជុគតំ នរំ

អតិវេលំ នមស្សិស្សំ   កម្មពន្ធូ ហិ មាណវា ។

សព្វេ វណ្ណា អធម្មដ្ឋា   បតន្តិ និរយំ អធោ

សព្វេ វណ្ណា វិសុជ្ឈន្តិ   ចរិត្វា ធម្មមុត្តមំ ។

(១៣៨) ឥទំ វត្វាន មឃវា   ទេវរាជា សុជម្បតិ

វេទេហមនុសាសិត្វា   សគ្គកាយំ អបក្កមិ ។

* ម. នឡគ្គិវណ្ណាតិ បាឋោ [illegible] ទិស្សតិ ។





(១៣៧) នៅប្រទេសខាងត្បូងនៃទិស មានស្ទឹងឈ្មោះសីតា មានជម្រៅដ៏ជ្រៅ ឆ្លងដោយកម្រ (ចំពោះខាងនៃស្ទឹងនោះ) មានភ្នំមាស ពណ៌ដូចភ្លើងឆេះ ភ្លឺរុងរឿងសព្វ ៗ កាល ។ (ទៀបឆ្នេរនៃស្ទឹងនោះ) សឹងមានដើមក្រស្នាល្អលាស់ខ្ពស់ខ្ពង់ មានចំណីព្រៃជាតិផ្សេងៗ មានរុក្ខល្អលាស់ [illegible] ក្នុងកាលមុន មានពួកឥសីចាស់ៗ មួយម៉ឺននាក់ នៅក្នុងទីនោះឯង ។ ខ្ញុំជាបុគ្គលប្រសើរដោយការឲ្យទាន ការប្រព្រឹត្តល្អ ដោយការសង្រួមនិងការទូន្មាន (ខ្លួនឯង) ហើយប្រព្រឹត្ត (ម្នាក់ឯង) លះបង់ (ភូត) ជាអ្នកមានចិត្តតាំងមាំ ។ ខ្ញុំមិនគោរពនូវជនអ្នកមានជាតិខាងផ្ទៃមានជាតិខ្ពស់ ខមស្ការចំពោះជន អ្នកមានចិត្តត្រង់ មិនមានកំណត់កាលវេលាឡើយ ព្រោះថា សត្វទាំងឡាយមានកម្មជាផៅពង្ស ។ វណ្ណៈ(*)ទាំងអស់ អ្នកមិនតាំងនៅក្នុងធម៌ រមែងធ្លាក់ចុះក្នុងនរក ជាខាងក្រោម វណ្ណៈទាំងអស់ បានប្រព្រឹត្តធម៌ដ៏ឧត្តមហើយ រមែងបរិសុទ្ធ ។

(១៣៨) មឃវទេវរាជ សុជម្បតិ ទ្រង់ពោលពាក្យនេះ ទ្រង់ប្រៀនប្រដៅព្រះបាទនេមិរាជក្នុងដែនវិទេហៈ រួចហើយទ្រង់ចៀសចេញទៅកាន់ពួកទេវតាក្នុងឋានសួគ៌ ។

* សំដៅយក ក្សត្រិយ៍, ព្រាហ្មណ៍, វេស្សៈ និង សូទ្រៈ ។

(១៥៩) ឥមំ ភោន្តោ និសាមេថ យាវន្តេត្ថ សមាគតា

ធម្មិកានំ មនុស្សានំ វណ្ណំ ឧច្ចាវចំ ពហុំ ។

យថា អយំ និមិរាជា បណ្ឌិតោ កុសលត្ថិកោ

រាជា សព្វវិទេហានំ អទា ទានំ អរិន្ទមោ ។

តស្ស តំ ទទតោ ទានំ សង្កប្បោ ឧទបជ្ជថ

ទានំ វា ព្រហ្មចរិយំ វា កតមំ សុ មហប្ផលំ ។

(១៦០) អព្ភុតោ វត លោកស្មិំ ឧប្បជ្ជិ លោមហំសនោ

ទិព្វោ រថោ បាតុរហុ វេទេហស្ស យសស្សិនោ ។

(១៦១) ទេវបុត្តោ មហិទ្ធិកោ មាតលិ ទេវសារថិ

និមន្តយិត្ថ រាជានំ វេទេហំ មិថិលគ្គហំ ។

ឯហិមំ រថមារុយ្ហ រាជសេដ្ឋ ទិសម្បតិ

ទេវា ទស្សនកាមា តេ តាវតឹសា សឥន្ទកា

សរមានា ហិ តេ ទេវា សុធម្មាយំ សមច្ឆរេ ។



(១៥៩) (ព្រះឥន្ទ្រ...) ម្នាលអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយទាំងប៉ុន្មានដែលបានមកប្រជុំគ្នាហើយក្នុងទីនេះ ចូរចាំស្ដាប់នូវគុណខ្ពស់និងទាប (១) មានប្រមាណច្រើននេះ របស់មនុស្សទាំងឡាយ អ្នកប្រកបដោយធម៌ ។ ដូចជាព្រះបាទនេមិរាជនេះ ជាបណ្ឌិត ជាអ្នកត្រូវការដោយកុសល ជាព្រះរាជាខ្ចាត់ខ្ចាយសត្រូវ បានឲ្យទានដល់អ្នកដែនវិទេហៈទាំងឡាយគ្រប់ៗគ្នា ។ កាលដែលព្រះរាជាអង្គនោះ កំពុងឲ្យនូវទាននោះ សេចក្ដីត្រិះរិះកើតឡើងថា ទានក្ដី ព្រហ្មចរិយៈក្ដី កុសលណា មានផលច្រើនជាង ។

(១៦០) (មហាជន...) ឱហ្ន៎ សេចក្ដីព្រឺរោម មិនធ្លាប់កើតមាន ក៏កើតឡើងហើយក្នុងលោក រថទិព្វកើតប្រាកដហើយ ដល់ព្រះបាទវិទេហៈ មានយស ។

(១៦១) (អភិសម្ពុទ្ធគាថា) មាតលិទេវបុត្រ អ្នកមានឫទ្ធិច្រើន ជាទេវសារថី បានអញ្ជើញព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលាថា ។ បពិត្រព្រះរាជា ដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងមក ទ្រង់ស្ដេចឡើងកាន់រថនេះ ដ្បិតទេវតាទាំងឡាយ នៅឋានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ ចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយនោះ រឭកនឹក (ព្រះអង្គ) ក៏កំពុងនៅប្រជុំក្នុងធម្មសភា ឈ្មោះសុធម្មា ។

---

១ សព្ទថាខ្ពស់ សំដៅយកសីលជាដើមដ៏ខ្ពង់ខ្ពស់ ទាបជាគុណទាប ។ អដ្ឋកថា ។

(១៦២) ឥតោ ភដា តរមានោ វេទេហោ មិថិលគ្គហោ

អាសនា វុដ្ឋហិត្វាន បមុខោ រថមារុហិ ។

អភិរុឡ្ហំ រថំ ឋិតំ មាតលិ ឯតទព្រវិ

កេន តំ នេមិ មគ្គេន រាជសេដ្ឋ ទិសម្បតិ

យេន វា បាបកម្មន្តា បុញ្ញកម្មា ច យេ នរា ។

(១៦៣) ឧភយេនេវ មំ នេហិ មាតលិ ទេវសារថិ

យេន វា បាបកម្មន្តា បុញ្ញកម្មា ច យេ នរា ។

(១៦៤) កេន តំ បឋមំ នេមិ រាជសេដ្ឋ ទិសម្បតិ

យេន វា បាបកម្មន្តា បុញ្ញកម្មា ច យេ នរា ។

(១៦៥) និរយេ តាវ បស្សាមិ អាវាសេ បាបកម្មិនំ

ឋានានិ លុទ្ទកម្មានំ ទុស្សីលានញ្ច យា គតិ ។

(១៦៦) ទស្សេសិ មាតលិ រញ្ញោ ទុគ្គំ វេតរណឹ នទឹ

កុថិតំ ខារសំយុត្តំ តត្តំ អគ្គិសិខូបមំ ។



(១៦២) លំដាប់នោះ ព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលា ទ្រង់ស្ទុះក្រោកចាកអាសនៈ បែរព្រះភក្ត្រឡើងកាន់រថ ។ មាតលិទេវបុត្រ ទូលសួរព្រះបាទនេមិរាជ ដែលស្តេចឡើងកាន់រថរួចហើយថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំនាំព្រះអង្គទៅតាមផ្លូវណា តាមផ្លូវដែលសត្វមានបាបកម្ម ឬតាមផ្លូវដែលសត្វមានបុញ្ញកម្ម ។

(១៦៣) (ព្រះបាទនេមិ...) ម្នាលមាតលិទេវសារថី អ្នកចូរនាំខ្ញុំទៅតាមផ្លូវទាំងពីរ គឺផ្លូវដែលសត្វមានបាបកម្មផង ផ្លូវដែលសត្វមានបុញ្ញកម្មផង ។

(១៦៤) (មាតលិ...) បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំនាំព្រះអង្គទៅតាមផ្លូវណាមុន តាមផ្លូវដែលសត្វមានបាបកម្មមុន ឬតាមផ្លូវដែលសត្វមានបុញ្ញកម្មមុន ។

(១៦៥) (ព្រះបាទនេមិ...) ខ្ញុំចង់ឃើញនរកជាទីនៅនៃសត្វអ្នកមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញឋាននៃសត្វអ្នកមានកម្មលាមក និងគតិនៃសត្វទ្រុស្តសីលទាំងឡាយមុន ។

(១៦៦) (អភិសម្ពុទ្ធគាថា) មាតលិទេវសារថី បង្ហាញព្រះរាជានូវស្ទឹងវេតរណី ដែលសត្វឆ្លងបានដោយកម្រ ប្រកបព្រមដោយទឹកក្តៅប្រឡាក់កំបោរ ក្តៅដូចអណ្តាតភ្លើង ។

(១៦៧) នេមិ ហវេ មាតលិមជ្ឈភាសិ(១)
ទិស្វា ជនំ បតមានំ វិទុគ្គេ
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា វេតរណឹ បតន្តិ ។

(១៦៨) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
យេ ទុព្ពលេ ពលវន្តា ជីវលោកេ
ហឹសេន្តិ រោសេន្តិ សុបាបធម្មា
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា វេតរណឹ បតន្តិ ។

(១៦៩) សាមា ច សោណា សពលា ច គិជ្ឈា
កាកោលសង្ឃា ច អទន្តិ ភេរវា
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនេ កាកោលសង្ឃា អទន្តិ ។

១ ឱ. ម. មាតលឹ អជ្ឈភាសិ ។



(១៦៧) ព្រះបាទនេមិ ទ្រង់ឃើញសត្វកំពុងធ្លាក់ទៅ ក្នុងស្ទឹងវេតរណីជាទីទុគ៌ឡើងបានដោយកម្រក្រៃលែង ហើយត្រាស់សួរមាតលិទេវសារថីថា ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ (សត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី) ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយនេះធ្លាក់ទៅកាន់ស្ទឹងវេតរណី តើពួកសត្វនេះ បានធ្វើបាបកម្មអ្វី ។

(១៦៨) មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយក៏ព្យាករផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជាទេវដែលមិនទ្រង់ជ្រាបថា ពួកសត្វណា មានកំឡាំងមានឥទ្ធិពលមក បៀតបៀនប្រទេចផ្តាសា នូវពួកសត្វដែលមានកំឡាំងខ្សោយ ក្នុងជីវលោក ពួកសត្វមានកម្មលាមកនោះរមែងធ្វើបាប ពួកសត្វទាំងនោះឯង តែងធ្លាក់ទៅកាន់ស្ទឹងវេតរណី ។

(១៦៩) (ព្រះបាទនេមិ...) ពួកឆ្កែក្រសម្បុរក្រហម និងពពាល ពួកត្មាត ពួកក្អែក ជាសត្វគួរខ្លាច តែងចឹកស៊ី (សត្វនរក ដែលក៏ប្រទះឃើញ) ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ហ្វូងក្អែកតែងចឹកស៊ីនូវសត្វទាំងឡាយនេះ តើសត្វទាំងឡាយនេះបានធ្វើបាបដូចម្តេច ។

(១៨០) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
យេ កេចិមេ មច្ឆរិនោ កទរិយា
បរិភាសកា សមណព្រាហ្មណានំ
ហឹសេន្តិ រោសេន្តិ សុទាបជម្មា
តេ លុទ្ធកម្មា បសវេត្វ បាបំ
តេមេ ជនេ កាកោលសង្ឃា អទេន្តិ ។

(១៨១) សញ្ជោតិភូតា បឋវឹ កមន្តិ
តត្តេហិ ខន្ធេហិ ច បោថយន្តិ
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា ខន្ធហតា សយន្តិ ។

(១៨២) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។





(១៨០) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃកម្មដែលខ្លួនដឹង ចំពោះព្រះរាជាដែលមិនទ្រង់ជ្រាបថា សត្វទាំងឡាយណាមួយ មានសេចក្តីកំណាញ់ កំណាញ់ស្វិតស្វាញ មានធម៌លាមកអាក្រក់ ជាអ្នកជេរប្រទេចបៀតបៀន ប្រទូស្តសមណព្រាហ្មណ៍ សត្វអ្នកមានកម្មលោភទាំងនោះ រមែងសាងបាប ទើបហ្វូងក្អែកនិងក្អែកស៊ីសត្វទាំងឡាយនោះ ។

(១៨១) (ព្រះរាជា ...) សត្វនរកទាំងឡាយ មានសរីរៈឆេះសព្វសព្វទៅ ដើរលើផែនដីដែក ដែលនាយនិរយ-បាលសំពង ដោយដំបងដែកទាំងឡាយ ដែលភ្លើងឆេះ ម្នាលទេវបុត្រ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលវាយដោយដំបង ដួលដេកនេះ តើពួកសត្វទាំងនេះ បានធ្វើបាបអ្វីទុក ។

(១៨២) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលបាបកម្មដែលខ្លួនដឹង ចំពោះព្រះរាជាដែលមិនទ្រង់ជ្រាបថា

យេ ជីវលោកស្មឹ សុបាបធម្មិនោ
នរញ្ច នារិញ្ច អបាបធម្មឹ
ហឹសេន្តិ រោសេន្តិ សុបាបធម្មា
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា ខុទ្ទហតា សយន្តិ ។
(១៨៣) អង្គារកាសុំ អបរេ ផុនន្តិ
នរា រុទន្តា បរិទឌ្ឍគត្តា
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា អង្គារកាសុំ ផុនន្តិ ។
(១៨៤) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
យេ កេចិ បូគាយ ធនស្ស ហេតុ
សក្ខឹ ករិត្វា ឥណំ ជាបយន្តិ
តេ ជាបយិត្វា ជនតំ ជនិន្ទ
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា អង្គារកាសុំ ផុនន្តិ ។





ជនទាំងឡាយមានបាបធម៌ ពេញបន្ទុក បៀតបៀនប្រទេចផ្តាសា នូវបុរសស្ត្រីដែលឥតបាបធម៌ ក្នុងជីវលោក ឈ្មោះថាជាអ្នកមានបាបធម៌ពេញបន្ទុក ជនអ្នកមានកម្មលាមកទាំងនោះ រមែងកើតបាប ជនទាំងឡាយនោះឯងហើយ ដែលនាយនិរយបាលបៀតបៀនដោយដំបង ដួលដេកនៅ ។

(១៨៣) (ព្រះពោធិ...) ពួកសត្វនរកដែលមានខ្លួនឆេះជុំវិញ ក៏ពុំខ្ញុញយំ (ធ្លាក់ទៅ) កាន់រណ្តៅរងើកភ្លើងហើយដុត ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយដែលធ្លាក់ទៅកាន់រណ្តៅរងើកភ្លើង ហើយដុត តើពួកសត្វទាំងឡាយនេះ បានធ្វើបាបដូចម្តេច ។

(១៨៤) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ក្រាបទូលផលនៃបាបកម្មដែលខ្លួនដឹងហើយ ចំពោះព្រះរាជាដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ពោលពាក្យសាក្សី (កោង) ក្នុងហេតុនៃទ្រព្យរបស់ប្រជុំជន ហើយញ៉ាំងទ្រព្យជាបំណុលរបស់ឲ្យវិនាស បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះញ៉ាំងពួកជនឲ្យវិនាសហើយ ជនទាំងឡាយអ្នកមានកម្មដ៏លាមកនោះ រមែងកើតបាប ទើបជនទាំងឡាយនោះឯង (ធ្លាក់ទៅ) កាន់រណ្តៅរងើកភ្លើង ហើយដុតខ្លួន ។

(១៩៥) សញ្ជោតិភូតា ផលិកា បទិត្តា
បទិស្សតិ មហតី លោហកុម្ភី
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ (៨៣) អវំសិរា លោហកុម្ភឹ បតន្តិ ។

(១៩៦) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
យេ សីលវន្តំ សមណំ ព្រាហ្មណំ វា
ហឹសេន្តិ រោសេន្តិ សុបាបធម្មា
តេ លុទ្ទកម្មា បសវេត្វា បាបំ
តេមេ ៨៣ (អវំសិរា) លោហកុម្ភឹ បតន្តិ ។

(១៩៧) លុញ្ចន្តិ គីវំ អថ វេឋយិត្វា
ឧណ្ហោទកស្មឹ បកិលោទយិត្វា(១)
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា លុត្តសិរា សយន្តិ ។

១ ម. បកិលោទយិត្វា ។ បកិលេទយិត្វា ឥតិបាឋោ ទិស្សតិ ។



(១៩៥) (ព្រះរាជា...) ខ្ទះទង់ដែងធំ មានភ្លើងឆេះ សន្ធោសន្ធៅ ក្តៅព្រាលឆ្អៅ ប្រាកដជាក់ស្តែង ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ខ្ទះពេញដោយទឹកទង់ដែង តើពួកសត្វទាំងនេះធ្វើបាបដូចម្តេច ។

(១៩៦) មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករ នូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ដល់ព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណាមានធម៌ដ៏លាមកពេក បៀតបៀនប្រទូស្តចំពោះ នូវសមណៈ ឬព្រាហ្មណ៍អ្នកមានសីល ជនអ្នកមានកម្មដ៏លាមកទាំងឡាយនោះ តែងកើននូវបាប ជនទាំងនោះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ខ្ទះពេញដោយទឹកទង់ដែង ។

(១៩៧) (ព្រះរាជា...) ពួកនាយនិរយបាល ក្រៀវដងកនៃសត្វនរក ហើយកាប់ពន្លះបោះទៅក្នុងទឹកក្តៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វដែលមានក្បាលដាច់ ហើយដេកនៅនេះ តើសត្វពួកនេះ បានធ្វើបាបដូចម្តេច ។

(១៨៨) តស្ស បុដ្ឋោ វិយាកាសិ    មាតលិ ទេវសារថិ

វិបាកំ បាបកម្មានំ    ជានំ អក្ខាសិជានតោ ។

យេ ជីវលោកស្មិំ សុបាបធម្មិនោ

បក្ខី គហេត្វាន វិហេឋយន្តិ

តេ ហេឋយិត្វា សកុណេ(១) ជនិន្ទ

តេ លុទ្ទកម្មា បសវេត្វា បាបំ

តេមេ ជនា លុត្តសិក សយន្តិ ។

(១៨៩) ពហុទកោ យា អតិខាតកូលា(២)

នទី អយំ សន្ទតិ សុប្បតិត្ថា

ឃម្មាភិតត្តា មនុជា បិវន្តិ

បិវតញ្ច តេសំ ភុស ហោតិ ខារិ

ភយំ ហិ មំ វិន្ទតិ សូត ទិស្វា

បុច្ឆាមិ តំ មាតលិ ទេវសារថិ

ឥមេ នុ មច្ចា កិមកំសុ បាបំ

បិវតញ្ច តេសំ ភុស ហោតិ ខារិ

---

១ ម. ជនស្ស ។ ២ ម. អតិខារកូលា ។





(១៨៨) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករ នូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកមានបាបធម៌ពេញបន្ទុក តែងចាប់បៀតបៀន នូវសត្វស្លាបទាំងឡាយ បពិត្រព្រះរាជដ៏ជាធំជាងជន ជនទាំងឡាយនោះ បៀតបៀនហើយនូវសត្វស្លាប ពួកជនអ្នកមានកម្មឃោរឃៅនោះ រមែងធ្វើនូវបាប ជនទាំងឡាយនោះ មានក្បាលដាច់ ហើយដេកនៅក្នុងនេះ ។

(១៨៩) (ព្រះរាជា ...) ស្ទឹងនេះ មានទឹកច្រើន មានច្រាំងមិនជ្រៅ មានកំពង់ល្អរាបហូរទៅ សត្វដែលមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយតែងផឹក ស្រាប់តែទឹកដែលសត្វទាំងឡាយនោះផឹកហើយក្លាយទៅជាអង្កាម ម្នាលទេពបុត្រ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះទឹកដែលសត្វទាំងឡាយនោះ ផឹកហើយ ក្លាយទៅជាអង្កាមវិញ ពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

(១៦០) កស្ស បុប្ផា វិយាកាសិ មាគលិ នេរសារជិ

វិជាកំ ជាយកម្មានំ ជាតំ អគ្គាសិជាតវោ ។

យេ សុទ្ធញ្ញំ បលាសេន មំសំ

អសុទ្ធកម្មា កាយំហោ ឆឆន្តិ

យម្មាកិតត្តាន បិតាសិតានំ

បំតេញ្ញ គេសំ ជុស ហោតិ ឋានំ ។

(១៦១) ទុស្សហំ សត្តិហំ ច តោមរេហិ

ទុកយានិ បសន្តិ តុឆន្តិ កាទ្ធតិ

ភយំ ហំ មំ វិន្ទតិ សុត និស្សា

បុញ្ញាម៉ំ តំ មាគលិ នេរសារជិ

នេម ទុ មច្ចា កិមកាំសុ ជាបំ

យោមេ ជនា សត្តិហតា សយន្តិ ។

(១៦២) កស្ស បុប្ផា វិយាកាសិ មាគលិ នេរសារជិ

វិជាកំ ជាយកម្មានំ ជាតំ អគ្គាសិជាតវោ ។



(១៦០) នាគលិនេរសាជី ដែលព្រះបាទទេមិយសួរហើយ កំ
ណត់ការ នូវផលនៃបាបកម្មដែលខ្លួនជួបហើយ ទូលព្រះករុណា
នោះដែលមិនគួរជាប្រាថ្នា ។ ជនតាំងឡាយណា ក្នុងមាន
កិច្ចការមិនបរិសុទ្ធ លាយនូវស្រូវស្រួងដោយអង្កាម ឲ្យផល
អ្នកទិញ បានជាទឹកដែលជនតាំងឡាយនោះ កំពុងមាន
សេចក្តីក្តៅរៀករៀង មានសេចក្តីស្រេកឃ្លានត្រូវសង្កត់
ហើយ ដឹកទៅ ក្លាយជាអង្កាមវិញ ។

(១៦១) (ព្រះករុណា...) នាយនិរយបាល តាំងឡាយ ចាក់នូវ
សរីរៈ តាំងពីខាងនៃសត្វនោះ ដែលកំពុងកន្ត្រាក់ក្រេញ
ដោយព្រួញតាំងឡាយក៏មាន ដោយលំពែងតាំងឡាយក៏
មាន ដោយលំពែងស្នងក្របីតាំងឡាយក៏មាន ខ្ញុំព្រះ
ទេសប្រេ៊ី សេចក្តីភ័យមានដល់ខ្ញុំព្រោះឃើញ ខ្លាលនាគ-
លីនេរសាជី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលបៀក
បៀនហើយដោយលំពែង ដេកទៅផ្ងារ ក៏ពួកសត្វតាំង
នេះ បានធ្វើនូវបាបដូចម្តេច ។

(១៦២) នាគលី នេរសាជី ដែលព្រះបាទទេមិយសួរហើយ
កំណត់ការ នូវផលនៃបាបកម្មតាំងឡាយ ដែលខ្លួនជួប
ហើយទូលព្រះករុណានោះ ដែលមិនគួរជាប្រាថ្នា ។

យេ ជីវលោកស្មិំ អសាធុកម្មិនោ
អទិន្នមាទាយ ករោន្តិ ជីវិកំ
ធញ្ញំ ធនំ រជតំ ជាតរូបំ
អជេឡកញ្ចាបិ បសុំ មហឹសំ
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា សត្តិហតា សយន្តិ ។

(១៦៣) កឹកាយ ពន្ធា កិស្សុមេ មុខេក
អញ្ញេ វិកន្តា វិលកាកា សយន្តិ
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា វិលកាកា សយន្តិ ។

(១៦៤) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
ឱរព្ភិកា សូការិកា ច មច្ឆិកា
បសុំ មហឹសញ្ច អជេឡកញ្ច
ហន្ត្វាន សូណេសុ បសារយឹសុ



ជនទាំងឡាយណា ក្នុងជីវលោក ជាអ្នកមានកម្មមិនល្អ លួចយកស្រូវ ទ្រព្យ ប្រាក់ មាស ព្រមទាំងសត្វចិញ្ចឹម គឺពពែ ចៀមនឹងក្របី ដែលគេមិនឲ្យ ហើយធ្វើនូវការចិញ្ចឹមជីវិត ជនអ្នកមានកម្មដ៏សាហាវទាំងនោះ រមែងតែងនូវបាប ទើបពួកជនទាំងនោះ ត្រូវនាយនិរយបាលចៀតចៀនហើយ ដោយលំពែង ដេកនៅផ្ងារ ។

(១៦៣) (ព្រះរាជា...) ហេតុអ្វី សត្វនរកទាំងឡាយនេះ មួយពួកត្រូវនាយនិរយបាលចងកខ្ពស់ ពួកដទៃត្រូវនាយនិរយ-បាលចិញ្ច្រាំ ពួកដទៃទៀតត្រូវនាយនិរយបាលធ្វើឲ្យខ្ទេច-ខ្ទី ផ្ងារដេកនៅ ម្នាលទេវបុត្រ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ជនទាំងឡាយដែលនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ហើយផ្ងារដេកនៅ តើពួកជនទាំងនោះ បានធ្វើនូវបាបដូចម្ដេច ។

(១៦៤) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ចំពោះព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ជាអ្នកសម្លាប់ក្របី សម្លាប់ជ្រូក សម្លាប់ត្រី សម្លាប់សត្វចិញ្ចឹម គឺក្របី ពពែនឹងចៀម ហើយដាក់លក់ក្នុងផ្សារលក់សាច់

តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា វិលោមកា សយន្តិ ។

(១៦៨) រហទោ អយំ មុត្តករីសបូរោ
ទុគ្គន្ធរូបោ អសុចិ បូតិ វាតិ
ខុទ្ទាបរេតា មនុជា អទេន្តិ
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា មុត្តករីសភក្ខា ។

(១៦៩)តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
យេ កេចិមេ ការណិកា វិរោសកា
បរេសំ ហិំសាយ សទា និវិដ្ឋា
តេ លុទ្ទកម្មា បសវេត្វ បាបំ
មិត្តទ្ទុនោ មីឡ្ហមទេន្តិ ពាលា ។



ជនអ្នកមានកម្មអាក្រក់ទាំងនោះ តែងដេកដួល ចុងជាដង
ទាំងនោះ ត្រូវនាយនិរយបាលឆ្ការខ្ទេចខ្ទី ហើយដេកនៅ ។

(១៦៨)(ព្រះរាជា ..)អន្លង់នេះ ពេញទៅ ដោយមូត្រនឹងករីស
មានក្លិនអាក្រក់ មិនស្អាត ស្អុយផ្សាយទៅ ពួកជនអ្នកមាន
សេចក្ដីស្រេកឃ្លានគ្របសង្កត់ហើយ ស៊ី(នូវមូត្រនឹងករីស
នេះ)ម្នាលទេវតាបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាល
មាតលីទេវសារថី ខ្ញុំសួរអ្នក ពួកជនអ្នកបរិភោគនូវមូត្រ
នឹងករីសនេះ តើពួកជនទាំងនេះ បានធ្វើនូវបាបដូចម្ដេច ។

(១៦៩) មាតលីទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏
ក្រាបទូលផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះ
រាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ
ជាអ្នកបង្កសេចក្ដីទុក្ខ អ្នកបៀតបៀនមិត្រសំឡាញ់ អ្នក
ទាំងនោះក៏តែងបៀតបៀន នូវជនដទៃសព្វៗកាល ពួកជន
ទាំងឡាយ មានកំហឹងមកនោះ រមែងដឹងចុះ ជនពាល
ទាំងឡាយជាអ្នកប្រទូស្តមិត្តនោះ តែងស៊ីអាចម៍ជានិច្ច ។

[១៦៧] រហទោ អយំ លោហិតបុព្វបូរោ
ទុគ្គន្ធរូបោ អសុចិ បូតិ វាតិ
ឃម្មាភិតត្តា មនុជា បិវន្តិ
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា លោហិតបុព្វភក្ខា ។

[១៦៨] តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
យេ មាតរំ វា បិតរំ វា ជីវលោកេ
បារាជិកា អរហន្តេ ហនន្តិ
តេ លុទ្ទកម្មា បសវេត្វា បាបំ
តេមេ ជនា លោហិតបុព្វភក្ខា ។

[១៦៩] ជិវ្ហញ្ច បស្ស ពឡិសេន វិទ្ធំ
វិហតំ យថា សង្កុសតេន ចម្មំ
ផន្ទន្តិ មច្ឆាវ ថលម្ហិ ខិត្តា
មុញ្ចន្តិ ខេឡំ រុទមានា កិមេតេ



(១៦៧) (ព្រះរាជា ...) អន្លង់នេះ ពេញដោយឈាមនិងខ្ទុះ មានក្លិនអាក្រក់ មិនស្អាត ស្អុយផ្សាយទៅ ពួកសត្វដែលក្តៅក្រហាយក្រៃពេកហើយ ផឹក (ឈាមនិងខ្ទុះនោះ) ម្នាលទេវសារថី ភ័យមកដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានឈាមនិងខ្ទុះជាអាហារនេះ គឺពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

(១៦៨) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ចំពោះព្រះរាជាដែលមិនជ្រាបថា ជនទាំងឡាយណាក្នុងជីវលោកនេះ សម្លាប់ព្រះអរហន្ត គឺជាការប្តូចិត ឈ្មោះថាបារាជិក (ក្នុងភាពជាគ្រហស្ថ) ពួកជនអ្នកមានចិត្តអាក្រក់នោះ តែងតែធ្វើបាប ជនទាំងនោះមានឈាមនិងខ្ទុះជាអាហារ ។

(១៦៩) (ព្រះរាជា...) អ្នកចូរមើលនូវសត្វនរក មានអណ្តាតមុតដោយសន្ទូច ចំដូចស្បែកដែលគេខ្ទាស់ដោយកញ្ញើរ ញាប់ញ័រដូចត្រី ដែលគេបោះទៅលើគោក ព្រោះហេតុអ្វី បានជាសត្វនរកទាំងនេះ យំបង្ហៀរទឹកមាត់

កយិំ ហិ មេ វិត្តិ សុត ទិស្វា
បុញ្ញាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា វេត្តរណ្យា សយន្តិ ។

(១៧០) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។

យេ តេធ សណ្ហានកគ មនុស្សា
អពេ្យន អក្សំ កាយំ(១) ហេឋយន្តិ
ក្រូជេន ក្រូរំ ជនលោកហេតុ
ធន្ធំ យថា ភរិចរំ វិជាយ ។
ន ហិ ក្រូរធារិស្ស ករន្តិ តាណា
សតោហិ កម្មេហិ បុរក្ខិតស្ស
តេ លុទ្ធកម្មា បសវេត្វ បាបំ
តេមេ ជនា វេត្តរណ្យា សយន្តិ ។

(១៧១) ជារិយោ ឥមា សម្បរិភិន្នគត្តា
បក្កុយា ភន្ទន្តិ កុជេ ធុជប្ផា(២)
សមក្ខិកា លោហិតបុព្វលិត្តា

១ ឱ. ពស់ ។ ២ អគ្គិកាល់ បនរុធិក្តាទិ ទំស្បូតិ ។



ព្រឺរោមប្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិ
ទេវសារថី ខ្ញុំសួរលោក ពួកជនដែលស៊ីសន្ធូបដេកទៅ តើ
ពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច ។

(១៧០) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ក្រាប
ទូលផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ
ដែលមិនទ្រង់ជ្រាបថា មនុស្សទាំងឡាយណាមួយ បៀត
នៅក្នុងលោកនេះ ជាអ្នកកាត់ថ្លៃទំនិញ ញ៉ាំងទំនិញដែល
មានថ្លៃ ឲ្យសាបសូន្យតម្លៃ (បន្ថោកទំនិញគេ) ប្រកប
ដោយអំពើកាច ធ្វើអំពើកាច ព្រោះហេតុបើបានទ្រព្យ
ប៉ុនជាសន្ធូបដែលគេចិញ្ចឹម (ដោយខុស) ដើម្បី
សម្លាប់ត្រី ។ ទីពឹងរបស់អ្នកធ្វើនូវអំពើកាច ជាបុគ្គល
ដែលកម្មរបស់ខ្លួនបៀតបៀនហើយមិនមានទេ ពួកជនអ្នកមាន
អំពើលាមកនោះ តែងដេកចុះ បានជាពួកជនទាំងនោះ ជា
អ្នកស៊ីសន្ធូបដេកទៅ ។

(១៧១) (ព្រះរាជា ...) ពួកស្ត្រីទាំងនេះ មានខ្លួនដាច់
រុះរី មានជាតិកក្រាក់ មានខ្លួនប្រឡាក់ ពាស
ពេញ ដោយឈាមនិងខ្ទុះ មានខ្លួនដាច់ រយះរយាយ

កាកេ យថា អាយាតនេ វិកណ្ណា
តា ភូមិភាគស្មិំ សទា និខាតា
ទុក្ខាតិវត្តន្តិ សជោតិភូតា ។
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមា នុ នារិយោ កិមកំសុ បាបំ
យា ភូមិភាគស្មិំ សទា និខាតា
ទុក្ខាតិវត្តន្តិ សជោតិភូតា ។

(៦៧៦)តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
កោលិត្ថិយាយោ ឥធ ជីវលោកេ
អសុទ្ធកម្មា អសតំ អចារុំ
តា ទិត្តរូបា[១] បតិ វិប្បហាយ
អញ្ញំ អចារុំ រតិខិឌ្ឌហេតុ
តា ជីវលោកស្មិំ រមាបយិត្វា
ទុក្ខាតិវត្តន្តិ សជោតិភូតា ។

១ ម. ទិដ្ឋរូបា ។



បក្សីក្អែកទាំងឡាយ ដែលគេពន្ធនាក្នុងទីសង្កាត់ ខ្ទង់ដើមដៃ ទាំងឡាយយកចំពុះចិកខ្វេញ ពួកស្ត្រីទាំងនោះ (មានខ្លួនត្រឹមបង្កេះ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានក្ដៅរមៀលក្នុងខ្លួនសព្វកាល ។ ម្នាលទេវបុត្រ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិ ជាទេវសារថី ខ្ញុំសូមសួរអ្នក ពួកស្ត្រីដែល (មានខ្លួនត្រឹមបង្កេះ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានក្ដៅរមៀលក្នុងខ្លួនសព្វៗកាល ពួកស្ត្រីទាំងនេះ បានធ្វើបាបដូចម្ដេច ។

(៦៧៦) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ក្រាបទូលនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកស្ត្រីមានត្រកូលក្នុងជីវលោកនេះ មានអំពើមិនបរិសុទ្ធ បានប្រព្រឹត្តនូវតែកើតជារបស់អសប្បុរស ពួកស្ត្រីទាំងនោះ មានសភាពជាអ្នកលេងលះបង់ស្វាមីហើយ ក្រាបទៅរកបុរសដទៃ ព្រោះហេតុតែកាមគុណនិងល្បែង កាល ពួកស្ត្រីទាំងនោះក្នុងជីវលោក លុះញុំាងចិត្តបុរសដទៃ ឲ្យត្រេកត្រអាល ទើបមានភ្លើងឆេះ សន្ធោសន្ធៅ មានក្ដៅរមៀលក្នុងខ្លួនដូច្នេះ ។

(១៧៣) បាទេ គហេត្វា កិស្ស ឥមេ បុនេកេ

អវំសិរា នរកេ បាតយន្តិ

ភយំ ហិ មំ វិន្ទតិ សូត ទិស្វា

បុច្ឆាមិ តំ មាតលិ ទេវសារថិ

ឥមេ នុ មច្ចា កិមកំសុ បាបំ

យេមេ ជនា (អវំសិរា) នរកេ បាតយន្តិ ។

(១៧៤) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ

វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។

យេ ជីវលោកស្មឹ អសាធុកម្មិនោ

បរស្ស ទារានិ អតិក្កមន្តិ

តេ តាទិសា ឧត្តមភណ្ឌថេនា

តេមេ ជនា (អវំសិរា) នរកេ បាតយន្តិ ។

តេ វស្សបូគានិ ពហូនិ តត្ថ

និរយេសុ ទុក្ខំ វេទនំ វេទយន្តិ



(១៧៣) (ព្រះរាជា ...) ព្រោះហេតុអ្វី ពួកសត្វ

នរកមួយពួកទៀតនេះ ត្រូវនាយនិរយបាលចាប់ជើង ឲ្យមាន

ក្បាលសំយុងចុះ ហើយទម្លាក់ទៅក្នុងរណ្តៅ ម្នាលទេព

បុត្រ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី

ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ ដែលមានក្បាលសំយុងចុះ

នាយនិរយបាលទំលាក់ទៅក្នុងរណ្តៅនរក ពួកសត្វទាំង

នេះ បានធ្វើបាបដូចម្តេច ។

(១៧៤) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ក្រាប

ទូលផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ

ដែលមិនជ្រាបច្បាស់ ជនទាំងឡាយណា ក្នុងជីវលោក-

នេះ អ្នកមានអំពើជារបស់អសប្បុរស ប្រព្រឹត្តកន្លងនូវ

ប្រពន្ធទាំងឡាយនៃជនដទៃ សត្វទាំងឡាយប្រាកដដូច្នោះ

នោះ ឈ្មោះថាជាអ្នកលួចនូវរបស់ដ៏ថ្លៃថ្លា បានជាសត្វ

ទាំងនោះ(មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទំលាក់

ទៅក្នុងរណ្តៅ ។ សត្វទាំងឡាយនោះ តែងសោយនូវទុក្ខ

វេទនា ក្នុងនរកទាំងឡាយនោះ អស់ប្រជុំនៃឆ្នាំដ៏ច្រើន

ន ហិ បាបការិស្ស ភវន្តិ តាណា
សកេហិ កម្មេហិ បុរក្ខតស្ស
តេ សន្តកម្មា បសវេត្វ បាបំ
ឃោរេ ជនា (អវំសិរ) នរកេ បាតយន្តិ ។

(១៧៥) ឧព្ភារទាមេ វិជា ឧបក្កមា
និរយេសុ និសីទន្តិ សុមេឃាវុធា
ភយំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ បាបំ
យេមេ ជនា អធិមត្តា ទុក្ខា តិព្វា
ខរា កដុកា វេទនា វេទយន្តិ ។

(១៧៦) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បាបកម្មានំ ជានំ អក្ខាសិជានតោ ។
យេ ជីវលោកស្មឹ សុបាបធម្មិនោ
វិស្សាសកម្មានិ ករោន្តិ មោហា
បរញ្ញ ធម្មេសុ សមាចរន្តិ



ព្រោះថា ទីពឹងទាំងឡាយរបស់បុគ្គលអ្នកធ្វើបាប ជាបុគ្គលដែលកម្មរបស់ខ្លួនប្រើហើយ មិនមានទេ ពួកសត្វអ្នកមាននាំកើតមកនោះ រមែងរឹតខ្ញុំបាប ទើបបានជាពួកជនទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទំលាក់ទៅក្នុងនរកក្ដៅ ។

(១៧៥) (ព្រះរាជា ...) ពួកសត្វទាំងឡាយនេះ ខ្លះទីងទាល ម្យ៉ាង ១ គ្នា ជាអ្នកត្រូវបក្រជួស មានប្រមូរត្វាចពាន់ភោគ ប្រាកដនៅក្នុងនរកទាំងឡាយ ម្នាលទេពបុត្រ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានសេចក្ដីទុក្ខវេទនា ក្លៀវក្លា ក្ដៅផ្សា ក្ដៅក្រហាយក្រៃលែងនេះ ពួកសត្វទាំងនេះ បានធ្វើបាបដូចម្ដេច ។

(១៧៦) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ក្រាបទូលផលបាបកម្ម ដែលខ្លួនដឹងហើយ ចំពោះព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ មានចិត្តលាមកក្រៃលែង តែងធ្វើអំពើដ៏សៅហ្មង ព្រោះមោហៈ ទាំងបៀតបៀនអ្នកដទៃ (ឲ្យយល់) ក្នុងចិត្តទាំងឡាយនោះផង

តេ បាបទិដ្ឋី បសវេត្វា បាបំ
តេមេ ជនា អធិមត្តា ទុក្ខា តិព្វា
ខរា កដុកា វេទនា វេទយន្តិ ។

(១៥៧) វិទិតានិ តេ មហារាជ អាវាសំ បាបកម្មិនំ
ឋានានិ លុទ្ទកម្មានំ ទុស្សីលានញ្ច យា គតិ
ឧយ្យាហិ ទានិ រាជិសិ ទេវរាជស្ស សន្តិកេ ។

(១៥៨) បញ្ចថូបំ ទិស្សតិទំ វិមានំ
មាលាបិឡន្ធា សយនស្ស មជ្ឈេ
តត្ថច្ឆតិ នារី មហានុភាវា
ឧច្ចាវចំ ឥទ្ធិ វិកុព្វមានា
វិត្តី ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
អយំ នុ នារី កិមកាសិ សាធុំ
យា មោទតិ សគ្គបត្តា វិមានេ ។

(១៥៩) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។



ជនទាំងឡាយនោះ មានទិដ្ឋិបាប បង្កើតបាប ទើបបាន
ជាពួកជនទាំងនោះ សោយនូវទុក្ខវេទនា ដ៏ក្លៀវក្លា ខ្លោចផ្សា
ក្តៅក្រហាយក្រៃលែង ។

(១៥៧) បពិត្រព្រះករុណា ទីលំនៅរបស់សត្វអ្នកមានបាបកម្មទាំងឡាយ ឋានរបស់សត្វអ្នកមានអំពើអាក្រក់ទាំងឡាយ និងគតិរបស់សត្វអ្នកទ្រុស្តសីលទាំងឡាយ ព្រះអង្គទ្រង់ជ្រាបហើយ បពិត្រព្រះករុណា អ្នកសិរីករុណាដ៏ធំ សូមទ្រង់ស្ដេចទៅក្នុងសំណាក់ទេវរាជ ឥឡូវនេះ ។

(១៥៨) (ព្រះបាទនេមិ...) វិមាននេះ មានកំពូលប្រាំ
ដែលយើងឃើញប្រាកដ មាននាងនារី មានអានុភាពធំ
ប្រដាប់ដោយកម្រងផ្កា សំដែងនូវឫទ្ធិមានប្រការផ្សេងៗ
នៅកណ្ដាលដំណេក ក្នុងវិមាននោះ ម្នាលទេវបុត្រ
សេចក្ដីត្រេកអរមានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិ
ទេវសារថី ខ្ញុំសួរអ្នក នារី ដែលបានដល់ឋានសួគ៌ហើយ
រីករាយក្នុងវិមាន តើនារីនេះ បានធ្វើកុសលដូចម្ដេច ។

(១៥៩) មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ
ក៏ក្រាបទូលថ្លែងផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួន
ដឹងហើយ ចំពោះព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា

យំ តេ សុតា ពីរណី(១) ជីវលោកេ
អាមាយទាសី អហុ ព្រាហ្មណស្ស
សា បត្តកាលេ អតិថឹ វិទិត្វា
មាតាវ បុត្តំ សកិមាភិនន្ទី
សញ្ញមា សំវិភាគា ច សា វិមានស្មឹ មោទតិ ។

(១៨០) ទទ្ទល្លមានា អាភន្តិ វិមានា សត្ត និម្មិតា
តត្ថ យក្ខោ មហិទ្ធិកោ សព្វាភរណភូសិតោ
សមន្តា អនុបរិយាយតិ នារីគណបុរក្ខតោ ។
វិត្តី ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
អយំ នុ មច្ចោ កិមកាសិ សាធុំ
យោ មោទតិ សគ្គប្បត្តោ វិមានេ ។

(១៨១) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។
សោណទិន្នោ គហបតិ ឯស ទានបតី អហុ
ឯស បព្វជិតុទ្ទិស្ស វិហារេ សត្ត ការយិ ។

---

១ វីរណីតិ អដ្ឋកថាយំ ទិស្សតិ ។





ពីរណី ដែលទ្រង់ធ្លាប់ជ្រាបហើយ ជាទាសីកើតហើយក្នុងផ្ទៃនៃទាសី ក្នុងផ្ទះនៃព្រាហ្មណ៍ក្នុងជីវលោក នាងពីរណីនោះ ដឹងថា ភិក្ខុជាភ្ញៀវមានកាលដល់ហើយ (ហើយក៏អង្គាស ចង្អុលប្រគេនភិក្ខុនោះ)ហាក់ដូចជាមាតាដែលត្រេកអរចំពោះបុត្របស់ខ្លួន នាងជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនាងរីករាយក្នុងវិមាន ។

[១៨០] (ព្រះបាទនេមិ . . . ) វិមានមាសទាំង៧ ដែលបុញ្ញកម្មតាក់តែងហើយ មានពន្លឺរុងរឿងផ្សព្វផ្សាយទៅ មានទេវបុត្រមានឫទ្ធិច្រើន ប្រដាប់ហើយដោយអាភរណៈគ្រប់យ៉ាង មានពួកនារីទេពធីតាចោមរោមហើយ ដើរប្រទក្សិណជុំវិញ ក្នុងវិមានទាំង ៧ នោះ ។ ម្នាលទេវសារថី ខ្ញុំមានសេចក្ដីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រនេះ បានធ្វើអំពើកុសលដូចម្ដេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន ។

[១៨១] មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ក្រាបទូល នូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រនេះ ជាគហបតី ឈ្មោះសោណទិន្ន ជាម្ចាស់នៃទាន (ក្នុងដែនកាសី) បានកសាងកុដិសម្រាប់នៅ ៧ ខ្នង ឧទ្ទិសចំពោះបព្វជិត ។

សញ្ញតត្តេ ឧបដ្ឋាសិំ   ភិក្ខវេ ឧត្តកសិរោ(១)
អន្នបានញ្ច ភត្តញ្ច   សេនាសនំ បទីបិយំ
អទាសិំ ឧជុភូតេសុ   វិប្បសន្នេន ចេតសា ។
ចាតុទ្ទសឹ បញ្ចទសឹ   យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច   អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសិំ   សទា សីលេសុ សំវុតា
សញ្ញមា សំវិភាគា ច   សោ វិមានស្មិ មោទតិ ។
(១៨៦) បភាសតិមិទំ ព្យម្ហំ   ផលិកាសុ សុនិម្មិតំ
នារីវរគណាកិណ្ណំ   កូដាគារវរោចិតំ
ឧបេតំ អន្នបានេហិ   នច្ចគីតេហិ ចូភយំ ។
វិត្តី ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥយំ នុ នារី កិមកាសិ សាធុំ
យា មោទតិ សគ្គបត្តា វិមានេ ។

១ អាសយោតិ អញ្ញបាឋោ ទិស្សតិ ។





ខ្ញុំបានបម្រើភិក្ខុទាំងឡាយ ដែលសង្រួមនៅក្នុងកុដិនោះ ដោយគោរព បានប្រគេនចីវរសម្រាប់ស្លៀកដណ្តប់ផង ភត្តាហារផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះពួកអ្នកមានចិត្តត្រង់ទាំងឡាយ ដោយចិត្តជ្រះថ្លា ។ ខ្ញុំបានរក្សាឧបោសថប្រកបដោយអង្គប្រាំបី រាល់ថ្ងៃទី ១៤ ផង ថ្ងៃទី ១៥ ផង និងថ្ងៃទី ៨ នៃបក្សផង បាដិហារិយបក្សផង ខ្ញុំជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វៗ កាល ជាអ្នកសង្រួមខ្លួនផង ជាអ្នកចែកទាន ទើបបានកើតក្នុងវិមាន ។

(១៨៦) (ក្រោកជា . . .) វិមាននេះដែលបុគ្គលនិម្មិតហើយ ដ៏រុងរឿងដោយដុំថ្មជាវិការៈនៃកែវផលិក ពាសពេញដោយពួកនារីដ៏ប្រសើរ រុងរឿងដោយផ្ទះកំពូល ប្រកបដោយទឹកនិងភោជន ដោយការរាំនិងច្រៀងទាំងពីរ ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើនារីនេះបានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ហើយត្រេកអរក្នុងវិមាន ។

(១៨៣) តស្ស បុដ្ឋោ វិយាកាសិ   មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ   ជានំ អក្ខាសិជានតោ ។
យេ កេចិ មានុសេ លោកេ
សីលវន្តោ ឧបាសកា
ទានេ រតា និច្ចបសន្នចិត្តា
សង្ឃេ ឋិតា ឧបោសថេ អប្បមត្តា
សញ្ញមា សំវិភាគា ច   តេ វិមានស្មិ មោទរេ ។

(១៨៤) បភាសតិទំ ព្យម្ហំ   វេឡុរិយាសុ និម្មិតំ
ឧបេតំ ភូមិភាគេហិ   វិភត្តំ ភាគសោ មិតំ ។
អាលម្ពរា មុទិង្គា ច   នច្ចគីតា សុវាទិតា
ទិព្វា សទ្ទា និច្ឆរន្តិ   សវនីយា មនោរមា ។
នាហំ ឯវំ គតំ ជាតុ   ឯវំ សុរុចិរំ បុរេ
សទ្ទំ សមភិជានាមិ   ទិដ្ឋំ វា យទិ វា សុតំ ។
វិត្តំ ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមេ នុ មច្ចា កិមកំសុ សាធុំ
យេ មោទរេ សគ្គបត្តា វិមានេ ។





(១៨៣) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករ ខ្លួនផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូល ព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកឧបាសកណាមួយ ក្នុងមនុស្សលោកនេះ មានសីល ជាឧបាសក ត្រេកអរ ក្នុងទាន មានចិត្តជ្រះថ្លាជានិច្ច តាំងនៅក្នុងសង្ឃ មិន ប្រមាទក្នុងឧបោសថ ជាអ្នកសង្រួម ជាអ្នក ចែកទាន ទើបនាំគ្នារីករាយក្នុងវិមាន ។

(១៨៤) (ព្រះរាជា . . .) វិមាននេះដែលបុគ្គលនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវពិទូរ្យ ប្រកបដោយ ភូមិភាគចែកចេញដោយចំណែក ៗ (ក្នុងវិមាននេះ) មានស្គរ សម្ពួនិងព្យាណចង្ហួតស្គរ សម្ភោរ តាំងយាក់ រៀបនឹងប្រគំ ឮស្គាប់ ជាទីរីករាយនៃចិត្ត ។ សម្លេងដែលប្រព្រឹត្តទៅ យ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ តាំងពីមិនដែលឮឡើយ ទើបតែបានដឹង ។ ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះបានឃើញ ម្នាលមាតលិ ទេវសារថី ខ្ញុំសួរអ្នក តើពួកមនុស្សទាំងនេះ ធ្វើកុសល កម្មដូចម្តេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន ។

(១៨៨) តស្ស បុព្វេ វិយាកាសិ    ហត្ថលិ ទេវការដិ
វិមានំ បុញ្ញកម្មាធំ   ជាតំ អក្ខាសិជាតកោ ។
យេ កោចិ មគ្គា តត្ថ ជីវលោកេ សីលវន្តា ឧបាសកា
អាកាយេ ឧតតាមេថ តថា សក្តិមតាធំ ច
អមោឃេ សីតិភូតេ សក្កច្ចំ បដិពាធយុំ
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
អតីសុ ឧជុភូតេសុ វិប្បសន្នេន ចេតសា ។
ចាតុទ្ទសី បញ្ចទសី យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាហិតំ
ឧបោសថំ ឧបវសុំ សទា សីលេសុ សំវុតា
សញ្ញមា សំវិភាគា ច តេ វិមានស្មិ មោទរេ ។
(១៨៦) បភាសតិមិទំ ព្យម្ហំ   ផលិកាសុ សុនិម្មិតំ
នារីវរគណាកិណ្ណំ   កូដាគារវរោចិតំ
ឧបេតំ អន្នបានេហិ   នច្ចគីតេហិ ចូភយំ
ឆផ្លា អត្តុបរិយាយតិ   នានាបុប្ផទុមាយុតា ។





(១៨៨) ឯវិមានទៅសាវទី ដែលព្រះពុទ្ធទ្រង់សម្តែងហើយ គឺពួកអ្នកដែលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនធ្វើហើយ ខ្លួនក្រោកជានោះ ដែលមិនទ្រង់ប្រាប់ថា ជនទាំងឡាយណាមានសីល ជាឧបាសកក្នុងជីវលោកនេះ បានកសាងសួនច្បារ ស្រះ អណ្តូងទឹកនឹងស្ពាន ប្រគេនភិក្ខុព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រជាក់ ដោយគោរពព្រមទាំងបានថ្វាយចីវរ បិណ្ឌបាត សេនាសនៈនិង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ ជនទាំងឡាយនោះបានរក្សាឧបោសថ ប្រកបដោយអង្គប្រាំបី គស់តិថីទី ១៥ ផង តិថីទី ១៤ ផង តិថីទី ៨ នៃបក្សផង បាដិហារិយបក្សផង សង្រួមក្នុងសីលទាំងឡាយ សព្វ ៗ កាល ជាអ្នកសង្រួមផង ចែកជាអ្នកចែកទាន ទើបជនទាំងឡាយនោះរីករាយក្នុងវិមាន ។

(១៨៦) (ព្រះរាជា ...) វិមាននេះដែលបុញ្ញកម្មនិម្មិតល្អហើយ រុងរឿងដោយដំណាំងដែកកែវផលិក ដេរដាសដោយពួកនារីដ៏ប្រសើរ ចំរើនដោយផ្ទះកំពូល ប្រកបដោយទឹកនិងភោជន ដោយរាំ និងច្រៀងទាំងពីរយ៉ាង មានស្ទឹង ៦ ប្រកបដោយព្រៃឈើមានផ្កាផ្សេង ៗ ព័ទ្ធជុំវិញ ។

វិត្តី ហិ មំ វិន្ទតិ សុត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
អយំ នុ មច្ចោ កិមកាសិ សាធុំ
យោ មោទតិ សគ្គបត្តោ វិមានេ ។

(១៨៧)តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។
មិថិលាយំ(១) គហបតិ ឯស ទានបតី អហុ
អារាមេ ឧទបានេ ច បបា សង្កមនានិ ច
អរហន្តេ សីតិភូតេ សក្កច្ចំ បដិបាទយិ
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
អទាសិ ឧជុភូតេសុ វិប្បសន្នេន ចេតសា ។
ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាហិតំ
ឧបោសថំ ឧបវសិ សោ វិមានស្មឹ មោទតិ ។

១ ម. កិម្ពិលាយំ ។



ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានច្រើនដល់ខ្ញុំ
ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រ
នេះបានធ្វើ នូវកុសលកម្មដូចម្តេច ទើបដល់នូវឋានសួគ៌
ហើយរីករាយក្នុងវិមាន ។

(១៨៧) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករ នូវផលនៃបុញ្ញកម្មទាំងឡាយដែលខ្លួនដឹងហើយ ទូលព្រះរាជាទោះដែលមិនទាន់ជ្រាបថា ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូងទឹកនិងស្ពាន បានប្រគេនបច្ច័យព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈនិង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តអ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា ។ បានរក្សាឧបោសថ ប្រកបដោយអង្គ៨ អស់ថ្ងៃទី ១៤ ផង ថ្ងៃទី ១៥ ផង ថ្ងៃទី៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វកាល ជាអ្នកសង្រួមខ្លួនត្រៀម ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន ។

(១៨៨) បភាសតិមិទំ ព្យម្ហំ ផលិកា វិម្ហិតំ
នារីវរគណាកិណ្ណំ កូដាគារ វរោចិតំ
ឧបេតំ អន្នបានេហិ នច្ចគីតេហិ ចូភយំ
នជ្ជោ អនុបរិយាយន្តិ នានាបុប្ផទុមាយុតា
ភជាយគតា កបិដ្ឋា ច អម្ពា សាលា ច ជម្ពុយោ
តិណ្ឌុកា ច បិយាលា ច ទុមា និច្ចផលា ពហូ ។
វិត្តី ហិ មំ វិន្ទតិ សុត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
អយំ នុ មច្ចោ កិមកាសិ សាធុំ
យោ មោទតិ សគ្គបត្តោ វិមានេ ។

(១៨៩) តស្ស បុដ្ឋោ វិយាកាសិ មាតលី ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។
មិថិលាយំ គហបតិ ឯស ទានបតី អហុ
អារាមេ ឧទបានេ ច បបា សង្កមនានិ ច
អរហន្តេ សីតិភូតេ សក្កច្ចំ បដិបាទយិ
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
អទាសិ ឧជុភូតេសុ វិប្បសន្នេន ចេតសា ។



(១៨៨) (ព្រះរាជា ...) វិមាននេះដែលបុញ្ញកម្មនិម្មិតល្អហើយ ដ៏រុងរឿងដោយផ្ទាំងផលិកានៃកែវផលិក ដេរដាសដោយពួកនារីដ៏ប្រសើរ ចំរើនដោយផ្ទះកំពូល ប្រកបដោយទឹកនឹងភោជន ដោយការច្រៀងនឹងការរាំទាំងពីរយ៉ាង មានស្ទឹងប្រកបដោយឈើ មានផ្កាផ្សេងៗហូរព័ទ្ធជុំវិញ មានឈើទាំងឡាយជាច្រើនគឺ ដើមខេស្ វ័ក ស្វាយ សាលព្រីង ត្រើង ខ្នាច់ មះរំចង សុទ្ធសឹងមានផ្លែជានិច្ច ។

ម្នាលទេវបុត្រ សេចក្ដីត្រេកអរមានប្រាកដដល់ខ្ញុំ ព្រោះ
ឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រនេះ
បានធ្វើកុសលកម្មដូចម្ដេច ទើបដល់ឋានសួគ៌ រីករាយ
ក្នុងវិមាន ។

(១៨៩) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ចំពោះព្រះរាជានោះដែលមិនទាន់ជ្រាបថា ទេវបុត្រនេះ ជាគហបតី ជាម្ចាស់នៃទានក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្ដូងទឹក បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលជាអ្នកមានចិត្តត្រជាក់ បានថ្វាយនូវចីវរ បិណ្ឌបាត សេនាសនៈនឹង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។

ចាតុទ្ទសឹ បញ្ចទសឹ យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាហិតំ
ឧបោសថំ ឧបវសិ សទា សីលេសុ សំវុតោ
សញ្ញមោ សំវិភាគោ ច សោ វិមានស្មិំ មោទតិ ។

(១៩០) បភាសតិមិទំ ព្យម្ហំ វេឡុរិយាសុ និម្មិតំ
ឧបេតំ ភូមិភាគេហិ វិភត្តំ ភាគសោ មិតំ ។
អាលម្ពរ មុទិង្គា ច នច្ចគីតា សុវាទិតា
ទិព្វា សទ្ទា និច្ឆរន្តិ សវនីយា មនោរមា ។
នាហំ ឯវំ គតំ ជាតុ ឯវំ សុរុចិំ បុរេ
សទ្ទំ សមភិជានាមិ ទិដ្ឋំ វា យទិ វា សុតំ ។
វិត្តោ ហំ មំ វិន្ទាមិ សុត្វា ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
អយំ នុ មច្ចោ កិមកាសិ សាធុំ
យោ មោទតិ សគ្គបត្តោ វិមានេ ។

(១៩១) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។



គហបតីនោះបានចាំឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ផង ថ្ងៃទី ១៥ ផង ថ្ងៃទី៨នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួម ក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែក ទាន ទើបគហបតីនោះកើតក្នុងវិមាន ។

(១៩០) (ព្រះរាជា ...) វិមាននេះដែលបុគ្គលនិម្មិតហើយ ដ៏រុងរឿងដោយផ្ទាំងដ៏ជាវិការៈនៃកែវពិទូរ្យ ប្រកបដោយភូមិភាគចែក ស្រស់ដោយចំណែក (ក្នុងវិមាននោះ) មានសូរសព្ទជាទិព្វលាន់ឮ គឺស្គរ សម្ពោរ គឺយោគ ក្រៀវ និងប្រគំ ល្អស្ដាប់ ជាទីគាប់ចិត្ត ។ សម្លេងដែលប្រព្រឹត្តទៅយ៉ាងនេះ ក៏រុងរឿងយ៉ាងនេះ គឺមុនមក ខ្ញុំមិន ដែលឃើញ ទាំងមិនដែលឮឡើយ ទើបកើតនឹងបានដឹង ។

ម្នាលទេវសារថី សេចក្ដីត្រេកអរមានដល់ខ្ញុំ ព្រោះ
ឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រ
អង្គនេះ បានធ្វើកុសលកម្មដូចម្ដេច ទើបដល់ឋាន
សួគ៌ ហើយកើតក្នុងវិមាន ។

(១៩១) មាតលិ ទេវសារថី ដែលព្រះរាជាសួរ ហើយ ក៏ព្យាករ នូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ចំពោះព្រះរាជានោះ ដែលមិនទ្រង់ជ្រាបជា

ពារាណសិយំ គហបតិ ឯស ទានបតី អហុ
អារាមេ ឧទបានេ ច បបា សង្កមនានិ ច
អរហន្តេ សីតិភូតេ សក្កច្ចំ បដិបាទយិ
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
អទាសិ ឧជុភូតេសុ វិប្បសន្នេន ចេតសា ។
ចាតុទ្ទសិំ បញ្ចទសី យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាហិតំ
ឧបោសថំ ឧបវសិ សទា សីលេសុ សំវុតោ
សញ្ញមោ សំវិភាគោ ច សោ វិមានស្មិំ មោទតិ ។

(១៤២)យថា ឧទយមាទិច្ចោ ហោតិ លោហិតកោ មហា
តថូបមំ ឥទំ ព្យម្ហំ ជាតរូបស្ស និម្មិតំ(១) ។
វិត្តី ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
អយំ នុ មច្ចោ កិមកាសិ សាធុំ
យោ មោទតិ សគ្គប្បត្តោ វិមានេ ។

១ ជាតរូបំ សុវណ្ណន្តិ អដ្ឋកថាយំ ទិស្សតិ ។



ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងពារាណសី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រគេនចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈនិង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ ទេវបុត្រនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ អស់ថ្ងៃទី ១៤ ផង ថ្ងៃទី ១៥ ផង ថ្ងៃទី ៨ នៃបក្សផង អស់បាដិហារិយបក្សផង សង្រួមក្នុងសីលទាំងឡាយ សព្វកាល ជាអ្នកសង្រួមផង ជាអ្នកចែកទាន ទើបទេវបុត្រនោះ រីករាយក្នុងវិមាន ។

(១៤២)(ព្រះរាជា ..) វិមាននេះ ជាវិការនៃមាសដែលបុគ្គលធ្វើនិម្មិត ហើយ ដូចព្រះអាទិត្យទើបនឹងរះឡើង មានពណ៌ក្រហម មានមណ្ឌលធំ ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំ
ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក
ទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើប
ដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន ។

[១៤៣] តស្ស បុញ្ញោ វិបាកាសិ ហតលំ ទេវសោភិតំ

វិហារំ បុញ្ញកម្មានំ ជាតំ អក្ខាសិ ជាតកោ ។

សាវត្ថិយំ គហបតិ ឯស ទានបតី អហុ

អារាមេ ឧទបានេ ច បបា សង្កមនានិ ច

អរហន្តេ សីតិភូតេ សក្កច្ចំ បដិបាទយិំ

ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ

អទាសិំ ឧជុភូតេសុ វិប្បសន្នេន ចេតសា ។

ចាតុទ្ទសិំ បញ្ចទសិំ យា ច បក្ខស្ស អដ្ឋមី

បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាហិតំ

ឧបោសថំ ឧបវសិំ សទា សីលេសុ សំវុតោ

សញ្ញមោ សំវិភាគោ ច សោ វិមានស្មិ អាវសិំ ។

[១៤៤] វេហាយសា មេ ពហុកា ជាតរូបស្ស និម្មិតា

ទទ្ទល្លមានា អាភន្តិ វិជ្ជុវព្ភឃនន្តរេ

តត្ថ យក្ខា មហិទ្ធិកា សព្ពាភរណភូសិតា

សមន្តា អនុបរិយាយន្តិ នារីគណបុរក្ខតា ។





(១៤៣) ទាតលំនៅសោភាទី ដែលព្រះបាទទេវម៉ស្សរហើយ ក៏ព្រោះនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្ញុំធ្វើហើយ ខ្ញុំព្រះករុណានោះ ដែលមិនប្រែប្រួល នៅក្នុងក្រុងនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងសាវត្ថី បានកសាងសួនច្បារ ស្រះ អណ្ដូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ ជាអ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ គហបតិនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ អស់ថ្ងៃទី ១៤ ផង ថ្ងៃទី ១៥ ផង ថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមវិន័យ ជាអ្នកចែកទាន ទើបគហបតីនោះនៅក្នុងវិមាន ។

(១៤៤) (ព្រះករុណា . . .) វិមានទាំងឡាយនេះ ជាវិការនៃមាស មានប្រមាណច្រើន ដែលបុញ្ញកម្មនិម្មិតហើយ តាំងនៅក្នុងអាកាស មានពន្លឺរុងរឿង ដូចជាផ្លេកបន្ទោរក្នុងចន្លោះនៃមេឃ ក្នុងវិមានទាំងឡាយនោះ មានពួកទេវតាមានឫទ្ធិច្រើន សឹងប្រដាប់ដោយគ្រឿងអាភរណៈគ្រប់បែប មានពួកនារីទេវអប្សរចោមរោមហើយ ប្រចរញ្ញូណវិលវល់ដោយជុំវិញ ។

វិត្តី ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
អយំ នុ មច្ចោ កិមកាសិ សាធុំ
យោ មោទតិ សគ្គបត្តោ វិមានេ ។

(១៩៥) តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។
សទ្ធាយ សុនិវិដ្ឋាយ សទ្ធម្មេ សុប្បវេទិតេ
អកាសិ សត្ថុ វចនំ សម្មាសម្ពុទ្ធសាវកោ(១)
តេសំ ឯតានិ ឋានានិ យានិ ត្វំ រាជ បស្សសិ ។

(១៩៦) វិទិតា តេ មហារាជ អាវាសំ បាបកម្មិនំ
អថោ កល្យាណកម្មានំ ឋានានិ វិទិតានិ តេ
ឧយ្យាហិ ទានិ រាជិសិ ទេវរាជស្ស សន្តិកេ ។

(១៩៧) សហស្សយុត្តំ ហយវាហិំ ទិព្វយានមធិដ្ឋិតោ
យាយមានោ មហារាជា អទ្ទា សីទន្តរេ នគេ
ទិស្វានាមន្តយី សូតំ(២) ឥមេ កេ នាម បព្វតា ។

១. សម្មាសម្ពុទ្ធសាសនំ ។ ម. សម្មាសម្ពុទ្ធសាសនេ ។ ២. ទូតំ ។ ឥច្ឆិតា ។



ហាប់ទេពបម្រើ សេចក្តីត្រេកអរមានប្រមាណ ដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ក្នុងទេវបុត្រទាំងនេះបាន ធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ រីករាយក្នុងវិមាន ។

(១៩៥) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្ម ដែលខ្លួនដឹងហើយ ចំពោះព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ក្នុងទេវបុត្រទាំងនោះ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ តាំងនៅស៊ប់ដោយសទ្ធាក្នុងព្រះសទ្ធម្ម ដែលព្រះមានព្រះភាគទ្រង់ប្រកាសទុកល្អហើយ បានធ្វើតាមនូវពាក្យប្រដៅរបស់ព្រះសាស្តា បពិត្រព្រះរាជា ឋានទាំងឡាយ ដែលទ្រង់ក្រឡេកឃើញហើយ គឺជាឋានរបស់ទេវបុត្រទាំងឡាយនោះ ។

(១៩៦) បពិត្រមហារាជ ឋានរបស់សត្វ អ្នកមានបាបកម្ម ទ្រង់បានជ្រាបហើយ ព្រោះទ្រង់ទតឃើញនូវលំនៅ(របស់សត្វ) ទាំងឋានរបស់សត្វអ្នកមានកល្យាណកម្ម ក៏ទ្រង់ជ្រាបហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកកុសលធម៌ ឥឡូវនេះ សូមទ្រង់យាងទៅក្នុងសំណាក់នៃទេវរាជ ។

(១៩៧) (អភិសម្ពុទ្ធគាថា) ព្រះបាទនេមិមហារាជ ទ្រង់ប្រថាប់លើទិព្វយាន មានសេះជាពាហនៈ ដែលទឹមដោយសេះសិន្ធព ១ ពាន់ កាលស្តេចកំពុងយាងទៅ ទ្រង់ក្រឡេកឃើញភ្នំទាំងឡាយ ក្នុងចន្លោះសីទន្តរសមុទ្រ លុះទ្រង់ទតឃើញហើយ ទ្រង់ត្រាស់ហៅទេវសារថីសួរថា ភ្នំទាំងនោះ ឈ្មោះអ្វី ។

(១៩៨) សុទស្សនោ ករវីកោ ឥសិន្ធរោ យុគន្ធរោ
នេមិន្ធរោ វិនតកោ អស្សកណ្ណោ គិរិព្រហា
ឯតេ សីទន្តរេ នគា អនុបុព្វសមុគ្គតា
មហារាជានមាវាសា យានិ ត្វំ រាជ បស្សសិ ។

(១៩៩) អនេករូបំ រុចិរំ នានាចិត្តំ បកាសតិ
អាកិណ្ណំ ឥន្ទសទិសេហិ ព្យគ្ឃេហេវ សុរក្ខិតំ ។
វិត្តី ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមំ នុ ទ្វារំ កិមភិញ្ញមាហុ
មនោរមំ ទិស្សតិ ទូរតោ វ ។

(២០០) តស្ស បុដ្ឋោ វិយាការសិ មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។
ចិត្តកូដោតិ យំ អាហុ ទេវរាជប្បវេសនំ
សុទស្សនស្ស គិរិនោ ទ្វារំ ហេតំ បកាសតិ
អនេករូបំ រុចិរំ នានាចិត្តំ បកាសតិ
អាកិណ្ណំ ឥន្ទសទិសេហិ ព្យគ្ឃេហេវ សុរក្ខិតំ
បវិសេតេន រាជិសិ អរជំ ភូមិមក្កម ។



(១៩៨) (មាតលិ...) ភ្នំទាំងឡាយនេះ ក្នុងសមុទ្រសីទន្តរ គឺភ្នំសុទស្សនៈ១ ករវិក១ ឥសិន្ធរ១ យុគន្ធរ១ នេមិន្ធរ១ វិនតក១ អស្សកណ្ណ១ ជាភ្នំមានកំពូលខ្ពស់ឡើងតាមលំដាប់រៀងគ្នា បពិត្រមហា-រាជ ភ្នំដែលទ្រង់ព្រះនេត្រឃើញ សុទ្ធតែជាលំនៅនៃមហារាជទាំងឡាយ ។

(១៩៩) (ព្រះរាជា...). (ទ្វារ) មានរូបជាអនេក ដ៏រុងរឿងវិចិត្រ ដោយពណ៌ផ្សេងៗ ១ ដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ ហាក់ដូចជា (ព្រៃធំ) ដែលពួកខ្លាធំចាំនៅហើយ ។

ម្នាលទេវសារថី សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះឃើញ
ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក អ្នកហៅទ្វារនេះ
ឈ្មោះអ្វី ទើបជាទីរីករាយនៃចិត្ត ប្រាកដអំពីចម្ងាយ ។

(២០០) មាតលិទេវសារថី ដែលព្រះរាជាទ្រង់សួរហើយ ក៏ក្រាបទូលដែលវិបាកនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ចំពោះព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ទ្វារនេះឈ្មោះចិត្តកូដ ជាទីចេញចូលនៃទេវរាជ (ជាទ្វារនៃទេពនគរដែលតាំងនៅត្រង់ទីចំផុតនៃភ្នំព្រះសុមេរុ) ជាទ្វារភ្នំសុទស្សន៍មើលប្រាកដ (ទ្វារនេះ) មានរូបជាអនេក ដ៏រុងរឿងវិចិត្រដោយពណ៌ផ្សេងៗ ១ ប្រាកដជាទ្វារដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ ហាក់ដូចជា (ព្រៃធំ) ដែលពួកខ្លារក្សាហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅតាមទ្វារនេះ សូមទ្រង់ជាន់លើផែនដីប្រាសចាកធូលី ។

(៦០១)សហស្សយុត្តំ ហយវាហិំ ទិព្វយានមធិដ្ឋិតោ
យាយមានោ មហារាជា អទ្ទា ទេវសភំ ឥទំ ។
យថា សរទេ អាកាសេ នីលោភាសោ បទិស្សតិ
តថូបមំ ឥទំ ព្យម្ហំ វេឡុរិយាសុ និម្មិតំ ។
វិត្តី ហិ មំ វិន្ទតិ សូត ទិស្វា
បុច្ឆាមិ តំ មាតលិ ទេវសារថិ
ឥមំ នុ ព្យម្ហំ កិមញ្ញមាហុ ។

(៦០២)តស្ស បុដ្ឋោ វិយាកាសិ មាតលិ ទេវសារថិ
វិបាកំ បុញ្ញកម្មានំ ជានំ អក្ខាសិជានតោ ។
សុធម្មា ឥតិ យំ អាហុ បស្សេសា(*)ទិស្សតេ សភា
វេឡុរិយារុចិរា ចិត្រា ធារយន្តិ សុនិម្មិតា
អដ្ឋំសា សុកតា ថម្ភា សព្វេ វេឡុរិយាមយា
យត្ថ ទេវា តាវតិំសា សព្វេ ឥន្ទបុរោហិតា
អត្ថំ ទេវមនុស្សានំ ចិន្តយន្តា សមច្ឆរេ
បវិសេនេន កជិសំ នេកំ អនុមោទនំ ។

* ម. បស្សេសា ។



(៦០១) (ឥតិសម្ពុទ្ធគាថា) ព្រះបាទនេមិមហារាជ ទ្រង់បរទៅលើទិព្វយាន ជារបស់អាជានេយ្យៈ ដែលទឹមដោយសេះស័ត្វ ១ ពាន់ ទ្រង់យាងទៅ បានទតឃើញនូវទេវសភា (ក្រសួងជា) នៃនោះ ដែលបុញ្ញកម្មនិម្មិតហើយ ដោយផ្ទាំងកែវពៃទូរ្យ ឃើញច្បាស់ ដូចអាកាសមានពន្លឺខៀវ ក្នុងសរទកាល ។

ម្នាលទេវបម្រើ សេចក្តីត្រេកអរ មានដល់ខ្ញុំ ព្រោះ
ឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅ
វិមាននុ៎ះឈ្មោះអ្វី ។

(៦០២) មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ក្រាបទូល នូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះករុណានូវផលដែលមិនទ្រង់ជ្រាបថា ទេវសភា ដែលព្រះអង្គទតឃើញនុ៎ះឯង គេហៅថា សុធម្មា (ទេវសភានុ៎ះ) រុងរឿងដោយកែវពៃទូរ្យដ៏វិចិត្រ ដែលបុញ្ញានុភាពនិម្មិតដោយប្រពៃតាំងនៅ សសរមានជ្រុងប្រាំបី ដែលបុញ្ញកម្មធ្វើល្អ សុទ្ធសឹងជាវិការនៃកែវពៃទូរ្យទាំងអស់ ពួកទេវតាជាន់តាវត្តិង្សទាំងអស់ ស៊ឹងមានព្រះឥន្ទ្រជាប្រមុខ តែងប្រជុំគិតគូរសេចក្តីចំរើន របស់ទេវតានិងមនុស្សទាំងឡាយ បពិត្រព្រះករុណា ទ្រង់ស្តែងគុណធម៌ សូមទ្រង់ចូលទៅកាន់ទីអនុមោទនារបស់ទេវតាទាំងឡាយ តាមច្បាប់នេះ ។

(២០៣) តំ ទេវា បដិនន្ទិំសុ ទិស្វា រាជានមាគតំ
ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ
និសីទ ទានិ រាជីសិ ទេវរាជស្ស សន្តិកេ ។
សក្កោបិ តំ បដិនន្ទិត្ថ[១] វេទេហំ មិថិលគ្គហំ
និមន្តយិត្ថ កាមេហិ អាសនេន ច វាសវោ ។
សាធុ ខោសិ អនុប្បត្តោ អាវាសំ វសវត្តិនំ
វស ទេវេសុ រាជីសិ សព្វកាមសមិទ្ធិសុ
តាវតិំសេសុ ទេវេសុ ភុញ្ជ កាមេ អមានុសេ ។
(២០៤) យថា យាចិតកំ យានំ យថា យាចិតកំ ធនំ
ឯវំ សម្បទមេវេតំ យំ បរតោ ទានបច្ចយា ។
ន ចាហមេតមិច្ឆាមិ យំ បរតោ ទានបច្ចយា
សយំ កតានិ បុញ្ញានិ តំ មេ អាវេណិយំ ធនំ ។

១ ម. បដិនន្ទិត្វា ។



(២០៣) (អភិសម្ពុទ្ធគាថា) ពួកទេវតាទាំង បានឃើញព្រះរាជានោះ ស្ដេចយាងមកដល់ហើយ ត្រេកអរទទួលថា បពិត្រមហារាជ ដំណើរ ដែលព្រះអង្គយាងមកនេះប្រពៃហើយ មិនមែនទ្រង់យាងមកអាក្រក់ទេ បពិត្រព្រះរាជា ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គគង់ក្នុងទីជិតនៃទេវរាជចុះ ។ សក្កទេវរាជ ទ្រង់ត្រេកអរទទួលព្រះបាទវិទេហៈ គ្រប់គ្រងក្រុងមិថិលានោះ ព្រះបាទវាសវៈអញ្ជើញព្រះអង្គ ដោយកាមគុណទាំងឡាយផង ដោយអាសនៈផងថា ព្រះអង្គស្ដេចមក ដល់លំនៅនៃទេវតាទាំងឡាយ ជាដំណើរប្រពៃណាស់ ព្រះរាជាទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងទេវលោកទាំងឡាយ ជាទីញុំាងសេចក្ដីប្រាថ្នាទាំងពួងឲ្យសម្រេច សូមព្រះអង្គបរិភោគកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្ស ក្នុងតាវត្តិំសទេវលោកចុះ ។

(២០៤) (ព្រះបាទនេមិ ...) វត្ថុណាដែលបានដោយអ្នកដទៃ ឲ្យជាបច្ច័យ ដូចយានជារបស់សូមគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនោះ ក៏មានឧបមេយ្យយ៉ាងនេះឯង ។ ខ្ញុំមិនប្រាថ្នានូវវត្ថុ ដែលបានមក ដោយអ្នកដទៃឲ្យជាបច្ច័យនោះទេ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយ ដោយខ្លួនឯង នោះទើបជាទ្រព្យសម្រេចដល់ខ្ញុំ ។

សោហំ គន្ត្វា មនុស្សេសុ  ការេស្សាមិ កុសលំ ពហុំ

ទានេន សមចរិយាយ  សញ្ញមេន ទមេន ច

យំ កត្វា សុខិតោ ហោតិ  ន ច បច្ឆានុតប្បតិ ។

(២០៧) ពហូបការោ នោ ភវំ  មាតលិ ទេវសារថិ

យោ មេ កល្យាណកម្មានំ  បាបានំ បដិទស្សយិ ។

(២០៨) ឥទំ វត្វា និមិរាជា  វេទេហោ មិថិលគ្គហោ

បុថុយញ្ញំ យជិត្វាន  សញ្ញមំ អជ្ឈុបាគមីតិ ។

និមិជាតកំ ចតុត្ថំ ។

---



ខ្ញុំនឹងត្រឡប់ទៅធ្វើកុសលដែលបុគ្គលធ្វើហើយ រមែងដល់សេចក្តីសុខ មិនក្តៅក្រហាយខាងក្រោយ ឲ្យបានប្រមាណច្រើន ដោយការឲ្យផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមឥន្ទ្រិយផង ដោយការទូន្មាននូវឥន្ទ្រិយផង ក្នុងពួកមនុស្ស ។

(២០៧) មាតលិជាទេវសារថី ដ៏ចំរើន ជាអ្នកមានឧបការៈច្រើនដល់យើង ព្រោះបានបង្ហាញនូវឋាននៃសត្វអ្នកមានបុញ្ញកម្ម និងឋាននៃសត្វអ្នកមានបាបកម្មដល់ខ្ញុំ ។

(២០៨) ព្រះបាទនិមិ ទ្រង់ជាឥស្សរៈក្នុងដែនវិទេហៈ គ្រប់គ្រងក្រុងមិថិលា ទ្រង់បានពោលដូច្នេះហើយ (ទើបទ្រង់លាសក្កទេវរាជ ត្រឡប់មកមនុស្សវិញ) ទ្រង់បានបូជាយញ្ញៈដ៏ច្រើន ហើយទ្រង់ចូលទៅកាន់ការសង្រួម (បព្វជ្ជា) ។

ចប់ និមិជាតក ទី ៤ ។

---

## មហោសធជាតកំ

(៦០៧)បញ្ចាលោ សព្វសេនាយ ព្រហ្មទត្តោយមាគតោ

សាយំ បញ្ចាលិយា សេនា អប្បមេយ្យា មហោសធ

វីថិមតី បត្តិមតី សព្វសង្គាមកោវិទា

ឩហារិនី សទ្ទវតី ភេរិសង្ខប្បពោធនា ។

លោហវិជ្ជា អលង្ការា ធជិនី(១) វាមរោហិនី

សិប្បិយេហិ សុសម្បន្នា សូរេហិ សុប្បតិដ្ឋិតា ។

ទសេត្ថ បណ្ឌិតា អាហុ ភូរិបញ្ញា រហោគតា

មាតា ឯកាទសី រញ្ញោ បញ្ចាលិយំ បសាសតិ

អថេត្ថេកសតំ ខត្យា អនុយន្តា យសស្សិនោ

អច្ឆិន្នរដ្ឋា ព្យថិតា បញ្ចាលីនំ វសំ គតា ។

១. ម. ធជនី ។



## មហោសធជាតក

(៦០៧) (ព្រះបាទវិទេហៈត្រាស់ថា) ម្នាលមហោសធ ព្រះរាជាចូឡនីព្រហ្មទត្ត ជាម្ចាស់ក្រុងបញ្ចាល យាងមកជាមួយនឹងសេនាទាំងពួង សេនារបស់ព្រះរាជាក្រុងបញ្ចាលនោះ ពុំអាចប្រមាណមិនបាន ។ (សេនាទាំងនោះ) មានពលជាដំរីសេះនិងពលថ្មើរជើង អ្នកឈ្លាសក្នុងសង្គ្រាមទាំងពួង កាចនឹងលុកចូលទៅក្នុងគួក ជាសេនាមានសំឡេង (មិនស្ងាត់បាត់សំឡេងទាំង ១០ យ៉ាង) ញ៉ាំងគេឲ្យដឹងដោយសំឡេងស្គរនិងស័ង្ខ ។ (ពួកសេនាទាំងនោះ) មានវិជ្ជាក្នុងផ្លូវលោហៈធាតុ នឹងមានគ្រឿងប្រដាប់ មានទង់ជ័យ មានមនុស្សពាក់ក្រោះកាន់ពាហនៈតាក់តែង ទាំងបរិបូណ៌ល្អដោយពួកមនុស្សអ្នកមានសិល្បៈ ដែលពួកយោធាដ៏ក្លៀវក្លា (មានកម្លាំងយោធាស្មើដោយមនុស្សសីហៈ) តាំងទុកដោយល្អហើយ ។ ក្នុងចំណោមសេនាទាំងនោះ មានបណ្ឌិត ១០ នាក់ ជាអ្នកឈ្លាសមានប្រាជ្ញាដូចផែនដី ប្រើតែពាក្យប្រឹក្សាក្នុងទីស្ងាត់ និងមាតារបស់ព្រះរាជាជាគំរប់ ១១ នៅគ្រប់គ្រងឲ្យប្រយោជន៍ដល់សេនាក្នុងក្រុងបញ្ចាល ។ បណ្ដាជនទាំងនោះ មានក្សត្រិយ៍ ១០១ សុទ្ធតែមានយសធំធេង ដែលព្រះបាទចូឡនីព្រហ្មទត្តដណ្ដើមយកដែនហើយ មានសេចក្ដីភ័យតក់ស្លុត ក៏ស្ថិតក្នុងអំណាចនៃព្រះបាទបញ្ចាល ។

យំវទា តក្ករា រញ្ញោ  អកាមា បិយភាណិនោ
បញ្ចាលមនុយាយន្តិ  អកាមា វសិនោ គតា ។
តាយ សេនាយ មិថិលា  តិសន្ធិបរិវារិតា
រាជធានី វិទេហានំ  សមន្តា បរិខញ្ញតិ ។
ឧទ្ធំ តារកជាតាវ  សមន្តា បរិវារិតា
មហោសធ វិជានាហិ  កថំ មោក្ខោ ភវិស្សតិ ។

(៦០៨) បាទេ ទេវ បសារេហិ  ភុញ្ជ កាមេ រមស្សុ ច
ហិត្វា បញ្ចាលិយោ សេនំ  ព្រហ្មទត្តោ បលាយតិ ។

(៦០៩) រាជា សន្ថវកាមោ តេ  រតនានិ បវេច្ឆតិ
អាគច្ឆន្តុ ឥតោ ទូតា  មញ្ជុកា បិយភាណិនោ ។
ភាសន្តុ មុទុកា វាចា  យា វាចា បដិនន្ទិតា
បញ្ចាលោ ច វិទេហោ ច  ឧភោ ឯកា ភវន្តុ តេ ។



(ក្សត្រិយ៍ ១០១ នោះ) ជាអ្នកធ្វើតាមព្រះរាជឱង្ការ មិនមានប្រាថ្នា តែពោលពាក្យជាទីស្រឡាញ់ មិនមានប្រាថ្នាក៏លុះអំណាចចុះចូលព្រះបាទបញ្ចាល ។ មិថិលារាជធានីរបស់ពួកអ្នកវិទេហ ត្រូវពួកសេនានោះហ៊ុមព័ទ្ធជាបីជាន់[១] (ដូចជា) ជីកកាសជុំវិញ ។ (ក្រុងមិថិលា) ត្រូវសេនាហ៊ុមព័ទ្ធជុំវិញ (ប្រាកដដោយសេចក្តីថា) ដូចជាផ្កាយដែលប្រាកដក្នុងអាកាស ម្នាលមហោសធ អ្នកចូរដឹងថា សេចក្តីរួច (ចាកទុក្ខនេះ) នឹងមានដល់ពួកយើងដោយប្រការដូចម្តេច ។

(៦០៨) (ព្រះមហាសត្វក្រាបបង្គំទូលថា) បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់លាតព្រះបាទ (ឲ្យស្រួលបួល) សូមព្រះអង្គទ្រង់ក្រសាលរីករាយក្នុងកាមគុណ ព្រះបាទព្រហ្មទត្ត មុខជានឹងលះបង់សេនាក្នុងក្រុងបញ្ចាលហើយរត់ទៅ ។

(៦០៩) (អាចារ្យនៅផ្ទះព្រាហ្មណ៍...) ព្រះរាជាចូលទ្រង់ប្រាថ្នាដើម្បីធ្វើសន្ថវមិត្រ (នឹងព្រះអង្គ) ក៏ទ្រង់នឹងយកកែវទាំងឡាយមានស្រីកែវជាដើមដល់ព្រះអង្គ (តាំងដើម) ក៏ឲ្យទៅ សូមឲ្យពួករាជទូតមានវាចាពីរោះពោលពាក្យជាទីស្រឡាញ់ (ក្រុងមិថិលានេះបាន) ។ សូមឲ្យពួករាជទូតទាំងនោះពោលវាចាទន់ភ្លន់ជាវាចាគួរត្រេកអរ សូមព្រះបាទបញ្ចាលនឹងព្រះបាទវិទេហៈ ទាំងពីរព្រះអង្គនោះ រួមគ្នាតែមួយ ។

---

• ក៏ទ្រង់ដោយកំពែង [illegible] ក៏ទ្រង់ដោយកំពែង [illegible] ក៏ទ្រង់ដោយកំពែង [illegible] ។ [illegible] ។

(២១០) កច្ចន្នុ សេនក មហោសធេន
សមាគមោ អាសិ តទិង្ឃ ព្រូហិ
កច្ចិ តេ បដិនិជ្ឈត្តោ កច្ចិ តុដ្ឋោ មហោសធោ ។

(២១១) អនរិយរូបោ បុរិសោ ជនិន្ទ
អសម្មោទកោ ថទ្ធោ អសព្ភិរូបោ
យថា មូគោ ច ពធិរោ ច ន កិញ្ចិ អភាសថ ។

(២១២) អទ្ធា ឥទំ មន្តបទំ សុទុទ្ទសំ
អត្ថោ សុទ្ធោ នរវីរេន ទិដ្ឋោ
តថា ហិ កាយោ មម សម្បវេធតិ
ហិត្វា សយំ កោ បរហត្ថមេស្សតិ ។

(២១៣) ឆន្នញ្ហិ ឯកាវ មតី សមេតិ
យេ បណ្ឌិតា ឧត្តមភូរិបញ្ញា(១)
យានំ អយានំ អថវាបិ ឋានំ
មហោសធ ត្វំបិ មតី ករោហិ ។

១ ឧ. ឧត្តមប្បញ្ញា ។



(២១០) (ព្រះបាទវិទេហៈ...) នែសេនកៈ អ្នកបានជួបនឹងមហោសធដែរឬ អ្នកចូរពោលសេចក្តីនោះ អ្នកបានពន្យល់ឲ្យមហោសធយល់ហើយ ឬ មហោសធត្រេកអរហើយឬ ។

(២១១) (សេនកទូលថា...) បពិត្រព្រះអង្គជាធំជាងជន មហោសធនោះ ពេញជាបុរសថោកទាប គ្មានសេចក្តីស្មោះស្មើ ជាមនុស្សរឹងរូស ជាអសប្បុរស គ្មានពោលសេចក្តីអ្វីពីបណ្ដោយសោះ ដូចជាមនុស្សគ ឬដូចជាមនុស្សថ្លង់ ។

(២១២) (ព្រះបាទវិទេហៈ...) ពិតណាស់ការដែលគិតនោះបុរសរកឃើញបានក្រណាស់ ដោយពិត សេចក្តីបរិសុទ្ធ នរជនអ្នកមានព្យាយាមមុខជានឹងឃើញ ហេតុនោះ កាយរបស់អញញាប់ញ័រ អ្នកណានឹងលះបង់នូវដៃរបស់ខ្លួន ហើយលុះនៅក្នុងកណ្ដាប់ដៃជនដទៃវិញកើត ។

(២១៣) គំនិតរបស់យើង ទាំង ៦ នាក់ ដែលជាអ្នកប្រាជ្ញ មានប្រាជ្ញាដ៏ខ្ពង់ខ្ពស់បំផុត ដូចផែនដី ស្មើគ្នាជាឯកច្ឆន្ទ នែមហោសធ អ្នកចូរគិតមើល ទៅឬកុំទៅ ឬក៏ឈប់ ។

(២១៤) ជាតាសិ តោ រាជ មហានុភាវោ
បហូតភោ ធនុមិព្រហ្មវន្តោ
រាជា ច តំ វន្ទតិ មាវណោត្ថំ
មិគំ យថា ឱការមវេន លុទ្ធោ ។
យថាបិ មច្ឆោ ពលិសំ វង្កំ មំសេន ឆាទិតំ
អាមគិទ្ធោ ន ជានាតិ មច្ឆោ មរណមត្តនោ ។
ឯវមេវ តុវំ រាជ ចូឡនេយ្យស្ស ធីតរំ
កាមគិទ្ធោ ន ជានាសិ មច្ឆោ មរណមត្តនោ ។
សចេ គច្ឆសិ បញ្ចាលំ ខិប្បមត្តំ ជហិស្សសិ
មិគំ បន្ថានុពន្ធំវ មហន្តំ ភយមេស្សតិ ។
(២១៥) មយមេវ ពាលម្ហសេ ឯឡមូគា
យេ ឧត្តមត្ថានិ តយី លបិម្ហា
កិមេវ តុំ នង្គលកោដិវឌ្ឍោ
អត្ថានិ ជានាសិ យថាបិ អញ្ញេ ។
(២១៦) ឥមំ គលេ គហេត្វាន នាសេថ វិជិតា មម
យោ មេ រតនលាភស្ស អន្តរាយាយ ភាសតិ ។



(២១៤) (ព្រះមហាសត្វ...) បពិត្រព្រះរាជា សូមព្រះអង្គទ្រង់ជ្រាបថា ព្រះបាទចូឡនីព្រហ្មទត្ត ជាអ្នកមានអានុភាពធំ មានពលច្រើន ផ្សព្វព្រះរាជា ដើម្បីនឹងសំឡាប់ព្រះអង្គ ដូចនាយព្រានដែលសំឡាប់ម្រឹគដោយឈ្នាក់ ។ ត្រីជាសត្វជាប់ចិត្តក្នុងចំណីស្រួស( លេប ) ផ្លែសន្ទូចដែលគេបិទបាំងដោយសាច់ មិនដឹងសេចក្តីស្លាប់ខ្លួនឡើយណា ។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកជាប់ក្នុងកាម បង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គដូចត្រីនោះឯង ។ បើព្រះអង្គស្តេចយាងទៅ កាន់ក្រុងបញ្ចាល ព្រះអង្គមុខជានឹងលះបាត់ព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គដូចភ័យធំមកដល់ម្រឹគដែលដើរទៅតាមផ្លូវ (ទៀបច្រកនៃស្រុកដែរ) ។

(២១៥) (ព្រះបាទវេទេហៈ...) យើងដែលបាននិយាយនូវប្រយោជន៍ដ៏ឧត្តមក្នុងសំណាក់នៃអ្នក ត្រឡប់ទៅជាមនុស្សល្ងង់ល្ងើវិញ អ្នកឯងជាអ្នកចំរើនដោយចុងនង្គ័ល ម្តេចនឹងដឹងសេចក្តីចំរើនដូចអ្នកដទៃកើត ។

(២១៦) អ្នកទាំងឡាយចូរចាប់អ្នកនេះត្រង់ក ហើយនិរទេសចាកដែនរបស់អញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ ។

(២១៧)តតោ ច សោ អបក្កម្ម វេទេហស្ស ឧបន្តិកា
អថ អាមន្តយី ទូតំ មាធុរំ សុវបណ្ឌិតំ ។
ឯហិ សម្ម ហរិតបក្ខ វេយ្យាវច្ចំ ករោហិ មេ
អត្ថិ បញ្ចាលរាជស្ស សាលិកា សយនបាលិកា ។
តំ សន្ធនេន(១) បុច្ឆស្សុ សា(២) ហិ សព្វស្ស កោវិទា
សា តេសំ សព្វំ ជានាតិ រញ្ញោ ច កោសិយស្ស ច ។
អាមោតិ សោ បដិស្សុត្វា មាធុរោ សុវបណ្ឌិតោ
អគមាសិ ហរិតបក្ខោ សាលិកាយ ឧបន្តិកំ ។
តតោ ច ខោ សោ គន្ត្វាន មាធុរោ សុវបណ្ឌិតោ
អថ អាមន្តយី សុឃរំ សាលិកំ មញ្ជុភាណិកំ ។
កច្ចិ តេ សុឃរេ ខមនីយំ កច្ចិ វេស្សេ អនាមយំ
កច្ចិ តេ មធុនា លាជំ លភសិ សុឃរេ តុវំ ។
កុសលញ្ចេវ មេ សម្ម អថោ សម្ម អនាមយំ
អថោ មេ មធុនា លាជា លព្ភតេ សុវបណ្ឌិត ។
កុតោ នុ សម្ម អាគម្ម កស្ស វា បហិតោ តុវំ
ន ច មេសិ ឥតោ បុព្វេ ទិដ្ឋោ វា យទិ វា សុតោ ។

---
១ ម. ពន្ធនេន ។ ២ ម. សាយំ ។



(៦១៧) (អភិសម្ពុទ្ធគាថា) លំដាប់នោះ មហោសធបណ្ឌិតចៀសចេញអំពីសំណាក់នៃព្រះបាទវេទេហៈហើយ ទើបហៅសុវបណ្ឌិតឈ្មោះមាធុរៈ ជាទូតមកប្រាប់ថា ម្នាលសំឡាញ់មានស្លាបខៀវ អ្នកចូរមកធ្វើការបំរើអញ ព្រោះមានសាលិកាញីមួយដែលគេចិញ្ចឹមទុកដាក់ទីក្រឡាបន្ទំនៃព្រះបាទបញ្ចាល ។ ឯងចូរទៅសួរសាលិកានោះដោយសព្វគ្រប់ ព្រោះថាសត្វនោះស្គាល់កិច្ចទាំងពួង ក៏ដឹងការណ៍ការកិច្ចទាំងពួង របស់ជនទាំងពីរ គឺព្រះរាជានិងកោសិយ-ព្រាហ្មណ៍ ។ មាធុរៈសុវបណ្ឌិតមានស្លាបខៀវនោះ បានទទួលស្តាប់ថាបាទម្ចាស់ហើយ ក៏ហើរទៅកាន់សំណាក់នៃនាងសាលិ-កា ។ មាធុរៈសុវបណ្ឌិត លុះហើរទៅដល់ហើយ ទើបហៅនាងសាលិកាមានទ្រនំល្អ ពោលពាក្យពីរោះថា នែនាងមានទ្រនំល្អ នាងល្មមអត់ទ្រាំបានដែរឬ នែនាងជាវេសជាតិ នាងមិនមានជម្ងឺតម្កាត់ទេឬ នែនាងមានទ្រនំល្អ នាងបានលាជលាយដោយទឹកឃ្មុំដែរឬ ។

(សាលិកាញី...) ម្នាលសំឡាញ់ សេចក្តីសុខស្រួលមានដល់ខ្ញុំ ម្នាលសំឡាញ់ មួយទៀត ខ្ញុំមិនមានជម្ងឺតម្កាត់ទេ ម្នាលសុវ-បណ្ឌិត ចំណីលាជលាយដោយទឹកឃ្មុំ ខ្ញុំក៏បានដែរ ។ នែសំឡាញ់ អ្នកមកអំពីណាហ្ន៎ ឬអ្នកណាប្រើមក មួយវិញទៀត អ្នកជាសត្វដែលខ្ញុំមិនធ្លាប់ឃើញ មិនធ្លាប់ឮក្នុងកាលមុន អំពីកាលនេះទេ ។

(៦៥៨)អហោសិ សិវិរាជស្ស ពាសាទេ សយនបាលកោ
តតោ សោ ធម្មិកោ រាជា ពទ្ធេ មោចេតិ ពន្ធនា ។
តស្ស មេកា ទុតិយាសិ សាលិកា មញ្ជុភាណិកា
តំ តត្ថ អវធិ សេនោ បេក្ខតោ សុយេរ មម ។
តស្សា កាមា ហិ សម្មត្តោ អាគតោស្មិ តវន្តិកេ
សចេ ករេយ្យ ឱកាសំ ឧភយោ វសេមសេ ។
(៦៥៩)សុវោ ច សុវឹ កាមេយ្យ សាលិកោ បន សាលិកំ
សុវស្ស សាលិកាយេវ សំវាសោ ហោតិ កីទិសោ ។
(៦៦០)យោ យំ កាមេ កាមយតិ អបិ ចណ្ឌាលិកាមបិ
សព្វោ ហិ សទិសោ ហោតិ នត្ថិ កាមេ អសាទិសោ ។
អត្ថិ ជម្ពាវតី នាម មាតា សិវិស្ស រាជិនោ
សា បិយា⁽¹⁾ វាសុទេវស្ស កណ្ហស្ស ច មហេសិយា⁽²⁾ ។
រថវតី⁽³⁾ កឹបុរិសី សាបិ វច្ឆំ អកាមយិ
មនុស្សោ មិគិយា សទ្ធឹ នត្ថិ កាមេ អសាទិសោ ។

១ ម. ភរិយា ។ ២ ម. កណ្ហស្ស មហេសី បិយា ។ ៣ ម. រដ្ឋវតី ។



(៦៥៨) (ស៊ុវបណ្ឌិត...) ខ្ញុំគេចិញ្ចឹមទុកនៅទីបន្ទំក្នុងប្រាសាទនៃព្រះបាទសិវិ ព្រះរាជានោះទ្រង់ឋិតនៅក្នុងធម៌ ក៏ទ្រង់ដោះលែងនូវសត្វទាំងឡាយដែលជាប់ចំណង ចាកចំណងអំពីទីនោះ ។ មាននាងសាលិកាមួយ ពោលពាក្យពីរោះ ជាភរិយារបស់ខ្ញុំ ខ្ញុំនិងនាង មានប្រុសល្អ កាលខ្ញុំកំពុងតែសម្លឹងមើលចំពោះ ស្រាប់តែខ្លែងសំឡាប់នាងសាលិកានោះទៅ ។ ខ្ញុំប៉ងប្រាណ ដោយសេចក្តីស្រឡាញ់ចំពោះភរិយានោះ ទើបជាមកក្នុងសំណាក់នៃនាង ប្រសិនបើនាងបើកឱកាស យើងទាំងពីរនាក់នឹងនៅក្នុងទីជាមួយគ្នា ។

(៦៥៩) (សាលិកា ...) ធម្មតាសេកឈ្មោលគួរតែស្រឡាញ់សេកញី សាលិកាឈ្មោលគួរតែស្រឡាញ់សាលិកាញី ចុះការនៅរួមជាមួយសេកឈ្មោលនឹងសាលិកាញី ដូចម្តេចកើត ។

(៦៦០) (ស៊ុវបណ្ឌិត... ) បុគ្គលណា ស្រឡាញ់ស្រីណាក្នុងកាម សូម្បីស្រីនោះជាចណ្ឌាលក៏ដោយ ព្រោះថាការនៅរួមទាំងអស់ដូចគ្នា ដែលមិនដូចគ្នាក្នុងកាមមិនមានទេ ។ ព្រះមាតានៃព្រះបាទសិវិ ព្រះនាមជម្ពាវតី (ជាចណ្ឌាលនារី) តែងតែជាអគ្គមហេសី ជាទីស្រឡាញ់របស់ព្រះបាទវាសុទេវកណ្ហាយនគោត្រ ។ សូម្បីនាងកិន្នរីឈ្មោះរថវតី ញុំាងកាមសេវនាឈ្មោះវច្ឆៈឲ្យស្រឡាញ់ដែរ ។ មនុស្សរួមសំវាសជាមួយនឹងមេម្រឹគក៏មាន ការនៅរួមក្នុងកាមមិនដូចគ្នាមិនមានទេ ។

ហន្ទ ខោ តំ គមិស្សាមិ សាលិកេ មញ្ជុភាណិកេ

បច្ចក្ខានុបទំ ហេតំ អតិមញ្ញសិ នូន មំ ។

(៦៦១) ន សិរី តរមានស្ស មាធុរ សុវបណ្ឌិត

ឥធេវ តាវ អច្ឆស្សុ យាវ រាជាន ទក្ខសិ

សោសិ សទ្ទំ មុទិង្គានំ អានុភាវញ្ច រាជិនោ ។

(៦៦២) យោ នុ ខ្វាយំ តិព្វោ សទ្ទោ តិរោជនបទេ សុតោ

ធីតា បញ្ចាលរាជស្ស ឱសធី វិយ វណ្ណិនី

តំ ទស្សតិ វិទេហានំ សោ វិវាហោ ភវិស្សតិ ។

(៦៦៣) ឯទិសោ មា អមិត្តានំ វិវាហោ ហោតុ មាធុរ

យថា បញ្ចាលរាជស្ស វេទេហេន ភវិស្សតិ ។

អានយិត្វាន វេទេហំ បញ្ចាលានំ រថេសភោ

តតោ នំ ឃាតយិស្សតិ នាស្ស សខី ភវិស្សតិ ។

(៦៦៤) ហន្ទ ខោ មំ អនុជានាហិ រត្តិយោ សត្តមត្តិយោ

យាវាហំ សិវិរាជស្ស អារោចេមិ មហេសិនោ

លទ្ធោ ច មេ អាវសថោ សាលិកាយ ឧបន្តិកា ។



នែនាងសាលិកា ពោលពាក្យពីរោះ បើដូច្នោះ យើងនឹងទៅវិញ

ព្រោះពាក្យនាងនុ៎ះទុកជាពាក្យប្រកែក នាងមើលងាយខ្ញុំពិត ។

(៦៦១)(សាលិកា...) នែមាធុរៈសុវបណ្ឌិត សិរីមែនមិនមានដល់អ្នកប្រ-

ញាប់ទេ អ្នកចូរឈប់នៅទីនេះ ដរាបដល់ឃើញព្រះរាជាសិន

អ្នកនឹងបានស្តាប់សំឡេងស្គរ បានឃើញអានុភាពព្រះរាជា ។

(៦៦២)(សុវណ្ណក...) សំឡេងអឺងកងនេះ ឮល្បីក្រៃពេកទៅដល់ជនបទ

ខាងក្រៅផង ព្រះរាជធីតាព្រះបាទបញ្ចាល មានវណ្ណៈដូចជា

ផ្កាយព្រឹក ព្រះអង្គនឹងប្រទានព្រះរាជធីតានោះ ដល់ព្រះបាទ

វិទេហៈ អាពាហមង្គលនោះគឺនឹងមានហើយ ( កើតឡើង ) ។

(៦៦៣)(សាលិកា...) នែមាធុរៈ ការរៀបអាពាហមង្គលប្រាកដដូចនេះ

របស់ពួកសត្រូវ ដូចអាពាហមង្គល របស់ព្រះបាទបញ្ចាលជា

មួយនឹងព្រះបាទវិទេហៈរបស់អ្នក ចូរលើកទុកចុះ ។ ព្រោះជាធំ

ប្រសើរលើរថ របស់អ្នកក្រុងបញ្ចាល នឹងនាំព្រះបាទវិទេហៈមក

ហើយនឹងសំឡាប់ព្រះបាទវិទេហៈនោះ ក្នុងវេលានោះ (ព្រះបាទ

ចូឡនី) មិនមែនជាសំឡាញ់របស់ព្រះបាទវិទេហៈនោះទេ ។

(៦៦៤)(សុវណ្ណក...) សូមនាងអនុញ្ញាតឲ្យបងទៅត្រឹម ៧ រាត្រី ទំរាំ

បងទូលព្រះបាទសិវិនឹងព្រះមហេសីថា ខ្ញុំបាននៅរួមក្នុងសំណាក់

នាងសាលិកាហើយ ។

(៦៦៥)ហន្ទ តេហំ អឌ្ឍជាតាមិ រត្តិយោ សត្តមត្តិយោ

សចេ តុំ សត្តរត្តេន នាគច្ឆសិ មមន្តិកំ

មញ្ញេ ឱក្កន្តសត្តំ មំ មតាយ អាគមិស្សសិ ។

(៦៦៦)តតោ ច ខោ សោ គន្ត្វាន មាឋរោ សុវបណ្ឌិតោ

មហោសធស្ស អក្ខាសិ សាលិកាយ វចំ ឥទំ ។

៦៦៧) យស្សេវ ឃរេ ភុញ្ជេយ្យ ភោគំ

តស្សេវ អត្ថំ បុរិសោ ចរេយ្យ ។

(៦៦៨) ហន្ទាហំ គច្ឆាមិ បុរេ ជនិន្ទ

បញ្ចាលរាជស្ស បុរំ សុរម្មំ

និវេសនានិ មាបេតុំ វេទេហស្ស យសស្សិនោ ។

និវេសនានិ មាបេត្វា វេទេហស្ស យសស្សិនោ

យទា តេ បហិណេយ្យាមិ តទា ឯយ្យាសិ ខត្តិយ ។

(៦៦៩) តតោ ច បាយាសិ បុរេ មហោសធោ

បញ្ចាលរាជស្ស បុរំ សុរម្មំ

និវេសនានិ មាបេតុំ វេទេហស្ស យសស្សិនោ ។

និវេសនានិ មាបេត្វា វេទេហស្ស យសស្សិនោ

អថស្ស បាហិណី ទូតំ វេទេហំ មិថិលគ្គហំ

ឯហិ ទានិ មហារាជ មាបិតំ តេ និវេសនំ ។



(៦៦៥)(សាលិកា ...) តើ ខ្ញុំគង់រង់ចាំអ្នកទៅត្រឹម ៧ រាត្រី បើអ្នកមិនត្រឡប់មកកាន់សំណាក់ខ្ញុំក្នុងរាត្រីទីប្រាំពីរទេ ខ្ញុំសំគាល់ខ្លួនខ្ញុំថា ដល់មរណៈ កាលបើខ្ញុំស្លាប់ហួសទៅហើយ ទើបអ្នកនឹងមកដល់ ។

(៦៦៦) (អភិសម្ពុទ្ធគាថា) លំដាប់នោះ មាឋរៈសុវបោតកនោះក៏ហើរទៅ ក្រាបទូលមហោសថ ពាក្យនេះ ជាពាក្យរបស់នាងសាលិកា ។

(៦៦៧) (មហោសធ. .) បុរសគប្បីបរិភោគ ភោគសម្បត្តិក្នុងផ្ទះរបស់បុគ្គលណា គប្បីធ្វើប្រយោជន៍ដល់បុគ្គលនោះឯង ។

(៦៦៨) បពិត្រព្រះជនិន្ទ ខ្ញុំព្រះអង្គនឹងសូមទៅកាន់បុរីគួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បុរីព្រះអង្គមានយសធំក្នុងដែនវិទេហៈ ។ បពិត្រក្សត្រិយ៍ លុះខ្ញុំព្រះអង្គសាងនិវេសន៍ដើម្បីព្រះអង្គមានយសក្នុងដែនវិទេហៈស្រេចហើយ នឹងបញ្ជូនទូតមកទូលព្រះអង្គ ក្នុងវេលាណា ព្រះអង្គគប្បីយាងទៅក្នុងវេលានោះ ។

(៦៦៩) (អភិសម្ពុទ្ធគាថា)លំដាប់នោះឯង ព្រះមហោសថក៏បានទៅកាន់បុរីគួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បុរីព្រះបាទវិទេហៈមានយស ។ ព្រះមហោសថលុះសាងនិវេសន៍ដើម្បីព្រះបាទវិទេហៈមានយសស្រេចហើយ ទើបបញ្ជូនទូតមកទូលព្រះបាទវិទេហៈគ្រប់គ្រងមិថិលាថា បពិត្រមហារាជ និវេសន៍ខ្ញុំព្រះអង្គសាងដើម្បីព្រះអង្គហើយ សូមព្រះអង្គស្ដេចមកក្នុងកាលឥឡូវនេះ ។

(៦៣០)តតោ ច រាជា បាយាសិ    សេនាយ ចតុរង្គិយា
អនន្តវាហនំ ទដ្ឋុំ    ផីតំ កបិលិយំ បុរំ ។
(៦៣១)តតោ ច បាវេសិ គន្ត្វាន ព្រហ្មទត្តស្ស បាហិណិ
អាគតោស្មិ មហារាជ តវ បាទានិ វន្ទិតុំ ។
ទទាហិ ទានិ មេ ភរិយំ    នារឹ សព្វង្គសោភនឹ
សុវណ្ណេន បដិច្ឆន្នំ    ទាសីគណបុរក្ខតំ ។
(៦៣២)ស្វាគតន្តេ វេទេហ    អថោ តេ អទុរាគតំ
នក្ខត្តញ្ញេវ បរិបុច្ឆ    អហំ កញ្ញំ ទទាមិ តេ
សុវណ្ណេន បដិច្ឆន្នំ    ទាសីគណបុរក្ខតំ ។
(៦៣៣)តតោ ច រាជា វេទេហោ    នក្ខត្តំ បរិបុច្ឆតិ
នក្ខត្តំ បរិបុច្ឆិត្វា    ព្រហ្មទត្តស្ស បាហិណិ ។
ទទាហិ ទានិ មេ ភរិយំ    នារឹ សព្វង្គសោភនឹ
សុវណ្ណេន បដិច្ឆន្នំ    ទាសីគណបុរក្ខតំ ។



(៦៣០)(អតីតសម្ពុទ្ធភាសិត) លំដាប់នោះឯង ព្រះរាជាព្រមដោយសេនា មានអង្គ ៤ យាងទៅដើម្បីទតបុរីដ៏ថ្កុំថ្កើង ដែលមានបាលស បណ្ដិតសាន់ទុកក្នុងដែនកប្បិលៈ មានពាហនៈមិនមានទីបំផុត ។
(៦៣១) លំដាប់នោះឯងព្រះបាទវេទេហៈនោះ លុះស្ដេចយាងទៅដល់(ដែនកប្បិលៈ)ហើយ ទើបបញ្ជូនរាជសាសន៍ទៅថ្វាយព្រះបាទព្រហ្មទត្តថា បពិត្រមហារាជ ខ្ញុំមកដើម្បីថ្វាយបង្គំព្រះបាទទាំងឡាយរបស់ព្រះអង្គ ។ សូមព្រះអង្គទ្រង់ប្រទាននាងនារីដែលមានសព្វាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសីជាបរិវារឲ្យជាភរិយា (របស់ខ្ញុំ) ក្នុងកាលឥឡូវនេះ ។
(៦៣២)(ព្រះបាទព្រហ្មទ...) បពិត្រព្រះបាទវេទេហៈ ព្រះអង្គស្ដេចមកល្អហើយ មួយទៀត ព្រះអង្គស្ដេចមកមិនអាក្រក់ទេ សូមព្រះអង្គសាកសួររកនក្ខត្តឫក្សចុះ ខ្ញុំនឹងថ្វាយនាងកញ្ញាដ៏ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសីជាបរិវារព្រះអង្គ ។
(៦៣៣)(អតីតសម្ពុទ្ធភាសិត) លំដាប់នោះឯង ព្រះបាទវេទេហៈសួររកនក្ខត្តឫក្ស លុះសួររកនក្ខត្តឫក្សរួចហើយ ទើបបញ្ជូនរាជសាសន៍ទៅថ្វាយព្រះបាទព្រហ្មទត្តថា សូមព្រះអង្គទ្រង់ប្រទាននារីដែលមានសព្វាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយារបស់ខ្ញុំក្នុងកាលឥឡូវនេះ ។

(៤៣៤)ឥមានិ ចិតានិ កេ ករំយំ ធារី សព្វត្ថសោភនី
សុវណ្ណខចិតំ បដិច្ឆន្នំ ធារិតំ ណបុរត្ថិតំ ។

(៤៣៥) ហត្ថី អស្សា រថា បត្តី សេនា តិដ្ឋន្តិ វម្មិកា
នេត្តឹសា បជ្ជិតា ឈាយន្តិ កិន្នុ មញ្ញន្តិ បណ្ឌិតា ។

(៤៣៦)ហត្ថី អស្សា រថា បត្តី សេនា តិដ្ឋន្តិ វម្មិកា
នេត្តឹសា បជ្ជិតា ឈាយន្តិ កិន្នុ កាហន្តិ បណ្ឌិតា ។

(៤៣៧) វត្តតិ តំ មហារាជ ចន្ទ្យនេយ្យោ មហព្ពលោ
ចតុរង្គោ តេ ព្រហ្មទត្តោ ធាតោ តំ ឃាតយិស្សតិ ។

(៤៣៨)ឧព្វេធតិ មេ ហទយំ មុខញ្ច បរិសុស្សតិ
និព្វុតឹ នាធិគច្ឆាមិ អគ្គិទឌ្ឍោវ អាតបេ ។
កម្មារានំ យថា ឧក្កា អន្តោ ឈាយតិ នោ ពហិ
ឯវម្បិ ហទយំ មយ្ហំ អន្តោ ឈាយតិ នោ ពហិ ។



(៤៣៤) (ព្រះបាទចន្ទសូរិយ...) ខ្ញុំក្ដាយធានីនារី ដែលមានសេចក្ដីការយ ដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានក្បួន ពាសីតាំងម៉ារ ឲ្យដាក់ឃាតរបស់ព្រះអង្គ កុំគាលខ្យល់ទោះ ។

(៤៣៥) (ព្រះបាទចន្ទ...) ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ទឹងសេនាពាក់គ្រឿងយោធា (គ្រឿងក្រោះ) ឥតប៉ាងនាក់ក្ដីនេះក្ដីសស្ត្រា សស្ត្រា ទើបភ្លោកហ្នឹងសម្លាប់ខ្ញុំម្ដេច ។

(៤៣៦) (អគ្គសមុទ្ទទេវី) ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ទឹងសេនាពាក់គ្រឿងយោធា (គ្រឿងក្រោះ) ឥតប៉ាងនាក់ក្ដីនេះសស្ត្រា សស្ត្រា នឹងបណ្ឌិត ធ្វើសេនាទាំងនោះ ធ្វើអ្វីហ្ន៎ ។

(៤៣៧) (មហាសេន...) បពិត្រមហារាជ ព្រះបាទចន្ទសូរិយក្រហមទត្ត មានពលច្រើន ប្រមូលកងពលព្រះអង្គ កោះព្រះអង្គទុក នឹង សម្លាប់ព្រះអង្គក្នុងព្រឹក ។

(៤៣៨) (ព្រះបាទចន្ទ...) ហទ័យរបស់យើងញ័ររន្ធត់ មាត់របស់យើងក៏ស្ងួតស្ងួត យើងមិនបាននូវសេចក្ដីរលត់ ដូចជាឈើក្រៀមក្នុងកណ្ដាលកំដៅថ្ងៃ ។ ឧក្កានៃជាងមាសរមែងឆេះ តែខាងក្នុងមិនឆេះខាងក្រៅ យ៉ាងណាមិញ ហទ័យរបស់យើងក៏ឆេះតែខាងក្នុងមិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ ។

(២៣៩) បមត្តោ បន្ធនាគីតោ កិច្ចមេត្តាសំ ទត្តិយ

ឥធាបិ ទោតំ កាយត្ថុ បណ្ឌិតា មន្តិនោ ជនា ។

អកាត្វាមច្ចស្ស វចនំ អត្ថកាមហិតេសិនោ

អត្តបីតិរតោ រាជ មិគោ កូដេវ ទុហិតោ ។

យថាបិ មច្ឆោ ពលិសំ វង្កំ មំសេន ឆាទិតំ

អាមគិទ្ធោ ន ជានាតិ មច្ឆោ មរណមត្តនោ ។

ឯវមេវ តុវំ រាជ ចូឡនេយ្យស្ស ធីតរំ

កាមគិទ្ធោ ន ជានាសិ មច្ឆោវ មរណមត្តនោ ។

សចេ គច្ឆសិ បញ្ចាលំ ខិប្បមត្តំ ជហិស្សសិ

មិគំ បន្ថានុពន្ធំវ មហន្តំ ភយមេស្សសិ ។

អនរិយរូបោ បុរិសោ ជនិន្ទ

អហីវ ឧច្ឆង្គគតោ ឌំសេយ្យ

ន តេន មិត្តិំ កយិរាថ ធីរោ

ទុក្ខោ ហវេ កាបុរិសេន សង្គមោ ។



(៦៧៩) (មហោសធ...) បពិត្រទេវ ព្រះអង្គស្រវឹង (ដោយកាម) ទើបប្រព្រឹត្តខុសការប្រឹក្សា ទំលាយការប្រឹក្សាចោល ដូច្នេះ សូមឲ្យបណ្ឌិត (ទាំង ៤ នាក់) ដែលជាអ្នកមានប្រាជ្ញា ទូលព្រះអង្គចុះ ។ បពិត្រព្រះរាជា ព្រះអង្គមិនធ្វើតាមពាក្យរបស់ខ្ញុំព្រះបង្គំជាអាមាត្យ ជាអ្នកប្រាថ្នាសេចក្តីចំរើនដ៏នឹងស្វែងរកប្រយោជន៍ ទ្រង់ត្រេកអរដោយបីតិដ៏សៅហ្មងរបស់ព្រះអង្គ ដូចម្រឹគជាប់អន្ទាក់ ។ (ខ្ញុំព្រះបង្គំចុះក្រាបទូលហើយថា) ត្រីជាសត្វល្មោភក្នុងរសស្រស់ លេបសន្ទូចដ៏ពួកខ្លួនមិនឃើញដែលគេបិទបាំងដោយសាច់ ត្រីមិនដឹងសេចក្តីស្លាប់របស់ខ្លួន យ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកល្មោភក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គ ដូចត្រីយ៉ាងនោះឯង ។ បើទ្រង់ស្តេចទៅកាន់ក្រុងបញ្ចាល ទ្រង់មុខជានឹងលះបង់ព្រះអង្គ យ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគ ដែលដើរទៅតាមផ្លូវ (ទៀបទ្វារនៃស្រុក) ។ បពិត្រព្រះជនិន្ទ បុរសមានសភាពមិនថ្លៃថ្នូរ ដូចពស់នៅក្នុងចុងក្បិន បុរសមានប្រាជ្ញាមិនគប្បីធ្វើនូវមេត្រីភាពដោយបុរសនោះទេ ព្រោះថា ការសេពគប់ដោយបុរសអាក្រក់ រមែងនាំមកនូវសេចក្តីទុក្ខដោយពិត ។

យំ ត្វេវ ជញ្ញា បុរិសោ ជនិន្ទ
សីលវាយំ ពហុស្សុតោ
តេនេវ មិត្តិំ កយិរាថ ធីរោ
សុខោ ហវេ សប្បុរិសេហិ សង្គមោ ។
(៥៦០) ពាលោ តុវំ ឯលមូគោសិ រាជ
យោ ឧត្តមត្ថានិ មយី លបិត្ថោ
កិមេទិហំ(១) នង្គលកោដិវឌ្ឍោ
អត្ថានិ ជានិស្សតិ យថាបិ អញ្ញេ ។
ឥមំ គលេ គហេត្វាន នាសេថ វិជិតា មម
យោ មេ រតនលាភស្ស អន្តរាយាយ ភាសតិ ។
(៥៦១)មហោសធ អតីតេន នានុវិជ្ជន្តិ បណ្ឌិតា
កឹ មំ អស្សំវ សម្ពន្ធំ បតោទេនេវ វិជ្ឈសិ ។
សចេ បស្សសិ មោក្ខំ មេ ខេមំ វា បន បស្សសិ
តេនេវ មំ អនុសាស កឹ អតីតេន វិជ្ឈសិ ។

---
១ ម. កេទិសំ ។



បពិត្រព្រះជនិន្ទ បណ្ឌិតបុរសស្គាល់នូវបុគ្គលណាថា អ្នកនេះមានសីល មានការចេះដឹងច្រើនដូច្នេះ បណ្ឌិតបុរសនោះគួរធ្វើមេត្រីភាពជាមួយនឹងបុគ្គលនោះ ព្រោះថាការសេពគប់ដោយសប្បុរសទាំងឡាយ រមែងនាំមកនូវសេចក្ដីសុខពិត ។

(៥៦០) បពិត្រព្រះរាជា ព្រះអង្គជាមនុស្សល្ងង់ល្ងីលា បានពោលនូវសេចក្ដីចំរើនដ៏ឧត្តម ក្នុងសំណាក់នៃខ្ញុំព្រះអង្គថា ខ្ញុំព្រះអង្គជាអ្នកចំរើនដោយចុងនង្គ័ល ធ្វើម្ដេច នឹងដឹងនូវសេចក្ដីចំរើនដូចអ្នកដទៃ ។ អ្នកទាំងឡាយ ចូរចាប់មហោសធនេះត្រង់ក ហើយឲ្យនិរាសចាកដែន របស់អញចេញទៅ ព្រោះវាហ៊ាននិយាយដើម្បីអន្តរាយនូវការបានស្រីកែវ ។

(៥៦១)(ព្រះបាទវេទេហៈ...) ម្នាលមហោសធ បណ្ឌិតទាំងឡាយ រមែងមិនចាក់ដោតដោយពាក្យដែលកន្លងទៅហើយទេ អ្នកចាក់ដោតយើង ដូចជាគេយកជន្លួញចាក់សេះ ដែលចងទុកហើយ ធ្វើអ្វី ។ ប្រសិនបើអ្នកឃើញសេចក្ដីរួចរបស់យើង ឬឃើញសេចក្ដីក្សេមរបស់យើង អ្នកចូរពន្យល់យើងដោយសេចក្ដីការនោះចុះ អ្នកចាប់ចាក់ដោតយើង ដោយពាក្យដែលកន្លងទៅហើយ ធ្វើអ្វី ។

(២៦២)អតីតំ មានុសំ កម្មំ ទុក្ករំ ទុរភិសម្ភវំ

ឯតំ សក្កោមិ មោចេតុំ ត្វំ បជានស្សុ ខត្តិយ ។

សន្តិ វេហាយសា នាគា ឥទ្ធិមន្តោ យសស្សិនោ

តេបិ អាទាយ គច្ឆេយ្យុំ យស្ស ហោន្តិ តថាវិធា ។

សន្តិ វេហាយសា អស្សា ឥទ្ធិមន្តោ យសស្សិនោ

តេបិ អាទាយ គច្ឆេយ្យុំ យស្ស ហោន្តិ តថាវិធា ។

សន្តិ វេហាយសា បក្ខី ឥទ្ធិ មន្តា យសស្សិនោ

តេបិ អាទាយ គច្ឆេយ្យុំ យស្ស ហោន្តិ តថាវិធា ។

សន្តិ វេហាយសា យក្ខា ឥទ្ធិមន្តោ យសស្សិនោ

តេបិ អាទាយ គច្ឆេយ្យុំ យស្ស ហោន្តិ តថាវិធា ។

អតីតំ មានុសំ កម្មំ ទុក្ករំ ទុរភិសម្ភវំ

ឯតំ សក្កោមិ មោចេតុំ អន្តលិក្ខេន ខត្តិយ ។

(២៦៣)អតីរទស្សី បុរិសោ មហន្តេ ឧទកណ្ណវេ

យត្ថ សោ លភតេ គាធំ[១] តត្ថ សោ វិន្ទតេ សុខំ ។

---

១ ម. ឋី ។



(២៦២) (មហាសត្វ...) អំពើជារបស់នៃមនុស្ស ដែលកន្លងហួសទៅហើយ ជាអំពើដែលធ្វើបានដោយក្រ សម្រេចវិញបានដោយក្រ ខ្ញុំព្រះអង្គមិនអាចនឹងដោះព្រះអង្គបានទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបចុះ ។ ដំរីទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន ដំរីបែបនោះ របស់ព្រះរាជាណា សូមឲ្យដំរីទាំងនោះនាំព្រះរាជានោះទៅចុះ ។ សេះទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន សេះបែបនោះរបស់ព្រះរាជាណា សូមឲ្យសេះទាំងនោះ នាំព្រះរាជានោះទៅចុះ ។ បក្សីទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន បក្សីបែបនោះរបស់ព្រះរាជាណា សូមឲ្យបក្សីទាំងនោះនាំព្រះរាជានោះទៅចុះ ។ យក្សទាំងឡាយមានឫទ្ធិ មានយស អាចទៅតាមអាកាសបាន យក្សបែបនោះ របស់ព្រះរាជាណា សូមឲ្យយក្សទាំងនោះ នាំព្រះរាជានោះទៅចុះ ។ អំពើជារបស់នៃមនុស្ស ដែលកន្លងហួសទៅហើយ ជាអំពើដែលធ្វើបានដោយក្រ សម្រេចវិញបានដោយក្រ បពិត្រក្សត្រិយ៍ ខ្ញុំព្រះអង្គមិនអាចដោះព្រះអង្គ ទៅតាមអាកាសបានទេ ។

(២៦៣) (ការព្យាសេនកៈ ...) បុរសជាអ្នកមិនឃើញត្រើយ ក្នុងមហាសមុទ្រ បុរសនោះបានទីពំនាក់ ក្នុងប្រទេសណា គេក៏បានសេចក្ដីសុខ ក្នុងប្រទេសនោះ (យ៉ាងណាមិញ) ។

ឃរំ អព្ភុញ្ញ រញ្ញោ ច ត្វំ បតិដ្ឋា មហោសធ
ត្វំ នោសិ មន្តិនំ សេដ្ឋោ អម្ហេ ទុក្ខា បមោចយ ។

(៦៤៤) អតីតំ មានុសំ កម្មំ ទុក្ករំ ទុរភិសម្ភវំ
ន តំ សក្កោមិ មោចេតុំ ត្វំ បជានស្សុ សេនក ។

(៦៤៥) សុណោហិ មេតំ វចនំ បស្សសេតំ មហព្ភយំ
សេនកំ ទានិ បុច្ឆាមិ កឹ កិច្ចំ ឥធ មញ្ញសិ ។

(៦៤៦) អគ្គឹ វា ទ្វារតោ ទេម គណ្ហាមសេ វិកន្តនំ
អញ្ញមញ្ញំ វធិត្វាន ខិប្បំ ហិស្សាម ជីវិតំ
មា នោ រាជា ព្រហ្មទត្តោ ចិរំ ទុក្ខេន មារយិ ។

(៦៤៧) សុណោហិ មេតំ វចនំ បស្សសេតំ មហព្ភយំ
បុក្កុសំ ទានិ បុច្ឆាមិ កឹ កិច្ចំ ឥធ មញ្ញសិ ។

(៦៤៨) វិសំ ខាទិត្វា មិយ្យាម ខិប្បំ ហិស្សាម ជីវិតំ
មា នោ រាជា ព្រហ្មទត្តោ ចិរំ ទុក្ខេន មារយិ ។



បពិត្រមហោសធ អ្នកជាទីពឹងរបស់ពួកយើងនិងព្រះរាជា ក៏យ៉ាងនោះដែរ ព្រោះអ្នកជាបុគ្គលប្រសើរជាងពួកយើងនិងពួកមន្ត្រី សូមអ្នកដោះពួកយើងអំពីទុក្ខ ។

(៦៤៤) (មហោសធ...) អំពើជារបស់នៃមនុស្ស ដែលកន្លងហួសទៅហើយ ជាអំពើធ្វើតែបានដោយក្រ សម្រេចបានដោយក្រ ខ្ញុំមិនអាចនឹងដោះអ្នកបានទេ នែសេនកៈ អ្នកចូរដឹងចុះ ។

(៦៤៥) (ព្រះបាទវិទេហៈ...) អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុះ (ស្រាប់ហើយ) ម្នាលសេនកៈ ឥឡូវនេះ អញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ។

(៦៤៦) (ពាក្យសេនកៈ...) ពួកយើងនាំគ្នាដុតភ្លើងត្រង់ទ្វារ ឬកាន់កាំបិតសម្លាប់គ្នានឹងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ កុំឱ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើង ឱ្យលំបាកអស់កាលយូរឡើយ ។

(៦៤៧) (ព្រះបាទវិទេហៈ...) អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុះ (ស្រាប់ហើយ) ម្នាលបុក្កុសៈ ឥឡូវនេះ អញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ។

(៦៤៨) (ពាក្យបុក្កុសៈ...) ពួកយើងគួរស៊ីថ្នាំពិសឱ្យស្លាប់ នឹងលះបង់ជីវិតយ៉ាងឆាប់ កុំឱ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើង ឱ្យលំបាកអស់កាលយូរឡើយ ។

(៤៦៩) សុណោហិ មេតំ វចនំ បស្ស សេនំ មហព្ភយំ
កាមិន្ទំ ទានិ បុច្ឆាមិ កិំ កិច្ចំ ឥធ មញ្ញសិ ។
(៤៧០) រជ្ជុយា ពជ្ឈ មិយ្យាម បបាតា បបតាមសេ
មា នោ រាជា ព្រហ្មទត្តោ ចិរំ ទុក្ខេន មារយិ ។
(៤៧១) សុណោហិ មេតំ វចនំ បស្ស សេនំ មហព្ភយំ
ទេវិន្ទំ ទានិ បុច្ឆាមិ កិំ កិច្ចំ ឥធ មញ្ញសិ ។
(៤៧២) អគ្គិំ វា ទ្វារតោ ទេម គណ្ហាមសេ វិកន្តនំ
អញ្ញមញ្ញំ វធិត្វាន ខិប្បំ ហិស្សាម ជីវិតំ
ន នោ សក្កោតិ មោចេតុំ សុខេនេវ មហោសធោ ។
(៤៧៣) យថា កទលិយា សារំ អន្វេសំ នាធិគច្ឆតិ
ឯវំ អន្វេសមានា នំ បញ្ហំ នជ្ឈគមាមសេ ។
យថា សិម្ពលិយា សារំ អន្វេសំ នាធិគច្ឆតិ
ឯវំ អន្វេសមានា នំ បញ្ហំ នជ្ឈគមាមសេ ។



(៤៦៩) (ព្រះបាទវិទេហៈ...) អ្នកចូរស្តាប់ពាក្យ របស់យើងនេះ អ្នកឃើញភ័យធំនុះ (ស្រាប់ហើយ) ម្នាលកាមិន្ទៈ ឥឡូវនេះ អញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ។

(៤៧០) (កាមិន្ទៈ...) ពួកយើងគប្បីយកខ្សែចងឲ្យស្លាប់ ឬលោតចុះទៅក្នុងអណ្តូង (ឲ្យស្លាប់) កុំឲ្យព្រះបាទព្រហ្មទត្ត សម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ ។

(៤៧១) (ព្រះបាទវិទេហៈ...) អ្នកចូរស្តាប់ពាក្យ របស់យើងនេះ អ្នកឃើញភ័យធំនុះ (ស្រាប់ហើយ) ម្នាលទេវិន្ទៈ ឥឡូវនេះ អញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ ។

(៤៧២) (ទេវិន្ទៈ...) ពួកយើង (បិទទ្វារ) ដុតភ្លើង ហើយកាន់កាំបិតសម្លាប់គ្នានឹងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ (ព្រោះ) មហោសធមិនអាចនឹងដោះពួកយើងឲ្យរួចបានដោយស្រួលទេ ។

(៤៧៣) (ព្រះបាទវិទេហៈ ) បុគ្គលស្វែងរកខ្លឹម នៃដើមចេក រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរក (ឧបាយជាគ្រឿងរួចខ្លួន) ក៏មិនបានប្រស្នានោះ ក៏យ៉ាងនោះដែរ ។ បុគ្គលស្វែងរកខ្លឹមនៃដើមរកា រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរក ក៏មិនបានប្រស្នានោះ ក៏យ៉ាងនោះដែរ ។

អនេសេ វត ភោ វុឌ្ឍិ កុញ្ជរំវ អនូទកេ

សក្កាសេ ទុម្មនុស្សានំ ពាលានំ អវិជានតំ ។

ឧព្ភេជតំ មេ ហទយំ មុខញ្ច បរិសុស្សតិ

និព្វុតឹ នាធិគច្ឆាមិ អគ្គិទឌ្ឍោវ អាតបេ ។

កម្មារានំ យថា ឧក្កា អន្តោ ឈាយតិ នោ ពហិ

ឯវម្បិ ហទយំ មយ្ហំ អន្តោ ឈាយតិ នោ ពហិ ។

[៤៨៦] តតោ សោ បណ្ឌិតោ ធីរោ អត្ថទស្សី មហោសធោ

វេទេហំ ទុក្ខិតំ ទិស្វា ឥទំ វចនមព្រវិ ។

មា ត្វំ ភាយិ មហារាជ មា ត្វំ ភាយិ រថេសភ

អហន្តំ មោចយិស្សាមិ រាហុគ្គហិតំវ ចន្ទិមំ ។

មា ត្វំ ភាយិ មហារាជ មា ត្វំ ភាយិ រថេសភ

អហន្តំ មោចយិស្សាមិ រាហុគ្គហិតំវ សុរិយំ ។





ការនាំនៃដំរីតាំងឆ្ងាយ ក្នុងទីមិនមានទឹក ឈ្មោះថានាំក្នុងទីមិនមែនប្រទេស (យ៉ាងណាមិញ) កាលបើយើងនៅក្នុងទីជិតនៃពួកមនុស្សអាក្រក់ល្ងង់ខ្លៅ មិនចេះមិនដឹង (ឈ្មោះថានៅក្នុងទីមិនមែនជាប្រទេស ក៏ដូច្នោះឯង) ។ ហឫទ័យរបស់យើងញាប់ញ័រខ្លាំង ទាំងមាត់របស់យើងក៏សោះស្គុត យើងមិនបានសេចក្ដីរលត់ ដូចជាឈើត្រូវភ្លើងឆេះ ក្នុងកណ្ដាលកំដៅថ្ងៃ ។ ចង្ក្រានរបស់ជាងមាសឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើងឆេះតែខាងក្នុង មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ ។

[៤៨៦] (អត្ថទស្សី...) វេលានោះ មហោសធជាអ្នកប្រាជ្ញ មានប្រាជ្ញា ឃើញប្រយោជន៍ជាប្រក្រតីនោះ បានឃើញព្រះបាទវិទេហៈ ទ្រង់មានសេចក្ដីទុក្ខ ទើបក្រាបបង្គំទូលថា បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះចន្ទដែលរាហូចាប់ហើយ ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះអាទិត្យ ដែលរាហូចាប់ហើយ ។

មា ត្វំ ភាយិ មហាគជ មា ត្វំ ភាយិ រថេសភ
អហន្តំ មោចយិស្សាមិ បង្កេ សន្នំវ កុញ្ជរំ ។
មា ត្វំ ភាយិ មហាគជ មា ត្វំ ភាយិ រថេសភ
អហន្តំ មោចយិស្សាមិ បេឡាពទ្ធំវ បន្នគំ ។
មា ត្វំ ភាយិ មហាគជ មា ត្វំ ភាយិ រថេសភ
អហន្តំ មោចយិស្សាមិ បក្ខឹ ពទ្ធំវ បញ្ជរេ
មា ត្វំ ភាយិ មហាគជ មា ត្វំ ភាយិ រថេសភ
អហន្តំ មោចយិស្សាមិ មច្ឆេ ជាលគតេរិវ ។
មា ត្វំ ភាយិ មហាគជ មា ត្វំ ភាយិ រថេសភ
អហន្តំ មោចយិស្សាមិ សយោគ្គពលវាហនំ ។
មា ត្វំ ភាយិ មហាគជ មា ត្វំ ភាយិ រថេសភ
បញ្ចាលំ វាហយិស្សាមិ កាកសេនំវ លេឌ្ឌុនា ។
អាទុ បញ្ញា កិមត្ថិយា អមច្ចោ វាបិ តាទិសោ
យោ តំ សម្ពាធបក្ខន្តំ ទុក្ខា ន បរិមោចយេ ។



បពិត្រមហាគជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ខ្ញុំព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះដំរីផុតពីភក់ ។ បពិត្រមហាគជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ខ្ញុំព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះពស់ដែលជាប់នៅក្នុងកំព្រូង ។ បពិត្រមហាគជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ខ្ញុំព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះបក្សី ដែលជាប់នៅក្នុងទ្រុង ។ បពិត្រមហាគជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ខ្ញុំព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះត្រីទាំងឡាយ ដែលជាប់នៅក្នុងសំណាញ់ ។ បពិត្រមហាគជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ខ្ញុំព្រះបង្គំនឹងដោះព្រះអង្គចេញ ព្រមទាំងយាន រេហ៍ពលនឹងពាហនៈ ។ បពិត្រមហាគជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ខ្ញុំព្រះបង្គំនឹងដេញព្រះបាទបញ្ចាលឲ្យរត់ទៅ ដូចជាគេដេញក្អែកនឹងខ្លែង ដោយដុំដី ។ បុគ្គលណាមិនជួយព្រះអង្គដែលមានសេចក្តីចង្អៀត (គ្រោះមរណៈ) ឲ្យរួចចាកទុក្ខបានទេ ប្រាជ្ញា (របស់បុគ្គលនោះ) មានប្រយោជន៍អ្វី ឬអាមាត្យបែបនោះ (មានប្រយោជន៍អ្វី) ។

(៤៨៥) ឯថ មាណវកា ឧដ្ឋេវ មុខំ សោធេត្វ សន្ធិនោ

វេទេហោ សហាមច្ចេហិ ឧម្មង្គំ គមិស្សតិ ។

(៤៨៦) តស្ស តំ វចនំ សុត្វា បណ្ឌិតស្សានុសារិនោ

ឧម្មង្គទ្វារំ វិវរុ យន្តយុត្តេ ច អគ្គឡេ ។

(៤៨៧) បុរតោ សេនកោ យាតិ បច្ឆតោ ច មហោសធោ

មជ្ឈេ ច រាជា វេទេហោ អមច្ចបរិវារិតោ ។

(៤៨៨) ឧម្មង្គា និក្ខមិត្វាន វេទេហោ នាវមារុហិ

អភិរុឡ្ហញ្ច ញត្វាន អនុសាសិ មហោសធោ ។

អយំ តេ សស្សុរោ ទេវ អយំ សស្សុ ជនាធិប

យថា មាតុ បដិបត្តិ ឯវំ តេ ហោតុ សស្សុយា ។

យថាបិ និយកោ ភាតា សោទរិយោ ឯកមាតុកោ

ឯវំ បញ្ចាលចន្ទោ តេ ទយិតព្វោ រថេសភ ។



(៤៨៥) រីឯមាណពពាក់ខ្សែស្ពាយ អ្នកពាក់ខ្សែស្ពាយជួយមក ចូរក្រោកឡើង អ្នកពាក់ខ្សែស្ពាយចូរបើកមាត់នៃគន្លុំយន្ត ព្រះបាទវិទេហៈមួយអន្លើដោយពួកអាមាត្យនិងស្ដេចទៅកាន់ឧម្មង្គ ។

(៤៨៦) ពួកជនអ្នកធ្វើការបំរើរបស់មហោសថបណ្ឌិត ស្ដាប់ពាក្យរបស់លោកហើយ ទើបបើកទ្វារនៃឧម្មង្គនិងគន្លឹះទ្វារ ដែលប្រកបដោយគ្រឿងយន្ត ។

(៤៨៧) អាចារ្យសេនកៈដើរមុខ មហោសថដើរក្រោយ ព្រះបាទវិទេហៈ មានអាមាត្យហែហម ស្ដេចយាងត្រង់កណ្ដាល ។

(៤៨៨) ព្រះបាទវិទេហៈស្ដេចទ្រង់ចេញអំពីឧម្មង្គ ហើយឡើងគង់លើព្រះទីនាំងនាវា មហោសថដឹងថា ព្រះរាជាឡើងគង់ហើយ ក៏ប្រៀនប្រដៅថា បពិត្រព្រះសម្មតិទេព ព្រះបាទចូឡនីព្រហ្មទត្តនេះ ជាព្រះបិតាក្មេករបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងជន ព្រះនាងទេវីនេះ ជាព្រះមាតាក្មេករបស់ព្រះអង្គ ការប្រតិបត្តិព្រះវរជមាតា (របស់ព្រះអង្គ) យ៉ាងណា ការប្រតិបត្តិព្រះមាតាក្មេក ចូរមានដល់ព្រះអង្គយ៉ាងនោះដែរ ។ ព្រះភាតាបង្កើត រួមឧទរ មានព្រះមាតាតែមួយគ្នា យ៉ាងណា បពិត្រព្រះអង្គប្រសើរលើរថ បញ្ចាលចន្ទកុមារ ព្រះអង្គគួរស្រឡាញ់យ៉ាងនោះដែរ ។

អយំ បញ្ចាលចន្ទី តេ    រាជបុត្តី អភិច្ឆិតា

កាមំ ករោហិ តេ តាយ    ភរិយា តេ ភវិស្សតិ ។

(២៥៩) អារុយ្ហ នាវំ តរមានោ    កិំ នុ តីរម្ហិ តិដ្ឋសិ

កិច្ឆា មុត្តម្ហ ទុក្ខតោ    យាម ទានិ មហោសធ ។

(២៦០) នេស ធម្មោ មហារាជ    យោហំ សេនាយ នាយកោ

សេនង្គំ បរិហាបេត្វា    អត្តានំ បរិមោចយេ ។

និវេសនម្ហិ តេ ទេវ    សេនង្គំ បរិហាបិតំ

តំ ទិន្នំ ព្រហ្មទត្តេន    អានយិស្សំ រថេសភ ។

(២៦១) អប្បសេនោ មហាសេនំ    កថំ វិគ្គយ្ហ ឋស្សសិ

ទុព្ពលោ ពលវន្តេន    វិហញ្ញិស្សសិ បណ្ឌិត ។



បពិត្រព្រះអង្គប្រសើរលើរថ ព្រះនាងបញ្ចាលចណ្ឌីនេះ ជាព្រះរាជបុត្រី (របស់ព្រះបាទចូឡនី ព្រហ្មទត្ត) ដែលព្រះអង្គប្រាថ្នា សូមព្រះអង្គធ្វើសេចក្ដីប្រាថ្នារបស់ព្រះអង្គ ចំពោះព្រះនាងនោះ ព្រះនាងនឹងជាភរិយារបស់ព្រះអង្គហើយ ។

(២៥៩) (ព្រះបាទវិទេហៈ ...) ម្នាលមហោសធ អ្នកចូរប្រញាប់ប្រញាល់ឡើងនឹងទូកមក នៅឈរលើច្រាំងធ្វើអ្វី យើងទាំងឡាយរួចចាកទុក្ខដោយលំបាក យើងនឹងទៅឥឡូវនេះ ។

(២៦០) (មហោសធ ...) បពិត្រមហារាជ ខ្ញុំព្រះអង្គដែលជានាយកនៃសេនា លះបង់ចោលនូវអង្គនៃសេនា ហើយនាំយកតែខ្លួនរួចមិនមែនជាធម៌ឡើយទេ ។ បពិត្រព្រះសម្មតិទេព ប្រសើរលើរថ ខ្ញុំព្រះអង្គនឹងដឹកនាំនូវអង្គនៃសេនា ដែលព្រះអង្គបោះបង់ចោលក្នុងរាជនិវេសន៍ គឺរបស់ដែលព្រះបាទព្រហ្មទត្តថ្វាយហើយ ។

(២៦១) (ព្រះបាទវិទេហៈ ...) ម្នាលបណ្ឌិត អ្នកឯង ជាអ្នកមានសេនាតិច នឹងសង្គ្រាមសង្គ្រាមនឹងពលរបស់ព្រះបាទចូឡនីព្រហ្មទត្ត ដែលមានសេនាច្រើន ដូចម្ដេចបាន អ្នកឯងជាអ្នកមានកម្លាំងខ្សោយ មុខជាលំបាកដោយព្រះបាទចូឡនីព្រហ្មទត្ត ដែលមានកម្លាំង ។

(២៦២)អប្បសេនោបិ ចេ មន្តី   មហាសេនំ អមន្តិនំ
ជិនាតិ រាជា រាជានោ   អាទិច្ចោវុទយំ តមំ ។

(២៦៣)សុសុខំ វត សំវាសោ   បណ្ឌិតេហីតិ សេនក
បក្ខីវ បញ្ជរេ ពទ្ធេ   មច្ឆេ ជាលគតេរិវ
អមិត្តហត្ថត្ថគតេ   មោចយី នោ មហោសធោ ។

(២៦៤) ឯវមេតំ មហារាជ   បណ្ឌិតា ហិ សុខាវហា
បក្ខីវ បញ្ជរេ ពទ្ធេ   មច្ឆេ ជាលគតេរិវ
អមិត្តហត្ថត្ថគតេ   មោចយី នោ មហោសធោ ។

(២៦៥)រក្ខិត្វា កសិណំ រត្តឹ   ចូឡនេយ្យោ មហព្ពលោ
ឧទេន្តំ អរុណុគ្គស្មឹ   ឧបការឹ ឧបាគមិ ។



(២៦២) (ពោធិសត្វ...) បុគ្គលមានប្រាជ្ញា ស្ងប់ស្ងៀមមានសេនាតិច រមែងឈ្នះបុគ្គល មិនមានប្រាជ្ញា ដែលមានសេនាច្រើន ព្រះរាជាតែមួយព្រះអង្គ (ជាអ្នកឈ្លាសក្នុងឧបាយ) រមែងឈ្នះ ព្រះរាជាទាំងឡាយ (ជាអ្នកល្ងង់ក្នុងឧបាយ) ដូចព្រះអាទិត្យ ដែលរះឡើង (រមែងឈ្នះ) នូវងងឹតបាន ។

(២៦៣) (ព្រះបាទវិទេហៈ...) នែអាចារ្យសេនកៈ ការនៅរួម ជាមួយនឹងពួកបណ្ឌិត នាំមកនូវសេចក្តីសុខស្រួលណាស់ហ្ន៎ ព្រោះថាមហោសធបានដោះលែងយើង ដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចជាគេដោះលែងពួកបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចជាគេដោះលែងពួកត្រី ដែលជាប់នៅក្នុងសំណាញ់ដូច្នោះ ។

(២៦៤) (អាចារ្យសេនកៈ...) បពិត្រមហារាជ ពិតមែនហើយ បណ្ឌិតទាំងឡាយនាំមកនូវសេចក្តីសុខយ៉ាងនេះឯង មហោសធ បានដោះលែងយើង ដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចជាគេដោះលែងពួកបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចជាគេដោះលែងពួកត្រី ដែលជាប់នៅក្នុងសំណាញ់ដូច្នោះ ។

(២៦៥) (អភិសម្ពុទ្ធគាថា) ព្រះបាទចូឡនី ព្រហ្មទត្ត មានកំឡាំងដ៏ច្រើន ទ្រង់រក្សា អស់រាត្រីទាំងមូល កាល អរុណរះឡើង ក៏ស្តេចចូលទៅ ដល់ក្រុងឧបការី ។

អារុយ្ហ បវរំ នាគំ ពលវន្តំ សដ្ឋិហាយនំ
រាជា អវោច បញ្ចាលោ ចូឡនេយ្យោ មហព្ពលោ ។
សន្នទ្ធោ មណិចម្មេន សរមាទាយ បាណិនា
បេសិយេ អជ្ឈភាសិត្ថ បុថុគុម្ពេ សមាគតេ ។
ហត្ថារោហេ អនីកដ្ឋេ រថិកេ បត្តិការកេ
ឧបាសនម្ហិ កតហត្ថេ វាលវេធេ សមាគតេ ។
(៦៦៦)បេសេថ កុញ្ជរេ ទន្តី ពលវន្តេ សដ្ឋិហាយនេ
មទ្ទន្តុ កុញ្ជរា នគរំ(១) វេទេហេន សុមាបិតំ ។
វច្ឆទន្តមុខា សេតា តិក្ខគ្គា(២) អដ្ឋិវេធិនោ
បនុណ្ណា ធនុវេគេន សម្បតន្តុតរីតរា ។
មាណវា វម្មិនោ សូរា ចិត្តទណ្ឌយុតាវុធា
បក្ខន្ទិនោ មហានាគា ហត្ថីនំ ហោន្តុ សម្មុខា ។
សត្តិយោ តេលធោតាយោ អច្ចិមន្តា បភស្សរា
វិជ្ជោតមានា តិដ្ឋន្តុ សតរំសីវ តារកា ។

---

១ ឱ. កុឌ្យំ តៈ ។ ២ ឱ. តិណ្ហគ្គា ។



ព្រះបាទចូឡនីព្រហ្មទត្តក្រុងបញ្ចាល មានកំឡាំងច្រើន ស្ដេចឡើងគង់លើដំរីប្រសើរ ដ៏មានកំឡាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ បានក្រោះពាក់ (នឹងសំណាប់ព្រះអង្គ) ។ ព្រះបាទចូឡនីព្រហ្មទត្តទ្រង់ស្លៀកគ្រឿងក្រោះ ជាវិការៈនៃកែវមណី ព្រះហស្តកាន់សរ បានត្រាស់ទៅនឹងនាយពលនាទូលបំរើ (របស់ព្រះអង្គ) ជាអ្នកមានសិល្បច្រើនដែលមកប្រជុំគ្នា ។ (ព្រះបាទចូឡនីត្រាស់ទៅ) នឹងពលដំរី ពលសេះ ពលរថ ពលថ្មើរជើង នឹងអ្នកធ្នូ ដែលមានដៃដ៏ស្ទាត់ក្នុងសិល្បធ្នូ អាចបាញ់រោមក្រៀ ដែលមកប្រជុំគ្នា ។
(៦៦៦) (ព្រះបាទចូឡនី...) អ្នកទាំងឡាយចូរបញ្ជូនដំរីមានភ្លុកដ៏មានកំឡាំង ជាដំរីមានអាយុ ប្រមាណ ៦០ ឆ្នាំ ចូរឲ្យដំរីទាំងឡាយជាន់ញីក្រុង ដែលព្រះបាទវិទេហៈសាងទុកហើយ ។ (កូនព្រួញ) មានសម្បុរស មានមុខដូចភ្លុក មានចុងដ៏មុត អាចចាក់ទំលាយឆ្អឹង ដែលបាញ់ដោយកំឡាំងធ្នូ ចូរធ្លាក់ចុះព្រមគ្នាអំពីខាងនេះខាងនោះ ។ ពួកសេនាក្មេង ៗ ស្លៀកពាក់គ្រឿងក្រោះ មានអាវុធប្រកបដោយដងដ៏វិចិត្រ ក្លាហានក្នុងដំណើរស្ទុះចូលមក ចូរអ្នកទាំងនោះ (ឈរ) ជាការមុខដំរីទាំងឡាយ ។ លំពែងទាំងឡាយ ដែលគេលាបដោយប្រេង ដោយស្រួច មានរស្មីភ្លឺ រុងរឿង ដូចផ្កាយព្រឹក មានរស្មីច្រើន ។

អាវុធពលវន្តានំ  គុណិកាយុរធារិនំ
ឯតាទិសានំ យោធានំ  សង្គាមេ អបលាយិនំ
វេទេហោ កុតោ មុច្ចិស្សតិ  សចេ បក្ខីវ កាហិតិ ។
តីសមេ បុរិសនាវុត្យោ  សព្វេ ឯកេកនិច្ឆិតា
យេសំ សមំ ន បស្សាមិ  កេវលំ មហិមំ ចរំ ។
នាគា ច កប្បិតា ទន្តី  ពលវន្តា សដ្ឋិហាយនា
យេសំ ខន្ធេសុ សោភន្តិ  កុមារា ចារុទស្សនា ។
បីតាលង្ការា បីតវសនា  បីតុត្តរនិវាសនា
នាគក្ខន្ធេសុ សោភន្តិ  ទេវបុត្តាវ នន្ទនេ ។
បាឋីនវណ្ណា(១) នេត្តឹសា  តេលធោតា បភស្សរា
និដ្ឋិតា នរធីរេហិ  សមធារា សុនិស្សិតា ។

១ ម. បាចីនវណ្ណា ។



កាលបើពួកយោធា (របស់យើង) មានគ្រឿងអាវុធជាកំឡាំង ប្រដាប់សង្វារគឺគ្រឿងក្រវិលប្រាក់ដៃ មិនបានរត់ក្នុងសង្គ្រាមទេ ព្រះបាទវេទេហៈនឹងរួចពីដៃយើងទៅណា បើគ្រាន់តែព្រះបាទវេទេ-ហៈនឹងធ្វើដូចបក្សី(ហើរចេញ) ។ ពួកយោធារបស់យើងទាំងអស់ មានចំនួន ៧៩,០០០ នាក់ តាមកាត់ក្បាលសត្រូវហើយរើសយកក្បាលមួយៗ មក យើងបានដើរស្វែងរកលើផែនដីមិនឃើញពួកយោធាណាស្មើឡើយ ។ ដំរីទាំងឡាយមានភ្លុក ប្រដាប់ហើយ មានកំឡាំងជាដំរីមានអាយុប្រមាណ៦០ ឆ្នាំ ពួកយោធានៅកដំរី ៗ មានសម្បុរដូចមាស រមែងល្អលើ-កនៃដំរីទាំងឡាយ ។ យោធាទាំងឡាយ មានគ្រឿងអលង្ការ មានពណ៌លឿង ស្លៀកសំពត់មានពណ៌លឿង ដណ្តប់សំពត់មានពណ៌លឿង រមែងល្អលើ-កនៃដំរីទាំងឡាយ ដូចទេវបុត្តទាំងឡាយក្នុងនន្ទនៈ ។ ព្រះខាន់ទាំងឡាយមានសម្បុរ ដូចត្រីស្លាត ដែលលាបនឹងប្រេងយ៉ាងប្រពៃ មានរស្មីភ្លឺផ្លេកដែលបុរសអ្នកមានព្យាយាមធ្វើសម្រេចហើយ មានមុខស្មើ ដែលគេសំលៀងល្អហើយ ។ ព្រះខាន់ទាំងឡាយមិនមានស្នឹម រុងរឿងដូចជាព្រះអាទិត្យ បិតនៅក្នុងទីពាក់កណ្តាល ដែលគេក្តោបដោយដែកថែបដ៏ម៉ាំដែលពួកយោធាអ្នកមានកំឡាំងដ៏ពេញ ក្នុងទីប្រហារទាំងកាន់យកហើយ ។

វេឡុរិយោ វីតមលោ សិក្កាយសមយា ឧគ្គហា

ឥហិតា ពលវន្តហិ សុប្បហារប្បហារិកិ ។

សុវណ្ណជុតសម្បន្នា លោហិតកញ្ចុកធារិកា

វិរត្តមាលា សោភន្តិ វិជ្ជុវត្តយមណ្ឌលេ ។

បជកា ចន្ទោ សុក អសិបន្ធស្ស តោរិតា

ឧឡុត្តមា សិក្ខិតា តាកញ្ចុនិតាតិនោ ។

ឯតានិ សេហិ បរិក្ខិត្តា ឧត្តិ សោភេត្វា ភតោ ការ

បការវន្ត ន បស្សាមិ យេន ត្វំ មជ្ឈឹមេ វជេ ។

(២៦៧) កិន្នុ សន្តរមានោវ ជាតិ បរេសិ កុញ្ជរំ

ពាហជ្ជូរោ អាគមសិ សន្នទ្ធោស្មិ មញ្ចសិ ។

ទុមាភេតិ ឧទុនាបិ ទុរប្បំ បដិសិហារ

ទុហារេតំ(១) សុកិ ចម្មំ វេឡុរិយមណិសន្ធិកំ(២) ។

(២៦៨) មសក្កមុនេវណ្ណាសិ មិគមុញ្ច ការសិ

បោតិទោ មរណកាលេ ឯតិសិ វណ្ណសម្បទា ។

១ ឱ. ទុហារេតុ ។ ២ ម. វេឡុរិយមណិសន្ថតំ ។



ព្រះនាងទាំងឡាយបាំងព្រះភ័ក្ត្រដោយផ្ទៃជាកែវនៃមាស ទ្រទ្រង់
ដោយស្រោមមាត់ពណ៌ក្រហម កាលបើគេត្រៀមឡើងដើម្បីល្អ
ដូចជាផ្លេកបន្ទោរក្លាំងផ្លេកក្នុងទីបញ្ចាំងនៃពពក ។ ក្នុងកាលនោះ អ្នក
ក្រៀមក្រំ ចាក់គ្រឿងក្រោះ សាចប្រព្រឹត្តទៅក្នុងអាកាសបាន
អ្នកឈ្លាសក្នុងការកាន់ដាវទីវល ជាអ្នកហាត់ក្នុងការកាន់
ដង្ហៅក្រវែង សាចកាត់ឡើងនៃដំរីឲ្យធ្លាក់ចុះបាន ។ អ្នក
ឯងត្រូវគេហែហមហោមរោមព្រោកដូចជាពើងហើយ អ្នកឯងមិនឃើញគតិ
ទីពេញ អ្នកនឹងទៅកាន់ព្រៃដ៏មិនដែលគេដឹងយកជាមុខគាតណា
ឃើញមិនបានឃើញជាទុក្ខគាតោរបស់អ្នក ។

(២៦៧) (ព្រះរាជសីហ ...) ព្រះអង្គទ្រង់ប្រញាប់ប្រញាល់បញ្ជូន
ដំរីប្រសើរមក ព្រះអង្គមានព្រះហឫទ័យរីករាយយាងមក ហើយ
ទ្រង់សំគាល់ថា អាត្មាអញនឹងបានសម្រេចប្រយោជន៍ដូចម្តេច
ហ្ន៎ ។ សូមព្រះអង្គដាក់ធ្នូនឹងបំពង់ព្រួញចុះចេញ សូមព្រះអង្គ
ដាក់ក្ដូចសាចុះចេញ សូមព្រះអង្គដាក់គ្រឿងក្រោះ ដ៏ល្អ
ប្រពៃលាយដោយកែវពិទូរ្យនឹងកែវមណីចុះចេញ ។

(២៦៨) (ព្រះភក្ត្រដូចខ្ទិ ...) អ្នកឯងជាអ្នកមានសម្បុរមុខស្រស់បស់
ចាំងចិញ្ចាយកញ្ចាញមញ្ចាញ់ញមជាប់ ឯការបារាំណីដោយសម្បុរ
ថ្លៃថ្លា នៃមនុស្សមានប្រាកដក្នុងមរណកាល ។

(៦៦៩) មោឃន្តេ គជ្ជិតំ(១) រាជ ភិន្នមន្តោសិ ខត្តិយ
ទុគ្គណ្ហោ ហិ តយា រាជា ខឡុង្កេនេវ សិន្ធវោ ។
តិណ្ណោ ហិយ្យោ រាជា គង្គំ សាមច្ចោ សបរិជ្ជនោ
ហំសរាជំ យថា ធង្កោ អនុបតិតុមិច្ឆសិ ។

(៦៧០) សិគាលា រត្តិភាគេន ផុល្លំ ទិស្វាន កឹសុកំ
មំសបេសីតិ មញ្ញន្តា បរិក្ខិំសុ មិគាធមា ។
វីតិវត្តាសុ រត្តីសុ ឧគ្គតស្មឹ ទិវាករេ
កឹសុកំ ផុល្លិតំ ទិស្វា អាសាច្ឆិន្នា មិគាធមា ។
ឯវមេវ តុវំ រាជ វេទេហំ បរិវារិយ
អាសច្ឆិន្នោ គមិស្សសិ សិគាលា កឹសុកំ យថា ។

(៦៧១) ឥមស្ស ហត្ថេ បាទេ ច កណ្ណនាសញ្ច ឆិន្ទថ
យោ មេ អមិត្តំ ហត្ថគតំ វេទេហំ បរិមោចយិ ។

១ ម. ថ្វិតំ ។



(៦៦៩) (មហោសធ...) បពិត្រព្រះរាជា ពាក្យដែលព្រះអង្គត្រាស់ហើយ ជាពាក្យសោះសូន្យទទេ ព្រះអង្គមានការប្រឹក្សាខ្ចាយហើយ ឯព្រះរាជា (របស់យើង) ព្រះអង្គមិនគប្បីនឹងចាប់យកបានទេ ដូចសេះសិន្ធពនឹងសេះខ្វាក់ ។ ព្រះរាជា (ក្រុងមិថិលា) ព្រមដោយអាមាត្យនឹងពលបរិវារ ឆ្លងស្ទឹងគង្គាតាំងពីថ្ងៃម្សិលទៅហើយ ម្តេច ក្អែកស្ទុះតាមហង្ស នឹងធ្លាក់ចុះក្នុងពាក់កណ្តាលផ្លូវ យ៉ាងណាមិញ (បើព្រះអង្គនឹងតាមព្រះរាជានោះនឹងដល់សេចក្តីវិនាសក្នុងពាក់កណ្តាលផ្លូវក៏យ៉ាងនោះដែរ)។

(៦៧០) ឆ្កែចចកទាំងឡាយជាម្រឹគថោកទាប ឃើញផ្កាចារដែលរីកក្នុងចំណែកនៃរាត្រី គិតស្មានថាជាដុំសាច់ ហើយចាំឃ្លាំមើល ។ (ឆ្កែចចកទាំងនោះ) ជាម្រឹគថោកទាប កាលបើរាត្រីកន្លងទៅហើយ ព្រះអាទិត្យរះឡើង ទើបឃើញច្បាស់ថាជាផ្កាចារ ក៏ដាច់សេចក្តីប្រាថ្នា (រត់ទៅ) យ៉ាងណា ។ បពិត្រព្រះរាជា ព្រះអង្គឡោមព័ទ្ធព្រះបាទវិទេហៈ នឹងដាច់សេចក្តីប្រាថ្នាហើយ ទៅដូចពួកឆ្កែចចក (ថោកទាប) ចាំផ្កាចារដូច្នោះដែរ ។

(៦៧១) (ព្រះបាទចូឡនី...) អ្នកទាំងឡាយ ចូរកាត់ដៃនឹងជើង ត្រចៀក នឹងច្រមុះ នៃមហោសធនេះ ព្រោះវាធ្វើព្រះបាទវិទេហៈ ជាសត្រូវដែលនៅក្នុងកណ្តាប់ដៃយើង ឲ្យរួចទៅវិញ ។

ឥមំ មំសញ្ច ធាតព្ភំ(១) ស្វេ កាកា បតន្តិ ធំ
យោ មេ អមិត្តំ ហត្ថគតំ វេទេហំ បរិមោចយិ ។
យថាបិ ឧសភចម្មំ បថព្យា វិតនីយតិ
សីហស្ស អថោ ព្យគ្ឃស្ស ហោតិ សង្កុសមាហតំ ។
ឯវន្តំ វិតនិត្វាន វេធយិស្សាមិ សត្តិយា
យោ មេ អមិត្តំ ហត្ថគតំ វេទេហំ បរិមោចយិ ។

(២៧២) សចេ មេ ហត្ថបាទេ ច កណ្ណនាសញ្ច ឆេទសិ
ឯវំ បញ្ចាលចន្ទស្ស វេទេហោ ឆេទយិស្សតិ ។
សចេ មេ ហត្ថបាទេ ច កណ្ណនាសញ្ច ឆេទសិ
ឯវំ បញ្ចាលចន្ទិយា វេទេហោ ឆេទយិស្សតិ ។
សចេ មេ ហត្ថបាទេ ច កណ្ណនាសញ្ច ឆេទសិ
ឯវំ នន្ទាយ ទេវិយា វេទេហោ ឆេទយិស្សតិ ។

១ ឧទ្ធាតាយំ អាចព្ភុនិ ទិស្សតិ ។



សេនាទាំងឡាយ ចូរដោតតាមបុរសនេះ ដោយឈើស្រួច ហើយចំអិនវា ដូចគេចំអិនសាច់ដែលឆ្អិនចំអិន ព្រោះវាធ្វើស្តេចវិទេហៈ ជាសត្រូវដែលនៅក្នុងកណ្តាប់ដៃយើងឲ្យរួចទៅវិញ ។ បុគ្គលដោតសន្ធឹងស្បែកគោឧសភលើផែនដី ពុំនោះសោត ដូចស្បែកសីហៈ ឬខ្លាធំដោយកាន្ទ្រៃ យ៉ាងណា ។ យើងនឹងចាក់ដោតវាដោយលំពែង យ៉ាងនោះ ព្រោះវាធ្វើព្រះបាទវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្តាប់ដៃយើង ឲ្យរួចទៅវិញ ។

(២៧២) (សចេ មេ . . .) បើព្រះអង្គកាត់នូវដៃជើងត្រចៀកនឹងច្រមុះ របស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (ដៃជើងត្រចៀកនឹងច្រមុះ) របស់ព្រះរាជបុត្រឈ្មោះបញ្ចាលចន្ទៈ យ៉ាងហ្នឹងដែរ ។ បើព្រះអង្គកាត់ដៃជើងត្រចៀក នឹងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈមុខជានឹងកាត់ (នូវដៃជើងត្រចៀកនឹងច្រមុះ) របស់ព្រះរាជធីតាឈ្មោះបញ្ចាលចន្ទី យ៉ាងហ្នឹងដែរ ។ បើព្រះអង្គកាត់ដៃ នឹងជើងត្រចៀក នឹងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃជើងត្រចៀកនឹងច្រមុះ) របស់អគ្គមហេសី ឈ្មោះនន្ទាទេវី យ៉ាងហ្នឹងដែរ ។

សចេ មេ ហត្ថបាទេ ច កណ្ណនាសញ្ច ឆេច្ឆសិ

ឯវន្តេ បុត្តទារស្ស វេទេហោ ឆេទយិស្សតិ ។

សចេ មំសញ្ច ពាតព្យំ សូលេ កត្វា បចិស្សសិ

ឯវំ បញ្ចាលចន្ទស្ស វេទេហោ បាចយិស្សតិ ។

សចេ មំសញ្ច ពាតព្យំ សូលេ កត្វា បចិស្សសិ

ឯវំ បញ្ចាលចណ្ឌិយា វេទេហោ បាចយិស្សតិ ។

សចេ មំសញ្ច ពាតព្យំ សូលេ កត្វា បចិស្សសិ

ឯវំ នន្ទាយ ទេវិយា វេទេហោ បាចយិស្សតិ ។

សចេ មំសញ្ច ពាតព្យំ សូលេ កត្វា បចិស្សសិ

ឯវន្តេ បុត្តទារស្ស វេទេហោ បាចយិស្សតិ ។

សចេ មំ វិហនិត្វាន វេធយិស្សសិ សត្តិយា

ឯវំ បញ្ចាលចន្ទស្ស វេទេហោ វេធយិស្សតិ ។



បើព្រះអង្គកាត់ដៃនឹងជើងត្រចៀក នឹងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃនឹងជើងត្រចៀកនឹងច្រមុះ) របស់ព្រះរាជបុត្រនឹងព្រះមហេសីរបស់ព្រះអង្គ យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំដោយឈើអណ្ដូតហើយចំអិន ដូចគេចំអិនសាច់ដែលស្នួចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឱ្យគេដោតព្រះរាជបុត្រឈ្មោះបញ្ចាលចន្ទៈ (ដោយឈើអណ្ដូត) ហើយចំអិនយ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំដោយឈើអណ្ដូត ហើយចំអិន ដូចគេចំអិនសាច់ ដែលស្នួចំអិន ព្រះបាទវិទេហៈមុខជានឹងប្រើឱ្យគេដោតព្រះរាជធីតាឈ្មោះបញ្ចាលចណ្ឌី (ដោយឈើអណ្ដូត) ហើយចំអិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្ដូតហើយចំអិន ដូចគេចំអិនសាច់ ដែលស្នួចំអិន ព្រះបាទវិទេហៈមុខជានឹងប្រើឱ្យគេដោតអគ្គមហេសីឈ្មោះនន្ទាទេវី (ដោយឈើអណ្ដូត) ហើយចំអិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្ដូត ហើយចំអិន ដូចគេចំអិនសាច់ ដែលស្នួចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឱ្យគេដោតព្រះរាជបុត្រនឹងព្រះមហេសី របស់ព្រះអង្គ (ដោយឈើអណ្ដូត) ហើយចំអិន យ៉ាងហ្នឹងដែរ ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈមុខជានឹងដោតព្រះរាជបុត្រឈ្មោះបញ្ចាលចន្ទៈ (ដោយលំពែង) យ៉ាងហ្នឹងដែរ ។

សចេ មំ វិហនិត្វាន វេធយិស្សសិ សត្តិយា

ឃរំ បញ្ចាលចណ្ឌិយា វេធព្យោ វេធយិស្សតិ ។

សចេ មំ វិហនិត្វាន វេធយិស្សសិ សត្តិយា

ឃរំ ឧត្តាយ តេរិយា វេធព្យោ វេធយិស្សតិ ។

សចេ មំ វិហនិត្វាន វេធយិស្សសិ សត្តិយះ

ឃរន្តុ បុត្តទារស្ស វេធព្យោ វេធយិស្សតិ ។

ឃរំ តោ មន្តិតំ វេធព្យោន មយា សហ

យថា ផលសតំ ចម្មំ កោត្ថុមត្តាសុនិដ្ឋិតំ

ឱមេតិ ឥទុតាលាយ សកាំ បជិហន្តវេ ។

សុខាវហោ ទុក្ខនុទោ វេទេហស្ស យសស្សិនោ

មតិន្តេ បដិហញ្ញាមិ ឧសុំ ផលសតេន វា ។



បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវេទេហៈ មុខជានឹងចាក់ដោតព្រាហ្មណ៍ ឈ្មោះបញ្ចាលចណ្ឌី ( ដោយលំពែង ) យ៉ាងនេះដែរ ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវេទេហៈ មុខជានឹងចាក់ដោតឧត្តមមហេសី ឈ្មោះ ឧត្តរទេវី ( ដោយលំពែង ) យ៉ាងនេះដែរ ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវេទេហៈ មុខជានឹងចាក់ដោតព្រះរាជបុត្រនឹងព្រះមហេសី របស់ព្រះអង្គ (ដោយលំពែង) យ៉ាងនេះដែរ ។ យើងទាំងពីរនាក់ គឺស្តេចវេទេហៈនឹងទូលព្រះបង្គំជាខ្ញុំប្រឹក្សារួចស្រេច គួរតែស្លាប់យ៉ាងនេះហើយ ដែលស្បែកមានខ្ទង់ ១០០បលៈ ដែលជាងស្បែកឲ្យសាប្រេងហើយ ដោយស្រួលរបស់ជាងស្បែក រមែងជួយការពារខ្លួន ដើម្បីទប់នឹងកូនសរចាំងឡាយយ៉ាងណា ។ ទូលព្រះបង្គំជាខ្ញុំ ជាអ្នកនាំសេចក្ដីសុខមក ជួយបន្ទោបង់សេចក្ដីទុក្ខនៃព្រះបាទវេទេហៈ ដ៏មានយស ក៏គង់ទប់នឹងកូនសរ គឺព្រួញគំនិតរបស់ព្រះអង្គ ដោយដែលស្បែក មានខ្ទង់ ១០០ បលៈ ( សេចក្ដីគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ គឺប្លែងនោះឯង ) ។

(២៧៣) ឥង្ឃ បស្ស មហារាជ   សុញ្ញំ អន្តេបុរំ តវ
ឱរោធា ច កុមារា ច   តវ មាតា ច ខត្តិយ
ឧម្មង្គា នីហរិត្វាន   វេទេហស្សុបនាមិតា ។

(២៧៤) ឥង្ឃ អន្តេបុរំ មយ្ហំ   គន្ត្វាន វិចិនាថ នំ
យថា ឥមស្ស វចនំ   សច្ចំ វា យទិ វា មុសា ។

(២៧៥) ឯវមេតំ មហារាជ   យថា អាហ មហោសធោ
សុញ្ញំ អន្តេបុរំ សព្វំ   កាកបដ្ដនកំ យថា ។

២៧៦) ឥតោ គតា មហារាជ   នារី សព្វង្គសោភនា
កោសុម្ភផលកសុស្សោណី   ហំសគគ្គរភាណិនី ។
ឥតោ នីតា មហារាជ   នារី សព្វង្គសោភនា
កោសេយ្យវសនា សាមា   ជាតរូបសុមេខលា ។



(២៧៣) បពិត្រមហារាជ សូមអញ្ជើញព្រះអង្គទតព្រះនេត្រមើលព្រះរាជវាំង របស់ព្រះអង្គដែលសូន្យឈឹងចុះ បពិត្រព្រះមហាក្សត្រិយ៍ ស្រីស្នំ ទាំងកុមារទាំងឡាយ នឹងព្រះវររាជមាតា របស់ព្រះអង្គ ត្រូវនាំចេញតាមឧមង្គ នាំទៅថ្វាយព្រះបាទវិទេហៈហើយ ។

(២៧៤) (ព្រះបាទចូឡនី ...) បើដូច្នោះ អ្នកទាំងឡាយ ចូរទៅឯព្រះរាជវាំង របស់អញ ហើយពិចារណាមើលហេតុនោះ តើសមដូចពាក្យ របស់មហោសធនេះ ពិតឬកុហកទេ ។

(២៧៥) (ពួកអាមាត្យ ...) បពិត្រមហារាជ មហោសធទូលយ៉ាងណា សេចក្តីនុះក៏យ៉ាងនោះឯង ព្រះរាជវាំងទាំងមូលសូន្យឈឹង ដូចឋានជាទីប្រជុំនៃពួកក្អែក ។

(២៧៦) (មហោសធ ...) បពិត្រមហារាជ ព្រះនាងនារីនេះទៅ ព្រះសព្វាង្គកាយដ៏ល្អ មានព្រះសោណីដ៏ល្អ ដូចផ្លែស្វាមាស មានប្រក្រតីពោលពាក្យពីរោះ ដូចជាសំឡេងនៃហង្ស បានចេញទៅ អំពីឧមង្គនេះហើយ ។ បពិត្រមហារាជ ព្រះនាងនារី មានសព្វាង្គកាយដ៏ល្អ ស្រទ្រង់កោសេយ្យពស្ត្រ មានសម្បុរដូចមាស មានខ្សែក្រវាត់ព្រះអង្គនោះក៏ល្អវិចិត្រដោយមាស ។

សុរត្តធារា កល្យាណី   សុវណ្ណមណិមេខលា

ធារេកត្តិ សុតនូ   ពិម្ពោដ្ឋា តនុមជ្ឈិមា ។

សុជាតា ភុជលដ្ឋីវ   វេទីវ តនុមជ្ឈិមា

ទីឃស្សា កេសា អសិតា   ឦសកគ្គបវេល្លិតា ។

សុជាតា មិគច្ឆាបីវ   ហេមន្តគ្គិសិខារិវ

នទីវ គិរិទុគ្គេសុ   សញ្ឆន្នា ខុទ្ទវេណុភិ ។

នាគនាសូរុ កល្យាណី   បរមា តិម្ពរុត្ថនី

នាតិទីឃា នាតិរស្សា នាលោមា នាតិលោមសា ។

តស្សាយ នូន អបោណេ   តស្មិំ សិរីភយាន

អហញ្ច នូន តស្សា ច   ពញ្ញាម យមកាគតំ ។

(២៧៧) ធិតិំ អធិយសេ មាយំ   អកាសិ ចក្ខុមោហនំ

យោ មេ អមិត្តំ ហត្ថគតំ   វេណេតំ ឧរាមោចយំ ។





ព្រះនាងនោះ មានព្រះបាទដ៏ព្រហ្មល្អ ប្រកបដោយលំអ (៥យ៉ាង) មានខ្សែក្រវាត់ជាវិការៈនៃមាសនិងកែវមណី មានផ្ទៃព្រះឧទរប្រាកដ ស្មើដោយនៃក្អែកសត្វព្រាប មានសរីរៈដ៏ល្អ មានដើមព្រះឧរូល្អិតល្អ ដូចជាផ្លែទុំក្លាច់ មានបង្កើរភ្នៀ ។ ព្រះនាងនោះមានបង្កើរភ្នៀ ដូចល្វៀងនៃលកាដែលល្អលាស់ល្អ ឬដូចក្ដាហើង (ជាវិការៈនៃមាស) ព្រះកេសរបស់ព្រះនាងនោះ វែងមានចុងខ្ចៅនិងបន្ថិច ដូចចុងកំប៊ិត ។ ព្រះនាងនេះទៀត មានផ្ទៃព្រះឧទរក្រសាយដ៏ដូច ជាក្អែកនៃកូនម្រឹគ កើត (ក្នុងឆ្នាំមួយ) ឬដូចជាអណ្ដាតភ្លើងក្នុង ហេមន្តរដូវ ក៏ឬនោះសាកដូចជាស្ទឹង ដ៏ជ្រៅជាស្រាដោយដើមឬស្សី តូច ៗ តាំងឡាយ ទៀតព្រះភក្ត្រ ។ ព្រះនាងនេះទៀត មានព្រះឧរូ ល្អដូចប្រមោយដំរី មានសុដន់ល្អដូចផ្លែទន្លាប់ដ៏ប្រសើរ មិនខ្ពស់ពេកមិនទាបពេក មិនមែនឥតព្រះលោមា មិនមែនមានព្រះលោមា ច្រើនពេក ។ បពិត្រព្រះអង្គមានតាបនៈ បញ្ចុណីដោយសិរី ព្រះអង្គក្រោកអោយមារណៈ នៃព្រះនាងនេះទៀតដោយពិត ឯខ្ញុំព្រះអង្គ នឹងព្រះនាងនេះ និងទៅកាន់សំណាក់យមកដោយពិត ។

(២៧៧) (ព្រះបាទបច្ចេកនិ . . .) អ្នកបានរៀនកលមាយាជាចិត្ត ហើយ បានធ្វើឲ្យបាយបំបាំងនៃភ្នែកខ្ញុំ បានជាអ្នកដោះលែង ព្រះបាទនោះ ជាសត្រូវនៅ ក្នុងកណ្ដាប់ដៃនៃយើងបាន ។

(៤៧៨)អច្ឆិយន្តិ វេ មហារាជ  និច្ចមាយិន បណ្ឌិតា
តេ ភោជយន្តិ អត្តានំ  បណ្ឌិតា បត្តិយោ ជនា។
សន្តិ មាណវបុត្តា មេ  កុសលា សន្ធិច្ឆេទកា
យេសំ កតេន មគ្គេន  វេទេហោ មិថិលំ គតោ។

(៤៧៩)ឥង្ឃ បស្ស មហារាជ  ឧម្មង្គំ សាធុមាបិតំ
ហត្ថីនំ អថ អស្សានំ  រថានំ អថ បត្តិនំ
អាលោកភូតំ តិដ្ឋន្តំ  ឧម្មង្គំ សាធុនិដ្ឋិតំ(១)។

(៤៨០)លាភា វត វិទេហានំ  យស្សិមេ ឯទិសា បណ្ឌិតា
ឃរេ វសន្តិ វិជិតេ  យថា ត្វមសិ មហោសធ។

(៤៨១)វុត្តិញ្ច បរិហារញ្ច  ទិគុណំ ភត្តវេតនំ
ទទាមិ វិបុលេ ភោគេ  ភុញ្ជ កាមេ រមស្សុ ច
មា វិទេហំ បច្ចគមា  កឹ វិទេហោ ករិស្សតិ។

១ ម. សាធុមាបិតំ ។



(៤៧៨) (មហោសធ ...) បពិត្រមហារាជ បណ្ឌិតទាំងឡាយ ក្នុងលោកនេះ រមែងរៀនខ្លួនក្នុងមាយាជានិច្ចដោយពិត ពួកបណ្ឌិតផងអ្នកមានសេចក្ដីដឹងនោះ រមែងដោះខ្លួន ( ចាកទុក្ខបាន ) ពួកមាណពក្មេង ៗ អ្នកបំរើរបស់ខ្ញុំព្រះអង្គ ជាអ្នកឈ្លាស ជាអ្នកកាត់ផ្លូវចូលទឹក ព្រះបាទវិទេហៈយាងទៅកាន់ក្រុងមិថិលា តាមផ្លូវដែលពួកជនទាំងនោះធ្វើទុកហើយ ។

(៤៧៩) បពិត្រមហារាជ សូមព្រះអង្គទតឧមង្គដែលពួកជនសាងទុកល្អហើយ សូមព្រះអង្គទតឧមង្គដ៏ភ្លឺរលើង ( ដោយរបៀប) នៃដំរី សេះ រថ និងពលថ្មើរជើង ដែលគេធ្វើឲ្យសម្រេចហើយដោយល្អ ។

(៤៨០) ( ព្រះបាទចូឡនី ... ) ម្នាលមហោសធ ជាលាភរបស់អ្នកដែនវិទេហៈដោយពិត បណ្ឌិតទាំងឡាយ ប្រាកដដូចជាអ្នកនេះ នៅក្នុងផ្ទះណា ក៏ក្នុងដែន របស់ព្រះរាជាណា ( ជាលាភរបស់ព្រះរាជានោះពិត ) ។

(៤៨១) យើងនឹងឲ្យគ្រឿងចិញ្ចឹមជីវិតនិងគ្រឿងគ្រង គ្រឿងរក្សាក៏ស្រេចនឹងចិត្ត ទាំងបាយទាំងថ្នូលជាទ្វេគុណដល់អ្នក ទាំងឲ្យភោគសម្បត្តិដ៏ធំទូលាយទៀត អ្នកចូរបរិភោគ ចូរត្រេកអរតាមប្រាថ្នាចុះ អ្នកកុំទៅកាន់ព្រះបាទវិទេហៈឡើយ ព្រះបាទវិទេហៈនឹងធ្វើអ្វីដល់អ្នក។

(២៨២) យោ ចជេថ មហារាជ ភត្តារំ ធនការណា

ឧភិន្នំ ហោតិ គារយ្ហោ អត្តនោ ច បរស្ស ច

យាវ ជីវេយ្យ វេទេហោ នាញ្ញស្ស វិជិតេ វសេ ។

យោ ចជេថ មហារាជ ភត្តារំ ធនការណា

ឧភិន្នំ ហោតិ គារយ្ហោ អត្តនោ ច បរស្ស ច

យាវ តិដ្ឋេយ្យ វេទេហោ នាញ្ញស្ស បុរិសោ សិយំ ។

(២៨៣) ទម្មិ និក្ខសហស្សានិ គាមាសីតិញ្ច កាសិសុ

ទាសីសតានិ ចត្តារិ ទម្មិ ភរិយាសតញ្ច តេ

សព្វំ សេនង្គមាទាយ សោត្ថឹ គច្ឆ មហោសធ ។

(២៨៤) យាវ ទទន្តុ ហត្ថីនំ អស្សានំ ទិគុណំ វិធំ

តប្បេន្តុ អន្នបានេន រថិកេ បត្តិការកេ ។

(២៨៥) ហត្ថី អស្សេ រថេ បត្តី គច្ឆេវាទាយ បណ្ឌិត

បស្សតុ តំ មហារាជា វេទេហោ មិថិលំ គតំ ។



(២៨២) (មហោសធ ...) បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គលអ្នកចិញ្ចឹមព្រោះហេតុនៃទ្រព្យ បុគ្គលនោះត្រូវជនទាំងពីរគឺ ខ្លួនឯងនឹងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈទ្រង់គង់ព្រះជន្មាយុដរាបណា ខ្ញុំក៏មិនគប្បីនៅក្នុងដែនខាងព្រះរាជាដទៃ(ដរាបនោះ) ។ បពិត្រមហារាជ បុគ្គលណាលះបង់នូវបុគ្គលអ្នកចិញ្ចឹម ព្រោះហេតុនៃទ្រព្យ បុគ្គលនោះត្រូវជនទាំងពីរគឺ ខ្លួនឯងនឹងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈទ្រង់ឋិតនៅដរាបណា ខ្ញុំមិនត្រូវជាបុរសរបស់បុគ្គលដទៃ (ដរាបនោះ) ។

(២៨៣) (ព្រះបាទចូឡនី ...) ម្នាលមហោសធ យើងឲ្យមាសនិក្ខ ១០០០ នឹងស្រុកចំនួន ៨០ ក្នុងដែនកាសីដល់អ្នក យើងឲ្យទាសី ៤០០ នឹងភរិយា ១០០ ដល់អ្នក អ្នកចូរនាំអង្គនៃសេនាទាំងពួងទៅដោយសួស្តីចុះ ។

(២៨៤) ជនទាំងឡាយ ចូរឲ្យគ្រឿងស៊ី ជាទ្វេគុណ ដល់ពួកដំរី ពួកសេះជាកំណត់ ចូរញុំាងពលរថនឹងពលថ្មើរជើងឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនឹងទឹកចុះ ។

(២៨៥) ម្នាលបណ្ឌិត អ្នកចូរនាំយកពួកដំរី ពួកសេះ ពួករថ នឹងពួកពលថ្មើរជើងទៅ ព្រះបាទវិទេហៈមហារាជ ចូរទតឃើញអ្នក ដែលទៅដល់ក្រុងមិថិលាចុះ ។

(៤៨៦) ហត្ថី អស្សា រថា បត្តី សេនា សាធិស្សតេ មហា
ចតុរង្គិនី ភីសរូបា កិំ នុ មញ្ញន្តិ បណ្ឌិតា ។

(៤៨៧) អានន្ទំ តេ មហារាជ ឧត្តមោ បដិនិស្សតិ
សព្វំ សេនង្គមាទាយ សោត្ថិំ បត្តោ មហោសធោ ។

(៤៨៨) យថា បេតំ សុសានស្មឹ ឆឌ្ឌេត្វា ចតុកេ ជនា
ឯវំ កាបិលិយេ ត្យត្តា ឆឌ្ឌយិត្វា ឥធាគតា
អថ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា
កេន វា អត្ថជាតេន អត្តានំ បរិមោចយិ ។

(៤៨៩) អត្ថំ អត្ថេន វេទេហ មន្តំ មន្តេន ខត្តិយ
បរិវារយិស្សំ រាជានំ ជម្ពុទីបំវ សាគរោ ។
ទិន្នំ និក្ខសហស្សំ មេ គាមាសីតិញ្ច កាសិសុ
ទាសីសតានិ ចត្តារិ ទិន្នំ ភរិយាសតញ្ច មេ
សព្វំ សេនង្គមាទាយ សោត្ថិនាម្ហិ ឥធាគតោ ។



(៤៨៦) (ព្រះបាទវេទេហៈ . . .) សេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ និងសេនាថ្មើរជើងនោះ ប្រាកដជាមានច្រើន មានសភាពគួរខ្លាច តើបណ្ឌិតទាំងឡាយសំគាល់ដូចម្តេចហ្ន៎ ។

(៤៨៧) (សាមន្តសេនកៈ . . .) បពិត្រមហារាជ សេចក្តីត្រេកអរយ៉ាងខ្ពង់ខ្ពស់ រមែងនឹងប្រាកដដល់ព្រះអង្គ មហោសធនាំយកអង្គនៃសេនាទាំងពួង មកដល់ហើយដោយសួស្តី ។

(៤៨៨) (ព្រះបាទវេទេហៈ...) ម្នាលមហោសធ ជនទាំង ៤ នាក់នាំមនុស្សស្លាប់ទៅចោលក្នុងព្រៃស្មសាន (ហើយត្រឡប់មក) យ៉ាងណា គួរយើងបោះបង់អ្នកចោលក្នុងដែនកបិលរដ្ឋ ហើយត្រឡប់មកក្នុងទីនេះ ក៏ដូច្នោះ ។ កាលបើដូច្នេះ អ្នកបានរួចខ្លួនមក ដោយហេតុដូចម្តេច ដោយបច្ច័យដូចម្តេច ដោយប្រការដូចម្តេច ។

(៤៨៩) (មហោសធ...) បពិត្រក្សត្រិយ៍ព្រះនាមវេទេហៈ ទូលព្រះបង្គំបានការពារនូវសេចក្តី ដោយសេចក្តី នូវការប្រឹក្សា ដោយប្រឹក្សា ទូលព្រះបង្គំបានការពារស្តេច ដូចជាសាគរការពារជម្ពូទ្វីបដូច្នោះ ។ ព្រះបាទចូឡនីបានប្រទាននិក្ខមាស ១០០០ និងស្រុកចំនួន ៨០ ក្នុងដែនកាសីដល់ទូលព្រះបង្គំ ប្រទានទាសី ៤០០ និងភរិយា ១០០ ដល់ទូលព្រះបង្គំ ទូលព្រះបង្គំជាអ្នកនាំអង្គនៃសេនាទាំងពួង មកកាន់ទីនេះដោយសួស្តី ។

(៦៩០) សុសុខំ វត សំវាសោ បណ្ឌិតេហីតិ សេនក
បក្ខីវ បញ្ជរេ ពទ្ធេ មច្ឆេ ជាលគតេរិវ
អមិត្តហត្ថត្តគតេ មោចយី នោ មហោសធោ។

(៦៩១) ឯវមេតំ មហារាជ បណ្ឌិតា ហិ សុខាវហា
បក្ខីវ បញ្ជរេ ពទ្ធេ មច្ឆេ ជាលគតេរិវ
អមិត្តហត្ថត្តគតេ មោចយី នោ មហោសធោ។

(៦៩២) អាហញ្ញន្តុ សព្វវីណា ភេរិយោ ទេន្ទិមានិ ច
ធមេន្តុ មាគធា សង្ខា[1] វគ្គូ នទន្តុ ទុន្ទុភី។

(៦៩៣) ឱរោធា ច កុមារា ច វេសិយានា ច ព្រាហ្មណា
ពហុំ អន្នញ្ច បានញ្ច បណ្ឌិតស្សាភិហារយុំ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
ពហុំ អន្នញ្ច បានញ្ច បណ្ឌិតស្សាភិហារយុំ។
សមាគតា ជានបទា នេគមា ច សមាគតា
ពហុំ អន្នញ្ច បានញ្ច បណ្ឌិតស្សាភិហារយុំ។
ពហុជ្ជនោ បសន្នោសិ ទិស្វា បណ្ឌិតមាគតំ
បណ្ឌិតម្ហិ អនុប្បត្តេ ចេលុក្ខេបោ បវត្តថាតិ។

មហោសធជាតកំ(២) បញ្ចមំ ។

---

១ ម. ធមន្តុ មាគធសង្ខា ។ ២ ម. ឧម្មង្គជាតកំ ។



(៦៩០) (ព្រះបាទវេទេហៈ ...) នែសេនកៈ ការនៅរួមជាមួយនឹងពួកប្រាជ្ញ នាំមកនូវសេចក្តីសុខស្រួលណាស់ហ្ន៎ មហោសធបានដោះពួកយើងដែលធ្លាក់ទៅក្នុងសេចក្តីលំបាកក្នុងដៃនៃសត្រូវ ដូចជាគេដោះបក្សីដែលជាប់នៅក្នុងទ្រុង ឬ ដូចជាគេដោះត្រីដែលជាប់នៅក្នុងសំណាញ់ ។

(៦៩១) (សេនកបណ្ឌិត...) បពិត្រមហារាជ វិសេសពិត ពួកបណ្ឌិតតែងនាំមកនូវសេចក្តីសុខយ៉ាងនេះឯង មហោសធបានដោះពួកយើងដែលធ្លាក់ទៅក្នុងសេចក្តីលំបាកនៃសត្រូវ ដូចជាគេដោះបក្សីដែលជាប់ក្នុងទ្រុង ឬដូចជាគេដោះត្រីដែលជាប់ក្នុងសំណាញ់ ។

(៦៩២) (ព្រះសម្ពុទ្ធត្រាស់...) ពួកជនចូរដេញពិណ ចូរវាយស្គរតូចនិងស្គរធំ ចូរផ្លុំស័ង្ខដែលកើតក្នុងដែនមគធៈ និងចូរឲ្យស្គរធំមានសំឡេងពីរោះ ។

(៦៩៣) ពួកស្រីស្នំ ពួកកុមារ ពួកវេស្សៈ និងពួកព្រាហ្មណ៍ នាំបាយនិងទឹកជាច្រើនមកជូន (មហោសធបណ្ឌិត) ។ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង នាំបាយនិងទឹកជាច្រើន មកជូនបណ្ឌិត ។ ពួកអ្នកជនបទប្រជុំគ្នា ទាំងពួកអ្នកនិគមក៏មកប្រជុំគ្នា នាំបាយនិងទឹកជាច្រើនមកជូនបណ្ឌិត ។ ជនជាច្រើន កាលបើបានឃើញបណ្ឌិតមកដល់ហើយ ក៏មានសេចក្តីជ្រះថ្លា កាលបើបណ្ឌិតមកដល់ហើយ ការលើកឡើងនូវសំពត់ ក៏ប្រព្រឹត្តទៅ ។

ចប់ មហោសធជាតក ទី ៥ ។

(២៩៤) យង្កិញ្ចិ រតនមត្ថិ ធតរដ្ឋនិវេសនេ
សព្វានិ តេ ឧបយន្តុ ធីតរំ ទេហិ រាជិនោ ។

(២៩៥) ន នោ វិវាហោ នាគេហិ កតបុព្វោ កុទាចនំ
តំ វិវាហំ អសំយុត្តំ កថំ អម្ហេ ករោមសេ ។

(២៩៦) ជីវិតំ នូន តេ ចត្តំ រដ្ឋំ វា មនុជាធិប
ន ហិ នាគេ កុបិតម្ហិ ចិរំ ជីវន្តិ តាទិសា ។
យោ ត្វំ ទេវ មនុស្សោសិ ឥទ្ធិមន្តំ អនិទ្ធិមា
វរុណស្ស និយំ បុត្តំ យាមុនំ អតិមញ្ញសិ ។

(២៩៧) នាតិមញ្ញាមិ រាជានំ ធតរដ្ឋំ យសស្សិនំ
ធតរដ្ឋោ ហិ នាគានំ ពហូនមបិ ឥស្សរោ ។
អហិ មហានុភាវោបិ ន មេ ធីតរមារហោ
ខត្តិយោ ច វិទេហានំ អភិជាតា សមុទ្ទជា ។



(២៩៤) (នាគទាំង ៤ ក្រាបបង្គំទូលថា) រតនៈណាមួយ មានក្នុងនិវេសន៍របស់នាគរាជព្រះនាមធតរដ្ឋ រតនៈទាំងអស់នោះ ចូរមកដល់ព្រះអង្គ សូមព្រះអង្គប្រទានព្រះធីតា ដល់ព្រះរាជាយើង ។

(២៩៥) (ព្រះបាទព្រហ្មទត្តត្រាស់ថា) វិវាហៈជាមួយនឹងពួកនាគ យើងមិនធ្លាប់ធ្វើ ក្នុងកាលណាមួយឡើយ យើងនឹងធ្វើវិវាហៈមិនសមគួរនោះ ដូចម្ដេចកើត ។

(២៩៦) (នាគទាំង ៤...) បពិត្រព្រះអង្គជាធំជាងមនុស្ស ជីវិតក្ដី ដែនក្ដី ព្រះអង្គនឹងលះបង់ដោយពិត កាលបើនាគទាំងនោះខឹងហើយ ព្រះរាជាទាំងឡាយប្រហែលនឹងព្រះអង្គ មិនគង់ព្រះជន្មនៅយូរទេ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គណាជាមនុស្ស ព្រះអង្គនោះមិនមានឫទ្ធិ មើលងាយព្រះរាជាដែលមានឫទ្ធិ ជាកូនបង្កើតនៃព្រះវរុណនាគ ដែលកើតក្នុងទន្លេយមុនា ។

(២៩៧) (ព្រះរាជា...) យើងមិនមើលងាយព្រះបាទធតរដ្ឋ ដ៏មានយសទេ ព្រោះថា ព្រះបាទធតរដ្ឋ ជាធំជាងនាគទាំងឡាយដ៏ច្រើន ។ ពស់ទុកជាមានអានុភាពច្រើន ក៏មិនសមគួរនឹងធីតារបស់យើងទេ ចំណែកខាងយើង ជាក្សត្រិយ៍ របស់អ្នកដែនវិទេហៈ ធីតា (របស់យើង) ឈ្មោះសមុទ្ទជា មានជាតិដ៏ប្រសើរ ។

[២៩៨] កម្ពលស្សតរា ឧដ្ឋេន្តុ សព្វេ នាគេ និវេទយ

ពារាណសឹ បវត្តន្តុ មា ច កញ្ចិ វិហេឋយុំ ។

[២៩៩] និវេសនេសុ សោច្ឆេសុ រថិយា ចច្ចរេសុ ច

រុក្ខគ្គេសុ ច លម្ពន្តុ វិតតា តោរណេសុ ច ។

អហម្បិ សព្វសេតេន មហតា សុមហំ បុរំ

បរិក្ខិបិស្សំ ភោគេហិ កាសីនំ ជនយំ ភយំ ។

[៣០០] តស្ស តំ វចនំ សុត្វា ឧរគានេកវណ្ណិនោ

ពារាណសឹ បវជ្ជឹសុ ន ច កញ្ចិ វិហេឋយុំ ។

និវេសនេសុ សោច្ឆេសុ រថិយា ចច្ចរេសុ ច

រុក្ខគ្គេសុ ច លម្ពឹសុ វិតតា តោរណេសុ ច ។

ឋាតេ(១) ទិស្វាន លម្ពន្តេ បុថូ កន្ទឹសុ នារិយោ

នាគេ សោណ្ឌិកតេ ទិស្វា បស្សសន្តេ មុហុំ មុហុំ ។

១ ម. ឧ. តេសុ ។





[២៩៨] (ព្រះបាទធតរដ្ឋ . . .) ពួកនាគឈ្មោះកម្ពលស្សតរៈ(១) ចូរក្រោកឡើង អ្នកចូរប្រាប់នាគទាំងអស់ថា នាគទាំងឡាយ ចូរទៅកាន់ក្រុងពារាណសី តែកុំបៀតបៀនបុគ្គលណាមួយឡើយ ។

[២៩៩] នាគទាំងឡាយដែលមានសរីរៈធំ ចូលសំយុងនៅក្នុងនិវេសន-ដ្ឋានទាំងឡាយក្នុងស្រុក ត្រង់ផ្លូវដើរ ក្នុងព្រលាន លើចុងឈើ និងលើក្លោងទ្វារ ។ ចំណែកខាងខ្ញុំ មានកាយធំសសុទ្ធ នឹងព័ទ្ធបុរីដែលធំទូលាយ ដោយភោគទាំងឡាយ នឹងញុំាងភ័យឲ្យកើតឡើង ដល់ពួកអ្នកដែនកាសី ។

[៣០០] នាគទាំងឡាយ មានសម្បុរដ៏ច្រើន បានស្តាប់ពាក្យព្រះបាទ-ធតរដ្ឋនោះហើយ ក៏ចូលទៅកាន់ក្រុងពារាណសី តែមិនបៀតបៀនបុគ្គលណាមួយឡើយ ។ នាគទាំងឡាយដែលមានសរីរៈធំ ក៏សំយុងនៅក្នុងនិវេសនដ្ឋានក្នុងស្រុក ត្រង់ផ្លូវដើរ ក្នុងព្រលាន លើចុងឈើ និងលើក្លោងទ្វារ ។ នារីទាំងឡាយជា-ច្រើនបានឃើញនាគទាំងនោះ កំពុងសំយុងនៅ លុះឃើញពួកនាគបើកពពារ កំពុងដង្ហើមរឿយៗ ក៏កន្ទក់កន្ទេញ ។

១ ពួកនាគដែលមានឈ្មោះយ៉ាងនេះ គឺជាពួកនាគនៅក្បែរភ្នំកម្ពលិះនោះ ត្រូវជាញាតិខាងមាតារបស់ព្រះបាទធតរដ្ឋ ។ អដ្ឋកថា ។

ពាកណាសី សព្យាធិកា អាតុរា សមបជ្ជិ

ពាហា បគ្គយ្ហ បញ្ជលិំ ជិតាំ នេហិ ភជិតោ ។

(៣០១) មុទ្ធាភិហារស្ស វនស្ស មជ្ឈេ

កោ លោហិតក្ខោ វិហតន្តរំសោ

កា កម្ពុកាយូរធរា សុវត្ថា

តិដ្ឋន្តិ នារិយោ ទស វន្ទមានា ។

កោ ត្វំ ព្រហាពាហុ វនស្ស មជ្ឈេ

វិរោចសិ ឃតសិត្តោវ អគ្គិ

មហេសក្ខោ អញ្ញតរោសិ យក្ខោ

ឧទាហុ នាគោសិ មហានុភាវោ ។

(៣០២) នាគោហមស្មិ ឥទ្ធិមា តេជស្សី ទុរតិក្កមោ

ឌំសេយ្យំ តេជសា កុទ្ធោ ផីតំ ជនបទំ អបិ ។

សមុទ្ទជា ហិ មេ មាតា ធតរដ្ឋោ ច មេ បិតា

សុទស្សនកនិដ្ឋោស្មិ ភូរិទត្តោតិ មំ វិទូ ។

(៣០៣) យំ គម្ភីរំ សទាវដ្ដំ រហទំ ភេស្មំ បេក្ខសិ

ឯសោ ទិព្យោ មមាវាសោ អនេកសតបោរិសោ ។





ពួកជនក្នុងពាកណាសី កក់ស្មុកក្ដៅក្រហាយ ក៏លើកដៃកន្តក់

ការទួញថា សូមព្រះអង្គប្រទានទឹកដល់ខាងកជ ។

(៣០១) (ក្រហមណាំមេសោម...) អ្នកជាអ្វី មានភ្នែក

ក្រហម មានចន្លោះស្មាទូលាយ (អង្គុយ) ក្នុង

កណ្ដាល នៃព្រៃជាទីគាប់ចិត្តដោយផ្កាឈើ

ស្រីទាំង១០ នាក់ ជាអ្វី ដែលប្រដាប់ខ្លួនសង្វារដៃ

ពាក់កងដៃមានសំពត់ដ៏ល្អក៏ក្ដីឈរសំពះ ។

អ្នកជាអ្វី មានដៃធំវែងរុងរឿងក្នុងកណ្ដាលព្រៃ ដូច

ភ្លើងនេះ ខ្ញុំទាំងឡាយ អ្នកជាយក្សណាមួយ

ដែលមានសក្តិធំ ឬជានាគមានអានុភាពធំ ។

(៣០២) (នាគោហមស្មិ...) ខ្ញុំជានាគមានឫទ្ធិ មានតេជះ ដែលគេកន្លង

មិនបាន ប្រសិនជាខ្ញុំក្រោធ គាបចិត្តសូម្បីនូវជនបទ ដែល

ចម្រើន (ដោយតេជះ) ដោយតេជះបាន ។ ឯមាតារបស់ខ្ញុំ

ឈ្មោះសមុទ្ទជា បិតារបស់ខ្ញុំឈ្មោះធតរដ្ឋ ខ្ញុំជាប្អូននៃនាគជ

ឈ្មោះសុទស្សនៈ ជនទាំងឡាយស្គាល់ខ្ញុំថា ភូរិទត្ត ។

(៣០៣) លោកនៅមើលឃើញ អន្លង់ទឹកណាជ្រៅ ដែលគួរ

ខ្លាចសព្វកាល ជាអន្លង់ទឹកគួរខ្លាច អន្លង់ទឹកនោះជាទិព្វ

ជាលំនៅរបស់ខ្ញុំ មានជម្រៅ ច្រើនរយនៃផ្ទៃបុរស ។

មយូរកោញ្ចាភិរុទំ   ទីលោធំ វនមជ្ឈតោ

យមុនំ បរិសមា ភិតោ ខេមំ វត្តតី សិរី ។

[៣០៦]តត្ថ បត្តោ សានុចរោ   សហ បុត្តេន ព្រាហ្មណោ

បូជិតោ មយ្ហំ ការេមហិ   សុខំ ព្រាហ្មណ វច្ឆសិ ។

[៣០៧]សទា សមន្តបរិតោ   បហុតកាក(១) មហី

ឥន្ទគោបកសញ្ឆន្នា   សោភតិ ហរិតុត្តមា ។

រម្មានិ វនគុម្ពានិ   រម្មា ហំសូបកូជិតា

ឧប្បបទុមា តិដ្ឋន្តិ   ពោក្ខរញ្ញោ សុនិម្មិតា ។

អដ្ឋំសា សុកតា ថម្ភា   សព្វេ វេឡុរិយាមយា

សហស្សថម្ភា បាសាទា បូរា កញ្ញាហិ ជោតរេ ។

វិមានំ ឧបបន្នោសិ   ទិព្វំ បុញ្ញេហិ អត្តនោ

អសម្ពាធំ សិវំ រម្មំ   អច្ចន្តសុខសញ្ហិតំ ។

មញ្ញេ សហស្សនេត្តស្ស   វិមានំ នាភិកង្ខសិ

ឥទ្ធិ ហិ ត្យាយំ វិបុលា   សក្កស្សេវ ជុតីមតោ ។

១ ម. បហុតាទន្តកា ។



អក្ខាត ហូចូលទៅកាន់ស្ទឹងយមុនា មានទឹកទៀត (ដែលហូរមក ) ត្រង់កណ្តាលព្រៃ ជាកន្លែងដែលក្ងោកនឹងក្រៀលយំ ជាស្ទឹងត្រជាក់ក្សេមក្សាន្ត ជាទីនៅរបស់ពួកអ្នកមានខ្ញុំ ។

(៣០៦) ម្នាលព្រាហ្មណ៍ អ្នកព្រមទាំងកូនមកដល់ក្នុងនោះហើយ នឹងបានប្រពន្ធ ម្នាលព្រាហ្មណ៍ យើងនឹងបូជាអ្នកដោយកាមទាំងឡាយរបស់យើង អ្នកចូរនៅឲ្យសុខចុះ ។

(៣០៧) ( ព្រាហ្មណ៍នេះលោក . . . ) ផែនដីមានផ្កាបាស្មើដោយជុំវិញ មានដើមក្រឹស្នាច្រើន ដេរដាសដោយមមាចៀង មានស្មៅខៀវដ៏ឧត្តមល្អ ។ ព្រៃព្រឹក្សគួរត្រេកអរ ស្រះបោក្ខរណីទាំងឡាយដែលបុគ្គលមករបស់ព្រះឥន្ទ្រនិម្មិតល្អហើយ ជាទីរីករាយ ដែលហង្សយំហើយ មានផ្កាឈូកផ្កាកុះ ៗ សសរមានជ្រុង ៨ ដែលគេធ្វើល្អហើយ ជាវិការៈនៃកែវពិទូរ្យទាំងអស់ ប្រាសាទទាំងឡាយមានសសរ ១ ពាន់ ពេញដោយនាងកញ្ញាភ្លឺរុងរឿង ។ ព្រះអង្គបានដល់នូវវិមានជាទិព្វ ដោយបុណ្យរបស់ព្រះអង្គ ជាវិមានមិនចង្អៀតជាទីក្សេមគួរត្រេកអរ ប្រកបដោយសេចក្តីសុខ ហួសក្រៃលែង ។ ខ្ញុំសំគាល់ថាព្រះអង្គ មិនប្រាថ្នាវិមានរបស់ព្រះឥន្ទ្រជាសហស្សនេត្រទេ ព្រោះថាឫទ្ធិរបស់ព្រះអង្គនេះ ដ៏ធំដូចជាឫទ្ធិនៃព្រះឥន្ទ្រដ៏រុងរឿងដែរ ។

(៣០៦) មនសាបិ ន បត្តោ   អានុភាវំ ជុតិមតោ
បរិចារិយមានានំ   ឥន្ទានំ វសវត្តិនំ ។

(៣០៧) តំ វិមានំ អភិជ្ឈាយ   អមរានំ សុខេសិនំ
ឧបោសថំ ឧបវសន្តោ   សេមិ វម្មិកមុទ្ធនិ ។

(៣០៨) អហញ្ច មិគមេសានោ   សបុត្តោ បាវិសឹ វនំ
តំ មំ មតំ វា ជីវំ វា   នាភិវេទេន្តិ ញាតកា ។
អាមន្តយេ ភូរិទត្តំ   កាសិបុត្តំ យសស្សិនំ
តយា នោ សមនុញ្ញាតា   អបិ បស្សេមុ ញាតកេ ។

(៣០៩) ឯសោ ហិ វត មេ ឆន្ទោ   យំ វសេសិ មមន្តិកេ
ន ហិ ឯតាទិសា កាមា   សុលភា ហោន្តិ មានុសេ ។
សចេ ត្វំ និច្ឆសេ វត្ថុំ   មម កាមេហិ បូជិតោ
មយា ត្វំ សមនុញ្ញាតោ   សោត្ថឹ បស្សាហិ ញាតកេ ។

(៣១០) ធារយិមំ មណឹ ទិព្វំ   បសុំ បុត្តេ ច វិន្ទតិ
អរោគោ សុខិតោ ហោហិ   គច្ឆេវាទាយ ព្រាហ្មណ ។



(៣០៦) (ភូរិទត្តនាគរាជ...) អានុភាពរបស់ព្រះវេស្សវណ្ណ អានុភាព របស់លោកបាលទាំង ៤ ញុំាងអំណាចឱ្យប្រព្រឹត្តទៅ ជាអ្នក បម្រើព្រះវេស្សវណ្ណ អ្នកមិនគប្បីដឹងដោយចិត្តបានទេ ។

(៣០៧) ខ្ញុំប្រាថ្នាវិមាននោះរបស់ទេវតាទាំងឡាយ អ្នកស្វែងរកសេចក្តី សុខ បានជាក្សត្រុឧបោសថ ហើយដេកលើក្បាលដំបូក ។

(៣០៨) (ព្រាហ្មណ៍នេសាទ...) ឯខ្ញុំព្រមទាំងកូនស្វែងរកម្រឹគ បាន ចូលទៅកាន់ព្រៃ ញាតិទាំងនោះ មិនដឹងខ្ញុំថា ស្លាប់ឬរស់ទេ ។ ខ្ញុំសូមលាព្រះភូរិទត្ត ជាបុត្រព្រះរាជធីតាក្នុងដែនកាសី ព្រះអង្គ មានយស បើខ្ញុំបានព្រះអង្គព្រមអនុញ្ញាតហើយ គប្បីឃើញ ពួកញាតិ ។

(៣០៩) (ភូរិទត្តនាគរាជ...) ឧន្ទៈកើតជាសេចក្តីពេញចិត្តរបស់ខ្ញុំ ហើយ ត្រង់ដែលអ្នកនៅក្នុងសំណាក់នៃខ្ញុំ ព្រោះថាកាមទាំងឡាយប្រាក-ដដូច្នេះ អ្នកមិនងាយបានក្នុងពួកមនុស្សទេ ។ អ្នកដែលខ្ញុំបូជា ដោយកាមទាំងឡាយរបស់ខ្ញុំ បើមិនចង់នៅទេ ខ្ញុំនឹងអនុញ្ញាត អ្នក សូមអ្នកទៅជួបពួកញាតិដោយសួស្តីចុះ ។

(៣១០) អ្នកកាន់យកត្បូងកែវមណីជាទិព្វនេះ រមែងបានសត្វចិញ្ចឹមនឹង បុត្រ អ្នកចូរមិនមានរោគបានសេចក្តីសុខ នែព្រាហ្មណ៍ អ្នក ចូរយក (ត្បូងកែវមណីនេះ) ហើយទៅចុះ ។

(៣១១) កុសលំ បដិនន្ទាមិ ភូរិទត្ត វចោ តវ

បព្វជិស្សាមិ ជិណ្ណោស្មិ ន កាមេ អភិបត្ថយេ ។

(៣១២) ព្រហ្មចរិយស្ស ចេ អន្តោ ហោតិ កោ តេ ហិ ការិយំ

អវិកម្បមានោ ឋយ្យាសិ ពហុំ បសវិស្សសិ បុញ្ញំ ។

(៣១៣) កុសលំ បដិនន្ទាមិ ភូរិទត្ត វចោ តវ

បុនបិ អាគមិស្សាមិ សាចេ អត្ថោ ភវិស្សតិ ។

(៣១៤) ឥទំ វត្វា ភូរិទត្តោ បេសេសិ ចតុរោ ជនេ

ឯថ គច្ឆថ ឧដ្ឋេថ ខិប្បំ គាមេថ ព្រាហ្មណំ ។

តស្ស តំ វចនំ សុត្វា ឧដ្ឋាយ ចតុរោ ជនា

បេសិតា ភូរិទត្តេន ខិប្បំ គាមេសុ ព្រាហ្មណំ ។

(៣១៥) មណី បគ្គយ្ហ មង្គល្យំ សាធុ វិត្តំ មនោរមំ

សេលំ ព្យញ្ជនសម្បន្នំ កោ ឥមំ មណិមជ្ឈគា ។



(៣១១) (ព្រាហ្មណ៍នេសាទ ...) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ខ្ញុំនឹងបួស ព្រោះខ្ញុំចាស់ ហើយខ្ញុំមិនប្រាថ្នាកាមទេ ។

(៣១២) (ភូរិទត្តនាគរាជ ...) បើមានការបែកធ្លាយព្រហ្មចរិយៈ កិច្ចការដែលត្រូវធ្វើដោយការៈទាំងឡាយ ( រឿងមិនមាន ) អ្នកកុំមានសេចក្តីកន្ទៀសឡើយ តបវិញមក យើងនឹងឲ្យទ្រព្យដ៏ច្រើនដល់អ្នក ។

(៣១៣) (ព្រាហ្មណ៍នេសាទ ...) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូល របស់ព្រះអង្គ ប្រសិនបើមានសេចក្តីត្រូវការ ខ្ញុំនឹងមកម្តងទៀត ។

(៣១៤) (អភិសម្ពុទ្ធគាថា) ព្រះភូរិទត្ត លុះពោលពាក្យនេះហើយ ក៏បញ្ជូនខ្ញុំនាគទាំង ៤ ថា អ្នកទាំងឡាយមកនេះ ចូរទៅ ចូរក្រោកឡើង ចូរញ៉ាំងព្រាហ្មណ៍ឲ្យដល់ ( នាំផ្លូវជាទីទៅកាន់ស្រុកពារាណសី ) ជាឆាប់ ។ នាគទាំង ៤ ត្រូវភូរិទត្តប្រើទៅ ហើយ បានស្តាប់ពាក្យនោះ របស់ភូរិទត្តនោះ ក៏ក្រោកឡើង ហើយបានញ៉ាំងព្រាហ្មណ៍ឲ្យដល់ឆាប់ ។

(៣១៥) (ព្រាហ្មណ៍នេសាទ ...) អ្នកកាន់យកកែវមណី ជាមង្គល ជាទ្រព្យដ៏ប្រសើរ ជាទីពេញចិត្ត ជាថ្មប្រណីត ដោយទ្រង់ទ្រាយ អ្នកបានកែវមណីនេះអំពីទីណា ។

(៣១៦) លោហិតង្កសហស្សេហិ សមន្តា បរិកិរិតំ

អជ្ជ កាលំ បថំ គច្ឆំ អជ្ឈគាហំ មណឹ ឥមំ ។

(៣១៧) សុចិណ្ណោ អយំ សេលោ អច្ចិមា ផលិកោបមោ

សុធារិតោ សុនិក្ខិត្តោ សព្វត្ថមភិសាធយេ ។

ឧបចារវិបន្នស្ស និក្ខេបេ ការណាយកំ

អយំ សេលោ វិនាសាយ បរិចិណ្ណោ អយោនិសោ ។

នយិមំ អកុសលោ និច្ចំ មណឹ ធារេតុមរហោ

បដិបជ្ជ សតំ និក្ខំ ទេហិមំ រតនំ មម ។

(៣១៨) ន ច មាយំ មណិ កេយ្យោ គោហិ[១] ភណ្ឌេហិ វា

សេលោ ព្យញ្ជនសម្បន្នោ នេវ កេយ្យោ មណិ មម ។

(៣១៩) នោ ចេ តយា មណិ កេយ្យោ គោហិ ភណ្ឌេហិ វា

អថ កេន មណិ កេយ្យោ តំ មេ អក្ខាហិ បុច្ឆិតោ ។

(៣២០) យោ មេ សំសេ មហានាគំ តេជស្សឹ ទុរតិក្កមំ

តស្ស ទជ្ជំ ឥមំ សេលំ ជលន្តមិវ តេជសា ។

១ ម. គវហិ ។



(៣១៦) (អាលម្ពាយនព្រាហ្មណ៍...) ថ្ងៃនេះខ្ញុំទៅកាន់ផ្លូវតាំងពីព្រឹក បានកែវមណីនេះ ដែលភ្ជួកដាក់ដោយកែវក្រហមមួយពាន់ជុំវិញហើយ ។

(៣១៧) (ព្រាហ្មណ៍នេសាទ...) កែវមណីនេះ បើបុគ្គលសន្សំទុកល្អដែលតាំង បូជាគ្រប់គ្រងល្អ ទុកដាក់ល្អហើយសព្វកាល គប្បីញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេចបាន ។ តែកាលបើបុគ្គលជាអ្នកប្រាសចាកការថែទាំ គឺការទុកដាក់ ឬគឺការប្រើប្រាស់វិញ កែវមណីនេះ ដែលគេសន្សំទុកដោយមិនត្រូវទំនងនឹងដល់សេចក្តីវិនាស ។ អ្នកជាបុគ្គលមិនឈ្លាស មិនគួរគ្រប់គ្រងកែវមណីជាទិព្វនេះទេ អ្នកចូរគ្រប់គ្រងនូវមាសមួយរយចុះ ចូរឲ្យកែវមណីនេះដល់ខ្ញុំ ។

(៣១៨) (អាលម្ពាយនព្រាហ្មណ៍...) កែវមណីនេះ ខ្ញុំមិនគប្បីលក់ ដោយគោ ឬដោយរតនៈទាំងឡាយទេ កែវមណីរបស់ខ្ញុំ ដែលពេញគាប់ចិត្ត បរិបូណ៌ដោយទ្រង់ទ្រាយ ខ្ញុំមិនគប្បីលក់ទេ ។

(៣១៩) (ព្រាហ្មណ៍នេសាទ...) បើកែវមណីអ្នកមិនលក់ ដោយគោ ឬដោយរតនៈទាំងឡាយទេ ចុះកែវមណីអ្នកនឹងលក់ដោយវត្ថុអ្វី ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនោះ ។

(៣២០) (អាលម្ពាយនព្រាហ្មណ៍...) បុគ្គលណាគប្បីបង្ហាញនាគដ៏មានតេជៈ ដែលគេកន្លងបានដោយក្រ ដល់ខ្ញុំ ខ្ញុំនឹងឲ្យកែវមណី ដ៏រុងរឿងដោយតេជៈដល់បុគ្គលនោះ ។

(៣៤១) កោ នុ ព្រាហ្មណវណ្ណេន សុបណ្ណោ បតតិ វេហា
ឆាតំ ជិគីសមន្វេតិ អន្វេសំ ភក្ខមត្តនោ ។

(៣៤២) នាហំ(១) ទិជាធិបោ ហោមិ ន ទិដ្ឋោ គរុឡោ មយា
អាសីវិសេន វិត្តាស្មិ វេជ្ជោ ព្រាហ្មណ មំ វិទូ ។

(៣៤៣) កឹ នុ តុយ្ហំ ផលំ អត្ថិ កឹ សិប្បំ វិជ្ជតេ តវ
កិស្មឹ វ ត្វំ បរត្ថទ្ធោ ឧរគំ នាបចាយសិ ។

(៣៤៤) អារញ្ញិកស្ស ឥសិនោ ចិរំ រត្តំ តបស្សិនោ
សុបណ្ណោ កោសិយស្សក្ខា វិសវិជ្ជំ អនុត្តរំ ។
តំ ភាវិតត្តញ្ញតរំ សម្មន្តំ បព្វតន្តរេ
សក្កច្ចំ ឧបដ្ឋាសឹ រត្តិន្ទិវមតន្ទិតោ ។
សោ តទា បរិចិណ្ណោ មេ វត្តវា ព្រហ្មចរិយវា
ទិព្វំ បាតុករី មន្តំ កាមសា ភគវា មមំ ។
ត្យាហំ មន្តេ បរត្ថទ្ធោ នាហំ ភាយាមិ(២) ភោគិនំ
អាចរិយោ វិសឃាតានំ អាលម្ពាយនោតិ មំ វិទូ ។

---
១ ម. នាហំ ។ ២ ម. ភយាមិ ។



(៣៤១) (ព្រាហ្មណ៍នេសាទ...) អ្នកជាអ្វី ជាគ្រុឌដ៏ប្រសើរជាងសត្វស្លាបទាំងឡាយ កាលស្វែងរកចំណីដើម្បីខ្លួន ទើបចាប់យកនាគ ដោយភេទជាព្រាហ្មណ៍មក ។

(៣៤២) (កាលាគមនព្រាហ្មណ៍...) ខ្ញុំមិនមែនជាស្តេចសត្វស្លាបទេ គ្រុឌខ្ញុំមិនដែលឃើញទេ ខ្ញុំជាអ្នកត្រេកអរ ដោយការពិស ម្នាលព្រាហ្មណ៍ ជនទាំងឡាយដឹងថា ខ្ញុំជាហ្មពស់ ។

(៣៤៣) (ព្រាហ្មណ៍នេសាទ..) កម្លាំងរបស់អ្នកដូចម្តេច សិល្បៈរបស់អ្នកដូចម្តេច ទាំងអ្នកពឹងពឹងព្រោះហេតុអ្វី បានជាមិនកោតខ្លាចនាគ ។

(៣៤៤) (កាលាគមនព្រាហ្មណ៍...) គ្រុឌបានប្រាប់វិជ្ជាពិសដ៏ប្រសើរ ដល់ឥសីមួយអង្គ ជាកោសិយគោត្រ នៅក្នុងព្រៃ ប្រព្រឹត្តតបធម៌ អស់កាលយូរ ។ ខ្ញុំជាអ្នកមិនខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃ បានបម្រើឥសីមួយអង្គនោះ ដែលមានខ្លួនចំរើនហើយ កាលគង់នៅក្នុងចន្លោះភ្នំដោយសេចក្តីគោរព ។ ឥសីនោះដែលខ្ញុំបានបម្រើ ហើយក្នុងកាលនោះ វត្តក្តី ព្រហ្មចរិយៈក្តី ឥសីនោះបានប្រព្រឹត្ត ហើយ ឥសីមានអំណាចនោះ ក៏បង្រៀនមន្តទិព្វ ដល់ខ្ញុំ តាមសេចក្តីប្រាថ្នា ។ ខ្ញុំជាអ្នកពឹងពឹង ព្រោះមន្តនោះ បានជាមិនខ្លាចនាគទាំងឡាយ ខ្ញុំជាអាចារ្យរបស់ពួកអ្នកសម្លាប់សត្វ មានពិសទាំងឡាយ ជនទាំងឡាយស្គាល់ខ្ញុំថា អាលម្ពាយន៍ ។

(៣៤៥)គណ្ហាមសេ មណឹ តាត សោមទត្ត វិជានាហិ
មា ទណ្ឌេន សិរំ ហត្តំ កាមសា បជហាមសេ។
(៣៤៦)សកំ និវេសនំ បត្តំ យោ តំ ព្រាហ្មណ បូជយិ
ឯវំ កល្យាណការិស្ស កិំ មោហា ទុព្ភិមិច្ឆសិ។
សចេ ត្វំ ធនកាមោសិ ភូរិទត្តោ បទិស្សតិ
តមេវ គន្ត្វា យាចស្សុ ពហុំ ទស្សតិ តេ ធនំ។
(៣៤៧)ហត្ថគតំ បត្តគតំ និក្ខិត្តំ ខាទិតុំ វរំ
មា នោ សន្ទិដ្ឋិកោ អត្ថោ សោមទត្ត ឧបច្ចគា។
(៣៤៨)បច្ចតិ និរយេ ឃោរេ មហិមស្ស វិទ្រិយតិ
មិត្តទុព្ភី ហិតច្ចាគី ជីវរេវាបិ សុស្សតិ។
សចេ ត្វំ ធនកាមោសិ ភូរិទត្តោ បទិស្សតិ
មញ្ញេ អត្តកតំ វេរំ ន ចិរំ វេទយិស្សសិ។



(៣៤៥) (ព្រាហ្មណ៍នេសាទ ...) ម្នាលសោមទត្ត កូន យើងនឹងកាន់យកកែវមណី ចូរអ្នកដឹងចុះ យើងកុំយកដំបងវាយពាល សិរីដែលមកដល់ហើយ តាមសេចក្តីប្រាថ្នាឡើយ ។

(៣៤៦) (សោមទត្តកុមារ...) បពិត្រព្រាហ្មណ៍ ភូរិទត្តណា បានបូជាលោកដែលដល់នូវនិវេសន៍របស់ខ្លួន លោកប្រាថ្នានឹងប្រទូស្ត ចំពោះព្រះភូរិទត្តនោះដែលធ្វើនូវសេចក្តីល្អយ៉ាងនេះ ព្រោះសេចក្តីវង្វេងធ្វើអ្វី ។ បើលោកឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រាកដ ចូរលោកឪពុកទៅសុំលោកចុះ លោកនឹងប្រទាននូវទ្រព្យច្រើនដល់លោកឪពុក ។

(៣៤៧) (ព្រាហ្មណ៍នេសាទ ...) ម្នាលសោមទត្ត យើងគួរស៊ីរបស់ដែលមកដល់ដៃឬដល់ភាជន៍ ប្រសើរជាង កុំឲ្យប្រយោជន៍ដែលឃើញច្បាស់នឹងភ្នែក កន្លងផុតពីយើងទៅបាន ។

(៣៤៨) (សោមទត្តកុមារ...) បុគ្គលជាអ្នកប្រទូស្តមិត្ត ជាអ្នកលះបង់ប្រយោជន៍ រមែងឆេះក្នុងនរកដ៏អាក្រក់ ផែនដីក៏ស្រូបបុគ្គលប្រទូស្តមិត្តនោះ បុគ្គលប្រទូស្តមិត្ត សូម្បីរស់នៅក៏រីងស្ងួត (ដូចជាប្រេត) បើឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទាន មិនខាន ខ្ញុំសំគាល់ថា មិនយូរប៉ុន្មាន ឪពុកនឹងដឹងច្បាស់នូវពៀរដែលខ្លួនធ្វើហើយ ។

(៣២៩) បហាយញ្ញំ យជិត្វាន ឯវំ សុជ្ឈន្តិ ព្រាហ្មណា
មហាយញ្ញំ យជិស្សាម ឯវំ មោក្ខាម បាបកា ។

(៣៣០) ហន្ទទានិ អបាយាមិ នាហំ អជ្ជ តយា សហ
បថមេកំ ន គច្ឆេយ្យំ ឯវំ កិព្វិសការិណា ។

(៣៣១) ឥទំ វត្វាន បក្កាមិ សោមទត្តោ ពហុស្សុតោ
ឧជ្ឈាបេត្វាន ភូតានិ តម្ហា ឋានា អបក្កមិ ។

(៣៣២) គណ្ហាហេតំ មហាធាតំ អាហរេតំ មណឹ មម
ឥន្ទគោបកវណ្ណាភា យស្ស លោហិតកោ សិខោ ។
កប្បាសបិចុរាសីវ ឯសោ កាយោ បទិស្សតិ
វទ្ធិកគ្គកតោ សេតិ តំ ត្វំ គណ្ហាហិ ព្រាហ្មណ ។

(៣៣៣) អថោ សដេហិ និព្វេហិ ជប្បំ ខគ្គបពានិ ច
ឯវត្តិ អសក្កំ ទុដ្ឋំ កាកា បវត្តមត្តកោ ។



(៣២៩) (ព្រាហ្មណ៍ទេសាខ ...) ព្រាហ្មណ៍ទាំងឡាយបូជាមហាយញ្ញហើយ រមែងបរិសុទ្ធយ៉ាងនេះ យើងនឹងបូជាមហាយញ្ញ គង់នឹងរួចចាកបាបដោយការយ៉ាងនេះ ។

(៣៣០) (សោមទត្ត ...) ណ្ហើយចុះឥឡូវនេះ ខ្ញុំនឹងចេញចេញថ្ងៃនេះ ខ្ញុំមិននៅជាមួយនឹងឪពុកទេ ខ្ញុំមិនទៅជាមួយនឹងឪពុក ដែលធ្វើអំពើអាក្រក់យ៉ាងនេះ អស់មួយជំហានទេ ។

(៣៣១) (អភិសម្ពុទ្ធគាថា) សោមទត្តកុមារ ជាពហុស្សុត លុះពោលពាក្យនេះនឹងបិតាហើយ ក៏ប្រកាសទៅកាន់ភូតទាំងឡាយ ហើយចេញចាកទីនោះ ។

(៣៣២) (ព្រាហ្មណ៍ទេសាខ ...) សត្វណាមានពណ៌ដូចជាសត្វរៀល សត្វមេក្បៀ មានក្បាលក្រហម អ្នកចូរចាប់នូវមាន់នុះចុះ ហើយ ចូរនាំមកឱ្យខ្ញុំផង ។ កាយរបស់មាន់នុះ រមែងប្រាកដ ដូចជាគំនរចុងកប្បាស មាន់នេះដេកលើម្លូក ម្នាលព្រាហ្មណ៍ អ្នកចូរចាប់យកមាន់នោះចុះ ។

(៣៣៣) (អភិសម្ពុទ្ធគាថា) គ្រានោះ កាលម្តាយនៃព្រាហ្មណ៍ កាលផ្ចប់ចុងនៃខន្តកាំងឡាយ ធ្វើជាគ្រឿងការពារខ្លួន ដោយទុសងច្ចិតទាំងឡាយហើយ ទើបកាប់មាន់នោះ ដោយពាក្យយ៉ាងនេះ ។

(៣៣៦) ឆម្ភី ទិស្វាន អាយន្តិំ សព្វកាមសមិទ្ធិនឹ

ឥន្ទ្រិយានិ អហដ្ឋានិ សាវំ ជាតំ មុខំ តវ ។

បទុមំ យថា ហត្ថគតំ បាណិនា បរិមទ្ទិតំ

សាវំ ជាតំ មុខំ តុយ្ហំ ឆម្ភី ទិស្វាន បតិសឹ ។

(៣៣៧) កច្ចិ នុ តេ នាភិសសិ កច្ចិ តេ អត្ថិ(១) វេទនា

យេន សាវំ មុខំ តុយ្ហំ ឆម្ភី ទិស្វាន អាគតំ ។

(៣៣៨) សុបិនំ តាត អទ្ទក្ខឹ ឥតោ មាសំ អធោគតំ

ទក្ខិណំ វិយ មេ ពាហុំ ឆេត្វា រុហិរមក្ខិតំ

បុរិសោ អាទាយ បក្កាមិ មម រោទន្តិយា សតិ ។

យតោហំ សុបិនមទ្ទក្ខឹ សុទស្សន វិជានាហិ

តតោ ទិវា វា រត្តឹ វា សុខំ មេ នោបលព្ភតិ ។

(៣៣៩) យំ បុព្វេ បរិវារឹសុ កញ្ញា រុចិរវិគ្គហា

ហេមជាលបដិច្ឆន្នា ភូរិទត្តោ ន ទិស្សតិ ។

---

១ ម. អត្ថុ ។



(៣៣៦) (សុខសុបនោគត ...) ឥន្ទ្រិយរបស់លោកមិនស្រស់បស់ ព្រះភក្ត្ររបស់លោកក៏ខ្មៅ ព្រោះឃើញខ្ញុំ ដែលសម្រេចសេចក្តីប្រាថ្នាទាំងពួងនឹងកំពុងមកតាមលំដាប់ ។ ព្រះភក្ត្ររបស់លោកខ្មៅ ដូចជាផ្កាឈូកដែលបិតនៅក្នុងដៃ ដែលគេប្រទាញ់ដោយដៃ ព្រោះតែឃើញខ្ញុំប្រាកដដូច្នេះ ។

(៣៣៧) តើកង្វល់ណាមួយ មិនកប់កាន់លោកទេឬ ឬវេទនារបស់លោកមានទេឬ ព្រះភក្ត្ររបស់លោកខ្មៅ ព្រោះឃើញខ្ញុំមក ដោយហេតុណា (សូមលោកប្រាប់នូវហេតុនោះដល់ខ្ញុំចុះ) ។

(៣៣៨) (តាតសុបិនំ ...) ម្នាលកូន ក្រោយមួយខែមកហើយ អំពីថ្ងៃនេះ យើងបានឃើញសុបិនថា ហាក់ដូចជាបុរសកាត់ដៃខាងស្តាំរបស់យើង ហើយនាំយកដៃដែលប្រឡាក់ដោយឈាម ដើរចេញទៅក្នុងកាលដែលយើងកំពុងយំ ។ ម្នាលសុទស្សនៈ កាលណាយើងបានឃើញសុបិន អ្នកចូរដឹងថា តាំងពីកាលណោះ យើងមិនបានសេចក្តីសុខទាំងថ្ងៃទាំងយប់ ។

(៣៣៩) នាងកញ្ញាទាំងឡាយ មានរាងកាយដ៏រុងរឿង ពាក់បណ្តាញមាស បានចោមរោមភូរិទត្តណា ពីក្នុងកាលមុន (ឥឡូវនេះ) ភូរិទត្តនោះ យើងមិនឃើញទេ ។

យំ បុព្វេ បរិកិរិំសុ   ចេត្តិសរជាវិយោ
កណិការាវ សម្ពុប្ផា   ត្យាជ្ជេត្តា ន ទិស្សតិ ។
ហត្ថជាតិ គតិស្សាម   ត្យាជ្ជត្តបុរេសតិ
ចម្ពុជ្ជី សីលសម្បន្នំ   បស្សាម ឥវ កាសាំ
(១៣៨)ឯតញ្ច ទិស្វាន អាយន្តិ   ត្យាជ្ជត្តស្ស មាតរំ (១)
កលហា បគ្គយ្ហ បញ្ចន្តំ   ត្យាជ្ជត្តស្ស ករិយាយោ ។
បុត្តេត្តយេ្យ ន ជាតាម   កំពោ មាសំ អទោគតំ
មតំ ក យទិ ក ជីវំ   ត្យាជ្ជត្តំ យសស្សិនំ ។
(១៣៩)សកុណី ហតបុត្តាវ   សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ   រាជបុត្តំ អបស្សតី ។
កុររី(២) ហតច្ឆាបាវ   សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ   រាជបុត្តំ អបស្សតី ។
សា ទូន ចក្កវាកីវ   បល្លលស្មិំ អនូទកេ
ចិរំ ទុក្ខេន ឈាយិស្សំ   រាជបុត្តំ អបស្សតី ។

---

១ ម. ឧ. តាវិយោ ។ ២ ម. ឧទ្ទាលោ សកុណី ហតបុត្តាវ សុញ្ញំ ទិស្វា កុលាវកំ តេន តេន បធាវន្តី បិយបុត្តំ អបស្សន្តី ឥតោ ឥតោ ទិស្សតិ ។





នាគទាំងឡាយដែលកាច់ព្រៃទ័ពដ៏ប្រសើរ ដូចជាផ្កាកណ្ណិការរីក ពោរពេញរាជបុត្រណា ពីព្រឹកកាលមុន (សង្ក្រាន្តនេះ) រាជបុត្រនោះ យើងមិនឃើញទេ ។ ឈ្នឿយចុះសង្ក្រាន្តនេះ យើងនឹងទៅកាន់លំនៅរបស់រាជបុត្រ យើងនឹងនឹងឃើញប្តូររបស់ទុក ដែលតាំងនៅក្នុងមិនបំពួណិដោយសំរេច ។

(១៣៨) (អភិសម្ពុទ្ធគាថា) ឯការោ តាំងឡាយរបស់រាជបុត្រ បានឃើញព្រះមាតានៃរាជបុត្រនោះ កំពុងដើរមក ក៏ផ្តន្ទាំងទៀតនឹកខ្ញុំកញ្ញ ជា ចក្រព្រះលោកឆ្លាយជាម្ចាស់ ក្រោយមួយរឹមកាលហើយអំពី-ថ្ងៃនេះ យើងមិនដឹងរាជបុត្រដ៏មានយស ជាបុត្ររបស់លោក ជាស្លាប់ឬរស់នៅទេ ។

(១៣៩) (អភិសម្ពុទ្ធគាថា ...) យើងកាលមិនឃើញរាជបុត្រទេ នឹងនេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេសត្វស្លាបបាត់កូន ឃើញតែសំបុកទទេដូច្នោះ ។ យើងកាលមិនឃើញរាជបុត្រ នឹងនេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេអកបាត់កូន ឃើញតែសំបុកទទេដូច្នោះ ។ យើងកាលមិនឃើញរាជបុត្រទេ នឹងនេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេសត្វចាក្រពាកនោះ នៅស្រះភក់ ដែលមិនមានទឹកដោយពិត ។

កម្មារានំ យថា ឧក្កា អន្តោ ឈាយតិ នោ ពហិ
ឯវំ ឈាយាមិ សោកេន ភូរិទត្តំ អបស្សតី ។

(៣៤០) សាលាវ សម្បមទ្ទិតា មាលុវេន បមទ្ទិតា
សេន្តិ បុត្តា ច ទារា ច ភូរិទត្តនិវេសនេ ។

(៣៤១) ឥមំ សុត្វាន និគ្ឃោសំ ភូរិទត្តនិវេសនេ
អរិដ្ឋោ ច សុភោគោ ច បធាវិំសុ អនន្តរា
អម្ម អស្សាស មា សោចិ ឯវំធម្មា ហិ បាណិនោ
ចវន្តិ ឧបបជ្ជន្តិ ឯសាស្ស បរិណាមតា ។

(៣៤២) អហម្បិ តាត ជានាមិ ឯវំធម្មា ហិ បាណិនោ
សោកេន ច បរេតស្មិ ភូរិទត្តំ អបស្សតី
អជ្ជ ចេ មេ ឥមំ រត្តឹ សុភោគ វិជានាហិ
ភូរិទត្តំ អបស្សន្តី មញ្ញេ ហិស្សាមិ ជីវិតំ ។



ភ្លើងក្រាននៃឡកជាងមាស តែងឆេះតែក្នុង មិនឆេះខាងក្រៅ យ៉ាងណា យើងកាលមិនឃើញភូរិទត្ត ទើបឆេះដោយសេចក្តីសោក យ៉ាងនោះ ។

(៣៤០) (សាលាវ សម្បមទ្ទិតា) កូនទាំងប្រពន្ធទាំងឡាយ ដួលដេកក្នុងនិវេសន៍របស់ព្រះភូរិទត្ត ដូចជាដើមឈើដែលត្រូវវល្លិ៍ញាំញី បំបាក់ផ្តួល ។

(៣៤១) អរិដ្ឋៈ នឹងសុភោគនាគផង បានឮសម្លេងកកងរអ៊ូរទាំក្នុងនិវេសន៍របស់ព្រះភូរិទត្ត ក៏ស្ទុះទៅតាមលំដាប់ ហើយពោលថា បពិត្រលោកម្តាយ សូមលោកម្តាយដកដង្ហើមស្រួលចុះ កុំសោយសោកឡើយ ព្រោះថាសត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតា តែងច្យុត តែងកើតឡើងវិញ នេះជាការប្រែប្រួលនៃលោក ។

(៣៤២) (អហម្បិ តាត ...) ម្នាលកូន យើងក៏ដឹងថាសត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតាដែរ តែថាយើងកាលមិនឃើញភូរិទត្តទេ ត្រូវសេចក្តីសោកគ្របសង្កត់ហើយ ប្រសិនបើ(ភូរិទត្ត) មិនបាន(មកដល់)នឹងយើងក្នុងថ្ងៃនេះយប់នេះទេ ម្នាលសុភោគៈ អ្នកចូរដឹងចុះ យើងកាលមិនឃើញភូរិទត្តទេ យើងមុខជានឹងលះបង់នូវជីវិតពុំខាន ។

(៣៦៣) អត្ថ អស្សាសមា សោចិ អាចយិស្សាម កាតវេ
ទិសោទិសំ គមិស្សាម កាតុបរិយេសនំ ចរំ
បព្ពតេ គិរិទុគ្គេសុ គាមេសុ និគមេសុ ច
ទិវេន សត្តាន្តស្ស កាតវំ បស្ស អាគតំ ។

(៣៦៤) ហន្ត្វា បទុក្កោ ទុរតោ ឆាទេ តេ ធិបតិ កុសំ
កាដ្ឋំ ទុ ធិសិតោ គាត មា កាយិ សុចិតោ គវំ ។

(៣៦៥) នេវ មយ្ហំ អយំ ទាតោ អលំ ទុក្ខាយ កាយចិ
យាវតេត្ថ មហិច្ឆោ ភោ មយា កិយ្យា ន វិជ្ជតិ ។

(៣៦៦) កោ នុ ព្រាហ្មណវណ្ណេន ទេត្តា[១] បរិសមាគតោ
អវ្ហាយតុ សុយុត្តេន សុណន្តុ បរិសា មម ។

(៣៦៧) ត្វំ នំ ធាវេន កាលត្ត អហំ មណ្ឌកជាបិយា
ហោតុ នោ អត្ថិ ឥត្ថ អា សមាស្សេហិ បញ្ហហិ ។

១ ម. ទិត្តា ។



(៣៦៣) (កូនតាំងឡាយ ...) បពិត្រព្រះតាត សូមលោកជកជង្រើម ស្រួលចុះ កុំសោយសោកឡើយ យើងតាំងឡាយ នឹងនាំ បង់មក យើងតាំងឡាយត្រាច់ទៅកាន់ទីស្រុកភេបង់ នឹងទៅ កាន់ទិសតួចជាលើភ្នំ ជ្រោះភ្នំ ក្នុងស្រុកនិងនិគមតាំងឡាយ លោកចូរឃើញបង់ ដែលមកក្នុងវេជ ទាន់ក្នុងពេលត្រី ។

(៣៦៤) (កាលត្មាយនព្រាហ្មណ៍ ...) តានដែលប្រមូលពីមេ (របស់ យើង) ក្រោយចុះឈើដើនលោកយកដឹកទាំង លោកត្រូវកស់ចិត្ត លោកកុំគ្វាបឡើយ ចូរជល់សេចក្តីសុខចុះ ។

(៣៦៥) (ស្ទាបស្ទួននាគក...) តានទេនមិនកាបឲ្យទុក្ខណាមួយដល់គ្នា ទេ អ្នកចាប់កស់មានតាំងប៉ុន្មានមិនមែនមានច្រើនជាងគ្នាទេ ។

(៣៦៦) កាលត្មាយនព្រាហ្មណ៍ ...) អ្នកណាហ្ន៎ ក្មេងៗ មានភេទ ដូចជាភេទនៃព្រាហ្មណ៍ មកកាន់បរិស័ទ ហើយហៅ (អញ) ឲ្យកើន បរិស័ទចូរស្តាប់ពាក្យរបស់យើងចុះ ។

(៣៦៧) (ស្ទាបស្ទួននាគក ...) ម្នាលកាលត្មាយនិ អ្នកចូលក្នុងនឹង យើងទៅយកតាន យើងក៏ចូលក្នុងនឹងអ្នក ដោយក្នុងកន្លែងដែល កាន្ទាល់ក្នុងចម្បាំងនោះ ចូរមានផល់យើង ដោយកហាបណៈ ៩.០០០ជាកំណត់ ។

(៣៦៨)អហញ្ហិ វសុមា អឌ្ឍោ ត្វំ ទលិទ្ទោសិ មាណវ
កោ នុ តេ បាដិភោគត្ថិ ឧបជ្ជញ្ច កឹ សយា ។
ឧបជ្ជកញ្ច មេ អស្ស បាដិភោគោ ច តាទិសោ
ហោតុ តោ មត្តឹ ឥត្ថ អា សហស្សេហិ បញ្ចហិ ។
(៣៦៩)សុណោហិ មេ មហារាជ វចនំ ភទ្ទមត្ថុ តេ
បញ្ចន្នំ មេ សហស្សានំ បាដិភោគោ ហិ កិត្តិមា ។
(៣៧០)មេត្តិការា ឥណំ ហោតិ យំ ហោតិ សយំ កតំ
កាតុំ បរំ ពហុំ មយ្ហំ ធនំ យាចសិ ព្រាហ្មណ ។
(៣៧១)កាលម្ពាយនោ ហិ ធាតេ ០ មមំ អកិដិតសតិ
អហំ មណ្ឌូកាបាចិយា ឧំសយិស្សតិ ព្រាហ្មណំ ។
តំ ត្វំ ឆដ្ឋំ មហារាជ អជ្ជ ជោតិវត្តេរ
ខុត្តសន្ទេសវរិព្យទេញ្ញា ដីយាហំ អហំនស្សំ ។



(៣៦៨) (កាលម្ពាយនព្រាហ្មណ៍ . . .) ម្នាលមាណព យើងជាអ្នកមានទ្រព្យស្តុកស្តម្ភ អ្នកឯង ជាអ្នកកាន់ក្រ តើបុគ្គលណាជាអ្នកធានាអ្នក ម្យ៉ាងទៀត ទ្រព្យដែលទុកក្នុងការធ្លាក់ មានដែរឬ ។ ទ្រព្យដែលទុកក្នុងការធ្លាក់របស់យើង មាន ចំណែកបុគ្គលជាអ្នកធានាប្រាកដដូច្នោះក៏មានដែរ ការធ្លាក់ក្នុងបញ្ចាំនោះ ប្រមាណដល់យើងដោយគណនាប្រមាណ ៥.០០០ ដាក់ណាក់ ។
(៣៦៩) (សុទស្សនមហារាជ . . .) បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យខ្ញុំព្រះករុណា សេចក្តីចំរើនចូរមានដល់ព្រះអង្គ ព្រះអង្គមានកិត្តិគុណ សូមព្រះអង្គជាធានា ដោយគណនាប្រមាណ ៥.០០០ របស់ខ្ញុំករុណា ។
(៣៧០) (ព្រាហ្មណ៍ . . .) នៃព្រាហ្មណ៍ បំណុលជារបស់នៃបិតា ឬជាខ្ញុំជាប់ដោយខ្លួនឯង បានជាអ្នកមកយកទ្រព្យរបស់យើងច្រើន កើតព្រោះហេតុអ្វី ។
(៣៧១) (សុទស្សនមហារាជ . . .) ព្រោះកាលម្ពាយនព្រាហ្មណ៍ ផ្តាញ់ការតក់ដោយមន្ត ការក្នុងក៏ញុំាងពិសចូលក្នុងបញ្ចាំព្រាហ្មណ៍ ។ បពិត្រមហារាជញុំាងដែលធ្វើប៉ះមិន ព្រោះហេតុនោះ សូមព្រះអង្គ មានព្រះអង្គជាកម្លាំងហាហម យាងទៅដើម្បីឲ្យតាមរំដែលឯងហ្នឹង ។

(៣៨២) នេតំ អតិមញ្ញាមិ សិប្បកេន មាណវ

អតិមញ្ញសិ សិប្បេន ឧរគំ នាបចាយសិ ។

(៣៨៣) អហម្បិ ឥតិមញ្ញាមិ សិប្បកេន ព្រាហ្មណ

អវិសេន ច នាគេន ភុសំ វញ្ចយសេ ជនំ ។

ឯវញ្ចេតំ ជនោ ជញ្ញា យថា ជានាមិ តំ អហំ

ន ត្វំ លភសិ អាលម្ព ធុសមុដ្ឋឹ កុតោ ធនំ ។

(៣៨៤) ខរាជិនោ ជដី ទុម្មី អនង្គោ បរិសមាគតោ

យោ ត្វំ ឯវំ គតំ នាគំ អវិសោ អតិមញ្ញសិ

អាសជ្ជ ខោ នំ ជញ្ញាសិ បុណ្ណំ ឧគ្គស្ស តេជសា

មញ្ញេ តំ ភស្មរាសឹ ខិប្បមេសោ ករិស្សតិ ។

(៣៨៥) សិយា វិសំ សិលុត្តស្ស ទេឌ្ឌុភស្ស សិលាភុនោ

នេវ លោហិតសីសស្ស វិសំ នាគស្ស វិជ្ជតិ ។



(៣៨២) (អាលម្ពាយនព្រាហ្មណ៍ ...) ម្នាលមាណព ខ្ញុំមិនមើលងាយអ្នកដោយសិល្បៈទេ ចំណែកអ្នកមើលងាយដោយសិល្បៈ ហ៊ានធ្វើមិនកោតក្រែងនាគ ។

(៣៨៣) (សុទស្សននាគរាជ ...) នែព្រាហ្មណ៍ អាត្មាក៏មិនមើលងាយអ្នកដោយសិល្បៈទេ តែអ្នកបញ្ឆោតជនច្រើនដោយនាគដែលមិនមានពិស ។ អាត្មាដឹងអ្នកយ៉ាងណា បើជនក៏គប្បីដឹងអ្នកយ៉ាងនោះដែរ ម្នាលអាលម្ពាយន៍ អ្នកមិនបានអង្កាម ១ ក្តាប់នឹងបានទ្រព្យអំពីណា ។

(៣៨៤) (អាលម្ពាយនព្រាហ្មណ៍ ...) អ្នកស្លៀកដណ្តប់ស្បែកខ្លាដ៏ក្រោត មានជដាសក់ ជាមនុស្សកខ្វក់ក្អែល មកកាន់បរិស័ទ ហើយមើលងាយនាគដែលមានយ៉ាងនេះថា មិនមានពិស អ្នកចូលមក ហើយគង់នឹងដឹងនាគនោះ ដែលពេញដោយតេជៈរបស់នាគ ដ៏ខ្ពង់ខ្ពស់ ខ្ញុំសំគាល់ថា នាគនុ៎ះ នឹងធ្វើអ្នកឲ្យដូចជាគំនរផេះ យ៉ាងឆាប់ ។

(៣៨៥) (សុទស្សននាគរាជ ...) ពិសនៃពស់ផ្ទះ ពស់ទឹក ពស់ទៀតគ្រាន់មានខ្លះ ឯពិសនៃនាគ មានក្បាលក្រហម មិនមានសោះឡើយ ។

(៣៨៦) សុតមេតំ អរហតំ សញ្ញតានំ ឥធស្សុតំ

ឥធ ទានានិ ទត្វាន សគ្គំ គច្ឆន្តិ ទាយកា

ជីវន្តោ ទេហិ ទានានិ យទិ តេ អត្ថិ ទាតវេ

អយំ នាគោ មហិទ្ធិកោ តេជស្សី ទុរតិក្កមោ

តេន តំ ឌំសយិស្សាមិ សោ តំ ភស្មំ ករិស្សតិ ។

(៣៨៧) មយាបេតំ សុតំ សម្ម សញ្ញតានំ ឥធស្សុតំ

ឥធ ទានានិ ទត្វាន សគ្គំ គច្ឆន្តិ ទាយកា

ត្វមេវ ទេហិ ជីវន្តោ យទិ តេ អត្ថិ ទាតវេ

អយំ អច្ចិមុខី នាម បុណ្ណា ឧគ្គស្ស តេជសា

តាយ តំ ឌំសយិស្សាមិ សា តំ ភស្មំ ករិស្សតិ

យា ធីតា ធតរដ្ឋស្ស វេមាតា ភគិនី មម

សា ឌំសតុ អច្ចិមុខី បុណ្ណា ឧគ្គស្ស តេជសា ។



(៣៨៦) (កាណារិដ្ឋព្រាហ្មណ៍ . . . ) ខ្ញុំបានស្ដាប់ពាក្យនេះ របស់ពួកព្រះអរហន្ត ដែលសង្រួមហើយ មានតបៈថា ទាយកទាំងឡាយ ក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុគួរឲ្យដែលគួរឲ្យ អ្នកកាលនៅរស់ ចូរឲ្យទានទាំងឡាយចុះ ។ នាគនេះ មានឫទ្ធិច្រើន មានតេជៈ ដែលគេកន្លងបានដោយក្រ ខ្ញុំនឹងប្រើនាគនេះឲ្យចឹកអ្នក នាគនោះនឹងធ្វើអ្នកឲ្យទៅជាផេះ ។

(៣៨៧) (សុទស្សនមាណព . . . ) ម្នាលសម្លាញ់ ខ្ញុំក៏បានស្ដាប់ពាក្យនេះ របស់ពួកព្រះអរហន្ត ដែលសង្រួមហើយមានតបៈថា ទាយកទាំងឡាយ ក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុគួរឲ្យដែលគួរឲ្យ អ្នកកាលនៅរស់ ចូរឲ្យទានទាំងឡាយចុះ ។ កូនកង្កែបនេះ ឈ្មោះអច្ចិមុខី ពេញដោយតេជៈរបស់ពស់ដ៏ខ្ពង់ខ្ពស់ ខ្ញុំនឹងប្រើនាងអច្ចិមុខីនោះ ឲ្យចឹកអ្នក នាងអច្ចិមុខីនោះ នឹងធ្វើអ្នកឲ្យទៅជាផេះ ។ នាងអច្ចិមុខីនោះ ជាធីតារបស់ព្រះបាទធតរដ្ឋ មានមាតាផ្សេងគ្នា ជាប្អូនស្រីរបស់ខ្ញុំ ដ៏ពេញដោយតេជៈរបស់ពស់ដ៏ខ្ពង់ខ្ពស់ ចូរចឹកចុះ ។

(៣៥៨) បឋព្យា ចេ និសិញ្ចិស្សំ ព្រហ្មទត្ត វិជានាហិ
តិណលតានិ ឱសធ្យោ ឧស្សុស្សេយ្យុំ អសំសយំ ។

(៣៥៩) ឧទ្ធញ្ចេ បាតយិស្សាមិ ព្រហ្មទត្ត វិជានាហិ
សត្ត វស្សានិ យំ ទេវោ ន វស្សេ ន ហិមំ បតេ ។

(៣៦០) ឧទកេ ចេ និសិញ្ចិស្សំ ព្រហ្មទត្ត វិជានាហិ
យាវន្តោទកជា បាណា មរេយ្យុំ មច្ឆកច្ឆបា ។

(៣៦១) លោក្យំ សជន្តំ ឧទកំ បយាគស្មិំ បតិដ្ឋិតំ
គោ មំ អជ្ឈោហរី ភូតោ ឱគាឡ្ហំ យមុនំ នទីំ ។

(៣៦២) យមេស លោកាធិបតី យសស្សី
ពារាណសឹ បក្រិយ សមន្តតោ
តស្សាហ បុត្តោ ឧរគូសភស្ស
សុភោគោតិ មំ ព្រាហ្មណ វេទយន្តិ ។



(៣៥៨) បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាព សាបពិសទៅលើផែនដី ស្មៅ វល្លិ៍ គុម្ពឈើ ឱសថ នឹងស្វិតស្រពោនគ្មានសល់ ។

(៣៥៩) បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាព សាបពិសទៅខាងលើ ភ្លៀងនឹងមិនបង្អុរចុះ ទឹកសន្សើម នឹងមិនធ្លាក់ចុះ អស់៧ឆ្នាំ ។

(៣៦០) បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាព សាបពិសទៅក្នុងទឹក ត្រីនិងអណ្តើក ដែលជាសត្វកើតក្នុងទឹកទាំងប៉ុន្មាន នឹងស្លាប់ទាំងអស់ ។

(៣៦១) (ព្រាហ្មណ៍នេសាទ ...) ទឹកដែលតាំងនៅក្នុងកំពង់បយាគៈ ដែលអ្នកស្រុកស្រោច ជាទឹកដែលលោកសន្មតថា សម្រាប់លាងបាប ចុះភូតអ្វី ជ្រមុជអញចុះទៅក្នុងស្ទឹងយមុនាធំជ្រៅ ។

(៣៦២) (សុភោគនាគពោល ...) នាគណា ជាធំក្នុងលោក
មានយសបុណ្យមកកាំចុះក្រុងពារាណសីជុំវិញ
អញជាកូននាគដ៏ប្រសើរនោះ ម្នាលព្រាហ្មណ៍
នាគទាំងឡាយហៅអញថា សុភោគៈដូច្នេះ ។

(៣៦៣) សចេសិ បុត្តោ ឧរគូសភស្ស
កាសិស្ស រញ្ញោ អមរាធិបស្ស
មហេសក្ខោ អញ្ញតរោ បិតា តេ
មច្ចេសុ មាតា បន តេ អតុល្យា
ន តាទិសោ អរហតិ ព្រាហ្មណស្ស
ទាសំបិ ឱហារិតុំ មហានុភាវោ ។

(៣៦៤) រុក្ខំ និស្សាយ វិជ្ឈិត្ថោ ឯណេយ្យំ បាតុមាគតំ
សោ វិទ្ធោ ទូរមាចរិ សរវេគេន សេឃវា ។
តំ ត្វំ បតិតមទ្ទក្ខិ អរញ្ញស្មិំ ព្រហាវនេ
ស មំសកាជមាទាយ សាយំ និគ្រោធុបាគមិ
សុវសាលិយសង្ឃុដ្ឋំ បិង្គិយំ សណ្ឋតាយុតំ
កោកិលាភិរុទំ រម្មំ ធុវំ ហរិតសទ្ទលំ
តត្ថ តេ សោ បាតុរាហុ ឥទ្ធិយា យសសា ជលំ
មហានុភាវោ ភាតា មេ កញ្ញាហិ បរិវារិតោ ។





(៣៦៣) (ព្រាហ្មណ៍នេសាទ ...) បើអ្នក ជាកូននៃនាគដ៏ប្រសើរ ជាព្រះរាជកូននៃដែនកាសី ជាធំជាងនាគដែលមានកាយវែង បិតារបស់អ្នក ជានាគមានស័ក្តិធំមួយដែរ បណ្តាសត្វទាំងឡាយ មាតារបស់អ្នក ក៏មិនមានស្មើណាផ្ទឹមបានឡើយ បុគ្គលមានអានុភាពច្រើន ដូចអ្នកមិនគួរចាប់ជ្រមុជបុគ្គល សូម្បីជាទាសៈ នៃព្រាហ្មណ៍ទេ ។

(៣៦៤) (សុភោគនាគរាជ ...) ឯងផ្អែកដើមឈើ ហើយបាញ់ទ្រាយដែលមកផឹក(ទឹក) ទ្រាយនោះ ដែលឯងបាញ់ហើយ ក៏ដើរមើលដោយកំលាំងនៃសរ ក៏ស្ទុះទៅកាន់ទីឆ្ងាយ ។ ឯងបានឃើញទ្រាយនោះ ដួលក្នុងព្រៃធំហើយ ក៏នាំសាច់មួយអម្រែកចូលទៅកាន់ដើមជ្រៃ ក្នុងវេលាល្ងាច ជាឈើដែលគឹកកងដោយសត្វសេកនិងសាលិកា មានស្លឹកលឿង ដេរដាសដោយវល្លិ ដែលសត្វតាវេកិលយំ ជាទីគួរត្រេកអរ មានផែនដីដុះស្មៅខៀវជានិច្ច បងរបស់អញ ដែលមានអានុភាពច្រើន រុងរឿងដោយឫទ្ធិនិងយស ដែលពួកនាគកញ្ញាចោមរោមហើយ ក៏ប្រាកដដល់ឯងក្នុងទីនោះ ។

សោ តេន បរិចិណ្ណោ ត្វំ សព្វកាមេហិ តប្បិតោ
អនុដ្ឋស្ស តុវំ ធុត្តិ តន្តេ វេរំ វិជានសិ ។
ចិរប្បំ តវំ បសាទេហិ ន តេ ទស្សាមិ ជីវិតំ
កាតុ បរិសំ វេរំ ឆេទយិស្សាមិ តេ សិរំ ។

(៣៦៥) អជ្ឈាយកោ យាចយោគី អាហុតគ្គី ច
ព្រាហ្មណោ
ឯតេហិ តីហិ ឋានេហិ អវជ្ឈោ ភវតិ ព្រាហ្មណោ

(៣៦៦) យំ បុរំ ធតរដ្ឋស្ស ឱគាឡ្ហំ យមុនំ នទី
ជោតតេ សព្វសោវណ្ណំ គិរិមាហច្ច យាមុនំ ។
តត្ថ តេ បុរិសព្យគ្ឃា សោទរិយា មម ភាតរោ
យថា តេ តត្ថ វត្តន្តិ តថា ហេស្សសិ ព្រាហ្មណ ។

(៣៦៧) អនិត្តរា ឥត្តរសម្បយុត្តា
យញ្ញា ច វេទា ច សុភោគ លោកេ
តទគ្គរយ្ហំ ហិ វិនិន្ទមានោ
ជហាតិ វិត្តញ្ច សតញ្ច ធម្មំ ។



ឯងនោះ ដែលបងរបស់អញនោះផ្គាប់ហើយ ឲ្យស្កប់ស្កល់ដោយកាមទាំងពួង ឯងបានប្រទូស្តចំពោះបង ដែលមិនប្រទូស្ត ទៀត នោះមកដល់ឯង គួរឯងដឹងខ្លួនហើយ ។ ឯងចូរផ្ទេកកយ៉ាងណាច់ អញនឹងមិនឲ្យជីវិតដល់ឯងទេ អញត្រូវការឃើញខ្លួនទៀត ( ដែលឯងធ្វើ ) ចំពោះបង អញនឹងកាត់ក្បាលឯងឥឡូវនេះ ។

(៣៦៥) (ព្រាហ្មណ៍ទេសាទ . . .) ព្រាហ្មណ៍ជាអ្នករៀនមន្ត ១ ជាអ្នកប្រកបដោយការសូម ១ ជាអ្នកបូជាភ្លើង ១ ព្រាហ្មណ៍ប្រកបដោយហេតុទាំងបីនេះ អ្នកមិនគួរសម្លាប់ទេ ។

(៣៦៦) (សុរោគតានកជ . . .) បុរីណា របស់ព្រះបាទធតរដ្ឋ ជាវិការៈនៃមាសទាំងអស់ ដែលចូលទៅកាន់ស្ទឹងយមុនា ទល់នឹងភ្នំហិមពាន្ត ដែលនៅជិតស្ទឹងយមុនា រមែងរុងរឿង ។ បងប្អូនរបស់អញទាំងនោះ ជាបុរសខ្លាំងពូកែ ជាអ្នករួមផ្ទៃ នៅក្នុងបុរីនោះ បងប្អូនទាំងនោះ ក្នុងបុរីនោះ នៅយ៉ាងណា ឯងនឹងនៅយ៉ាងនោះ ។

(៣៦៧) (កណ្ហវិជ្ជានកជ . . .) បពិត្រសុភោគ យញ្ញទាំងវេទទាំងឡាយ ក្នុងលោកនេះ ដែលព្រាហ្មណ៍ឯទៀតប្រកបហើយមិនមែនជារបស់ផ្ដេសផ្ដាសទេ ព្រោះហេតុនោះ បុគ្គលកាលតិះដៀលព្រាហ្មណ៍ដែលមិនគួរតិះដៀល ឈ្មោះថាលះបង់ទ្រព្យនឹងធម៌របស់ពួកសប្បុរស ។

(៣៦៨) អជ្ឈេនមរិយា បថវឹ ជនិន្ទា
វេស្សា កសឹ បារិចរិយញ្ច សុទ្ទា
ឧបាគុ បច្ចេកំ យថាបទេសំ
កតាហុ ឯតេ វសិនាតិ អាហុ ។

(៣៦៩) ធាតា វិធាតា វរុណោ កុវេរោ
សោមោ យមោ ចន្ទិមា វាយុ សុរិយោ
ឯតេបិ យញ្ញំ បុថុសោ យជិត្វា
អជ្ឈាយកានំ អថ សព្វកាមេ ។
វិកាសិតា ចាបសតានិ បញ្ច
យោ អជ្ជុនោ ពលវា ភីមសេនោ
សហស្សពាហុ អសមោ បថព្យា
សោបិ តទា អាទហិ ជាតវេទំ ។

(៣៧០) យោ ព្រាហ្មណេ ភោជយិ ទីឃរត្តំ
អន្នេន បានេន យថានុភាវំ
បសន្នចិត្តោ អនុមោទមានោ
សុភោគ ទេវញ្ញតរោ អហោសិ ។



(៣៦៨) ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់នូវការរៀនមន្ត ពួកជាធំជាងជន (ក្សត្រិយ៍) ប្រកាន់នូវការផែនដី ពួកវេស្សៈ ប្រកាន់នូវការភ្ជួររាស់ ពួកសូទ្រៈ ប្រកាន់នូវការបម្រើ ស្មើៗគ្នា តាមសមគួរដល់ប្រទេសជនចាត់ចែងឲ្យបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានចាត់ចែងហើយ ។

(៣៦៩) ទេវតាជាព្រះធាតា វិធាតា វរុណៈ កុវេរៈ សោមៈ យមៈ ចន្ទិមៈ វាយុ សុរិយៈ ស្តេចទាំងនេះ បានបូជាយញ្ញដ៏ច្រើន ទាំង (បានឲ្យ) វត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ពួកព្រាហ្មណ៍អ្នករៀនមន្ត ។ ព្រះបាទអជ្ជុនណាមានកម្លាំង មានសេនាគួរខ្លាច មានដៃមួយពាន់ (១) មិនមានបុគ្គលណាស្មើ លើផែនដី ជាអ្នកយកធ្នូ ៥០០ បាន ព្រះបាទអជ្ជុនៈនោះឯង ក៏បូជាភ្លើងក្នុងកាលនោះដែរ ។

(៣៧០) បុគ្គលណា មានចិត្តជ្រះថ្លា រីករាយ បានញ៉ាំងព្រាហ្មណ៍ ឲ្យបរិភោគបាយនិងទឹក អស់កាលយូរ ដ៏សមគួរ តាមអានុភាព បពិត្រសុភោគ បុគ្គលនោះ នឹងបានជាទេវតាមួយអង្គ ។

---

១ មិនមែនមានដៃមួយពាន់ទេ គឺអាចយកធ្នូដែលគ្រាន់ខ្លាំងប្រាំរយនាក់យកបាន ។ អដ្ឋកថា ។

(៣៧១) មហាសនំ ទេវមនោមវណ្ណំ
យោ សប្បិនា អសក្ខិ ភោជេតុមគ្គឹ
ស យញ្ញតន្តំ វរតោ យជិត្វា
ទិព្វំ គតិំ មុចលិន្ទជ្ឈគច្ឆិ(១) ។

(៣៧២) មហានុភាវោ វស្សសហស្សជីវី
យោ បព្វជិ ទស្សនេយ្យោ ឧឡារោ
ហិត្វា អបរិយន្តំ រដ្ឋំ សសេនំ
រាជា ទុទីបោបជ្ឈគាមិ សគ្គំ ។

(៣៧៣) យោ សាគរោ សាគរន្តំ វិជិត្វា
យូបំ សុភំ សោវណ្ណមយំ ឧឡារំ
ឧស្សេសិ វេស្សានរមាទហានោ
សុភោគ ទេវញ្ញតរោ អហោសិ ។
យស្សានុភាវេន សុភោគ គង្គា
បវត្តតិ ទធិសន្និសិន្នំ(២) សមុទ្ទំ
ស លោមបាទោ បរិចរិយមគ្គឹ
អង្គោ សហស្សក្ខបុរជ្ឈគច្ឆិ ។

---

១ គន្ថន្តរេសុ បន សោ យញ្ញតន្តំ វរតោ យជិត្វា ទិព្វំ គតឹ មុចលិន្ទជ្ឈគច្ឆីតិ បាឋោ ទិស្សតិ ។ ២ ម. ទធិសន្និំ ។ ៣ ម. ទធិសន្និភា ។





(៣៧១) ព្រះបាទមុចលិន្ទ កាលញុំាងទេវតាភ្លើង ជាអ្នកស៊ីច្រើន មានពន្លឺមិនថោកទាប ឲ្យស្កប់ស្កល់ ដោយសប្បិ បានបូជាវិធីយញ្ញដ៏ពោរពេញទេវតាភ្លើងដ៏ប្រសើរ ទ្រង់បានទៅកាន់គតិជាទិព្វ ។

(៣៧២) ព្រះរាជា ព្រះនាមទុទីបៈ មានអានុភាពច្រើន មានព្រះជន្ម ១.០០០ឆ្នាំ បានលះបង់នូវដែនព្រមទាំងសេនា មិនមានទីបំផុត ហើយបួស បានជាទក្ខិណេយ្យបុគ្គល គួរមើលមើលដ៏លើសលុប ទ្រង់បានទៅកាន់ឋានសួគ៌ ។

(៣៧៣) បពិត្រសុភោគ ព្រះបាទសាគរឈ្នះផែនដី មានសាគរជាទីបំផុត បានលើកសសរយញ្ញដ៏ល្អ ជាវិការៈនៃមាសដ៏លើសលុប បូជាភ្លើង ទ្រង់បានជាទេវតាមួយអង្គ ។ បពិត្រសុភោគ ទន្លេគង្គា ប្រព្រឹត្តទៅដោយអានុភាពនៃព្រះរាជាណា ទឹកជាដេរ ដែលស្ងប់ស្ងៀម ទៅជាសមុទ្រដោយអានុភាពនៃព្រះរាជាណា ព្រះរាជានោះ គឺព្រះបាទអង្គៈ មានលោមគ្រប់ព្រះបាទ បម្រើភ្លើង ក៏ទ្រង់បានទៅកាន់បុរីនៃព្រះឥន្ទ្រ ។

(៣៧៦) មហិទ្ធិកោ ទេវវរោ យសស្សី
សេនាបតិ តិទិវេ វាសវស្ស
សោ សោមយាគេន មលំ វិហន្ត្វា
សុភោគ ទេវញ្ញតរោ អហោសិ ។

(៣៧៧) អការយិ លោកមិមំ បរញ្ច
ភាគីរថី ហិមវន្តញ្ច វិជ្ឈំ
យោ ឥទ្ធិមា ទេវវរោ យសស្សី
សោបិ តទា អាទហិ ជាតវេទំ ។
មាលាគិរី ហិមវា យោ ច វិជ្ឈោ
សុទស្សនោ និសភោ កាកនេរុ
ឯតេ ច អញ្ញេ ច នគា មហន្តា
ចិត្យា កតា យញ្ញករេហិ មាហុ ។

(៣៧៨) អជ្ឈាយកំ មន្តគុណូបបន្នំ
តបស្សិនំ យាចយោគោតិធាហុ
តីរេ សមុទ្ទស្សុទកំ សជន្តំ
តំ សាគរោជ្ឈោហរិ តេនបេយ្យោ ។



(៣៧៦) បពិត្រសុភោគ ទេវតាដ៏ប្រសើរ មានឫទ្ធិច្រើន មានយស ជាសេនាបតីនៃព្រះបាទវាសវៈ ក្នុងឋានត្រៃត្រឹង្ស ព្រោះលោកបានកំចាត់បង់នូវមន្ទិលដោយសោមយាគវិធី ក៏បានជាទេវតាមួយអង្គ ។

(៣៧៧) ទេវតាដ៏ប្រសើរ ព្រហ្មមានឫទ្ធិច្រើន មានយស បានសាងលោកនេះនឹងលោកដទៃ នឹងស្ទឹងភាគីរថីនទី ភ្នំហិមពាន្តនឹងភ្នំវិជ្ឈៈផង ព្រហ្មនោះឯង ក៏បានបូជាភ្លើងក្នុងកាលនោះដែរ ។ ម្យ៉ាងទៀត ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកនេរុ ១ ពួកព្រាហ្មណ៍ពោលថា ភ្នំទាំងនេះក្តី ភ្នំដទៃធំៗក្តី ពួកព្រាហ្មណ៍អ្នកបូជាយញ្ញ បានធ្វើឲ្យវិចិត្រហើយ ។

(៣៧៨) ជនទាំងឡាយ បានពោលចំពោះព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈ ក្នុងលោកនេះ ថាជាអ្នកប្រកបដោយការសូម សាគរបានពន្លិចព្រាហ្មណ៍នោះ ដែលឋិតនៅលើត្រើយ កំពុងសាចទឹកសមុទ្រ ហេតុនោះ បានជាសមុទ្រមានទឹកប្រៃ ផឹកមិនបាន ។

(៣៧៧) អាយសៈកវត្ថុចិ ចុត្វ ជបញ្ញា
សំវិជ្ជន្តិ ព្រាហ្មណា ភិសស្ស
ឃរំមិ ធនំ បហូតំ ឧក្ខិណាត្វំ
សំវិជ្ជមានា ជនយន្តិ វេរំ ។

(៣៧៨) តាលី ហំ ទីរាន តាតំ ឧតាថំ
តវន្តិ វេនជ្ឈេតា អរិដ្ឋ
មរិចិធម្មំ អសមេក្ខិតត្តា
មាយាគុណា នាតិវហន្តិ បញ្ញំ ។
វេតា ន តាណាយ ភវន្តិ ស្ស
មិត្តទ្ទុនោ ភូនហុនោ នរស្ស
ន តាយតេ បរិចិណ្ណោ អគ្គិ
ទោសន្តរំ មច្ចមនរិយកម្មំ ។
សព្វញ្ច មច្ចា សធនា សភោគា
អាទីបិតំ ទារុតិណេន មិស្សំ
ធហំ ន តប្បេ អសមត្ថតេជោ
កោ តំ សុភិក្ខំ ទិរសញ្ញ កយិរា ។



(៣៧៧) ព្រាហ្មណ៍ទាំងឡាយ ជាវត្ថុសម្រាប់បូជា មានច្រើនលើផែនដី មានក្នុងទិសខាងកើត ទិសខាងលិច ទិសខាងត្បូង និងទិសខាងជើង តែងញ៉ាំងសេចក្តីក្រោធ ឲ្យកើតដល់ពស់ៈ ។

(៣៧៨) (ត្រូវចូលទៅកាន់...) ម្នាលអរិដ្ឋ ការរៀនយកនូវវេទទាំងឡាយ ជាទោសរបស់អ្នកប្រាជ្ញទាំងឡាយ តែជាអំពើរបស់បុគ្គលពាលទាំងឡាយ (វេទត្រៃ) ជាធម៌ ដូចជាបណ្តើរកូន ព្រោះសំឡឹងមើលទៅ មិនស្មើវេទទាំងឡាយ ជាទីណាគនៃគលទុក្ខ ទង់តាញអ្នកមានបញ្ញាមិនបានទេ ការពារជនអ្នកប្រទូស្តមិត្រ បំផ្លាញសេចក្តីចំរើននោះ ក៏មិនបានទេ ភ្លើងដែលបុគ្គលបម្រើហើយ ដែលមិនការពារខ្លួនត្ថមានកម្មបានទេ ជារបស់មិនប្រសើរ ប្រកបដោយទោស ។ មួយទៀត សត្វទាំងឡាយមានទ្រព្យ មានភោគៈ យកទ្រព្យទាំងអស់លាយដោយឧសនឹងស្មៅហើយដុតភ្លើងមានតេជះ មិនមានគ្រឿងស្មើ កាលនោះវត្ថុដែលគេដុតហើយ ក៏មិនគប្បីឆ្អែត ម្នាលអ្នកដ៏និរោធដោយអណ្តាតទាំងពីរ ចុះបុគ្គលណា គប្បីធ្វើភ្លើងនោះឲ្យឆ្អែតបាន ។

យថាបិ ខីរំ វិបរិណាមធម្មំ
ទធិ ភវិត្វា នវនីតំបិ ហោតិ
ឯវំបិ អគ្គិ វិបរិណាមធម្មោ
តេជោ សមារភតិ យោគយុត្តោ ។
ន ទិស្សតិ អគ្គិមនុប្បវិដ្ឋោ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ
នាមត្ថមានោ អរណីនរេន
នាកម្មុនា ជាយតិ ជាតវេទោ ។
សចេ ហិ អគ្គិ អន្តរតោ វសេយ្យ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ
សព្វានិ សុស្សេយ្យុំ វនានិ លោកេ
សុក្ខានិ កដ្ឋានិ ច បជ្ជលេយ្យុំ ។
ករោតិ ចេ ទារុតិណេន បុញ្ញំ
ភោជំ នរោ ធូមសិខិំ បតាបវំ
អង្គារិកា លោណករា ច សូទា
សរីរទាហាបិ ករេយ្យុំ បុញ្ញំ ។





ទឹកដោះកាលប្រែប្រួលជាធម្មតា ក្លាយទៅជាទធិ ហើយទៅជានវនីត យ៉ាងណា ភ្លើងជាតេជោធាតុ មានការប្រែប្រួលជាធម្មតា យ៉ាងនោះដែរ លុះតែប្រកបដោយគ្រឿងពួត ទើបឆេះ ។ ភ្លើងដែលចូលទៅក្នុងឈើស្ងួត ឬឈើស្រស់ ក៏មិនប្រាកដ ភ្លើងដែលមនុស្សមានឈើកំពួតក្ដិតដែរ មិនបានពួត ក៏មិនឆេះ ភ្លើងមិនមែនឆេះដោយការមិនធ្វើទេ ។ ប្រសិនបើ ភ្លើងនៅក្នុងឈើស្ងួត ឬឈើស្រស់ នៅខាងក្នុង នៅក្នុងព្រៃទាំងអស់ ក្នុងលោក គប្បីស្ងួតក្រៀម ឯឈើស្ងួតទាំងឡាយ គប្បីឆេះ ។ ជាបើ នរជនញុំាងភ្លើងដ៏ក្ដៅ ប្រកបដោយផ្សែងនិងអណ្ដាត ឲ្យស៊ីដោយឧសនិងស្មៅ ឈ្មោះថា ធ្វើបុណ្យឬ ជនអ្នកធ្វើធ្យូង អ្នកធ្វើអំបិល អ្នកធ្វើអាហារ និងអ្នកដុតសរីរៈនៃបុគ្គលស្លាប់ ឈ្មោះថា ធ្វើបុណ្យដែរ ។

អថ ចេ ហិ ឯតេបិ ករោន្តិ បុញ្ញំ
អជ្ឈេនមគ្គឹ ឥធ តប្បយិត្វា
ន កោចិ លោកស្មិ ករោតិ បុញ្ញំ
ភោជំ នរោ ធូមសិខឹ បតាបវំ ។
កថំ ហិ លោកាបចិតោ សមានោ
អមនុញ្ញគន្ធំ ពហូនំ អកន្តំ
យទេវ មច្ចា បរិវជ្ជយន្តិ
តទប្បសដ្ឋំ ទិរសញ្ញ កុណបំ
សិខិញ្ហិ ទេវេសុ វទន្តិ ឯកេ
អាបំ មិលក្ខូ បន ទេវមាហុ
សព្វេវ ឯតេ វិតថំ ភណន្តិ
អគ្គិ ន ទេវញ្ញតរោ ន អាបោ ។
អនិន្ទ្រិយំ(១) សន្តមសញ្ញកាយំ(២)
វេស្សានរំ កម្មករំ បជានំ
បរិចរិយមគ្គឹ សុគតឹ កថំ វជេ
បាបានិ កម្មានិ បកុព្វមានោ ។

---

១ ឱ. និរិន្ទ្រិយំ ។ ២ ឱ. ពន្ធមសញ្ញកាយំ ។



ប្រសិនបើព្រាហ្មណ៍ទាំងនុ៎ះ ញុំាងការរៀនមន្តនិងភ្លើងឲ្យឆ្អែតក្នុងលោកនេះ ទើបឈ្មោះថាធ្វើបុណ្យ នរជនណាមួយក្នុងលោក កាលញុំាងភ្លើងមានកំពូលប្រកបដោយផ្សែងនឹងអណ្ដាត ឲ្យស៊ី មិនឈ្មោះថាធ្វើបុណ្យទេ ។ ម្នាលអ្នកដ៏ដឹងរសដោយអណ្ដាតពីរ (អណ្ដាតទ្វេរបស់អ្នក) ដែលលោកគោរពហើយ ម្ដេចក៏ស៊ីវត្ថុមានក្លិនមិនជាទីគាប់ចិត្ត មិនជាទីត្រេកអរនៃជនដ៏ច្រើន ដែលពួកមនុស្សតែងវៀរ ជាវត្ថុមិនប្រសើរនោះ ។ មនុស្សពួកខ្លះ ពោលថាភ្លើង(ជាទេវតាមួយអង្គ)ក្នុងពួកទេវតា ចំណែកមិលក្ខជន ពោលថាទឹកជាទេវតា ជនទាំងអស់នុ៎ះពោលខុស ភ្លើងមិនមែនជាទេវតាណាមួយទេ ទឹកក៏មិនមែនដែរ ។ ភ្លើងមិនមានឥន្ទ្រិយ ជាវត្ថុមិនមានចេតនា សម្រាប់ធ្វើការងាររបស់ពួកមនុស្ស អ្នកធ្វើបាប-កម្មទាំងឡាយកាលបម្រើភ្លើង គប្បីទៅកាន់សុគតិដូចម្ដេចកើត ។

សច្ចាភិក្កតាហុធ ជីវិកត្ថា
អត្តស្ស ព្រហ្មា បរិចារកោតិ
សញ្ញានុការី ច ឥសី កតមន្តី
អធិម្មិកោ ធម្មិតិ វត្តិតស្ស ។
ហាសំ អធិជ្ឈានត្តមំ អតត្ថិ
សត្តារភោគ បរិការីសុ ឋុតេ
តេ លោកសត្ថារេ អភាតុក្កាតេ(*)
សច្ចាភិតា ជន្តុតិ សត្តិធម្មំ ។
អជ្ឈេនមរិយា បថវី ជនិន្ទា
វេស្សា កសឹ បារិចរិយញ្ច សុទ្ទា
ឧបាគុ បច្ចេកំ យថាបទេសំ
កតាហុ ឯតេ វសិនាតិ អាហុ ។
ឯតញ្ច សច្ចំ វចនំ ភវេយ្យ
យថា ឥទំ ភាសតិ ព្រាហ្មណានំ
នាខត្តិយោ ជាតុ លភេថ រជ្ជំ
នាព្រាហ្មណោ មន្តបទានិ សិក្ខេ
នាញ្ញត្រ វេស្សេហិ កសឹ ករេយ្យ
សុទ្ទោ ន មុច្ចេ បរបេសនាយ ។

* ម. ឆ. អនត្តភាវេ ។



ពួកព្រាហ្មណ៍ជាអ្នកត្រូវការដោយជីវិត ក្នុងលោកនេះ ពោលថា (មហាព្រហ្ម) ជាអ្នកគ្រប់សត្វលោកទាំងអស់ ហើយពោលថា ព្រហ្មជាអ្នកបម្រើភ្លើងផ្ទះ បើ (មហាព្រហ្ម) មានអានុភាពជាធំលោកទាំងអស់ មានអំណាចមិនមានអ្នកណាសាង ហេតុអ្វីក៏សិការភ្លើងដែលខ្លួនមិនកៀញ ។ ពាក្យព្រាហ្មណ៍ ជាពាក្យគួរសើច មិនគួរជឿលើការពិតទេ ជាពាក្យមិនពិត ពួកព្រាហ្មណ៍គង់តែលមុខ ពាក់កែង (ពាក្យមិនពិត) ព្រោះហេតុនៃសក្ការៈព្រាហ្មណ៍ទាំងនោះ គេលើលោកសក្ការៈ មិនកើតឡើងទេ ក៏តន្ត្រសត្ថមិនពោលតាមលទ្ធិរបស់ខ្លួន ជាមួយនឹងពួកសត្វ ។ ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់ការរៀនមន្ត ពួកជាធំជាងជន (ក្សត្រិយ៍) ប្រកាន់ផែនដី ពួកវេស្សៈប្រកាន់ការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ការបម្រើ ផ្សេងៗគ្នា សមគួរតាមប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំងនេះ ព្រហ្មបានតាក់តែងហើយ ។ ប្រសិនបើពាក្យនុ៎ះ ជាពាក្យពិត ដូចយ៉ាងពាក្យដែលព្រាហ្មណ៍ទាំងឡាយពោលហើយនេះ បុគ្គលមិនមែនជាក្សត្រិយ៍មិនត្រូវបានរាជ្យដោយដាច់ខាត បុគ្គលមិនមែនជាព្រាហ្មណ៍មិនគប្បីសិក្សានូវបទនៃមន្ត បុគ្គលវៀរលែងពួកវេស្សៈ មិនគប្បីធ្វើការភ្ជួររាស់ ពួកសូទ្រៈមិនគប្បីរួចអំពីការប្រើនៃជនដទៃ ។

យស្មា ច ឯកំ វចនំ អភូតំ
មុសាភិមេ វិនរិយា ករោន្តិ
តថប្បញ្ញា អភិសទ្ទហន្តិ
បស្សន្តិ តំ បណ្ឌិតា អត្តនា ។
ចក្ខុ ហិ វេស្សាន ពលី ហរន្តិ
អាទាយ សត្ថានិ ចរន្តិ ព្រាហ្មណា
តំ តាទិសំ សង្ខុភិតំ បភិន្នំ
កស្មា ព្រហ្មា ន ឧជុំ ករោតិ លោកំ ។
សចេ ហិ សោ ឥស្សរោ សព្វលោកេ
ព្រហ្មាបហូ ភូតបតី បជានំ
កិំ សព្វលោកំ វិទហិ អលក្ខឹ
កិំ សព្វលោកំ ន សុខី អកាសិ ។
សចេ ហិ សោ ឥស្សរោ សព្វលោកេ
ព្រហ្មាបហូ ភូតបតី បជានំ
មាយា មុសាវជ្ជមទេន ចាបិ(១)
លោកំ អធម្មេន កិមត្ថការី ។

---

១ ឱ. មុសាវជ្ជបទេន ។



ពាក្យនេះ ជាពាក្យមិនពិត ព្រោះហេតុណា (ហេតុនោះ) ព្រាហ្មណ៍ទាំងនេះ ពោលពាក្យកុហកដើម្បីការបរិភោគញ្ញៃ បុគ្គលអ្នកមិនមានប្រាជ្ញាទាំងឡាយ រមែងជឿស៊ប់នូវពាក្យនោះ ចំណែកខាងពួកបណ្ឌិតរមែងឃើញហេតុនោះ ដោយខ្លួនឯង ។ ពួកក្សត្រិយ៍នាំយកពលី (ហ្វូភគទ្ធ) របស់ពួកវេស្សៈ ពួកព្រាហ្មណ៍ កាន់យកគ្រឿងសស្ត្រាទាំងឡាយ ហើយដើរទៅ (សម្លាប់សត្វ) ហេតុអ្វី ព្រហ្មមិនធ្វើលោកដែលជ្រួលច្រើមបែកខ្ញែកបែបនោះៗនោះឲ្យត្រង់ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះជាប្រធាន ជាម្ចាស់លើពួក របស់ពួក.បុគ្គលក្នុងលោកទាំងអស់ ហេតុអ្វី ក៏ចាត់ចែងលោកទាំងអស់ឲ្យមានទុក្ខ ហេតុអ្វី មិនធ្វើលោកទាំងអស់ឲ្យបានសេចក្ដីសុខ ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើពួករបស់ពួកសត្វ ក្នុងលោកទាំងអស់ ហេតុអ្វី ក៏ធ្វើលោកឲ្យវិនាស ដោយកល ។ ពុយម៉ឹងការញ៉ាំញី ដោយការពោលពាក្យកុហក ដែលមិនមែនជាធម៌ ។

សចេ ហិ សោ ឥស្សរោ សព្វលោកេ
ព្រហ្មា ពហូ ភូតបតី បជានំ
អធម្មិកោ ភូតបតី អរិដ្ឋ
ធម្មេ សតី សោ វិទហី អធម្មំ ៕
កីដា បដង្គា ឧរគា ច ភិង្គា
ហន្ត្វា កិមី សុជ្ឈតិ មក្ខិកា ច
ឯតេ ហិ ធម្មា អនរិយរូបា
កម្ពោជកានំ វិតថា ពហូនំ ៕

(៣៧៨) សចេ ហិ សោ សុជ្ឈតិ យោ ហនាតិ
ហតោបិ សោ សគ្គមុបេតិ ឋានំ
ភោវាទិ ភោវាទិនមារយេយ្យុំ
យេ ចាបិ តេសំ អភិសទ្ទហេយ្យុំ ៕
នេវ មិគា ន បសូ នោបិ គាវោ
អាយាចន្តិ អត្តវធាយ កេចិ
វិប្ផន្ទមានេ ឥធ ជីវិកាយ
យញ្ញេសុ បាណេ បសុមារភន្តិ ៕



ប្រសិនបើព្រហ្ម ជាឥស្សរៈនោះជាប្រធាន ជាម្ចាស់លើពួករបស់ពួកសត្វក្នុងលោកទាំងអស់ ម្នាលអរិដ្ឋ ព្រហ្មជាម្ចាស់លើពួកមិនប្រកបដោយធម៌ទេ ព្រោះកាលបើធម៌មាន រៀបចាត់ចែងអធម៌វិញ ។ បុគ្គលសម្លាប់កណ្ដូប កន្ទុំរុយ ពស់ កង្កែប ដង្កូវ រុយ ទើបឈ្មោះថា បរិសុទ្ធ ឯធម៌ទាំងនេះ ជាធម៌របស់ពួកជនពួកនៅក្នុងដែនកម្ពុជៈដ៏ច្រើន ជាធម៌មានសភាពមិនប្រសើរ ជាធម៌មិនពិត ។

(៣៧៨) ប្រសិនបើអ្នកសម្លាប់នោះ បរិសុទ្ធ ឬអ្នកដែលត្រូវសម្លាប់នោះ ទៅកាន់ឋានសួគ៌បាន ពួកព្រាហ្មណ៍ គប្បីសម្លាប់ពួកព្រាហ្មណ៍ ឬសម្លាប់ពួកជនអ្នកជឿពាក្យព្រាហ្មណ៍នោះ (មុន) ។ មិនមានពួកម្រឹគ មិនមានពួកសត្វចិញ្ចឹម ពួកគោណាមួយអង្វរឲ្យសម្លាប់ខ្លួនទេ សត្វទាំងឡាយ ក្នុងលោកនេះ សុទ្ធតែញាប់ញ័រត្រេកអរដោយជីវិត (ព្រោះថា) ជនទាំងឡាយ ព្រាហ្ម តែងសម្លាប់សត្វទាំងឡាយ គឺសត្វចិញ្ចឹម ក្នុងយញ្ញទាំងឡាយ ។

យុម្មស្សេ វសុពន្ទេ ច ពាលា
ចិត្រេហិ វណ្ណេហិ មុខំ នយន្តិ
អយន្តេ យូបោ កាមទុហោ បរត្ថ
ភវិស្សតិ សស្សតោ សម្បរាយេ ។
សចេ ច យូបេ មណិសង្ខមុត្តំ
វត្ថំ ធនំ រជតំ ជាតរូបំ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ
សចេ ទុហេ តិទិវេ សព្វកាមេ
តេវិជ្ជសង្ឃារ បុថុ យជេយ្យុំ
ន ព្រាហ្មណំ កិញ្ចិ ន យាជយេយ្យុំ ។
កុតោ ច យូបេ មណិសង្ខមុត្តំ
វត្ថំ ធនំ រជតំ ជាតរូបំ
សុក្ខេសុ កដ្ឋេសុ នវេសុ ចាបិ
កុតោ ទុហេ តិទិវេ សព្វកាមេ ។
សឋោ ច លុទ្ទោ ច បលុទ្ធពាលា
ចិត្រេហិ វណ្ណេហិ មុខំ នយន្តិ
អាទាយ អគ្គី មម ទេហិ វិត្តំ
តតោ សុខី ហោហិសិ សព្វកាមេ ។



ពួកបុគ្គលពាល រមែងបើកមាត់និយាយ ដោយហេតុទាំងឡាយ ដ៏វិចិត្រ ក្នុងការលើកតម្កើងនូវសសរយញ្ញៈ គឺជាទីចងនៃសត្វបូជា ជា សសរយញ្ញនេះបង្ហូរសេចក្តីប្រាថ្នាដល់អ្នក ក្នុងបរលោក ទីទីឲ្យសេចក្តីទៀងទាត់ក្នុងបរលោក ។ ប្រសិនបើ បុគ្គលនឹងបាននូវកែវមណី ស័ង្ខ កែវមុក្តា ស្បៃ ទ្រព្យ ប្រាក់ និងមាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ ម្យ៉ាងទៀត ប្រសិនបើសសរយញ្ញ នឹងបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ ពួកជនអ្នកចេះត្រៃវេទជាច្រើននឹងបូជា បុគ្គលមិនមែនជាព្រាហ្មណ៍មិននឹងឲ្យបូជាតិចតួចទេ ។ កែវមណី ស័ង្ខ កែវមុក្តា ស្បៃ ទ្រព្យ ប្រាក់ មាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ នឹងមានពីណា សសរយញ្ញនឹងបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ដូចម្តេចកើត ។ ពួកព្រាហ្មណ៍ជាអ្នកបោកប្រាស ចិត្តអាក្រក់ ជាពួកពាល ប្រលោមលោក តែងបើកមាត់និយាយដោយហេតុ ដ៏វិចិត្រថា អ្នកឯងចូរយកភ្លើងចុះ ហើយឲ្យទ្រព្យដល់យើង សំដៅចំពោះ អ្នកឯងនឹងបាននូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយនឹងដល់នូវសេចក្តីសុខ ។

តមគ្គិហុត្តំ សរណំ បវិស្ស
ចិត្រេហិ វណ្ណេហិ មុខំ ធមន្តិ
ឱរោបយិត្វា កេសមស្សុំ នខញ្ច
វេទេហិ វិត្តំ អធិគច្ឆយន្តិ ។
កាកា ឧលូកំវ រហោ លភិត្វា
ឯកំ សមានំ ពហុកា សមេច្ច
អន្នានិ ភុត្វា កុហកា កុហិត្វា
មុណ្ឌំ ករិត្វា យញ្ញបថោស្សជន្តិ ។
ឯវំ ហិ សោ វញ្ចិតោ ព្រាហ្មណេហិ
ឯកោ សមានោ ពហុកា សមេច្ច
តេ យោគយោគេន វិលុម្បមានា
ទិដ្ឋំ អទិដ្ឋេន ធនំ ហរន្តិ ។
អកាសិយា រាជូហិវានុសិដ្ឋា
តទស្ស អាទាយ ធនំ ហរន្តិ
តេ តាទិសា ចោរសមា អសន្តា
វជ្ឈា ន ហញ្ញន្តិ អរិដ្ឋ លោកេ ។





ពួកព្រាហ្មណ៍ កាន់ចុន្ទុលជាសរណៈ (ព្រោះជាទីពឹងមហាមាត្រ) ចូលទៅកាន់វេទីសម្រាប់បូជាភ្លើងនោះ ក៏បើកមាត់ និយាយដោយពាក្យវិចិត្រ ឲ្យគេកោរសក់ ពុកមាត់ កាត់ក្រចក ហើយនាំយកទ្រព្យដោយវេទទាំងឡាយ ។ ពួកព្រាហ្មណ៍ជាអ្នកកុហកដ៏ច្រើន បានតាយកម្នាក់ ហើយក៏ហោមស៊ីបាយ ដូចជាក្អែកទាំងឡាយ ហោមចាប់មៀម ក្នុងទីស្ងាត់ កុហកធ្វើឲ្យរលីងហើយដាក់ចុះទៅក្នុងផ្លូវនៃយញ្ញ ។ ទាយកតែម្នាក់នោះ ត្រូវពួកព្រាហ្មណ៍បញ្ឆោតហើយដោយអាការយ៉ាងនេះឯង ព្រាហ្មណ៍ទាំងនោះដ៏ច្រើន ហោមជួនដោយការប្រកបដោយឧបាយ ក៏នាំយកទ្រព្យដែលឃើញ ដោយអាងទៅលោកដែលមិនឃើញនោះ ។ ដូចជាពួកចោរ ដែលព្រះរាជាប្រើទៅហើយ ក៏នាំយកទ្រព្យរបស់គេ ម្នាលអរិដ្ឋ ពួកព្រាហ្មណ៍ប្រាកដដូច្នោះ ប្រៀបស្មើគ្នានឹងពួកចោរ ជាអសប្បុរស ជាបុគ្គលគួរសម្លាប់ តែគេមិនសម្លាប់ក្នុងលោក ។

ឥន្ទស្ស ពាហារសិ ទក្ខិណាតិ
យញ្ញេសុ ជិន្នត្ថិ បលាសយដ្ឋី
តញ្ចេបិ សព្វំ បរមំ ទិន្នពាហុ
តេនស្ស ឥន្ទោ អសុរេ ជិនាតិ ។
តញ្ចេវ ធជំ បរមំ សមត្ថិ
ហត្វា អវេជ្ជោ បរមោ សុធេកំ
មន្តា ឥមេ ព្រាហ្មណា ទុជ្ជរា
សន្ទិដ្ឋិកា វញ្ចនា ឯស លោកេ ។
មាលាគិរី ហិមវា យោ ច វិជ្ឈា(១)
សុទស្សនោ និសភោ កាកេរុ
ឯតេ ច អញ្ញេ ច នគា មហន្តា
ចិត្យា កតា យញ្ញការេហិ មាហុ ។
យថាបការានិ ហិ ឥដ្ឋកានិ
ចិត្យា កតា យញ្ញការេហិ មាហុ
ន បព្វតា ហោន្តិ តថាបការា
អញ្ញា ទិសា អចលា តិដ្ឋសេលា ។

១ ម. ច. គិជ្ឈ. ។





ពួកព្រាហ្មណ៍បានកាត់ដើមចារ មករៀបក្នុងពិធីយញ្ញ (ប្រាប់ថា នេះ) ជាដៃស្តាំរបស់ព្រះឥន្ទ្រ បើពាក្យនោះពិត ព្រះឥន្ទ្រទៅជាដាច់ដៃ ចុះព្រះឥន្ទ្រឈ្នះពួកអសុរ ដោយកម្លាំងដៃដូចម្តេច ។ ពាក្យនោះទទេទេសោះ ព្រះឥន្ទ្រនៅមានដើមដៃគ្រប់គ្រាន់ ជាទេវតាដ៏ប្រសើរ មិនមានអ្នកណាសម្លាប់បាន បានកំចាត់ពួកអសុរ មន្តទាំងឡាយនេះ របស់ពួកព្រាហ្មណ៍ មានសភាពជារបស់ទទេ នេះជាការបញ្ឆោត ដែលគេឃើញច្បាស់ ក្នុងលោក ។

ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកេរុ ១ ភ្នំទាំងនុ៎ះក្តី ភ្នំធំ ៗ ឯទៀតក្តី ព្រាហ្មណ៍ទាំងឡាយ ពោលថា ពួកព្រាហ្មណ៍អ្នកបូជាយញ្ញ កសាងហើយជាចិត្រដូច្នោះ ។ ព្រាហ្មណ៍ទាំងឡាយ ពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ កាន់យកឥដ្ឋទាំងឡាយ មានប្រការយ៉ាងណា ធ្វើចិត្រហើយ ភ្នំទាំងឡាយ មិនមែនមានប្រការដូច្នោះទេ ឯភ្នំទាំងឡាយ មិនដូចរបស់ដទៃទេ ជារបស់មិនកម្រើក ជាថ្មសុទ្ធដែលគេឃើញច្បាស់ ។

ន ឥជ្ជតា ហោន្តិ សិលា ចិរេន
ន គន្ធ សញ្ញាយតិំ អយោ ន លោហំ
យញ្ញញ្ច ឯតំ បរិវណ្ណយន្តា
ចិត្យា កតា យញ្ញការេតិមាហុ ។
អជ្ឈាយកំ មន្តគុណូបបន្នំ
តបស្សិនំ យាចយោគីតិជាហុ
តីរេ សមុទ្ទស្សុទកំ សជន្តំ
តំ សាគរជ្ឈោហរិ តេនបេយ្យោ ។
បរោសហស្សំបិ សមន្តវេទេ
មន្តូបបន្នេ នទិយោ វហន្តិ
ន តេន ព្យាបន្នរសូទកានិ
កស្មា សមុទ្ទោ អតុលោ អបេយ្យោ ។
យេ កេចិ កូបា ឥធ ជីវលោកេ
លោណូទកា កូបខណេហិ ខាតា
ន ព្រាហ្មណជ្ឈោហរណេន តេសុ
អាបោ អបេយ្យោ ទ្វិរសញ្ញុមាហុ ។





ភ្នំទាំងឡាយ មិនមែនជាឥដ្ឋទេ ជាយូរយារៈហើយ ដែលមិនមែនកើតក្លិនផ្កាទេ លោហៈ ក៏មិនមែនកើត ក្លិនផ្កា នោះដែរ ពួកព្រាហ្មណ៍តែងសរសើរនូវយញ្ញនេះ ថាជាគោល ថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ ធ្វើវិចិត្រហើយ ។ ព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ ថាជា គោលនូវព្រាហ្មណ៍ អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈ ថាជាអ្នកប្រកបដោយការសូម សាគរលេបព្រាហ្មណ៍ នោះ ដែលកំពុងសាចទឹកនៃសមុទ្រលើច្រាំង ព្រោះហេតុនោះ ទុកជាទឹកសមុទ្រនោះប្រៃ ផឹកមិនបាន ។ ស្ទឹងទាំងឡាយ ក្តួចយកពួកព្រាហ្មណ៍អ្នកបរិបូណ៌ដោយវេទ បរិបូណ៌ដោយមន្ត ច្រើនជាងពាន់នាក់ ទឹកទាំងឡាយមិនខូចរស ព្រោះហេតុនោះទេ សមុទ្រមិនមានគូរស្មើ មានរសប្រៃ ផឹកមិនបាន តើព្រោះហេតុអ្វី ។ អណ្តូងទាំងឡាយ ក្នុងជីវលោកនេះ មានទឹកប្រៃ ដែលពួកជនអ្នកជីកអណ្តូងបានជីកហើយ ព្រាហ្មណ៍អ្នកជីវិតដោយ អណ្តាតទាំងពីរ ដល់ទាំងឡាយមិនពោលថា ទឹកក្នុងអណ្តូងទាំងនោះ មានរសប្រៃផឹកមិនបាន ព្រោះតែលួចយកព្រាហ្មណ៍ទេ ។

បុរេ បុរត្ថា កា កាស្ស ភរិយា
មនោ មនុស្សំ អជ្ឈាសិ បុរេ
តេជាបិ ចម្មេន ច កោចិ ហីរោ
ឯវម្បិ កេសុត្តរិគត្តមាហុ ។

ចណ្ឌាលបុត្តោបិ អតិច្ច វេរេ
ការេយ្យ មន្តេ កុសលោ មតីមា
ន តស្ស មុទ្ធា វិផលេយ្យ សត្តធា
មន្តា ឥមេ អត្តវធាយ កតា ។

ភិជា កាកា កិត្តិ កាកា តហិតា
ទុម្មោចយា កាព្យមថានុបញ្ញា
ពលាន ចិត្តំ វិសមេ និវិដ្ឋំ
តនប្បញ្ញា អតិសន្ធហន្តិ ។

សីហស្ស ព្យគ្ឃស្ស ច ទីបិនោ ច
ន វិជ្ជតី ពោរិសិយំ ពលេន
មនុស្សភាវេ ច គវំ បមោក្ខា
ជាតី ហិ តេសំ អសមា សមានំ ។



តាំងពីមុនដម្បូងមក ស្ត្រីណា ជាភរិយា របស់បុរសណា មនោបានញ៉ាំងមនុស្សឲ្យកើតឡើងក្នុងកាលមុន មិនមានក្នុងណាមួយ ដើកតាបដាំងគ្នា ដោយតម្រិះនោះ ព្រាហ្មណ៍ទាំងឡាយបានពោលនូវការចែក(វណ្ណៈ)ដោយការលះបង់(ធម៌នោះ) យ៉ាងនេះឯង ។ សូម្បីកូនចណ្ឌាល ជាអ្នកឈ្លាសវៃមានប្រាជ្ញ បានរៀនវេទទាំងឡាយ ពោលមន្តទាំងឡាយ ក្បាលនៃកូនជនចណ្ឌាលនោះ មិនបែកជា៧ភាគទេ មន្តទាំងនេះពួកព្រាហ្មណ៍ធ្វើហើយ ដើម្បីសម្លាប់ខ្លួន ។ ពាក្យកុហក ពួកព្រាហ្មណ៍បានតាក់តែងហើយ ការបង់បាន ពួកព្រាហ្មណ៍បានតាក់តែងកាន់យកហើយ កើតឡើងតាមតន្ត្រនៃពាក្យឃ្លោង ដែលគេប្រាថ្នាបានដោយក្រ ចិត្តរបស់បុគ្គលពាលទាំងឡាយជឿស៊ប់ក្នុងសំពីមិនស្មើ បុគ្គលឥតប្រាជ្ញ រមែងជឿពាក្យនោះ ។ ព្រាហ្មណ៍ មិន(ប្រាកដ) ដោយកម្លាំងដ៏មាំ ដូចកម្លាំងនៃរាជសីហ៍ ខ្លាធំ និងខ្លាដំបង មនុស្សភាព (របស់ព្រាហ្មណ៍ទាំងនោះ) ត្រូវយល់ថា ដូចគោដែរ ព្រោះជាតិរបស់ព្រាហ្មណ៍ទាំងនោះ ស្មើ(ដោយគោ) ស្មើដោយសីហៈជាដើម ។

សចេ ច រាជា បថវឹ វិជិត្វា
សជីវវា អស្សវ បារិសជ្ជោ
សយមេវ សោ សត្តុសង្ឃំ វិជេយ្យ
តស្សប្បជា និច្ច សុខី ភវេយ្យ ។
ខត្តិយមន្តា ច តយោ ច វេទា
អត្ថេន ឯតេ សមកា ភវន្តិ
តេសញ្ច អត្ថំ អវិនិច្ឆិនិត្វា
ន ពុជ្ឈតិ ឱឃបថំវ ឆន្នំ ។
ខត្តិយមន្តា ច តយោ ច វេទា
អត្ថេន ឯតេ សមកា ភវន្តិ
លាភោ អលាភោ យសោ អយសោ ច
សព្វេវ តេសំ ចតុន្នញ្ច ធម្មា ។
យថាបិ ឥក្កា ធនធញ្ញហេតុ
កម្មានិ ករោន្តិ បុថូ បថព្យា
តេវិជ្ជសង្ឃាបិ តថេវ អជ្ជ
កម្មានិ ករោន្តិ បុថូ បថព្យា ។



ប្រសិនបើព្រះរាជាឈ្នះផែនដី ប្រកបដោយអាមាត្យមានអ្នកស្តាប់បង្គាប់ មានបរិស័ទ ព្រះរាជានោះ គប្បីឈ្នះពួកសត្រូវដោយព្រះអង្គឯង ប្រជាជនរបស់ព្រះរាជានោះ គប្បីបានសេចក្តីសុខជានិច្ច ។ មន្តរបស់ក្សត្រិយ៍ និងវេទទាំងបីនេះ ស្មើគ្នាដោយអត្ថ (តែក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី) មិនបានវិនិច្ឆ័យនូវអត្ថនៃមន្តនិងវេទទាំងនោះទេ ទាំងមិនដឹងដូចបុគ្គលកាលមិនដឹងផ្លូវ ដែលគេបាំងដោយទឹក ។ មន្តរបស់ក្សត្រិយ៍ និងវេទទាំងបីនេះ ស្មើគ្នាដោយអត្ថ លាភ អលាភ យសនិងអយសទាំងអស់នេះជាធម៌របស់វណ្ណៈទាំង ៤ នោះ ។ ពួកគហបតី ជាច្រើនលើផែនដី ញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ព្រោះហេតុតែទ្រព្យ និងស្រូវយ៉ាងណា សូម្បីពួកអ្នកមានត្រៃវេទ ជាច្រើនលើផែនដី ក៏ញុំាងបុគ្គលឲ្យធ្វើការងារទាំងឡាយ ក្នុងថ្ងៃនេះ យ៉ាងនោះដែរ ។

សន្តេហិ ឋិតេ សមណា ករន្តិ

និច្ចុស្សុកា កាមគុណេសុ យុត្តា

កាម្ភានិ កាវេន្តិ បុថុ បថព្យា

តេនប្បបញ្ញា និរសញ្ញកា តេ ។

[៣៨០] កស្ស កេហិ មុនិន្ទា ច សន្ធ្វា បណាមេជិន្នុមា(១)

បុរតោ បដិបជ្ជាតិ ហាសយន្តា វេជសកំ ។

កស្ស កញ្ចនបដ្ដេន បុថុនា វិជ្ជុវណ្ណិនា

យុគំ កណាបសន្នទ្ធោ តោ បតិ សិរិយា សហ ។

ខគ្គាមុខេ បមាជ្ជេ ទនិន្តាសេន្ទិកំ

មុទុំ ធារុំកាកតិ តោ បតិ សិរិយា សហ ។

កស្ស ជម្ពោនទំ ឆត្តំ សសលាកំ ឧឡោរមំ

អាទិច្ចរំសាវរណំ តោ បតិ សិរិយា សហ ។

១ ឥត្តីបាយំ បន បណាមេន្តិ ម្ពាតោ ទិស្សតិ ។





ព្រាហ្មណ៍ទាំងនោះ ស្មើគ្នានឹងមហាបថពី ព្រាហ្មណ៍ទាំងឡាយ ជាច្រើនលើផែនដី ជាអ្នកខ្វល់ខ្វាយដោយចិត្ត ប្រកបក្នុងកាមគុណ ទាំងឡាយ តែងញ៉ាំងបុគ្គលឲ្យធ្វើការដល់ទាំងឡាយ ឆ្លាលតាំង ក្នុងដីដែលដោយសណ្ដានទាំងពីរ ព្រោះហេតុនោះ ព្រាហ្មណ៍ ទាំងនោះ ជាអ្នកឥតបញ្ញា ។

[៣៨០] (ព្រះពុទ្ធសាសនព្រហ្មទត្ត ...) ស្ដេច សង្កោរ ស័ទ្ធ ស្ដេច ជ័យនឹងស្ដេចកើត របស់អ្នកណា ដែលដើរទៅមុខ ហើយញ៉ាំង ព្រះរាជាដ៏ប្រសើរក្នុងវេទឲ្យរីករាយ ។ (សម្បុរខ្មុំ) របស់អ្នកណា (ដ៏រុងរឿង) ដោយផ្សាភ្ជាប់ដ៏ក្រាស់ មានពន្លឺដូចផ្លេកបន្ទោរ អ្នកណា នៅកណ្ដាល ប្រដាប់ដោយបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក ។ មុខអ្នកណាស្រស់បស់ដូចមាសឆ្អិន លើមាត់ ដើមក្រោច ឬព្រាតផ្សើរដោយភ្លើងក្នុងសសរធំ អ្នកណារុងរឿង ដោយសិរីហើយដើរមក ។ ឆត្ររបស់បុគ្គលណា ជាវិការៈនៃមាស ជម្ពូនទ ប្រកបដោយឆ្អឹងជាទីរីករាយនៃចិត្ត ជាគ្រឿងបិទបាំង រស្មីនៃព្រះអាទិត្យ អ្នកណា រុងរឿងដោយសិរីហើយដើរមក ។

កស្ស អគ្គិ សរិក្ខយ្ហ ភាសតិ ជធិមុទ្ធនិ
ឧក្កាកោ វិបញ្ចស្ស មុទ្ធនិ មុខបរំ ។
កស្ស បេក្ខុណហត្ថានំ ចិត្រានិ ច មុទ្ធនិ ច
សុវណ្ណមណិបណ្ណានិ ឧរត្ថិ ឧកាកាមុទំ ។
ទធិវក្កិវណ្ណកា ឧក្កាមុខបហំសិតា
កស្សេតេ កុណ្ឌលា វគ្គុ សោភន្តិ ឧភតោ មុខំ
កស្ស ភរេន ចុមិតា សម្ពិន្ធក្កា មុទ្ទ កាន្ត្យា
សោភយន្តិ ឧណាតក្ខិ ធកា វិជ្ជុវត្តគា ។
កស្ស មិគានិ អក្ខីនិ អាយតានិ មុទ្ធនិ ច
តោ សោភតិ វិសាលក្ខោ កាសេត្តំ ឧណ្ណជិ មុខំ
កាសេត្តេ លេខជាតា សុទ្ធា សង្ខវរូបមា
ភាសមានស្ស សោភន្តិ ទន្តា កុន្ទវឡសាធិតា ។
កស្ស លាខារសសមា ហត្ថតលា សុខេ ឋិតា
តោ សោ ជិម្ពាផលសង្កាសោ ទិត សុរិយោវ សោភតិ ។
ហិមច្ចយេ ហិមវតោ ព្រហា សាលោវ បុប្ផិតោ
តោ សោ ទុមោ ចិតាភវេ ជយំ សំភ្នាវ សោភតិ ។



គន្ធ ( អ្នកកាន់ថ្ពិត ) ថ្ពុតកាន់យកភ្លើងដ៏ធំចេញ រាងរលើ ក្បាលកំពស់ពីរោគ នៃបុគ្គលមានបញ្ញាដ៏ប្រសើរណា ។ បុគ្គលនៃគន្ធយក្កោត ដ៏វិចិត្រផង ខ្ចប់ផង មានពន្លឺជាផ្កាកៈនៃមាសនិងកែវមណី ប្រព្រឹត្តទៅតាំងពីរោគមុខ របស់បុគ្គលណា ។ កុណ្ឌលពាំងឡាយនេះ ដ៏ល្អមានពន្លឺដូចជាពណ៌រងើកភ្លើងនៃខ្សែសងើរ ដ៏ភ្លឺរលើមាត់ដើមព្រាន វែងស្រើងរឿងតាំងពីរោគមុខរបស់បុគ្គលណា ។ សក់របស់បុគ្គលណា មានចុងដ៏ស្អិត ខ្ចប់ ខ្មៅ ត្រៀបល្អបក់ហើយ គឺញ៉ាងទីបំផុតនៃថ្ងាសឱ្យល្អ ដូចជាផ្លេកបន្ទោរដែលចេញអំពីមេឃ ។ ភ្នែកតាំងនេះវែងធំរបស់អ្នកណា អ្នកណាមានភ្នែកធំល្អយសម មុខនេះរបស់អ្នកណា ភ្លឺដូចកញ្ចក់មាសមាត់នេះរបស់អ្នកណាដ៏ស្អាត ដូចជាសង្ខដ៏ប្រសើរ ធ្មេញរបស់បុគ្គលណា កាលនិយាយទៀតដូចជាផ្ការមណ្ឌាត្រកួន ។ ដៃនឹងជើងតាំងឡាយ របស់អ្នកណា ដូចជាទឹកល័ក្ខ តាំងនៅក្នុងសេចក្ដីសុខ អ្នកណា មានមែមបបូរមាត់ដូចផ្លែព្រាស ដ៏ល្អដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ ។ អ្នកណា មានសំពត់ស្ពាក់ៈដ៏សដូចដើមរាំងដ៏ធំមានផ្កាក៏ហើយ ក្នុងព្រៃហិមពាន្តក្នុងកាលដែលកន្លងទៅនៃរដូវរងា ល្អដូចព្រះឥន្ទ្រដែលមានជ័យជំនះ ។

សុវណ្ណបិញ្ឆកាកណ្ណំ ឧណ្ហិឧណ្ណាវិចិត្តកំ
កោ សោ បរិសមោក្ខេយ្យ អំសេ ទត្តុំ មមុញ្ចតុំ ។
សុវណ្ណវិការា ចក្រា សុការា ចក្រសិត្តិទី
កោ សោ ឱមុញ្ចតេ នាគា ឥមោ ការា មហាសិតោ ។
(៣៨១)ជាតរូបស្ស តេ នាគា ឥទ្ធិមន្តោ យសស្សិនោ
សមុទ្ទជាយ ឧប្បន្នា បរេ នាគា មហិទ្ធិកាតិ ។

ភូរិទត្តជាតកំ ឆដ្ឋំ ។

---





អ្នកណាទៅក្នុងបរិស័ទដោះដាក់នៅលើស្មា ដែលមានផងដីវិចិត្រ ដោយកែវមណី ដ៏ដេរដោសដោយពពកជាវិការៈនៃមាស ។ អ្នកណាដោះវិស្សកដើង ដែលចាក់ដោយមាស វិចិត្រដោយកែវពៅ ប្រៃការ ដេរដោយស្ទួក្រឥវិចិត្រ ចេញល្អហើយ គឺដូយបន្ទិ ភាពសម្ពក់ស្នូរកេតុណាដ៏ធំ ។

(៣៨១) (កាពស ជាប៉ក . . .) នាគទាំងនោះ ជានាគមានឫទ្ធិ មានយស ជាកូននៃព្រះទាហធតរដ្ឋ កើតអំពីនាងសមុទ្ទជា នាគទាំងនេះ សុទ្ធតែជានាគមានឫទ្ធិច្រើន ។

ចប់ ភូរិទត្តជាតក ទី ៦ ។

## បន្ធកុមារជាតកំ[១]

(៣៨៦) រាជាសិ លុទ្ទកកម្មោ[២]
ឯករាជា បុប្ផវតិយាយំ
សោ បុច្ឆិ ព្រហ្មពន្ធុំ
ខណ្ឌហាលំ បុរោហិតំ មូឡ្ហំ
សគ្គានមគ្គមាចិក្ខ
ត្វំសិ ព្រាហ្មណ ធម្មវិនយកុសលោ
យថា ឥតោ វជន្តិ សុគតិំ
នរា បុញ្ញានិ កត្វាន ។

(៣៨៧) អតិទានំ ទទិត្វាន
អវជ្ឈេ ទេវ ឃាតេត្វា
ឯវំ វជន្តិ សុគតិំ
នរា បុញ្ញានិ កត្វាន ។

(៣៨៨) កឹ បនេតំ អតិទានំ
កេ ច អវជ្ឈា ឥមស្មឹ លោកស្មឹ
ឯតញ្ច ខោ នោ អក្ខាហិ
យជិស្សាមិ ទទាមិ ទានានិ ។

១ ឧ. ម. ខណ្ឌហាលជាតកំ ។ ២ ឧ. លុទ្ទកម្មោ ។ ម. លុទ្ទកម្មោសិ ។

## បន្ធកុមារជាតក

(៣៨៦) ( អភិសម្ពុទ្ធគាថា ) ព្រះបាទឯករាជ អ្នកមានអំពើអាក្រក់ នៅក្នុងក្រុងបុប្ផវតីនោះ សួរផ្លូវទៅព្រហ្មលោក ពីបុរោហិត ឈ្មោះខណ្ឌហាល ជាពូជពង្សព្រហ្ម ជាមនុស្សល្ងង់ខ្លៅថា ម្នាលព្រាហ្មណ៍ អ្នកជាមនុស្សឈ្លាសក្នុងធម៌វិន័យ សូមអ្នកប្រាប់ផ្លូវឋានសួគ៌ តាមទំនងដែលពួកជនធ្វើបុណ្យទាំងឡាយ ហើយចេញចាកលោកនេះ ទៅកាន់សុគតិដូច្នោះ ។

(៣៨៧) ( ខណ្ឌហាលព្រាហ្មណ៍បុរោហិតទូលថា ) បពិត្រព្រះទេវៈ ពួកជនធ្វើបុណ្យទាំងឡាយ ឲ្យទានដ៏ក្រៃលែង សម្លាប់បុគ្គលដែលមិនគួរសម្លាប់ទាំងឡាយ ហើយទៅកាន់សុគតិយ៉ាងនេះ ។

(៣៨៨) ( ព្រះបាទឯករាជ. . . ) ទានដ៏ក្រៃលែងនុ៎ះ ដូចម្ដេច ក្នុងលោកនេះ បុគ្គលទាំងឡាយ ដូចម្ដេច ដែលមិនគួរសម្លាប់ ចូរអ្នកប្រាប់សេចក្ដីនុ៎ះដល់យើង យើងនឹងបូជា នឹងឲ្យទានទាំងឡាយ ។

[៣៨៥] បុត្តេហិ ទេវ យជិតព្វំ
មហេសីហិ នេគមេហិ ច
ឧសភេហិ អាជានិយេហិ ចតូហិ
សព្វចតុក្កេន ទេវ យជិតព្វំ ។

[៣៨៦] តំ សុត្វា អន្តេបុរេ
កុមារា មហេសិយោ ច ហញ្ញន្តុ
ឯកោ អហោសិ និគ្ឃោសោ
ភេស្មា អច្ចុគ្គតោ សទ្ទោ ។

[៣៨៧] គច្ឆថ វទេថ កុមារេ
ចន្ទំ សុរិយញ្ច ភទ្ទសេនញ្ច
សូរញ្ច វាមគោត្តញ្ច
បចុរា កិរ ហោថ យញ្ញត្ថាយ ។

[៣៨៨] កុមារិយោបិ វទេថ
ឧបសេនញ្ច កោកិលញ្ច
មុទិតញ្ច នន្ទញ្ចាបិ កុមារិកំ
បចុរា កិរ ហោថ យញ្ញត្ថាយ ។



(៣៨៥) (ខណ្ឌហាលព្រាហ្មណ៍ ...) បពិត្រព្រះទេវៈ ព្រះអង្គគប្បី
បូជា ដោយព្រះរាជបុត្រទាំងឡាយផង ដោយព្រះអគ្គមហេសី
ទាំងឡាយផង ដោយអ្នកនិគម ( សេដ្ឋី ) ទាំងឡាយផង
បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជា ដោយគោឧសភ សេះអាជា-
នេយ្យបួន ១ ដោយវត្ថុសព្វបួន ១ ទាំងអស់ ។

(៣៨៦) សំឡេងគឹកកងតែមួយ សំឡេងខ្លាំងក្រៃលែង លាន់ឮឡើងក្នុងទីវាំង
ព្រោះព្រះរាជឱង្ការនោះថា ព្រះកុមារទាំងឡាយ និងព្រះអគ្គ-
មហេសីទាំងឡាយ ត្រូវសម្លាប់ ។

(៣៨៧) (ព្រះរាជា ...) អ្នកទាំងឡាយ ចូរទៅប្រាប់កុមារទាំងឡាយ
គឺចន្ទកុមារ ១ សុរិយកុមារ ១ ភទ្ទសេនកុមារ ១ សូរកុមារ ១
វាមគោត្តកុមារ ១ ថា អ្នកទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បី
ប្រយោជន៍ដល់ការបូជាយញ្ញ ។

(៣៨៨) អ្នកទាំងឡាយ ចូរប្រាប់កុមារីទាំងឡាយ គឺកុមារីឈ្មោះ
ឧបសេនា ១ កោកិលា ១ មុទិតា ១ នន្ទា ១ ថា នាងទាំង
ឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។

(៣៨៩)វិជយញ្ច មយ្ហំ មហេសឹ
ឯកបតឹ កេសិនឹ សុនន្ទញ្ច
លក្ខណវរូបបន្នា
ឧបនេថ តា ហោន្តុ យញ្ញត្ថាយ ។

(៣៩០)គហបតយោ ច គណ្ហថ
បុណ្ណមុខំ ភទ្ទិយំ សិង្គាលញ្ច
វឌ្ឍញ្ចាបិ គហបតឹ
ឧបនេថ តេ ហោន្តុ យញ្ញត្ថាយ ។

(៣៩១) តេ តត្ថ គហបតយោ អវោចយឹសុ
សមាគតា បុត្តទារបរិកិណ្ណា
សព្វេ សិខិនោ ទេវ ករោហិ
អថវា នោ ទាសេ សាវេហិ ។

(៣៩២)អភយង្ករម្បិ[១] មេ ហត្ថឹ នាឡាគិរឹ អច្ចុគ្គតំ
(វរុណទន្តំ)
អានេថ ខោ នេ ខិប្បំ យញ្ញត្ថាយ ភវិស្សន្តិ ។
អស្សរតនម្បិ មេ កេសឹ សុរាមុខំ បុណ្ណកំ វិនតកញ្ច
អានេថ ខោ នេ ខិប្បំ យញ្ញត្ថាយ ភវិស្សន្តិ ។

១ ម. អភយករំ ។



(៣៨៩) អ្នកទាំងឡាយ ចូរចាប់មហេសីអញ គឺនាងវិជយា ១ នាងឯកបតី ១ នាងកេសិនី ១ នាងសុនន្ទា ១ ដែលជាស្ត្រីបរិបូណ៌ ដោយលក្ខណៈដ៏ប្រសើរ នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។

(៣៩០) អ្នកទាំងឡាយ ចូរចាប់គហបតីទាំងឡាយ គឺគហបតីឈ្មោះ បុណ្ណមុខៈ ១ ភទ្ទិយៈ ១ សិង្គាលៈ ១ វឌ្ឍៈ ១ ជា ចូរអ្នកទាំងឡាយ មកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។

(៣៩១) (អភិសម្ពុទ្ធគាថា) ពួកគហបតីទាំងនោះ មកជួបជុំគ្នាហែហម ដោយកូននិងប្រពន្ធក្នុងទីនោះ ក្រាបបង្គំទូលថា បពិត្រព្រះទេវៈ សូមព្រះអង្គ ធ្វើយើងខ្ញុំទាំងអស់ឲ្យមានផ្នួងលើក្បាលវិញ ពុំនោះសោត សូមព្រះអង្គប្រកាសឲ្យយើងខ្ញុំជាទាសៈ ។

(៣៩២) (ព្រះរាជា...) អ្នកទាំងឡាយ ចូរនាំមកនូវដំរីរបស់អញឈ្មោះ អភយង្ករៈ ១ នាឡាគិរី ១ អច្ចុគ្គតៈ ១ (ឈ្មោះវរុណទន្តៈ) ១ ដំរីទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងពិតជាប់ ។ អ្នកទាំងឡាយ ចូរនាំមកនូវសេះកែវរបស់អញឈ្មោះ កេសី ១ សុរាមុខៈ ១ បុណ្ណកៈ វិនតកៈ ១ សេះទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយញ្ញយ៉ាងពិតជាប់ ។

ឧសភញ្ច មេ យូថបតី

អនោជំ និសភំ គវម្បតី

តេបិ មយ្ហំ អានេថ សព្វេ ការេន្តុ សត្តំ

យជិស្សាមិ ទទាមិ ទានានិ ។

សព្វំ បដិយាទេថ

យញ្ញំ បន ឧគ្គតម្ហិ សុរិយម្ហិ

អាណាបេថ ចន្ទកុមារេ

អភិរមន្តុ ឥមំ រត្តិំ ។

សព្វំ ឧបដ្ឋាបេថ

យញ្ញំ បន ឧគ្គតម្ហិ សុរិយម្ហិ

វទេថ ទានិ កុមារេ

អជ្ជ ហោ បច្ឆិមា រត្តិ ។

(៣៨៣) តំ តំ មាតា អវច

រោទន្តី អាគន្ត្វា វិមានតោ

យញ្ញោ កិរ តេ បុត្ត

ការិស្សតិ ចតុរោ បុត្តេ ។



អ្នកទាំងឡាយ ចូរនាំយកគោឧសភទាំងនោះរបស់អញ គឺគោ ឧសភឈ្មោះយូថបតិ ១ អនោជៈ ១ និសភៈ ១ គវម្បតិ ១ មកដល់អញ អ្នកទាំងឡាយ ចូរធ្វើកិច្ចការទាំងពួង ក្នុងទីចំពោះ មុខអញ ទីបូជា ទីនឹងឲ្យតាមទាំងឡាយ ។ អ្នកទាំងឡាយ ចូរតាក់តែងគ្រឿងបូជាគ្រប់មុខ កាលបើព្រះអាទិត្យ រះឡើង ហើយ អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់ពួកកុមារ ទាំងបួនកុមារថាយើងថា កុមារទាំងឡាយ ចូរដេកឲ្យអស់ ១ យប់នេះចុះ ។ អ្នកទាំងឡាយ ចូរដំកល់ទុកនូវគ្រឿងយញ្ញ គ្រប់មុខ កាលបើព្រះអាទិត្យ រះឡើង អញនឹងបូជា អ្នកទាំង ឡាយ ចូរប្រាប់កុមារទាំងឡាយ ក្នុងកាលវេលានេះ ថា ព្រឹក ថ្ងៃនេះឯង ជាកាលក្រោយបំផុត ។

(៣៨៣) (អភិសម្ពុទ្ធគាថា) ព្រះរាជមាតា (ព្រះបាទឯករាជ) ទ្រង់ ព្រះកន្សែង ទ្រង់ស្តេចមកអំពីវិមាន ទ្រង់មានព្រះរាជសវនីយ៍ ស្ដាប់សេចក្ដីនោះ ដល់ព្រះរាជាថា ឱកូន ឮថា កូនឯង នឹងបូជាយញ្ញ ដោយព្រះរាជបុត្រទាំង ៤ ពិតមែនឬ ។

(៣៩៤) សចេ មយ្ហំ បុត្តា ចត្តា
ចន្ទស្មិំ ហញ្ញមានស្មិំ
បុត្តេហិ យញ្ញំ យជិត្វាន
សុគតិំ សគ្គំ គមិស្សាមិ ។

(៣៩៥) មា ត្វំ បុត្ត សទ្ទហេសិ
សុគតិ កិរ ហោតិ បុត្តយញ្ញេន
និរយានេសោ មគ្គោ
នេសោ មគ្គោ ហិ សគ្គានំ ។
ទានានិ ទេហិ កោណ្ឌញ្ញ
អហិំសា សព្វភូតភព្យានំ
ឯស មគ្គោ សុគតិយា
ន ច មគ្គោ បុត្តយញ្ញេន ។

(៣៩៦) អាចរិយានំ វចនា
ឃាតេស្សំ ចន្ទញ្ច សូរិយញ្ច
បុត្តេហិ យជិត្វា ទុច្ចជេហិ
សុគតិំ សគ្គំ គមិស្សាមិ ។





(៣៩៤) (ព្រះបាទឯករាជ ...) កាលបើខ្ញុំសម្លាប់ចន្ទកុមារហើយ បុត្ររបស់ខ្ញុំទាំងអស់ ក៏ខ្ញុំលះបង់ ដើម្បីបូជាយញ្ញផង លុះខ្ញុំបូជាដោយបុត្រទាំងឡាយហើយ ខ្ញុំនឹងទៅកាន់សុគតិសួគ៌ ។

(៣៩៥) (ព្រះចន្ទរាជ ...) ម្នាលកូន អ្នកកុំជឿខណ្ឌហាល. ព្រាហ្មណ៍នោះថា សុគតិបានដោយការបូជាបុត្រឡើយ ផ្លូវនេះ ជាផ្លូវទៅកាន់នរក មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ ។ ម្នាលកូនកោណ្ឌញ្ញគោត្រ ចូរអ្នកឲ្យទានទាំងឡាយ (អ្នក) កុំបៀតបៀនសព្វសត្វដែលកើតហើយនិងត្រូវកើតឡើយ នេះជាផ្លូវនៃសុគតិ ផ្លូវ (នៃសុគតិ) មិនមែនបានដោយការបូជាបុត្រទេ ។

(៣៩៦) (ព្រះបាទឯករាជ ...) ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យខណ្ឌហាលអាចារ្យ បូជាបុត្រទាំងឡាយ ដែលគេលះបង់បានដោយក្រហើយ នឹងទៅកាន់សុគតិសួគ៌ ។

(៣៩៧) តំ តំ បិតាបិ អវច

វសវត្តិ ទិវសំ សតាំ បុត្តិំ

យញ្ញោ កិរ តេ បុត្ត

ភវិស្សតិ ចតូហិ បុត្តេហិ ។

(៣៩៨) សព្វេបិ មយ្ហំ បុត្តា ចត្តា

ចន្ទស្មិំ ហញ្ញមានស្មិំ

បុត្តេហិ យញ្ញំ យជិត្វាន

សុគតិំ សគ្គំ គមិស្សន្តិ ។

(៣៩៩) មា តំ បុត្ត សទ្ទហេសិ

សុគតិំ កិរ ហោតិ បុត្តយញ្ញេន

និរយានេសោ មគ្គោ

នេសោ មគ្គោ ហិ សគ្គានំ ។

ទានានិ ទេហិ កោណ្ឌញ្ញ

អហិំសា សព្វភូតភព្យានំ

ឯស មគ្គោ សុគតិយា

ន ច មគ្គោ បុត្តយញ្ញេន ។



(៣៩៧) (អភិសម្ពុទ្ធគាថា) ពរណាៗ ដែលព្រះវសវត្តី ជាព្រះជនកត្រាស់ ស្ដាប់ហេតុនោះ ចំពោះព្រាហ្មណ៍ខណ្ឌហាល ជាជនបុត្រកើតអំពីព្រះទេវ នោះថា ម្នាលកូនឮថា អ្នកនឹងបូជាយញ្ញដោយបុត្រទាំង ៤ មែនឬ ។

(៣៩៨) (ព្រាហ្មណ៍ខណ្ឌហាល ...) កាលបើខ្ញុំសម្លាប់ចន្ទកុមារ ( បុត្រ ) ហើយ បុត្រទាំងឡាយទាំងអស់ ក៏ខ្ញុំលះបង់ដែរ ខ្ញុំបូជាយញ្ញ ដោយបុត្រទាំងឡាយហើយ នឹងទៅកាន់សុគតិសួគ៌ ។

(៣៩៩) ( ព្រះរាជបិតា ... ) ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍ ថា សុគតិមាន ដោយការបូជាបុត្រឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរក មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ ។ ម្នាលកូនកោណ្ឌញ្ញព្រាហ្មណ៍ ចូរអ្នកឲ្យទានទាំងឡាយ (ចុះ) កុំបៀតបៀនសព្វសត្វទាំងឡាយ ដែលកើតហើយ នឹងត្រូវកើត នេះជាផ្លូវនៃសុគតិ ផ្លូវ ( នៃសុគតិ ) មិនមែនដោយការបូជាបុត្រទេ ។

(៦០០) អាចរិយានំ វចា
ឃាតេស្សំ ចន្ទញ្ច សុរិយញ្ច
បុត្តេហិ យជិត្វា ទុច្ចជេហិ
សុគតិំ សគ្គំ គមិស្សាមិ ។

(៦០១) ទានានិ ទេហិ កោណ្ឌញ្ញ
អហឹសា សព្វភូតានំ
បុត្តបរិវុតោ ធុវំ
រដ្ឋំ ជនបទញ្ច បាលេហិ ។

(៦០២) មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពទ្ធកាបិ
ហត្ថី អស្សេ ច បាលេម ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពទ្ធកាបិ
ហត្ថិឆកណានិ ឧជ្ឈេម ។



(៦០០) (ព្រះបាទឯកពល...) ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យនៃខណ្ឌហាលអាចារ្យ ខ្ញុំបូជាបុត្រទាំងឡាយ ដែលគេលះបង់ បានដោយកម្រ ហើយនឹងទៅកើតក្នុងសុគតិសួគ៌ ។

(៦០១) (ព្រះរាជបិតា...) ម្នាលកូន កោណ្ឌញ្ញគោត្រ អ្នកចូរឲ្យទានទាំងឡាយ (ផង) កុំបៀតបៀនសព្វសត្វដែលកើតហើយនិងត្រូវកើតទាំងឡាយឡើយ អ្នកចូរជាមនុស្ស ដែលកូនទាំងឡាយហែហមហើយ រក្សាដែននិងជនបទចុះ ។

(៦០២) (ចន្ទកុមារ...) បពិត្រព្រះបិតា ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានខ្ញុំព្រះបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងខ្ញុំព្រះបង្គំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយឃ្វាលដំរីនិងសេះ ។ បពិត្រព្រះបិតា ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយឡើយ សូមព្រះអង្គ ព្រះរាជទានខ្ញុំព្រះបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាង ខ្ញុំព្រះបង្គំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយ នឹងចោលអាចម៍ដំរី ។

មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ
អស្សេ ច ការណានិ ទេស្សេម ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
យស្ស ហោន្តិ តវ កាមា
អបិ រដ្ឋា បព្វាជិតា ភិក្ខាចរិយំ ចរិស្សាម ។

(៨០៣) ទុក្ខំ ខោ មេ ជនយថ
វិលបន្តា ជីវិតស្ស កាមាហិ
មុញ្ចេថ ទានិ កុមារេ
អលំបិ មេ ហោតុ បុត្តយញ្ញេន ។

(៨០៤) បុព្វេវ ខោសិ មេ វុត្តោ
ទុក្ករំ ទុរភិសម្ភវំ ចេតំ
អថ នោ ឧបក្ខតស្ស យញ្ញស្ស
កស្មា ករោសិ វិក្ខេបំ ។



បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយ នឹងឃ្វាលដំរីសេះ ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ព្រះអង្គមានប្រាថ្នា (ដើម្បីព្រះរាជទាន) ដល់ខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានទូលបង្គំ ជាខ្ញុំទាំងឡាយឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត នឹងសូមព្រះអង្គបំបរបង់ទូលបង្គំជាខ្ញុំទាំងឡាយ ចេញចាកដែន ក៏ទូលបង្គំជាខ្ញុំទាំងឡាយ នឹងត្រាច់ទៅកាន់ភិក្ខាចារ ។

(៨០៣) (ព្រះបាទឯករាជ . . .) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយ យំស្រែក ព្រោះតែបំណងជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយ លែងកុមារទាំងឡាយទៅ ការបូជាយញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ ។

(៨០៤) (ខណ្ឌហាលព្រាហ្មណ៍ ..) ទូលព្រះបង្គំជាខ្ញុំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយញ្ញនុះ ជាការធ្វើបានដោយកម្រផង ទាំងដោយនឹងធ្វើឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញដែលទូលព្រះបង្គំជាខ្ញុំត្រៀមត្រៀបស្រេចហើយ ហេតុអ្វីព្រះអង្គធ្វើឲ្យរាតរាយទៅវិញ

សព្វេ វទន្តិ សុគតិំ
យេ យជន្តិ យេ ចេ យាជាបេន្តិ[១]
យេ ចាបិ អនុមោទន្តិ
យជន្តានំ ឯទិសំ មហាយញ្ញំ ។

[៦០៨] អថ កិស្ស ច នោ បុព្វេ
សោត្ថានំ ព្រាហ្មណេ អវាចេសិ
អថ នោ អការណស្មា
យញ្ញត្ថាយ ទេវ ឃាតេសិ ។
បុព្វេវ នោ ទហរកាលេ
ន ហនេសិ ន ឃាតេសិ
ទហរម្ហា យោព្វនប្បត្តា
អទូសកា តាត ហញ្ញាម ។
ហត្ថិគតេ អស្សគតេ
សន្នទ្ធេ បស្ស នោ មហារាជ
យុទ្ធេ វា យុជ្ឈមានេ វា
ន ហិ មាទិសា ហោន្តិ យញ្ញត្ថាយ ។

១ ម. យេច យាជេន្តិ ។





ជនទាំងឡាយណាបូជាយញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនា មហាយញ្ញ ដែលអ្នកដទៃកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំង ឡាយ ទាំងអស់នោះ រមែងទៅកាន់សុគតិ ។

[៦០៨] (ចន្ទកុមារ ...) ចុះព្រះអង្គឲ្យពួកព្រាហ្មណ៍ទាយសួស្តីរបស់ ទូលព្រះបង្គំជាខ្ញុំ ពីមុនមកម្តេចក្តី បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គឲ្យគេសម្លាប់ពួកទូលបង្គំជាខ្ញុំ ដើម្បីប្រយោជន៍ដល់យញ្ញ ដោយឥតហេតុ ។ កាលដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយ នៅក្មេងនៅឡើយ(ម្តេចក៏)ព្រះអង្គមិនសម្លាប់មិនឲ្យគេសម្លាប់ទៅ បពិត្រព្រះបិតា ឥឡូវនេះទូលបង្គំជាខ្ញុំទាំងឡាយ ជាក្មេងពេញ កម្លោះជាអ្នកឥតប្រទូស្ត ក៏ស្រាប់តែព្រះអង្គឲ្យគេសម្លាប់ ។ បពិត្រ មហារាជ សូមព្រះអង្គទតមើល ទូលបង្គំជាខ្ញុំទាំងឡាយដែល គាត់គ្រឿងក្រោះជិះដំរីជិះសេះ ច្បាំងហើយនឹងកំពុងច្បាំង មនុស្ស ទាំងឡាយ ដែលដូច្នេះ មិនមែនជាមនុស្សសម្រាប់បូជាយញ្ញទេ ។

បទ្ធេត្ត ក កុម្មិ ត
អដ្ឋស្សុ ក មានិសេ ឆិយោធេន្តិ
អថ នោ អគារណាស្មា
អក្ខិយំ ការ ហញ្ញេឌ ។
យោ កាចិ សកុណិកាយោ(១)
វសន្តិ តិណយកនិ កោត្ថាន
តាសំ បិយា បុត្តា
អថ ហោ ត្វំ ហេវ យាទេសិ ។
មា ខ្វស្ស សន្ទុហេសិ
ន ទំ ខណ្ឌហាលោ យាចេយ្យ
ជមញ្ញិ សោ យាចេត្វាន
អនន្តក តម្បិ ហេវ យាចេយ្យ ។
កាមជំ និគមវំ ធនន្តិ
កោតំបិស្ស ឧហារាជ
អជ្ឈុបិណ្ឌិ តាបិ
កុលេ កុលេ ហោតេ កុញ្ចន្តិ ។

១ ម. យាចិតំ វា សកុណិយោ ។





ជនទាំងឡាយ តែងបញ្ចាន់ក្នុងមនុស្សដូចទូលបង្គំជាខ្ញុំ ទៅក្តី បព្វជិតក្រោម ដែលចេះហោះឡើងហើយ ពួកដទៃទៀត បពិត្រព្រះបិតា កាលបើដូច្នោះ ទូលបង្គំជាខ្ញុំទាំងឡាយ មិនត្រូវព្រះអង្គឲ្យគេសម្លាប់ ក្នុងទីមិនជាឱកាស ដោយឥតហេតុទេ ។ ពពួកសត្វស្លាបទាំងឡាយណាមួយ ធ្វើសម្បុកដោយស្មៅទាំងឡាយហើយនៅ កូនទាំងឡាយជាទីស្រឡាញ់របស់ពពួកស្លាបទាំងនោះ បពិត្រព្រះរាជា កាលបើដូច្នេះ ព្រះអង្គនៅតែឲ្យគេសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយ ។ ព្រះអង្គកុំជឿពាក្យខណ្ឌហាលព្រាហ្មណ៍នោះជា ខណ្ឌហាលព្រាហ្មណ៍ មិនគប្បីសម្លាប់គញ្ញុំ ដូចនេះឡើយ បពិត្រព្រះរាជា ព្រោះខណ្ឌហាលព្រាហ្មណ៍នោះ សម្លាប់ទូលបង្គំ ជាខ្ញុំទាំងឡាយហើយ គប្បីសម្លាប់ព្រះអង្គ ក្នុងកាលជាលំដាប់ ។ បពិត្រមហារាជ ព្រះរាជាទាំងឡាយ តែងព្រះរាជទានស្រុកដ៏ប្រសើរផង និគមដ៏ប្រសើរផង គោរៈផង ដល់ព្រាហ្មណ៍នោះ កាលបើដូច្នោះ ពួកព្រាហ្មណ៍ទាំងនោះ ជាអ្នកបរិភោគភត្ត ៗ ដុំធ្លាយដីដ៏ស្អាត តែងបានបរិភោគភក្តក្នុងត្រកូល ។

តេសំបិ តានិសានិ
ឥជ្ជន្តិ ទុក្កិត្តិ មហាភដ
យេភុយ្យេន ហិ សំគេ
អកាតញ្ញុតោ ព្រាហ្មណា ទេវ ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ
ហត្ថី អស្សេ ច បាលេម ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ
ហត្ថិឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ
អស្សឆកណានិ ឧជ្ឈេម ។



បពិត្រមហារាជ ព្រាហ្មណ៍នុ៎ះ ប្រាថ្នាដើម្បីប្រទូស្តចំពោះជនអ្នកឲ្យទាំងនោះ ដូចជាព្រះអង្គ បពិត្រព្រះទេវៈ ពួកព្រាហ្មណ៍ទាំងនុ៎ះជាមនុស្សអកតញ្ញូដោយច្រើន បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណងហើយនឹងឃ្វាលដំរីនឹងសេះ ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់ ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទាន នូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាប់ចំណងហើយនឹងចាក់អាចម៍ដំរី ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈ នៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណងនឹងចាក់អាចម៍សេះ ។

មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
យស្ស ហោន្តិ តវ កាមា
អបិ រដ្ឋា បព្វាជិតា ភិក្ខាចរិយំ ចរិស្សាម ។

(៦០៦) ទុក្ខំ ខោ មេ ជនយថ
វិលបន្តា ជីវិតស្ស កាមាហិ
មុញ្ចេថ ទានិ កុមារេ
អលម្បិ មេ ហោតុ បុត្តយញ្ញេន ។

(៦០៧) បុព្វេវ ខោសិ មេ វុត្តោ
ទុក្ករំ ទុរភិសម្ភវញ្ចេតំ
អថ នោ ឧបក្ខដស្ស យញ្ញស្ស
កស្មា ករោសិ វិក្ខេបំ ។
សព្វេ វជន្តិ សុគតឹ
យេ យជន្តិ យេបិ យាជេន្តិ
យេ ចាបិ អនុមោទន្តិ
យជន្តានំ ឯទិសំ មហាយញ្ញំ ។



បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ ពួកទូលបង្គំទាំងឡាយ ឡើយ ព្រះអង្គសព្វព្រះរាជហឫទ័យ ចំពោះខណ្ឌហាលព្រាហ្មណ៍ ណា សូមព្រះរាជទាន ពួកទូលបង្គំទាំងឡាយ ឲ្យជាទាសៈ នៃខណ្ឌហាលព្រាហ្មណ៍នោះវិញចុះ ពុំនោះសោត ទូលបង្គំ ទាំងឡាយ បើព្រះអង្គបំបរបង់ចេញចាកដែន នឹងត្រាច់ ទៅកាន់ភិក្ខាចារ ។

(៦០៦) (ព្រះបាទឯកករាជ ...) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើង ក្រៃណាស់ អ្នកទាំងឡាយ យំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ពួកអ្នកទាំងឡាយ លែងកុមារទាំងឡាយទៅ ការ បូជាយញ្ញដោយកូនរបស់អញ ល្មមហើយតែប៉ុណ្ណេះ ។

(៦០៧) (ខណ្ឌហាលព្រាហ្មណ៍ ...) ទូលបង្គំបានក្រាបទូល ទាំងពីដើមមកថា ការបូជាយញ្ញនុ៎ះ ជាការធ្វើបានដោយកម្រ ផង មិនងាយនឹងឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញ ដែលទូលបង្គំប្រុងប្រៀបស្រេចហើយ ហេតុអ្វីព្រះអង្គធ្វើ ឲ្យរាក់រានទៅវិញ ។ ជនទាំងឡាយណា បូជាយញ្ញខ្លួន ឯងក្តី ជនទាំងឡាយណាឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយ ណា ត្រេកអរអនុមោទនាមហាយញ្ញ ដែលអ្នកដទៃកំពុងបូជា ប្រាកដដូច្នេះក្តី ជនទាំងអស់ (នោះ) រមែងទៅកាន់សុគតិ ។

(៤០៨) យទិ ការ យជិត្វា បុត្តេហិ
ទេវលោកំ ឥតោ ចុតា យន្តិ
ព្រាហ្មណោ តាវ យជតុ
បច្ឆាបិ យជិស្សសិ ភវ(១) ។
យទិ ការ យជិត្វា បុត្តេហិ
ទេវលោកំ ឥតោ ចុតា យន្តិ
ឯសេវ ខណ្ឌហាលោ
យជតុ សកេហិ បុត្តេហិ ។
ឯវំ ជានំ ចេ ខណ្ឌហាលោ
កិំ បុត្តកេ ន ឃាតេសិ
សព្វញ្ច ញាតិជនំ
អត្តានញ្ច ន ឃាតេសិ ។
សព្វេ វជន្តិ និរយំ
យេ យជន្តិ យេបិ ចេវ យជាបេន្តិ
យេ ចាបិ អនុមោទន្តិ
យជន្តានំ ឯទិសំ មហាយញ្ញំ ។

១ ម. យជិស្សសេ ភវំ ។



(៤០៨) (ចន្ទកុមារ . . .) បើប្រាកដជាបុគ្គលទាំងឡាយ បូជាយ័ញ្ញដោយបុត្រទាំងឡាយហើយ ច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់ទេវលោក បពិត្រមហារាជ សូមព្រាហ្មណ៍បូជាមុនចុះ សូមព្រះអង្គបូជាតាមក្រោយ ។ ក្មួយ បើប្រាកដជាបុគ្គលទាំងឡាយ បូជាយ័ញ្ញដោយបុត្រទាំងឡាយហើយ ច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់ទេវលោក សូមខណ្ឌហាលព្រាហ្មណ៍នេះឯង បូជាដោយកូនទាំងឡាយរបស់ខ្លួនចុះ ។ បើខណ្ឌហាលព្រាហ្មណ៍ ដឹងយ៉ាងនេះហើយ ហេតុអ្វីក៏មិនសម្លាប់កូនតូចៗ ទាំងឡាយផង មិនសម្លាប់ផងជាញាតិទាំងអស់ផង មិនសម្លាប់ខ្លួនឯងផង ។ ជនទាំងឡាយណា បូជាយ័ញ្ញដោយខ្លួនឯងក្តី ជនទាំងឡាយណាឲ្យគេបូជាយ័ញ្ញក្តី ឬក៏ជនទាំងឡាយណា ត្រេកអរអនុមោទនាមហាយ័ញ្ញប្រាកដដូច្នេះក្តី ជនទាំងអស់ (នោះ) រមែងទៅកាន់នរក ។

(៦០៨) កាមញ្ចា(១) តាត បុត្តកាមាយោ
គហបតយោ យសស្សិនោ ច
ធតរដ្ឋិ ច ទុយ្យធន្តិ ករាធំ
មា យាចយិ ទុរសំ បុត្តិ ។
កាមញ្ច តាត បុត្តកាមាយោ
គហបតយោ យសស្សិនោ ច
ធតរដ្ឋិ ច ទុយ្យធន្តិ ករាធំ
មា យាចយិ អត្រជំ បុត្តិ ។
វញ្ចោ ចដ្ឋិ អត្តកាមោ
ហំកោ ច សព្វជនបទស្ស
ន កោចិ អស្ស បដិយំ ឧយោ
ជនបទោ ន បវេធតិ ។

---

១ ម. ឯត្តកេ សហេ ហ៍ សោ សុជ្ជូតិ យោ ហេតុ ហេតោ សោ សក្កុបេតិ ឆ្នាំ កោរិ កោរិ នមោហេយ្យ ហេតុ ហេសំ តាសុហេយ្យុំ អយំ គាថា ទិស្សតិ ។



(៦០៨) ម្តេចក៏ពួកម្ចាស់ផ្ទះ ទាំងស្រីមេផ្ទះជាតិឧឡារ ដែលជាអ្នកចង់បានកូនច្រើន មិនទូលហាស់ព្រះពលាចា កុំច្រង់សម្លាប់បុត្រ ដែលកើតអំពីទ្រូងឡើយ ។ ម្តេចក៏ពួកម្ចាស់ផ្ទះ ទាំងស្រីមេផ្ទះជាតិឧឡារដែលជាអ្នកចង់បានកូន ច្រើន មិនទូលហាស់ព្រះពលាចា កុំច្រង់សម្លាប់បុត្រ ដែលកើតអំពីទ្រូងឡើយ ។ ខ្ញុំជាអ្នកប្រាថ្នាប្រយោជន៍ដល់ព្រះពលាចា ប្រយោជន៍ដល់អ្នកជនបទទាំងអស់ អរិកាសត្រូវណាមួយធ្វើជាស៊ីបក្ខ ចំទំរូវឡើយ (ព្រោះហេតុនោះ) អ្នកជនបទមិនក្រោមខ្ពុលឡើងក្តៅឡើយ ។

(៦១០) គច្ឆថ ភោ ឃរណិយោ
តាតញ្ច វទេថ ខណ្ឌហាលញ្ច
មា ឃាតេថ កុមារេ
អទូសកេ សីហសង្កាសេ
គច្ឆថ ភោ ឃរណិយោ
តាតញ្ច វទេថ ខណ្ឌហាលញ្ច
មា ឃាតេថ កុមារេ
អបេក្ខិតេ សព្វលោកស្ស ។

(៦១១) យន្នូនាហំ ជាយេយ្យំ
រថការកុលេ វា
បុក្កុសកុលេ វា វេស្សេសុ វា ជាយេយ្យំ
ន ហជ្ជ មំ រាជ យញ្ញេ ឃាតេយ្យ ។

(៦១២) សព្វាបិ ឧត្តិនិយោ
គច្ឆថ អយ្យស្ស ខណ្ឌហាលស្ស
បាទេសុ និបតថ
អបរាធាហំ ន បស្សាមិ ។



(៦១០) ម្នាលនាងឃរណីទាំងឡាយ (ស្រីមេផ្ទះ) ចូរនាងទាំងឡាយ
ទៅអង្វរព្រះរាជបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះ
អង្គកុំសម្លាប់កុមារទាំងឡាយ ដូចជាសីហៈ ជាអ្នកមិនប្រទូស្ត
ម្នាលនាងឃរណីទាំងឡាយ ចូរនាងទាំងឡាយទៅនិយាយអង្វរ
ព្រះបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់
កុមារទាំងឡាយ ជាទីអាល័យ របស់សត្វលោកទាំងអស់ ។

(៦១១) បើខ្ញុំបានទៅកើតអញ កើតក្នុងត្រកូលអ្នកធ្វើរថ ឬអ្នកចោល
សម្រាម ឬកើតក្នុងត្រកូលវេស្សៈ ទើបព្រះរាជាមិនសម្លាប់
អញ ដើម្បីយញ្ញក្នុងថ្ងៃនេះ ។

(៦១២) ម្នាលពួកស្រី អ្នកមានគំនិតទាំងឡាយ ចូរនាងទាំងអស់
ទៅក្រាបទៀបបាទា នៃខណ្ឌហាលព្រាហ្មណ៍ ជាម្ចាស់
ហើយ (ក្រាបថា) ខ្ញុំមិនឃើញកំហុសសោះ ។

សព្វាបិ យវណ្ណិយោ(១)
គច្ឆថ អយ្យស្ស ខណ្ឌហាលស្ស
បាទេសុ និបតថ
ពាប្តេ កប្តេ ខយំ អនុសេម ។
(៦១៣) កាបណា វិលបតិ សេលា
ទិស្វាន ភាតរេ ឧបនីតត្តេ
យញ្ញោ កិរ មេ ឧក្ខិបិតោ
តាតេន សគ្គកាមេន ។
(៦១៤) អាវត្តិ ច បរិវត្តិ ច
វសុលោ សម្មុខា រញ្ញោ
មា នោ ទេវ បិតរំ អវធិ
ទហរម្ហា អយោព្ពនប្បត្តា ។
(៦១៥) ឯសោ តេ វសុល បិតា
សមេហិ បិតរា សហ
ទុក្ខំ ហោ មេ ជនយំ
វិលបន្តោ អន្តេបុរស្មឹ
ឧបញ្ញាធំ កុមារេ
អលំ បិ មេ ហោតុ បុត្តយញ្ញេន ។

១ ម. សព្វាសំ ទន្តីយោ ។



ម្នាលអ្នកស្រីជាមេផ្ទះទាំងអស់គ្នា ចូរនាំគ្នាទាំងឡាយទៅក្រាប ទៀបបាទនៃខណ្ឌហាលព្រាហ្មណ៍ ជាម្ចាស់ ហើយ (និយាយថា) បពិត្រលោកខណ្ឌហាលដ៏ចំរើន យើងទាំងឡាយបានប្រទូស្តនឹងលោក ។

(៦១៣) លំដាប់នោះព្រះនាងសេលាជាព្រះរាជធីតា ទ្រង់កន្សែងកាលឃើញ ព្រះភាតាទាំងឡាយ ដែលគេនាំចូលទៅហើយ ទ្រង់ព្រះកន្សែងថា ឮថា យញ្ញព្រះវរបិតាអញ ទ្រង់ប្រាថ្នាឋានសួគ៌ ឲ្យប្រព្រឹត្តទៅហើយ ។

(៦១៤) (លំដាប់នោះ) វសុលកុមារបម្រះខ្លួនទៀត ក្នុងទីចំពោះ ព្រះភក្ត្រព្រះរាជា ទ្រង់ព្រះកន្សែងអង្វរថា បពិត្រព្រះបិតា សូមព្រះអង្គ កុំសម្លាប់បិតារបស់ទូលបង្គំទាំងឡាយឡើយ ព្រោះទូលបង្គំ ទាំងឡាយនៅក្មេង កុំទាន់ធំនៅឡើយ ។

(៦១៥) (ព្រះរាជា . . . ) ម្នាលវសុលកុមារ នុ៎ះបិតារបស់ឯង ចូរ ឯងស្ទុះទៅជាមួយនឹងបិតារបស់ឯងចុះ ឯងយំស្រែកក្នុងព្រះ រាជវាំង ពោលថា ញ៉ាំងទុក្ខឲ្យកើតឡើងដល់អញ អ្នកទាំងឡាយ ចូរលែងកូនកុមារក្នុងកាលឥឡូវនេះចុះ ការ បូជាយញ្ញ ដោយកូនរបស់អញ ល្មមហើយលែងចុះ ។

(៦១៦) បុច្ឆេ ហោសិ មេ វុត្តោ
ឥច្ឆាំ ឥច្ឆិតសទ្ធាំ ទេតិ
អថ សោ ទុបត្ថកស្ស យញ្ញស្ស
កស្មា ការេសិ វិក្កមំ ។
សព្វេ វជន្តិ សុគតិំ
យេ យជន្តិ យេបិ តេ យាជាបេន្តិ
យេ ចាបិ អនុមោទន្តិ
យជន្តានំ ឯទិសំ មហាយញ្ញំ ។

(៦១៧) សព្វាគតស្ស យញ្ញោ ទុបត្ថោតោ
បាការេ តេ បដិយត្តោ
អភិនិក្ខមស្សុ ទេវ
សគ្គំ គតោ តុំ មោទិស្សសិ ។

(៦១៨) ជហោភ សត្តសតា ឯតា
ចន្ទកុមារស្ស ភរិយាយោ
កេសេ វិកិរិត្វាន
កន្ទន្តិយោ មគ្គមនុយាយន្តិ ។



(៦១៦) (ខណ្ឌហាលព្រាហ្មណ៍ . . .) ទូលបង្គំក្រាបទូលព្រះអង្គថា
តាំងពីដើមមកថា ការបូជាយញ្ញនេះ ជាកិរិយាធ្វើឲ្យទៅជាយកស្រួលផង
មិនកើតយសនឹងឲ្យកើតឡើងបានផង ការលើកឡើងយញ្ញដែលទូល
បង្គំចាត់ចែងប្រៀបរួចស្រេចហើយ ហេតុអ្វីព្រះអង្គធ្វើឲ្យឃាត់
វិញ ។ ជនទាំងឡាយណា បូជាយញ្ញដោយខ្លួនឯងក្តី
ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា
ត្រេកអរតាមបូជាមហាយញ្ញ ដែលអ្នកដទៃកំពុងបូជាក្រៃលែង
ដូច្នេះក្តី ជនទាំងអស់នោះ រមែងទៅកាន់សុគតិ ។

(៦១៧) បពិត្រព្រះឯករាជ យញ្ញដែលទូលបង្គំចាត់ចែងរៀបចំ ដើម្បី
ព្រះអង្គដោយគ្រប់ទាំងគ្រឿងហើយ បពិត្រព្រះរាជា សូមព្រះ
អង្គយាងចេញទៅ ព្រះអង្គនឹងទៅរីករាយក្នុងឋានសួគ៌ ។

(៦១៨) (អភិសម្ពុទ្ធគាថា) ពួកស្ត្រីទាំង ៧០០ នុ៎ះ ទៅក្រោយ ៗ ដែល
ជាភរិយា ចន្ទកុមារ រំសាយកេសា ទ្រហោយំដើរតាមផ្លូវទៅ ។

អបក ឞន សោកេន
ចិក្ខិត្តា ឆន្ទេន វីយ សេភ
កោសា វីកោវីត្វាន
កេនត្ថិយោ មត្តមតុយាយន្តិ ។
(៤១៨) កាសិកសុចិវត្ថធរា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសុរិយា
យញ្ញត្ថាយ ឯកករាជស្ស ។
កាសិកសុចិវត្ថធរា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសុរិយា
មាតុ កត្វា ហទយសោកំ
កាសិកសុចិវត្ថធរា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
នីយន្តិ ចន្ទសុរិយា
ជនស្ស កត្វា ហទយសោកំ ។



ចំណែកក្នុងស្រុកនោះទៀត ក៏បញ្ឈប់ដោយសេចក្តីសោកស្តាយ សោយគេសា ឲ្យញ៉ាំងដើរតាមផ្លូវទៅ ដូចជាខែទៀត ( ពោម ពោមខោលបុត្រដែលរៀបឲ្យន ) ក្នុងទិសខាងត្បូង ។

(៤១៨) ចន្ទកុមារ និងសុរិយកុមារ ប្រដាប់សំពត់ដំណាប់ដែលកើតក្នុងដែនកាសី ជាអ្នកប្រដាប់កុណ្ឌល លាបស្រឡាប ដោយខ្លឹមនិងគ្រឿងចន្ទន៍ ត្រូវគេនាំយកទៅ ដើម្បីប្រយោជន៍ដល់យញ្ញនៃព្រះបាទឯកករាជ ។ ចន្ទកុមារនិងសុរិយកុមារ ជាអ្នកប្រដាប់សំពត់ដំណាប់ ដែលកើតក្នុងដែនកាសី ប្រដាប់កុណ្ឌល លាបស្រឡាប ដោយខ្លឹមនិងគ្រឿងចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារនិងសុរិយកុមារ ជាអ្នកប្រដាប់សំពត់ដំណាប់ ដែលកើតក្នុងដែនកាសី ប្រដាប់កុណ្ឌល លាបស្រឡាប ដោយខ្លឹមនិងគ្រឿងចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ ។

មំសរសភោជនា ន្ហាបកសុន្ហាតា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យន្តិ ចន្ទសុរិយា
យញ្ញត្ថាយ ឯករាជស្ស ។
មំសរសភោជនា ន្ហាបកសុន្ហាតា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យន្តិ ចន្ទសុរិយា
មាតុ កត្វា ហទយសោកំ ។
មំសរសភោជនា ន្ហាបកសុន្ហាតា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យន្តិ ចន្ទសុរិយា
ជនស្ស កត្វា ហទយសោកំ ។
យស្សុ បុព្វេ ហត្ថិវរធុរគតេ
ហត្ថិកា(១) អនុវជន្តិ
ត្យជ្ជ ចន្ទសុរិយា
ឧភោវ បត្តិកា យន្តិ ។

---
១ ម. ហត្ថីហិ ។



ចន្ទកុមារនឹងសុរិយកុមារ ដែលជាអ្នកបរិភោគសាច់នឹងរស ជាអ្នកដែលភ្នាក់ក្រោកសផ្ងូតស្អាតហើយទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយក្លាននឹងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅ ដើម្បីប្រយោជន៍ដល់យញ្ញ នៃព្រះបាទឯករាជ ។ ចន្ទកុមារនឹងសុរិយកុមារ ជាអ្នកបរិភោគនូវសាច់នឹងរស ជាអ្នកដែលភ្នាក់ប្រោកសផ្ងូតស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយក្លាននឹងខ្លឹមចន្ទន៍ ធ្វើសេចក្ដីសោក ក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ ។ ចន្ទកុមារនឹងសុរិយកុមារ ជាអ្នកបរិភោគសាច់នឹងរស ជាអ្នកដែលភ្នាក់ក្រោកសផ្ងូតស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយក្លាននឹងខ្លឹមចន្ទន៍ ធ្វើសេចក្ដីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ ។ កាលពីមុនពួកពលដំរី តែងដើរតាមពីក្រោយ នូវចន្ទកុមារនឹងសុរិយកុមារណា ដែលគង់លើខ្នងដំរីដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារនឹងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទទទេ ។

យស្ស បុព្វេ អស្សវរធុរគតោ
អស្សកា អនុយន្តិ
ស្វជ្ជ ចន្ទសុរិយា
ឧភោ បត្តិកា យន្តិ ។
យស្ស បុព្វេ រថវរធុរគតោ
រថិកា អនុយន្តិ
ស្វជ្ជ ចន្ទសុរិយា
ឧភោ បត្តិកា យន្តិ ។
យេ ហិស្សុ បុព្វេ និយឹសុ
គជនីយកប្បេហិ កុញ្ជរេហិ
ស្វជ្ជ ចន្ទសុរិយា
ឧភោ បត្តិកា យន្តិ ។

(៦២០) យទិ សកុណិ មំសមិច្ឆសិ
ទយ្យស្ស[១] បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ ចតូហិ បុត្តេហិ ។

១ ម. ទយស្ស ។



កាលពីមុន ក្ពុកពលសេះ ដែលតាមហែ នូវចន្ទកុមារនឹងសុរិយ
កុមារណា ដែលគង់លើខ្នងសេះដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ
នឹងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទ
ទទេ ។ កាលពីមុន ក្ពួករថ ដែលតាមហែ នូវចន្ទកុមារនឹងសុរិយ
កុមារណា ដែលគង់ក្នុងកណ្តាលរថដ៏ប្រសើរ ថ្ងៃនេះ ចន្ទ-
កុមារនឹងសុរិយកុមារ ទាំងពីរព្រះអង្គនោះ យាងទៅ ដោយ
ព្រះបាទទទេ ។ កាលពីមុន ចន្ទកុមារនឹងសុរិយកុមារណា
ស្តេចទៅ ដោយព្រះទីនាំងសេះ ដែលគេតាក់តែង ដោយ
គ្រឿងមាស ថ្ងៃនេះ ចន្ទកុមារនឹងសុរិយកុមារ ទាំងពីរព្រះអង្គ
នោះ យាងទៅដោយព្រះបាទទទេ ។

(៦២០) (ចន្ទកុមារ . . . ) ម្នាលបក្សី បើឯងចង់ស៊ីសាច់ ចូរឯងហើរទៅ
ខាងទិសខាងកើតនៃក្រុងបុប្ផវតី ព្រោះព្រះបាទឯករាជ វង្វេង
ស្មារតី ទ្រង់យកព្រះរាជបុត្រ ៤ ព្រះអង្គធ្វើយញ្ញ ក្នុងទីនុ៎ះ ។

យទិ សកុណិ មំសមិច្ឆសិ
ឌយស្សុ បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ ចតូហិ កញ្ញាហិ ។
យទិ សកុណិ មំសមិច្ឆសិ
ឌយស្សុ បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ ចតូហិ មហេសីហិ ។
យទិ សកុណិ មំសមិច្ឆសិ
ឌយស្សុ បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ ចតូហិ គហបតីហិ ។
យទិ សកុណិ មំសមិច្ឆសិ
ឌយស្សុ បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ ចតូហិ ហត្ថីហិ ។





ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតីត្រូវយកព្រះរាជកញ្ញាទាំង ៤ ព្រះអង្គបូជាយញ្ញ កន្លែងនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ត្រូវយកព្រះមហេសីទាំង ៤ ព្រះអង្គបូជាយញ្ញ កន្លែងនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះស្ដេចឯករាជ ភាន់ស្មារតី ត្រូវយកគហបតីទាំង ៤ បូជាយញ្ញ កន្លែងនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត ក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ត្រូវយកដំរីទាំង ៤ បូជាយញ្ញ កន្លែងនុ៎ះ ។

យទិ សកុណិ មំសមិច្ឆសិ
ឌយស្សុ បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ ចតូហិ អស្សេហិ ។
យទិ សកុណិ មំសមិច្ឆសិ
ឌយស្សុ បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ ចតូហិ ឧសភេហិ ។
យទិ សកុណិ មំសមិច្ឆសិ
ឌយស្សុ បុព្វេន បុប្ផវតិយាយំ
យជតេត្ថ ឯករាជា
សម្មូឡ្ហោ សព្វចតុក្កេន ។

(៦២១) អយមស្ស បាសាទោ
សោវណ្ណោ បុប្ផមាល្យវីតិកិណ្ណោ(១)
តេធាចំ អយ្យបុត្តា
ចត្តារោ វធាយ និន្នីតា ។

១ ម. ធំ មាល្យបុប្ផំ សុវណ្ណាយំ ។



ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីបុរ ព្រោះព្រះរាជាឯករាជ ភាន់ស្មារតី ទ្រង់យកសេះ ៤ បូជាយញ្ញ ក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីបុរ ព្រោះព្រះរាជាឯករាជ ភាន់ស្មារតី ទ្រង់យក គោឧសភ ៤ បូជាយញ្ញ ក្នុងទីនុ៎ះ ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើត នៃក្រុងបុប្ផវតីបុរ ព្រោះព្រះរាជាឯករាជ ភាន់ស្មារតី ទ្រង់យកសត្វបួន ៗ គ្រប់មុខបូជាយញ្ញ ក្នុងទីនុ៎ះ ។

(៦២១) ប្រាសាទមាសនេះ ចាក់កណ្តាលមាស ដេរដាស ដោយផ្កាកម្រងផ្កា ពីប្រាសាទនេះ ព្រះអយ្យបុត្រទាំង៤ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់

ឥទមស្សុ កូដាគារំ

សោវណ្ណំ បុប្ផមាល្យាភិកិណ្ណំ

តេទានិ អយ្យបុត្តា

ចត្តារោ វធាយ និន្នីតា ។

ឥទមស្សុ ឧយ្យានំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

តេទានិ អយ្យបុត្តា

ចត្តារោ វធាយ និន្នីតា ។

ឥទមស្សុ អសោកវនំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

តេទានិ អយ្យបុត្តា

ចត្តារោ វធាយ និន្នីតា ។

ឥទមស្សុ កណិការវនំ

សុបុប្ផិតំ សព្វកាលិកំ រម្មំ

តេទានិ អយ្យបុត្តា

ចត្តារោ វធាយ និន្នីតា ។

---

១ ម. អន្តេបុរំ សុរម្មណីយ ។



ផ្ទះកំពូលនេះ ជាវិការៈនៃមាស ដេរដាស ដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ឧទ្យាននេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃអសោកនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ព្រៃកណ្ណិការនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។

ឥទមស្ស ពាដលិវនំ
សុបុប្ផិតំ សព្វកាលិកំ រម្មំ
នេន្តិ អយ្យបុត្តា
ចត្តារោ វធាយ និន្នីតា ។
ឥទមស្ស អម្ពវនំ
សុបុប្ផិតំ សព្វកាលិកំ រម្មំ
នេន្តិ អយ្យបុត្តា
ចត្តារោ វធាយ និន្នីតា ។
អយមស្ស បោក្ខរណី
សញ្ឆន្នា បទុមបុណ្ឌរីកេហិ
នាវា ច សោវណ្ណវិកតា
បុប្ផវល្លិយា ចិត្តា សុរម្មណីយា
នេន្តិ អយ្យបុត្តា
ចត្តារោ វធាយ និន្នីតា ។
(៦៦៦) ឥទមស្ស ហត្ថិរតនំ
ឯរាវណោ គជោ ពលី ទន្តី
នេន្តិ អយ្យបុត្តា
ចត្តារោ វធាយ និន្នីតា ។



ព្រៃប្រទៀតនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ស្ដេចនេះ
ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។
ព្រៃស្វាយនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ស្ដេចនេះ
ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។
ស្រះបោក្ខរណីនេះ ដេរដាសពាសពេញ ដោយផ្កាឈូកស
ឈូកក្រហម ទាំងទូកដែលរចនាដោយមាស វិចិត្រដោយក្បាច់វល្លិ៍
ជាទីរីករាយចិត្ត ដោយក្រៃលែង ស្ដេចនេះ ព្រះអយ្យបុត្រ
ទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។
(៦៦៦) ដំរីកែវនេះ ជាដំរីឈ្មោះឯរាវ័ណ មានកំឡាំង មានភ្លុក ស្ដេចនេះ
ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។

ឥធមស្ស អស្សរតនំ
ឯកខុរោ វេគោ អស្សោ
តេនាហំ អយ្យបុត្តា
ចត្តារោ វោយ និដ្ឋិកា ។
អយមស្ស អស្សរាជា
សាលិយោ វិយ និក្ខោសោ(១)
សុភោ គតវិចិត្តោ យត្ថស្ស
អយ្យបុត្តា សោភិសុ ចន្ទិម វិយ គេហ
តេនាហំ អយ្យបុត្តា
ចត្តារោ វោយ និដ្ឋិកា ។
កាជច្ឆាម សាមសមសុទ្ធហោ
ចង្កបុទុកាគត្តហោ(២)
កជា យធិស្សរេ យញ្ញំ
សម្មាទេ ចត្តហោ បុគ្គហោ ។

---

១ ម. សាលិកនិក្ខោសោ ។ ឌ. សាលិយនិក្ខោសោ ។ ២ ម. ចន្ទនោរាគកគ្គហោ ។





សេះកែវនេះ ជាសេះ មានក្រចកមួយ មានសម្បុរប៉ាល ផង្សនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ ចំណែកសេះនេះ មានសម្បុរស៊ើ ដូចសំឡេង នៃស្រូវសាលី ជាវេជីស្តាត វិចិត្រដោយរតនវត្ថុ ជាសេះ របស់អ្នកព្រះអយ្យបុត្រ ដូចជាអ្នកទៅនៅក្នុងទីខ្ពស់ ផង្សនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់ ។ រថ្ហាក ព្រះការក្រាប់បេញ្ញ ទឹងដូចយ៉ាងដោយព្រះបុត្រ ទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាឬក្ខល ស្តាត (ឥតោស) ដែលមានខ្ចួយណាបហើយដោយទ្រំធុរិ ។

កាជន្ទាម សាមសមសុគន្ធកហិ
ចន្ទនមុទុកគត្តាហិ
កទា យជិស្សតេ យញ្ញំ
សម្មុឡ្ហោ ចតូហិ កញ្ញាហិ ។
កាជន្ទាម សាមសមសុគន្ធកហិ
ចន្ទនមុទុកគត្តាហិ
កទា យជិស្សតេ យញ្ញំ
សម្មុឡ្ហោ ចតូហិ មហេសីហិ ។
កាជន្ទាម សាមសមសុគន្ធកេហិ
ចន្ទនមុទុកគត្តេហិ
កទា យជិស្សតេ យញ្ញំ
សម្មុឡ្ហោ ចតូហិ គហបតីហិ ។
យថា ហោន្តិ គាមនិគមា
សុញ្ញា អមនុស្សកា ព្រហារញ្ញា
តថា ហេស្សតិ បុប្ផវតិយា
យិដ្ឋេសុ ចន្ទសុរិយេសុ ។



ម្ដេចក៏ ព្រះរាជាកាន់ប្រឡូងនឹងបូជាយញ្ញ ដោយព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយ ដោយខ្លឹមចន្ទន៍ ។ ម្ដេចក៏ ព្រះរាជាកាន់ប្រឡូងនឹងបូជាយញ្ញ ដោយព្រះមហេសីទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយ ដោយខ្លឹមចន្ទន៍ ។ ម្ដេចក៏ ព្រះរាជាកាន់ប្រឡូងនឹងបូជាយញ្ញ ដោយគហបតីទាំង ៤ នាក់ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាប ដោយខ្លឹមចន្ទន៍ ។ ស្រុកនិងនិគមទាំងឡាយ សូន្យអមនុស្ស ក្លាយទៅជាព្រៃធំ យ៉ាងណាមិញ កាលបើចន្ទកុមារនឹងសុរិយៈកុមារ ត្រូវព្រះរាជា យកទៅបូជាយញ្ញហើយ ក្រុងបុប្ផវតី ( ក្រុងពារាណសី ) យ៉ាងនោះដែរ ។

(៦៦៣) ឧម្មត្តិកា ភវិស្សាមិ
ភូនហតា បំសុនា បរិកិណ្ណា
សចេ ចន្ទកុមារំ ហន្តិ
បាណា មេ ទេវ រុជ្ឈន្តិ(១) ។
ឧម្មត្តិកា ភវិស្សាមិ
ភូនហតា បំសុនា បរិកិណ្ណា
សចេ សុរិយកុមារំ ហន្តិ
បាណា មេ ទេវ រុជ្ឈន្តិ ។

(៦៦៤) កិន្នុមា ន រមាបេយ្យុំ
អញ្ញមញ្ញំ បិយំវទា
ឃដ្ដិកា ឧបរិក្ខី ច
បោក្ខរណី ច ភាយិកា
ចន្ទសុរិយេសុ នច្ចន្តិយោ
សមា តាសំ ន វិជ្ជតិ ។

១ ឱ. គិជ្ឈន្តិ ។ ម. រុជ្ឈិ ។



(៦៦៣) (ព្រះនាងចន្ទាទេវី . . . ) ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាក
សេចក្ដីចំរើន ប្រឡាក់ប្រឡូស ដោយធូលីដី ក៏មាន
បើនឹងសម្លាប់ចន្ទកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់
ខ្ញុំម្ចាស់នឹងបែកធ្លាយ ។ ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាក
សេចក្ដីចំរើន ប្រឡាក់ប្រឡូស ដោយធូលីដីក៏មាន បើនឹង
សម្លាប់សុរិយកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់
នឹងបែកធ្លាយ ។

(៦៦៤) ស្រីទាំងឡាយនេះ គឺនាងឃដ្ដិកា នាងឧបរិក្ខី នាងពោក្ខរណី
នឹងនាងភាយិកា ជាអ្នកពោលពាក្យជាទីស្រឡាញ់ ទៅវិញ
នឹងគ្នា ម្ដេចក៏មិនធ្វើ ឲ្យចន្ទកុមារនឹងសុរិយកុមារ សប្បាយរីករាយ
(ព្រោះស្រីដទៃ) ស្មើដោយស្រីទាំងនោះ មិនមានទេ ។

(៦៤៨) ឥមំ មយ្ហំ ហទយសោកំ
បដិមុញ្ចតុ ខណ្ឌហាល តវ មាតា
យោ មយ្ហំ ហទយសោកោ
ចន្ទស្មិំ វធាយ និន្នីតេ ។
ឥមំ មយ្ហំ ហទយសោកំ
បដិមុញ្ចតុ ខណ្ឌហាល តវ មាតា
យោ មយ្ហំ ហទយសោកោ
សុរិយស្មិំ វធាយ និន្នីតេ ។
ឥមំ មយ្ហំ ហទយសោកំ
បដិមុញ្ចតុ ខណ្ឌហាល តវ ជាយា
យោ មយ្ហំ ហទយសោកោ
ចន្ទស្មិំ វធាយ និន្នីតេ ។
ឥមំ មយ្ហំ ហទយសោកំ
បដិមុញ្ចតុ ខណ្ឌហាល តវ ជាយា
យោ មយ្ហំ ហទយសោកោ
សុរិយស្មិំ វធាយ និន្នីតេ ។



(៦៤៨) សេចក្ដីសោកក្នុងហឫទ័យនៃអាត្មាអញ ព្រោះតែចន្ទកុមារដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្ដាយអ្នកឯង ចូរទទួលយកសេចក្ដីសោកក្នុងហឫទ័យ នៃអាត្មាអញនោះចុះ ។ សេចក្ដីសោកក្នុងហឫទ័យ នៃអាត្មាអញ ព្រោះតែសុរិយកុមារ ដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្ដាយអ្នកឯង ចូរទទួលយកសេចក្ដីសោក ក្នុងហឫទ័យ នៃអាត្មានោះចុះ ។ សេចក្ដីសោក ក្នុងហឫទ័យ នៃអាត្មាអញ ព្រោះតែចន្ទកុមារ ដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង ចូរទទួលយកសេចក្ដីសោក ក្នុងហឫទ័យ នៃអាត្មានោះចុះ ។ សេចក្ដីសោកក្នុងហឫទ័យ នៃអាត្មាអញ ព្រោះតែសុរិយកុមារ ដែលគេនាំយកទៅសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធរបស់អ្នក ចូរទទួលយកសេចក្ដីសោក ក្នុងហឫទ័យ នៃអាត្មានោះចុះ ។

មា ច បុត្តំ មា ច បតឹ
អទ្ទក្ខិ ខណ្ឌហាល តវ មាតា
យោ ឃាតេសិ កុមារេ
អទូសកេ សីហសង្កាសេ ។
មា ច បុត្តំ មា ច បតឹ
អទ្ទក្ខិ ខណ្ឌហាល តវ មាតា
យោ ឃាតេសិ កុមារេ
អបេក្ខិតេ សព្វលោកស្ស ។
មា ច បុត្តំ មា ច បតឹ
អទ្ទក្ខិ ខណ្ឌហាល តវ ជាយា
យោ ឃាតេសិ កុមារេ
អទូសកេ សីហសង្កាសេ ។
មា ច បុត្តំ មា ច បតឹ
អទ្ទក្ខិ ខណ្ឌហាល តវ ជាយា
យោ ឃាតេសិ កុមារេ
អបេក្ខិតេ សព្វលោកស្ស ។



អ្នកឯងសម្លាប់ពួកកុមារ ដែលឥតទោសដូចសីហៈ ជាអ្នកមិនប្រទូស្ត ខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯង កុំបានឃើញកូនចៅទាំងឡាយផង ប្តីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសព្វលោកចាំនឹកស់ គោរពអាល័យ ខណ្ឌហាល-ព្រាហ្មណ៍ ម្តាយអ្នកឯង កុំបានឃើញកូនចៅទាំងឡាយផង ប្តីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលឥតទោសដូចសីហៈ ជាអ្នកមិនប្រទូស្ត ខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង កុំបានឃើញកូនចៅទាំងឡាយផង ប្តីផងឡើយ ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសព្វលោកចាំនឹកស់ គោរពអាល័យ ខណ្ឌហាល-ព្រាហ្មណ៍ ប្រពន្ធអ្នកឯង កុំបានឃើញកូនចៅទាំងឡាយផង ប្តីផងឡើយ ។

(៤២៦) មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ
ហត្ថី អស្សេ ច បាលេម ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ
ហត្ថិឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
អបិ និគឡពន្ធកាបិ
អស្សឆកណានិ ឧជ្ឈេម ។
មា នោ ទេវ អវធិ
ទាសេ នោ ទេហិ ខណ្ឌហាលស្ស
យស្ស ហោន្តិ តវ កាមា
អបិ រដ្ឋា បព្វាជិតា
ភិក្ខាចរិយំ ចរិស្សាម ។



(៤៤៦) (ចន្ទកុមារ . . .) បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយឡើយ សូមប្រទានព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយឃ្វាលដំរីនឹងសេះ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយឡើយ សូមប្រទានព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌ-ហាលព្រាហ្មណ៍ចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណងហើយចោលលាមកដំរី ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយឡើយ សូមប្រទានព្រះរាជទាន ខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ខ្ញុំព្រះអង្គទាំងឡាយសូមឲ្យជាអ្នកជាប់ចំណង ហើយចោលលាមក-សេះ ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំឡើយ បើព្រះអង្គសព្វព្រះទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមប្រទានព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌ-ហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត សូមព្រះអង្គបំបរបង់ ឲ្យចេញចាកដែន ព្រះអង្គនឹងត្រាច់ទៅកាន់ភិក្ខាចារ ។

តិស្ស ទេវ ឧបយាចន្តិ
បុត្តត្ថិកា ទលិទ្ទាបិ
បដិការណានិបិ ហិត្វា
បុត្តេ ន លភន្តិ ឯកច្ចា
អាសាសិកានិ ករោន្តិ
បុត្តា នោ ជាយន្តុ ឥតោ បបុត្តា
អថ នោ អការណស្មា
យញ្ញត្ថាយ ទេវ ឃាតេសិ ។
ឧបយាចិតកេន បុត្តំ លភន្តិ
មា តាត នោ អឃាតេសិ
មា កិច្ឆលទ្ធកេហិ បុត្តេហិ
យជិត្ថោ ឥមំ យញ្ញំ ។
ឧបយាចិតកេន បុត្តំ លភន្តិ
មា តាត នោ អឃាតេសិ
មា កបណលទ្ធកេហិ បុត្តេហិ
អម្មាយ នោ វិប្បវាសេសិ ។





បពិត្រព្រះសម្មតិទេព នារីពួកខ្លះ សូម្បីជាស្ត្រីកំសត់ នៅតែបន់បានកូន ហើយបន់ស្រន់ទេវតា ស៊ូលះបង់ចំណង់ផ្លូក នៅតែមិនបានកូនទាំងឡាយគ្រប់គ្នា ។ នារីពួកខ្លះ ធ្វើពាក្យប្រកបដោយសេចក្ដីចង់បានថា កូនទាំងឡាយ របស់យើង ចូរកើតបន្តចំពោះ ចៅទាំងឡាយ ចូរកើតទៀត បពិត្រព្រះសម្មតិទេព កាលបើដូច្នេះ ( ហេតុអ្វី ) ព្រះអង្គសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយ ដើម្បីបូជាយញ្ញដោយមិនសមហេតុ ។ ពួកស្ត្រីតែងបានកូន ដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយឡើយ ព្រះអង្គកុំបូជាយញ្ញនេះដោយបុត្រទាំងឡាយ ដែលបានដោយលំបាកឡើយ ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ខ្ញុំព្រះបង្គំទាំងឡាយឡើយ សូមព្រះអង្គកុំញុំាងខ្ញុំព្រះបង្គំទាំងឡាយ ឲ្យព្រាត់ប្រាសចាកមាតានៃបុត្រទាំងឡាយ ដែលបានដោយលំបាក ។

(៤៦៧) ពហុទុក្ខំ បោសិយា ចន្ទំ

អម្ម តុវំ ជីយសេ បុត្តំ

វន្ទាមិ ខោ តេ បាទេ

លភតំ តាតោ បរលោកំ

ហន្ទ ច មំ ឧបគូហ

បាទេ តេ អម្ម វន្ទិតុំ ទេហិ

គច្ឆាមិទានិ បវាសំ

យញ្ញត្ថាយ ឯករាជស្ស ។

ហន្ទ ច មំ ឧបគូហ

បាទេ តេ អម្ម វន្ទិតុំ ទេហិ

គច្ឆាមិទានិ បវាសំ

មាតុ កត្វា ហទយសោកំ ។

ហន្ទ ច មំ ឧបគូហ

បាទេ តេ អម្ម វន្ទិតុំ ទេហិ

គច្ឆាមិទានិ បវាសំ

ជនស្ស កត្វា ហទយសោកំ ។



(៤៦៧) បពិត្រព្រះមាតា ព្រះអង្គបានបង្កើតបុត្រ គឺចន្ទកុមារមក មានទុក្ខព្រួយច្រើនណាស់ ព្រោះតែការចិញ្ចឹម ខ្ញុំជាកូន សូមក្រាបថ្វាយបង្គំព្រះបាទា នៃព្រះមាតា សូមឲ្យព្រះជនកបិតា បានទៅបរលោក (ដែលបរិបូណ៌ដោយសម្បត្តិ) ចុះ ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបក្រៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ដ្បិតថា ខ្ញុំនឹងទៅកាន់ទីព្រាត់ប្រាស ដើម្បីប្រយោជន៍ដល់យញ្ញរបស់ព្រះបាទឯករាជ ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបក្រៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ដ្បិតថា ខ្ញុំនឹងធ្វើសេចក្តីសោកក្នុងហឫទ័យ នៃព្រះមាតា ហើយទៅកាន់ទីព្រាត់ប្រាស ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបក្រៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ដ្បិតថា ខ្ញុំនឹងធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ហើយទៅកាន់ទីព្រាត់ប្រាស ។

(៤៤៨) ហត្ថិ ច បទុមបក្ខំ

អោលឹ ពន្ធស្ស គោតមិបុត្ត

ចន្ទ្រាគលមិស្សាយោ(១)

ឯសា តេ គោកណ្ណិកា បកតិ ។

ហត្ថិ ច វិលេបនេត្ត

បដ្ឋមកំ ចន្ទនំ វិលិម្បស្សុ

យេហិ ច សុវិលិត្តោ

សោភសិ រាជបរិសាយំ ។

ហត្ថិ ច មុទុកានិ វត្ថានិ

បច្ឆិមំ កាសិកំ និវាសេហិ

យេហិ ច សុនិវត្ថោ

សោភសិ រាជបរិសាយំ ។

មុត្តាមណិកនកវិភូសិតានិ

គណ្ហស្សុ ហត្ថាភរណានិ

យេហិ ច ហត្ថាភរណេហិ

សោភសិ រាជបរិសាយំ ។

---

១-២. ឧ. ចន្ទ្រាគលមិស្សាយោ ។ ម. ចន្ទ្រាគលោហិ មិស្សាយោ ។



៤៤៨] (ព្រះមាតា...) ម្នាលគោតមីបុត្រ ហេតុអ្វីចុះ ព្រះអង្គនឹងប្តូរនៅពាលី

ដោយស្លឹកឈូក ព្រះអង្គប្រដាប់ផ្កាកម្រង ដែលលាយដោយ

ត្រកកូលខ្មៅ នេះ ជាប្រក្រតីដើមរបស់ព្រះ ។ ហេតុ ព្រះអង្គធ្លាប់

លាបស្រឡាបដោយខ្លឹមចន្ទន៍ពិតដ៏ល្អយ៉ាងណា ហើយល្អរុងរឿង

ក្នុងរាជបរិស័ទ (នេះ)ជាគ្រឿងលាបរបស់ព្រះ ព្រះអង្គលាបខ្លឹមចន្ទន៍

ជាទីបំផុតព្រះ ។ ហេតុ ព្រះអង្គស្លៀកដណ្តប់សំពត់ពិតដ៏ល្អយ៉ាងណា

មានសាច់ទន់ រមែងល្អរុងរឿងក្នុងរាជបរិស័ទ ( នេះ ) ជាសំពត់

មានសាច់ទន់ ព្រះអង្គស្លៀកសំពត់ដែលកើតក្នុងដែនកាសី មាន

ក្នុងទីបំផុតព្រះ ។ ព្រះអង្គល្អរុងរឿងដោយហត្ថាភរណៈណា ក្នុង

រាជបរិស័ទ ព្រះអង្គពាក់នូវហត្ថាភរណៈ ដ៏រហ៊ូយដោយកែវមុក្តា

កែវមណី និងមាស (នោះ)ចុះ ។

(៦២៩) ន ហិ នូនាយំ រដ្ឋបាលោ
ភូមិបតិ ជនបទស្ស ទាយាទោ
លោកិស្សរោ មហន្តោ
បុត្តេ សិនេហំ ជនយតិ ។

(៦៣០) មយ្ហំ បិយា បុត្តា អត្តា ច
បិយោ(១) តុម្ហេ ច ភរិយាយោ
សគ្គញ្ច បត្ថយមានោ
តេនាហំ ឃាតយិស្សាមិ ។

(៦៣១) មំ(២) បឋមំ ឃាតេហិ
មា មេ ហទយំ ទុក្ខំ អនេហេសិ
អលង្កតោ សុន្ទរកោ បុត្តោ
ទេវ តវ សុខុមាលោ ។
ហន្ទយ្យ មំ ហនស្សុ
សលោកា ចន្ទកេន(៣) ហេស្សាមិ
បុញ្ញំ ករស្សុ វិបុលំ
វិចរាម ឧភោ បរលោកេ ។

១ ឱ. អត្តាចិ បិយោ ។ ២ ម. មំ ។ ៣ ឱ. សលោកា ចន្ទកេន ។



(៦២៩) (នាងចន្ទាទេវី...) ព្រះបាទឯករាជនេះ ជាអ្នករក្សាដែន ជាម្ចាស់ផែនដី ជាអ្នកទទួលមត៌ករបស់អ្នកជនបទ ជាធំល្បី លើលោក ប្រសើរជាតិ តែមិនញ៉ាំងសេចក្ដីស្នេហា ឲ្យកើតក្នុងព្រះរាជបុត្រ ដោយពិត ។

(៦៣០) (ព្រះបាទឯករាជ...) បុត្រប្រុសទាំងឡាយ ជាទីស្រឡាញ់ របស់អញ ម្យ៉ាងទៀត ខ្លួនឯងក្ដី ភរិយាទាំងឡាយ (ឯទៀត) ក្ដី ក៏ជាទីស្រឡាញ់របស់អញ ប៉ុន្តែអញចង់បានឋានសួគ៌ទេតើ បានជាអញឲ្យគេសម្លាប់ ដោយហេតុនោះ ។

(៦៣១) (នាងចន្ទាទេវី...) បពិត្រព្រះសម្មតិទេព សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់មុន កុំឲ្យសេចក្ដីទុក្ខចាំបែកហឫទ័យខ្ញុំម្ចាស់ឡើយ បពិត្រព្រះសម្មតិទេព បុត្ររបស់ព្រះអង្គ ជាអ្នកមានគ្រឿងអលង្ការប្រដាប់ ហើយជាបុត្រល្អល្អ ជាសុខុមាលជាតិ ។ បពិត្រព្រះអង្គជាម្ចាស់ នែ ណ្ហើយចុះ សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់ជាស្រ្តីមានសេចក្ដីសោក ជាមួយគ្នានឹងចន្ទកុមារ សូមព្រះអង្គធ្វើបុណ្យឲ្យបរិបូណ៌ចុះ ដើម្បីខ្ញុំទាំងពីរនាក់ នឹងត្រាច់ទៅក្នុងបរលោក ។

(៤៣៦) មា ត្វំ ចន្ទេ ខលិ(១) អហុ
អរ តេន វិសាលក្ខិ
គេ តំ ខេមិ សន្តិ
យង្គស្មិ ពោធិបុត្តេ ។

(៤៣៧) យំ វុត្តំ ចន្ទា អត្តានំ
ហន្តិ ពាក្ខតលតោហិ
អលមេត្ថុ(២) ជីវិតេន
បិស្សាមិ(៣) វិសំ មរិស្សាមិ ។
ន ហិ នូនិមស្ស រញ្ញោ
ញាតិមិត្តា ច វិជ្ជរេ
សុហទា យេ ន វទន្តិ រាជានំ
មា ឃាតយិ ឱរសេ បុត្តេ ។
ន ហិ នូនិមស្ស រញ្ញោ
ញាតិមិត្តា ច វិជ្ជរេ
សុហទា យេ ន វទន្តិ រាជានំ
មា ឃាតយិ អត្រជេ បុត្តេ ។

១ ម. ចក្ខុកាណិ ។ ឱ. ឆ្វឹ ខលិ ។ ក្រឹស ហតុ ។
២ ម. អលមត្ថុ ជីវិតេន ។ ៣ ម. បិវាមិ ។ ម. មរិស្សាមិ ។



(៤៣៦) (ព្រះចន្ទកុមារ . . .) ម្នាលនាងចន្ទា មានភ្នែកវៃសស
វិសាល នាងកុំយំឡើយ ជនទាំងឡាយជាបន្ទុកនាងនឹង របស់
នាងមានច្រើន ជនទាំងនោះ នឹងញ៉ាំងនាងឲ្យត្រេកអរ ព្រោះ
គោតមីបុត្រ ត្រូវគេបូជាយញ្ញហើយ ។

(៤៣៧) (អគ្គិសម្ពុទ្ធតា) កាលបើព្រះចន្ទកុមារ ទ្រង់ត្រាស់យ៉ាងនេះ
ហើយ នាងចន្ទាទៅ ក្រាបទូលទ្រង់ ដោយយល់នូវចិត្តទាំងឡាយ
(ទ្រង់គិតថា) ការរស់នៅក្នុងលោកនេះ ស្មើនឹងស្លាប់ហើយ
អញនឹងផឹកថ្នាំពិសឲ្យស្លាប់ ។ ព្រោះថា ជនទាំងឡាយជា
ញាតិមិត្រ ជាសំឡាញ់ របស់ព្រះរាជានេះ មិនមានអ្នក
ណាមួយ ហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់
ព្រះរាជបុត្រទាំងឡាយ ដែលកើតអំពីព្រះទ្រូងឡើយ ។
ជនទាំងឡាយ ជាញាតិមិត្រ ជាសំឡាញ់ របស់ព្រះរាជានេះ
មិនមានអ្នកណាមួយ ហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គ
កុំសម្លាប់ព្រះរាជបុត្រ ដែលកើតអំពីព្រះអង្គឡើយ ។

ឥមេ តេបិ បហូ បុត្តា
កុណ្ឌលិនោ កាយុរធារិនោ
កតា តេហិបិ យជស្សុ យញ្ញំ
អថ មុញ្ចតុ គោតមីបុត្តេ ។
ពិលសតំ មំ កត្វា
យជស្សុ សត្តធា មហារាជ
មា ជេដ្ឋបុត្តំ អវធិ
អទូសកំ សីហសង្កាសំ ។
ពិលសតំ មំ កត្វា
យជស្សុ សត្តធា មហារាជ
មា ជេដ្ឋបុត្តំ អវធិ
អនបេក្ខំ សព្វលោកស្ស ។

[២៣២] ពហុកា តវ ទិន្នា អាភរណា
ឧច្ចាវចា សុភណិតម្ហិ
មុត្តា មណិ វេឡុរិយា
ឯតន្តេ បច្ឆិមកំ ទានំ ។



បុត្ររបស់ខ្ញុំម្ចាស់ទាំងឡាយនេះ ពាក់កុណ្ឌល ទ្រទ្រង់គ្រឿងប្រដាប់ដៃគឺកងនៃមាស សូមព្រះរាជា បូជាយញ្ញ ដោយកូនបុត្រទាំងឡាយនុ៎ះ ប៉ុន្តែ សូមព្រះអង្គលែងគោតមីបុត្រ ។ បពិត្រមហារាជ សូមព្រះអង្គកាប់ខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយញ្ញ ត្រង់ទីនៅ ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បង ដែលជាអ្នកគ្មានទោសដូចសីហៈ ជាអ្នកមិនប្រទូស្ត ។ បពិត្រមហារាជ សូមព្រះអង្គចិញ្ច្រាំខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយញ្ញ ត្រង់ទីនៅ ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បង ដែលសត្វលោកទាំងអស់ ការព្រះទ័យឡើយ ។

(២៤២) (បន្តុតារ . . .) គ្រឿងអាភរណៈច្រើនយ៉ាង គឺកែវមុក្តា កែវមណី កែវពិទូរ្យដែលប្រសើរ និងមិនប្រសើរ យើងឲ្យហើយដល់នាង ក្នុងគ្រឿងដែលនាងនិយាយល្អហើយ នេះជាអំណោយទីបំផុត ចុងក្រោយដល់នាងចុះ ។

(៦៣៨) យេសំ បុព្វេ សមន្តេសុ ធុល្វា
មាលាគុណា វិវត្តិសុ
តេសជ្ជបិ សុធសិតោ ធេត្តិសោ
វិវត្តិស្សន្តិ សមន្តេសុ ។
យេសំ បុព្វេ សមន្តេសុ ចិត្តា
មាលាគុណា វិវត្តិសុ
តេសជ្ជបិ សុធសិតោ ធេត្តិសោ
វិវត្តិស្សន្តិ សមន្តេសុ ។
អធិក វត ធេត្តិសោ
វិវត្តិស្សន្តិ រាជបុត្តានំ សមន្តេសុ
អជ មម ឋានេយំ ន ជលតិ
ការេ ធម្មពន្ធញ្ញ មេ អាសិ ។
កាសិកាសុចិវត្ថក
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា
យញ្ញត្ថាយ បំកាជស្ស ។



(៦៣៨) (តាមនិទ្ទេសទៅ...) កាលពីដើម ព្រះរាជបុត្រទាំងឡាយណា ដែលមានកម្រងផ្កាកែសរពោធិ៍ ពាក់ហើយលើ-កទាំងឡាយ ថ្ងៃនេះព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវ ដែលគេសំលៀងមុត នឹងធ្លាក់លើ-កទាំងឡាយវិញ ។ កាលពីដើម ព្រះរាជ-បុត្រទាំងឡាយណា ដែលមានកម្រងផ្កាដ៏វិចិត្រហើយ ពាក់លើ-កទាំងឡាយ ថ្ងៃនេះព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវ ដែលគេសំលៀងមុត នឹងធ្លាក់លើ-កទាំងឡាយវិញ ។ មិនយូរប៉ុន្មានទេ មុខដែលដាវនឹងធ្លាក់លើ-កនៃរាជបុត្រទាំងឡាយ កុំខាន ហឫទ័យរបស់ខ្ញុំម្ចាស់ នឹងបែកធ្លាយឯណាចុះ ព្រោះចំណាប់យ៉ាងនេះ នាំដល់ខ្ញុំម្ចាស់ហើយ ។ ម្នាលចន្ទកុមារនឹងស៊ូរិយកុមារ អ្នកទាំងឡាយ ជាអ្នកប្រូប្រឹស៊ាក់លាចល្អដែលកើតក្នុងដែនកាសី ប្រដាប់កុណ្ឌល លាបស្រឡាបដោយខ្លឹម នឹងខ្លឹមចន្ទន៍ ចូរចេញទៅ ដើម្បីយញ្ញនៃព្រះបាទឯករាជចុះ ។

កាសិកសុចិវត្ថធរា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា
មាតុ កត្វា ហទយសោកំ ។
កាសិកសុចិវត្ថធរា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា
ជនស្ស កត្វា ហទយសោកំ ។
មំសរសភោជនា ន្ហាបកសុន្ហាតា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា
យញ្ញត្ថាយ ឯករាជស្ស ។
មំសរសភោជនា ន្ហាបកសុន្ហាតា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា
មាតុ កត្វា ហទយសោកំ ។



ពួកចន្ទកុមារនិងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរចេញទៅចុះ ។ ពួកចន្ទកុមារនិងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ ។ ពួកចន្ទកុមារនិងសុរិយកុមារ អ្នកទាំងឡាយជាអ្នកបរិភោគភោជន ដែលលាយដោយសាច់មានរសជាអ្នកដែលពួកអ្នកផ្ងូតឲល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាននិងខ្លឹមចន្ទន៍ ចូរចេញទៅដើម្បីយញ្ញ របស់ព្រះរាជាឯករាជចុះ ។ ពួកចន្ទកុមារនិងសុរិយកុមារ អ្នកទាំងឡាយជាអ្នកបរិភោគភោជន ដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្ងូតឲល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យ នៃមាតា ចូរស្តេចចេញទៅចុះ ។

មំសសោភោជនា ញ្ហាបកសុញ្ហាតា
កុណ្ឌលិនោ អគ្គលុចន្ទនវិលិត្តា
និយ្យាថ ចន្ទសុរិយា
ជនស្ស ភក្ខា ហនយសោតាំ ។
(៤៣៦) សព្វស្មិំ ឧបក្ខតស្មិំ និសីទិតេ
ចន្ទសុរិយស្មិំ យញ្ញត្ថាយ
បញ្ចាលរាជធីតា បញ្ជលិកា
សព្វបរិសន្តានុបរិយាសិ ។
យេន សច្ចេន ខណ្ឌហាលោ
បាបកម្មំ ករោតិ ទុម្មេធោ
ឯតេន សច្ចវជ្ជេន
សមង្គិនី សាមិកេន ហោមិ ។
យេ ឥធត្ថិ អមនុស្សា
យានិ ច យក្ខភូតភព្យានិ
ករោន្តុ មេ វេយ្យាវដិកំ
សមង្គិនី សាមិកេន ហោមិ ។



ម្ចាស់ចន្ទកុមារនឹងសុរិយកុមារ អ្នកទាំងឡាយជាអ្នកបរិភោគ ភោជនដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកងូតឲ ល្អហើយ ប្រដាប់កុណ្ឌល លាបស្រឡាបដោយគ្រឿងខ្លឹម ចន្ទន៍ ធ្វើសេចក្តីសោក ក្នុងទ្រូងនៃជន ចូរចេញទៅចុះ ។

(៤៣៦) (អភិសម្ពុទ្ធគាថា) កាលបើគ្រឿងប្រដាប់បូជាយញ្ញគ្រប់យ៉ាង ដែលគេតាក់តែងហើយ កាលបើចន្ទកុមារនឹងសុរិយកុមារអង្គុយ ដើម្បីប្រយោជន៍ដល់យញ្ញហើយ នាងបញ្ចាលរាជធីតា លើកកំបង់អញ្ជលី ដើរចូលទៅក្រឡំពួកបរិស័ទទាំងពួង(ប្រកាសថា) ខណ្ឌហាលព្រាហ្មណ៍ ជាមនុស្សយល់ខុស ធ្វើបាបកម្ម ដោយពាក្យសច្ចៈណា ខ្ញុំគួរព្រមព្រៀង ជាមួយនឹងព្រះស្វាមី តាមពាក្យសច្ចៈនុ៎ះ ។ ពួកអមនុស្សក្នុងទីនេះនឹងពួកសត្វកើត ហើយនឹងសត្វដែលត្រូវកើត មានក្នុងទីនេះ ចូរធ្វើនូវសេចក្តីខ្វល់ខ្វាយចំពោះខ្ញុំ ខ្ញុំសូមព្រមព្រៀង (ជាមួយ) នឹងព្រះស្វាមីហើយ ។

យា ទេវតា ឥធាគតា
យានិ ច សព្វភូតភព្យានិ
សរណេសិនំ អនាថំ តាយថ មំ
យាចាមិ វោ បតិមាហំ អវេយ្យំ ។

(២៣៧) តំ សុត្វា អមនុស្សោ
អយោកុដំ បរិព្ភមិត្វាន
ភយមស្ស ជនយន្តោ
ភដាទំ ឥទមព្រវិ ។

ពុជ្ឈស្សុ ខោ រាជកាលិ
មា តេហំ ឧត្តមំ និតាប្បេសិ
មា ជេដ្ឋបុត្តំ អវធិ
អទូសកំ សីហសង្កាសំ ។

កោ តេ ទិដ្ឋោ រាជកាលិ
បុត្តភរិយាយោ ហញ្ញមានាយោ
សេដ្ឋី ច គហបតយោ
អទូសកា សគ្គគាមា ហំ ។



ពួកទេវតា ពួកសត្វកើតហើយ និងសត្វដែលត្រូវកើតទាំងអស់ ដែលមកក្នុងទីនេះ សូមអ្នកទាំងឡាយការពារខ្ញុំ ជាមនុស្សអនាថ ដែលស្វែងរកទីពឹង ខ្ញុំសូមអង្វរព្រះស្វាមី ដែលគួរបណ្ដាមិត្រ ផ្ញាញ់មិនចុះ ចំពោះលោកទាំងឡាយ ។

(២៣៧) អមនុស្ស ( សក្កទេវរាជ ) ឮពាក្យនោះហើយ ក៏ក្រវីញញួរដែក ចំពីលើព្រះរាជានោះ ហើយនិយាយនឹងព្រះរាជាឲ្យខ្លាច ម្នាលស្ដេចកាឡកណ្ណី ព្រះអង្គចូរដឹងចុះ កុំឲ្យខ្ញុំបំបែកក្បាលព្រះអង្គឡើយ ព្រះអង្គកុំសម្លាប់បុត្រច្បង ជាអ្នកឥតទោសដូចសីហៈ ជាអ្នកមិនប្រទូស្ដ ។ ម្នាលស្ដេចកាឡកណ្ណី ព្រះអង្គធ្លាប់ឃើញអ្នកណា ដែលសម្លាប់បុត្រភរិយា និងសេដ្ឋីគហបតី ជាអ្នកមិនប្រទូស្ដ ព្រោះប្រាថ្នាឋានសួគ៌ ។

(៤៣៨) តំ សុត្វា ខណ្ឌហាលោ
រាជា ច អព្ភុតមិទំ ទិស្វាន
សព្វេសំ ពន្ធនានិ មោចេសុំ
យថា តំ អនុបឃាតំ(១) ។
សព្វេសុ វិប្បមុត្តេសុ
យេ តត្ថ សមាគតា តទា អាសុំ
សព្វេ ឯកេកលេឌ្ឌុមទំសុ
ឯស វធោ ខណ្ឌហាលស្ស ។

(៤៣៩) សព្វេ បវិដ្ឋា និរយំ
យថា តំ បាបកម្មំ ករិត្វាន
ន ហិ បាបកម្មំ កត្វា
លព្ភា សុគតិ ឥតោ គន្តុំ ។

(៤៤០) សព្វេសុ វិប្បមុត្តេសុ
យេ តត្ថ សមាគតា តទា អាសុំ
ចន្ទំ អភិសិញ្ចិំសុ
សមាគតា រាជបរិសា ច ។

---
១. ម. អនុបាតំ ។



(៤៣៨) ខណ្ឌហាលព្រាហ្មណ៍ ផងក្សត្រនោះ ទាំងព្រះរាជាក៏ ឃើញសក្កទេវរាជ ដែលព្រះអង្គ មិនធ្លាប់ឃើញនេះ ទើបឲ្យស្រាយចំណង ពីជនទាំងពួង ឲ្យរួចជាមិនមានទោសភ័យទៀត ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកជនដែលមកប្រជុំក្នុងកន្លែងនោះ ក៏នាំគ្នាគប់ដុំដីម្នាក់មួយដុំៗ នេះជាការសម្លាប់ខណ្ឌហាលព្រាហ្មណ៍ ។

(៤៣៩) ពួកជនទាំងពួង ធ្វើបាបកម្មហើយ ទៅកាន់នរក យ៉ាងណា ពួកជនមិនធ្វើបាបកម្ម ហើយទៅកាន់លោកខាងនាយ គប្បីបាននូវសុគតិ យ៉ាងនោះឯង ។

(៤៤០) កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកជនប្រុសដែលមកប្រជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។

សព្វេសុ វិប្បមុត្តេសុ
យា តត្ថ សមាគតា តទា អាសុំ
ចន្ទំ អភិសិញ្ចិសុ
សមាគតា រាជកញ្ញាយោ ។
សព្វេសុ វិប្បមុត្តេសុ
យេ តត្ថ សមាគតា តទា អាសុំ
ចន្ទំ អភិសិញ្ចិសុ
សមាគតា ទេវបុរិសា ច ។
សព្វេសុ វិប្បមុត្តេសុ
យា តត្ថ សមាគតា តទា អាសុំ
ចន្ទំ អភិសិញ្ចិសុ
សមាគតា ទេវកញ្ញាយោ ។
សព្វេសុ វិប្បមុត្តេសុ
យេ តត្ថ សមាគតា តទា អាសុំ
ចេលុក្ខេបមការុំ
សមាគតា ពលបុរិសា ច ។



កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកប្រជុំគ្នា ក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកប្រជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញា ដែលមកប្រជុំគ្នា ក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេក នូវចន្ទកុមារ ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកពលបរិស័ទ ដែលមកប្រជុំគ្នា ក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។

សព្វេសុ វិប្បមុត្តេសុ
យា តត្ថ សមាគតា តទា អាសុំ
ចេលុក្ខេបមការុំ
សមាគតា រាជកញ្ញាយោ ។

សព្វេសុ វិប្បមុត្តេសុ
យេ តត្ថ សមាគតា តទា អាសុំ
ចេលុក្ខេបមការុំ
សមាគតា ទេវបុត្តា ច ។

សព្វេសុ វិប្បមុត្តេសុ
យា តត្ថ សមាគតា តទា អាសុំ
ចេលុក្ខេបមការុំ
សមាគតា ទេវកញ្ញាយោ ។

សព្វេសុ វិប្បមុត្តេសុ
ពហូ អានន្ទិនោ អហុ
វាទឹសុ នន្ទិប្បវេសិនគរំ
ពន្ធនា មោក្ខោ អឃោសិត្ថាតិ ។

ចន្ទកុមារជាតកំ សត្តមំ ។

---



កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញា ដែលមកប្រជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។

កាលបើពួកជនទាំងអស់រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុត្រដែលមកប្រជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកប្រជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់ ។

កាលបើពួកជនទាំងអស់រួចពីចំណងហើយ ពួកជនជាច្រើនត្រេកអរពេកពេយ ចាំតែនិន្ទចូលកាន់នគរ ក្នុងកាលដែលចន្ទកុមារចូលទៅក្នុងនគរ ពួកជនបានប្រកាសការរួចចាកចំណង (របស់ពួកសត្វ) ។

ចប់ ចន្ទកុមារជាតក ទី ៨ ។